

តុលា 2022

## ការិយាល័យប្រតិបត្តិផ្នែកថាមពលនិង កិច្ចការបរិស្ថាន

# យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន

យុទ្ធសាស្ត្ររបស់លេខាធិការដ្ឋាននិងទីភ្នាក់ងារសម្រាប់ការលើកកម្ពស់យុត្តិធម៌បរិស្ថានឱ្យបានសកម្មខ្លាំងឡើងនៅក្នុងខំមិនវែលនៃរដ្ឋម៉ាសាជូសេត។

Executive Office of Energy and Environmental Affairs

# សំបុត្រពីលេខា

ខ្ញុំមានសេចក្តីរំពឹងទុកថា ខ្ញុំនឹងចេញផ្សាយយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន (EJ) របស់ ការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន (EEA) ដើម្បីទទួលបានការផ្តល់មតិយោបល់ជាសាធារណៈ។ កិច្ចខិតខំប្រឹងប្រែងក្នុងការបង្កើតឯកសារនៅទូទាំងលេខាធិការដ្ឋាននេះ ត្រូវបានដឹកនាំដោយក្រុមការងារយុត្តិធម៌បរិស្ថាន ក្រោមអធិបតីភាពនៃប្រធានយុត្តិធម៌បរិស្ថានរបស់យើង នៅក្នុងខែកញ្ញា ឆ្នាំ2020។ ក្រុមនេះបានរួមគ្នាដាក់ចេញនូវចក្ខុវិស័យជាបន្តបន្ទាប់ដើម្បីធានាថា ពលរដ្ឋដែលស្នាក់នៅក្នុងខំមិនវែលនេះ អាចទទួលបានប្រយោជន៍ក្នុងលក្ខណៈមួយដែលមានភាពស្មើគ្នា និងត្រឹមត្រូវនៅចំពោះមុខច្បាប់ និងគោលនយោបាយនានាដែលដោះស្រាយបញ្ហាបរិស្ថាន ថាមពល និងអាកាសធាតុនៅក្នុងរដ្ឋម៉ាសាជូសេតនេះ។

នេះគឺជាការទាមទារមួយខ្ពស់ ដែលតម្រូវឱ្យមានការចូលរួមជាបន្តបន្ទាប់ពីពលរដ្ឋនៅក្នុងខំមិនវែលរបស់យើង ភាគីពាក់ព័ន្ធខាងយុត្តិធម៌បរិស្ថាន អាជីវកម្ម និងសហគមន៍អភិវឌ្ឍន៍ និងរដ្ឋាភិបាលរដ្ឋជាដើម។ បញ្ហាដែលយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយនេះ ប៉ុនប៉ងដើម្បីធ្វើការដោះស្រាយនោះ មិនអាចដោះស្រាយបានត្រឹមពេលមួយថ្ងៃ ឬមួយឆ្នាំឡើយ។ យើងមានរឿងជាច្រើនទៀតដែលត្រូវធ្វើដើម្បីសម្រេចគោលដៅរបស់យើងសម្រាប់យុត្តិធម៌បរិស្ថាន ថាមពល និងអាកាសធាតុ។ ការិយាល័យរបស់ខ្ញុំ ផ្តួចផ្តើមគិតអំពីយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាននេះក្នុងលក្ខណៈជា “ឯកសាររស់” ជាឯកសារមួយដែលនឹងធ្វើការផ្លាស់ប្តូរខ្លួនជាបន្តបន្ទាប់ក្នុងការឆ្លើយតបនឹងមតិយោបល់ចូលរួមពីសាធារណជនដែលមានព័ត៌មាននិងជាក់ស្តែង និងការពិភាក្សា។ រយៈពេលនៃការផ្តល់មតិយោបល់ជាសាធារណៈនេះ ឆ្លុះបញ្ចាំងពីការខិតខំប្រឹងប្រែងរយៈពេលយូរ។

នៅក្នុងសៀវភៅយុទ្ធសាស្ត្រនេះ ពលរដ្ឋម៉ាសាជូសេត នឹងឃើញមានជំហាន និងគោលដៅ ដែលមានចេតនាក្នុងការផ្សព្វផ្សាយពីសមធម៌បរិស្ថាន ដោយទីភ្នាក់ងារនីមួយៗ និងការិយាល័យធំៗស្ថិតក្រោមរចនាសម្ព័ន្ធគ្រប់គ្រងរបស់ EEA។ ទីភ្នាក់ងារ និងការិយាល័យទាំងនេះ បានដាក់លក្ខខណ្ឌតម្រូវស្ថិតក្រោមគោលនយោបាយយុត្តិធម៌បរិស្ថានរបស់ EEA ឱ្យស្របទៅតាមបេសកកម្មនៃស្ថាប័នរបស់ពួកគេ។ បន្ថែមពីលើគោលវិធីផ្តោតលើបេសកកម្មរបស់ទីភ្នាក់ងារនេះ ក៏មានគោលដៅរួមជាច្រើនដែលត្រូវបានបង្កើតឡើងនៅទូទាំងលេខាធិការដ្ឋានផងដែរៈ ការប្តេជ្ញាចិត្តដើម្បីទទួលបានសេវាផ្នែកភាសាល្អប្រសើរសម្រាប់ពលរដ្ឋ MA ដែលមានចំណេះដឹងភាសាអង់គ្លេសតិចតួច ជាលក្ខខណ្ឌមួយដែលបង្កើនបរិមាណបន្ទាត់គោលបច្ចុប្បន្ន និងខ្នាតរង្វាស់ទៅអនាគត ដើម្បីវាស់ស្ទង់វឌ្ឍនភាព ធ្វើផែនការសម្រាប់ការបណ្តុះបណ្តាលបុគ្គលិកជាបន្តបន្ទាប់ និងការទទួលស្គាល់ថា រដ្ឋាភិបាលរដ្ឋត្រូវជ្រើសរើសបុគ្គលិកបម្រើការពីគ្រប់ប្រជាជនប្រជាសាស្ត្រនៃខំមិនវែលនេះ ដើម្បីអនុវត្តគោលនយោបាយរដ្ឋាភិបាលក្នុងលក្ខណៈមួយដែលមានសមភាព។

ខ្ញុំសង្ឃឹមថា លោកអ្នកនឹងអានសេចក្តីព្រាងយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាននេះដោយយកចិត្តទុកដាក់ បំពេញបន្ថែមលើគោលវិធីនានាដែលទំនងជា ទទួលបានជោគជ័យ កំណត់ពីយុទ្ធសាស្ត្រនានាដែលមិនបានលើកឡើង និងរំលេចពីការអនុវត្តនានាដែលអាចមានការខ្វះចន្លោះនៅក្នុងគោលដៅរួមគ្នារបស់យើង ដើម្បីធ្វើឱ្យខំមិនវែលនេះកាន់តែមានយុត្តិធម៌ និងសមធម៌។

សូមផ្តល់មតិយោបល់ជាលាយលក្ខណ៍អក្សរនៅក្នុងគេហទំព័រផ្តល់យោបល់ជាសាធារណៈនៅលើទំព័រវេបសាយយុត្តិធម៌បរិស្ថានរបស់ EEA៖ [https://www.mass.gov/environmental-justice](https://www.mass.gov/environmental-justice). វេបសាយនេះ ក៏មានព័ត៌មានអំពីកិច្ចប្រជុំស្តាប់យោបល់សាធារណៈជាច្រើនផងដែរ ដែលក្នុងនោះអ្នកអាចបញ្ចេញយោបល់ដោយផ្ទាល់មាត់បាន។ មតិចូលរួមរបស់លោកអ្នក មានតម្លៃមិនអាចកាត់ថ្លៃបាន ហើយនឹងបានធ្វើជាកម្លាំងដឹកនាំដល់ការអនុវត្តយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់ EEA។

ដោយសេចក្តីគោរពអំពីខ្ញុំ
Bethany A. Card
លេខាថាមពលនិងកិច្ចការបរិស្ថាន

# សេចក្តីថ្លែងអំណរគុណ

**ការបង្កើតយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់ EEA គឺជាដំណើរការនៃការវិភាគនិងការធ្វើផែនការរយៈពេលពីរឆ្នាំ ស្ថិតក្រោមការដឹកនាំរបស់៖**

លោកស្រី Bethany A. Card លេខាធិការផ្នែកថាមពលនិងកិច្ចការបរិស្ថាន
លោកស្រី Kathleen Theoharides អតីតលេខាផ្នែកថាមពលនិងកិច្ចការបរិស្ថាន
លោក Daniel Sieger អតីតអនុរដ្ឋមន្ត្រីបរិស្ថាន
លោកស្រី Judy Chang អនុរដ្ឋមន្ត្រីថាមពល និងដំណោះស្រាយអាកាសធាតុ
Rishi Reddi នាយកផ្នែកយុត្តិធម៌បរិស្ថាន
ក្រុមការងារយុត្តិធម៌បរិស្ថានរបស់ EEA ដូចមានសមាសភាពខាងក្រោម។

## សមាជិកបច្ចុប្បន្ន និងអតីតសមាជិកនៃក្រុមការងារយុត្តិធម៌បរិស្ថានរបស់ EEA នៃរដ្ឋម៉ាសាជូសេត

**Rose Arruda**, *នាយកដ្ឋានធនធានកសិកម្មរដ្ឋម៉ាសាជូសេត (MDAR)*

**Jorge J. Ayub**, *នាយកដ្ឋានអភិរក្ស និងការកម្សាន្ត (DCR)*

**Vallery Cardoso**, *ការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន (EEA)*

**Major Kevin Clayton**, *ការិយាល័យអនុវត្តច្បាប់ (OLE)*

**Beverly Craig**, *មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC)*

**Tomeka Cribb-Jones**, *អាជ្ញាធរធនធានទឹករដ្ឋម៉ាសាជូសេត (MWRA)*

**Page Czepiga**, *ការិយាល័យច្បាប់ស្តីពីគោលនយោបាយបរិស្ថានរដ្ឋម៉ាសាជូសេត (MEPA)*

**Rebecca Davidson**, *នាយកដ្ឋានធនធានកសិកម្មរដ្ឋម៉ាសាជូសេត (MDAR)*

**Tamika Jacques**, *អតីតមជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC)*

**Tori Kim**, *ការិយាល័យច្បាប់ស្តីពីគោលនយោបាយបរិស្ថានរដ្ឋម៉ាសាជូសេត (MEPA)*

**Carline Lemoine**, *នាយកដ្ឋានសេវាសាធារណៈ (DPU)*

**Jade Lu**, *មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC)*

**Cindy Montoya**, *ផ្នែកធនធានមនុស្សរបស់ EEA (EEA HR)*

**Danilo Morales**, *នាយកដ្ឋានធនធានថាមពល (DOER)*

**Dominique Pahlavan**, *ប្រព័ន្ធព័ត៌មានភូមិសាស្ត្ររបស់ EEA (EEA GIS)*

**Rishi Reddi**, *ការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន (EEA)*

**Mark Reil**, *អតីតនាយកដ្ឋានរុក្ខាប្រមាញ់នេសាទ និងល្បែងកម្សាន្ត (DFG)*

**Francisco Rodriguez**, *នាយកដ្ឋានអភិរក្ស និងការកម្សាន្ត (DCR)*

**James Rossignol**, *នាយកដ្ឋានរុក្ខាប្រមាញ់នេសាទ និងល្បែងកម្សាន្ត (DFG)*

**Kari Sasportas**, *ការិយាល័យជំនួយបច្ចេកទេស (OTA)*

**Deneen Simpson**, *នាយកដ្ឋានការការពារបរិស្ថាន (DEP)*

**Tiffany Skogstrom**, *ការិយាល័យជំនួយបច្ចេកទេស (OTA)*

**Tyler Soleau**, *ការិយាល័យគ្រប់គ្រងតំបន់ឆ្នេរ (CZM)*

***យើងខ្ញុំសូមថ្លែងអំណរគុណដល់ភាគីពាក់ព័ន្ធដែលបានចូលរួមក្នុងការពិភាក្សា និងបានផ្តល់ជាមតិយោបល់ដែលជួយដល់ការបង្កើតឯកសារនេះឡើង។***

**Wayne Wang**, *ក្រុមប្រឹក្សាអាណត្តិផ្នែកសំណង់បរិក្ខារថាមពល (EFSB)*

**Alexis Washburn**, *អតីតនាយកដ្ឋានធនធានថាមពល (DOER)*

ព្រាង

***យើងខ្ញុំសូមថ្លែងអំណរគុណដល់ភាគីពាក់ព័ន្ធដែលបានចូលរួមក្នុងការពិភាក្សា និងបានផ្តល់ជាមតិយោបល់ដែលជួយដល់ការបង្កើតឯកសារនេះឡើង។***

# គោលបំណង និងការប្រើប្រាស់

ការប្រមូលផ្តុំចងក្រងនូវយុទ្ធសាស្រ្តយុត្តិធម៌បរិស្ថាននេះ គឺមានគោលបំណងក្នុងការលើកកម្ពស់ការគ្រប់គ្រងផ្ទៃក្នុងនៃទីភ្នាក់ងារ EEA និងប្រមូលផ្តល់ចងក្រងយុទ្ធសាស្រ្តជាច្រើនដែលបានអនុវត្តនៅក្នុងលេខាធិការដ្ឋានទាំងមូលមកជាឯកសារតែមួយ។ យុទ្ធសាស្រ្តទាំងនេះ អាចមានការប្រែប្រួល ដោយពុំចាំបាច់មានការជូនដំណឹងណាមួយឡើយ។ មិត្តអ្នកអានដែលជាគោលដៅនៃឯកសារនេះ គឺជាបុគ្គលិករបស់ EEA ដើម្បីប្រើប្រាស់ដើម្បីជួយដល់បុគ្គលិក EEA ក្នុងការចូលរួមជាមួយសាធារណជនចំពោះបញ្ហាដែលពាក់ព័ន្ធនឹងមុខងារ EEA និងការអនុវត្តកម្មវិធីនិងគោលនយោបាយស្ថិតក្រោមវង្វង់សមត្ថកិច្ចរបស់ខ្លួន។ យុទ្ធសាស្រ្តទាំងនេះ មិនមានគោលបំណង ឬអាចមិនអនុវត្តលើ ហើយក៏មិនមែនដើម្បីបង្កើតជាសិទ្ធិ អត្ថប្រយោជន៍ ឬកាតព្វកិច្ច ជាខ្លឹមសារឬនីតិវិធី ដែលអនុវត្តចំពោះមុខច្បាប់ ឬសមភាពដោយភាគីណាមួយនៅក្នុងបញ្ហាណាមួយ មិនថាជាបញ្ហារដ្ឋប្បវេណី ព្រហ្មទណ្ឌ ឬរដ្ឋបាលឡើយ។ យុទ្ធសាស្រ្តទាំងអស់នេះ មិនត្រូវបកស្រាយថាបានបង្កើតជាសិទ្ធិណាមួយដល់ការត្រួតពិនិត្យខាងតុលាការ ដែលពាក់ព័ន្ធនឹងអនុលោមភាព ឬមិនអនុលោមភាពនៃ EEA ទីភ្នាក់ងាររបស់ខ្លួន មន្ត្រីរបស់ខ្លួន ឬបុគ្គលណាម្នាក់ដែលពាក់ព័ន្ធនឹងយុទ្ធសាស្រ្តទាំងនេះឡើយ។

# តារាងមាតិកា

**ការិយាល័យលេខាធិការដ្ឋាន ... 8**

ការិយាល័យគ្រប់គ្រងតំបន់ឆ្នេរ ... 24

ការិយាល័យអនុវត្តច្បាប់រដ្ឋម៉ាសាជូសេត និងប៉ូលិសបរិស្ថានរដ្ឋម៉ាសាជូសេត ... 33

ការិយាល័យច្បាប់គោលនយោបាយបរិស្ថានរដ្ឋម៉ាសាជូសេត ... 42

ការិយាល័យជំនួយបច្ចេកទេសរដ្ឋម៉ាសាជូសេត ... 54

**នាយកដ្ឋានធនធានកសិកម្មរដ្ឋម៉ាសាជូសេត ... 66**

**នាយកដ្ឋានអភិរក្ស និងការកម្សាន្ត ... 77**

**នាយកដ្ឋានការពារបរិស្ថានរដ្ឋម៉ាសាជូសេត (MassDEP) ... 88**

**នាយកដ្ឋានរុក្ខាប្រមាញ់ នេសាទ និងល្បែងកម្សាន្ត ... 104**

**នាយកដ្ឋានធនធានថាមពល ... 114**

**នាយកដ្ឋានសេវាសាធារណៈ ... 125**

**ក្រុមប្រឹក្សាអាណត្តិផ្នែកសំណង់បរិក្ខារថាមពលនៃខំមិនវែលរដ្ឋម៉ាសាជូសេត (EFSB) ... 135**

**មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត ... 153**

**អាជ្ញាធរធនធានទឹករដ្ឋម៉ាសាជូសេត ... 168**

# ការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន

## ការិយាល័យលេខាធិការដ្ឋាន

## យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន

# តារាងមាតិកា

**ការិយាល័យលេខាធិការដ្ឋាន ........ 8**

សេចក្តីថ្លែងការណ៍បេសកកម្មនៃការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន ..... 10

លក្ខខណ្ឌតម្រូវស្ថិតក្រោមគោលនយោបាយយុត្តិធម៌បរិស្ថានរបស់ EEA ........ 10

សិទ្ធិអំណាចតាមផ្លូវច្បាប់ ........ 11

និយមន័យ ........ 11

បញ្ជីពាក្យកាត់ក្នុងឯកសារនេះ ........ 13

លទ្ធភាពដែលអាចអនុវត្តបាន ........ 14

យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាននៃការិយាល័យលេខាធិការដ្ឋានរបស់ EEA ........ 14

*គំនិតផ្តួចផ្តើមយុត្តិធម៌បរិស្ថានបច្ចុប្បន្ន និងបន្តបន្ទាប់ ........ 14*

*អនាគតគំនិតផ្តួចផ្តើមយុត្តិធម៌បរិស្ថាន ........ 18*

*ការផ្សព្វផ្សាយដល់ភាគីពាក់ព័ន្ធ ការចូលរួមរបស់សហគមន៍ និងការចូលរួមជាសាធារណៈ .... 21*

ការអនុវត្តយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់ការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន ........ 23

## សេចក្តីថ្លែងការណ៍បេសកកម្មនៃ ការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន

ការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន (EEA) ខិតខំដើម្បីការពារ អភិរក្ស និង ធ្វើឱ្យប្រសើរឡើងនូវធនធានបរិស្ថានរបស់ខំមិនវែលនេះ ហើយក្នុងពេលជាមួយគ្នា ក៏ធានានូវ អនាគតថាមពលស្អាតសម្រាប់ពលរដ្ឋនៅក្នុងរដ្ឋ។ តាមរយៈការគ្រប់គ្រងដោយយកចិត្តទុកដាក់ និងមានទំនួលខុសត្រូវលើទីលំហ ការការពារធនធានបរិស្ថាន និងការធ្វើឱ្យប្រសើរឡើងនូវ ថាមពលស្អាត ការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន បានខិតខំប្រឹងប្រែងធ្វើ ការដោយមិនខ្លាចនឿយហត់ក្នុងការធ្វើឱ្យរដ្ឋម៉ាសាជូសេតក្លាយជាកន្លែងដ៏អស្ចារ្យមួយដើម្បីរស់ នៅ ធ្វើការ និងកសាងគ្រួសារ។

## លក្ខខណ្ឌតម្រូវស្ថិតក្រោមគោលនយោបាយយុត្តិធម៌បរិស្ថានរបស់ EEA

យុត្តិធម៌បរិស្ថាន គឺផ្អែកលើគោលការណ៍ដែលមនុស្សរាល់គ្នាមានសិទ្ធិទទួលបានការការពារពី គ្រោះថ្នាក់បរិស្ថាន និងដើម្បីរស់នៅ និងទទួលបានបរិស្ថានស្អាត និងមានសុខភាពល្អ ដោយមិ នប្រកាន់ពូជសាសន៍ ពណ៌សម្បុរ សញ្ជាតិកំណើត ប្រាក់ចំណូល ឬសមត្ថភាពចំណេះដឹងភាសា អង់គ្លេសឡើយ។ យុត្តិធម៌បរិស្ថាន គឺជាការការពារស្មើភាពគ្នា និងការចូលរួមប្រកបដោយអត្ថន័យ ពីសំណាក់ពលរដ្ឋ និងសហគមន៍ពាក់ព័ន្ធនឹងការអភិវឌ្ឍ ការអនុវត្ត និងការពង្រឹងការអនុវត្ត ច្បាប់ បទបញ្ញត្តិ និងគោលនយោបាយស្តីពីថាមពល បម្រែបម្រួលអាកាសធាតុ និងបរិស្ថាន និងការបែងចែកដោយស្មើភាពគ្នានូវអត្ថប្រយោជន៍និងបន្ទុកបរិស្ថាន និងថាមពល។[1]

គោលនយោបាយយុត្តិធម៌បរិស្ថានរបស់ EEA (ហៅកាត់ថា គោលនយោបាយយុត្តិធម៌បរិស្ថាន) ដឹកនាំ គ្រប់ទីភ្នាក់ងារទាំងអស់របស់ EEA ។[2] ឱ្យបង្កើតយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានផ្ទាល់ដើម្បី " ជំរុញលើកកម្ពស់យុត្តិធម៌បរិស្ថានឱ្យបានសកម្មនៅគ្រប់សង្កាត់ទាំងអស់ ក្នុងលក្ខណៈដែលផ្តោត សំខាន់ទៅតាមបេសកកម្មរបស់ទីភ្នាក់ងារនោះ"។ គោលនយោបាយយុត្តិធម៌បរិស្ថាន ក៏ចែងបន្ថែម ទៀតថា យុទ្ធសាស្ត្រដាច់ដោយឡែកនេះ នឹងត្រូវចាត់ទុកជា "គោលនយោបាយយុត្តិធម៌បរិស្ថានរបស់ លេខាធិការដ្ឋាន" ហើយត្រូវសម្រេចជាចុងក្រោយនៅត្រឹមថ្ងៃចុះផ្សាយដោយលេខាធិការដ្ឋាន។[3]

ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវនេះ យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានគ្រប់ជ្រុងជ្រោយរបស់លេខា ធិការដ្ឋាននេះ ត្រូវបានបង្កើតឡើងដោយកម្មវិធីយុត្តិធម៌បរិស្ថានរបស់ EEA រួមជាមួយទីភ្នាក់ងារ

---

[1] សូមមើល "គោលនយោបាយយុត្តិធម៌បរិស្ថាននៃការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន" និយមន័យ [https://www.mass.gov/doc/environmental-justice-policy6242021-update/download]

[2] ទីភ្នាក់ងារដែលត្រូវឱ្យបង្កើតយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរួមមាន នាយកដ្ឋានកសិកម្មរដ្ឋម៉ាសាជូសេត (MDAR), នាយកដ្ឋានអភិរក្ស និងការកម្សាន្ត (DCR), នាយកដ្ឋានការពារបរិស្ថាន (DEP), នាយកដ្ឋានរុក្ខាប្រមាញ់ នេសាទ និងល្បែងកម្សាន្ត (DFG), នាយកដ្ឋានធនធានថាមពល (DOER), នាយកដ្ឋានសេវាសារធារណៈ (DPU)។ ការិយាល័យរបស់ EEA ដែលបង្កើតយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរួមមាន ការិយាល័យគ្រប់គ្រងតំបន់ឆ្នេរ (CZM), ប៉ូលិសបរិស្ថានរដ្ឋម៉ាសាជូសេត / ការិយាល័យអនុវត្តច្បាប់បរិស្ថាន (MEP), ច្បាប់ស្តីពីគោលនយោបាយ បរិស្ថានរដ្ឋម៉ាសាជូសេត (MEPA), និងការិយាល័យជំនួយបច្ចេកទេស និងបច្ចេកវិទ្យា (OTA)។ បន្ថែមលើនេះ ទីភ្នាក់ ងារជាបុគ្គលសម្ព័ន្ធរបស់ EEA មជ្ឈមណ្ឌលថាមពលស្អាត (CEC) អាជ្ញាធរធនធានទឹករដ្ឋម៉ាសាជូសេត (MWRA) បាន បង្កើតយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានផ្ទាល់ខ្លួនពួកគេ។

[3] សូមមើល "គោលនយោបាយយុត្តិធម៌បរិស្ថានរបស់ EEA ," *កថាខណ្ឌ 13*; [https://www.mass.gov/doc/environmental-justice-policy6242021-update/download]

ការិយាល័យ និងកម្មវិធីរបស់ EEA។ យោងតាមគោលនយោបាយយុត្តិធម៌បរិស្ថាននេះ យុទ្ធសាស្ត្ររបស់ទីភ្នាក់ងារគប្បី "...គិតពិចារណាអំពីរបៀបដាក់បញ្ចូលការគិតគូរពីយុត្តិធម៌បរិស្ថានឱ្យបានសមស្របទៅក្នុងនាយកដ្ឋានរបស់ខ្លួន តាមរយៈគោលនយោបាយ កម្មវិធី ឬយុទ្ធសាស្ត្រដទៃផ្សេងទៀត...។ ទីភ្នាក់ងារ EEA ត្រូវធ្វើការកំណត់ និងជំរុញលើកកម្ពស់គម្រោងដែលឧបត្ថម្ភដោយទីភ្នាក់ងារ ដោយផ្តល់ប្រាក់ឧបត្ថម្ភដល់ការធ្វើសេចក្តីសម្រេចចិត្តការកំណត់វិធាន ឬចំណាត់ការដទៃទៀតដែលមានបំណងក្នុងការលើកកម្ពស់យុត្តិធម៌បរិស្ថានបន្ថែមទៀតនៅទូទាំងខំមិនវែលទាំងមូល ដើម្បីបង្ហាញពីរបៀបនៃការវាស់វែងការបែងចែកអត្ថប្រយោជន៍ដែលត្រឹមត្រូវ"។

## សិទ្ធិអំណាចតាមផ្លូវច្បាប់

EEA និងទីភ្នាក់ងារ ការិយាល័យ និងកម្មវិធីរបស់ខ្លួន ត្រូវបានតម្រូវឱ្យអនុវត្តតាមអាជ្ញាធរច្បាប់របស់ជាតិមួយចំនួន ដែលធានាគុណភាពក្នុងការអនុវត្តច្បាប់ និងកម្មវិធីរបស់ EEA។ អាជ្ញាធរទាំងអស់នេះរួមមានជាអាទិ៍ គោលនយោបាយយុត្តិធម៌បរិស្ថានរបស់ EEA, ជំពូកទី 8 នៃច្បាប់ឆ្នាំ2021៖ *ជាច្បាប់មួយដែលបង្កើតផែនទីបង្ហាញផ្លូវដល់អ្នកជំនាន់ក្រោយសម្រាប់គោលនយោបាយធាតុអាកាសរដ្ឋម៉ាសាជូសេត*, បទបញ្ជាអនុវត្តរបស់រដ្ឋម៉ាសាជូសេត (EO) 526 & EO 552, និង គោលនយោបាយស្តីពីការទទួលបានសេវាភាសា (ព្រឹត្តិបត្រសារព័ត៌មាន #16) របស់ការិយាល័យប្រតិបត្តិផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ (A&F)។ បន្ថែមលើនេះ ដោយសារស្ថានភាពរបស់ខ្លួនក្នុងនាមជាអ្នកទទួលបានមូលនិធិពីរដ្ឋាភិបាលសហព័ន្ធ ដូច្នេះ EEA ត្រូវធានាថា កម្មវិធីរបស់ខ្លួនស្របទៅតាមច្បាប់របស់សហព័ន្ធដែលហាមឃាត់ការរើសអើងផ្អែកលើជាតិសាសន៍ ពណ៌សម្បុរ ឬសញ្ជាតិកំណើតជាដើម។[4]

សូមអានបន្តដើម្បីស្វែងយល់ពីយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានដែលពាក់ព័ន្ធនឹងទីភ្នាក់ងារនីមួយៗការិយាល័យ និងកម្មវិធីស្ថិតក្រោមដែនសមត្ថកិច្ចរបស់ EEA។

## និយមន័យ

"យុត្តិធម៌បរិស្ថាន" គឺផ្អែកលើគោលការណ៍ដែលមនុស្សរាល់គ្នាមានសិទ្ធិទទួលបានការការពារពីគ្រោះថ្នាក់បរិស្ថាន និងដើម្បីរស់នៅ និងទទួលបានបរិស្ថានស្អាត និងមានសុខភាពល្អ ដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ សញ្ជាតិកំណើត ប្រាក់ចំណូល ឬសមត្ថភាពចំណេះដឹងភាសាអង់គ្លេសឡើយ។ យុត្តិធម៌បរិស្ថាន គឺជាការការពារស្មើភាពគ្នា និងការចូលរួមប្រកបដោយអត្ថន័យពីសំណាក់ពលរដ្ឋ និងសហគមន៍ពាក់ព័ន្ធនឹងការអភិវឌ្ឍ ការអនុវត្ត និងការពង្រឹងការអនុវត្តច្បាប់ បទបញ្ញត្តិ និងគោលនយោបាយស្តីពីថាមពល បម្រែបម្រួលអាកាសធាតុ និងបរិស្ថាន និងការបែងចែកដោយស្មើភាពគ្នានូវអត្ថប្រយោជន៍និងបន្ទុកបរិស្ថាន និងថាមពល។

"គោលការណ៍យុត្តិធម៌បរិស្ថាន" គាំទ្រដល់ការការពារពលរដ្ឋពីការបំពុលបរិស្ថាន និងសមត្ថភាពក្នុងការរស់នៅ និងទទួលបានបរិស្ថានស្អាត និងមានសុខភាពល្អ ដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ប្រាក់ចំណូល វណ្ណៈ ពិការភាព អត្តសញ្ញាណភេទ ទំនោរផ្លូវភេទ សញ្ជាតិកំណើត ជាតិពន្ធ ឬដូនតា ជំនឿសាសនា ឬសមត្ថភាពចំណេះដឹងភាសាអង់គ្លេសនោះទេ ដែលក្នុងនោះរួមបញ្ចូលនូវ

[4] សូមមើលចំណងជើងច្បាប់ទី VI ស្ថិតក្រោមច្បាប់ស្តីពីសិទ្ធិស៊ីវិលឆ្នាំ1964 [https://www.epa.gov/ocr/title-vi-laws-and-regulations], គោលការណ៍ណែនាំនៅ [https://www.epa.gov/ogc/ecrco-guidance-and-policies]

៖ (i) ការចូលរួមប្រកបដោយអត្ថន័យរបស់ពលរដ្ឋពាក់ព័ន្ធនឹងការអភិវឌ្ឍ ការអនុវត្ត និងការពង្រឹងការអនុវត្តច្បាប់ បទបញ្ញត្តិ និងគោលនយោបាយស្តីពីបរិស្ថាន និង (ii) ការបែងចែកដោយស្មើភាពគ្នានូវអត្ថប្រយោជន៍បរិស្ថាននិងថាមពល និងបន្ទុកបរិស្ថាន។

"ក្រុមប្រជាជនយុត្តិធម៌បរិស្ថាន" សំដៅលើសង្កាត់[5] ដែលបំពេញតាមលក្ខខណ្ឌវិនិច្ឆ័យមួយឬច្រើនដូចខាងក្រោម៖

- ប្រាក់ចំណូលគ្រួសារមធ្យមប្រចាំឆ្នាំ គឺមិនលើសពី 65 ភាគរយនៃប្រាក់ចំណូលគ្រួសារមធ្យមប្រចាំឆ្នាំទូទាំងរដ្ឋ[6]
- ប្រជាជនភាគតិចមានចាប់ពី 40 ភាគរយឡើងទៅក្នុងចំណោមក្រុមប្រជាជននេះ[7]។
- សមាជិកគ្រួសារចាប់ 25 ភាគរយ ឬច្រើនជាងនេះ ខ្វះសមត្ថភាពជំនាញផ្នែកភាសាអង់គ្លេស[8]
- ប្រជាជនភាគតិចមានចំនួន 25 ភាគរយឡើងទៅ ហើយប្រាក់ចំណូលគ្រួសារមធ្យមប្រចាំឆ្នាំនៃទីក្រុងដែលសង្កាត់នោះមានទីតាំងស្ថិតនៅ គឺមិនលើសពី 150 ភាគរយនៃប្រាក់ចំណូលគ្រួសារមធ្យមប្រចាំឆ្នាំទូទាំងរដ្ឋ។ ឬ
- ចំណែកភូមិសាស្ត្រនៃសង្កាត់មួយដែលបានកំណត់ដោយលេខាធិការជាក្រុមប្រជាជនយុត្តិធម៌បរិស្ថាន ស្របទៅតាមច្បាប់នេះ។

"អត្ថប្រយោជន៍ថាមពល" សំដៅលើការទទួលបានមូលនិធិ ការបណ្តុះបណ្តាល ថាមពលកកើតឡើងវិញ ឬថាមពលផ្សេង ប្រសិទ្ធភាពថាមពល ឬធនធានអត្ថប្រយោជន៍ដទៃផ្សេងទៀត ដែលបានបែកចែកដោយ EEA ទីភ្នាក់ងារ និងការិយាល័យរបស់ខ្លួន។

"អត្ថប្រយោជន៍បរិស្ថាន" សំដៅលើការទទួលបានធនធានធម្មជាតិស្អាត រួមមានខ្យល់អាកាស ធនធានទឹក ទីលំហ ទីធ្លាលេងកម្សាន្តដែលសាងសង់ និងសំណង់បរិក្ខារ និងទីកន្លែងកម្សាន្តសប្បាយនៅក្រៅអគារ វគ្គសិក្សាអំពីថាមពលស្អាតកកើតឡើងវិញ ការអនុវត្តច្បាប់បរិស្ថាន ការបណ្តុះបណ្តាល និងការទទួលបានមូលនិធិដែលបែងចែក និងគ្រប់គ្រងដោយ EEA។

"បន្ទុកបរិស្ថាន" សំដៅលើការបំផ្លាញ ការខូចខាត ឬវិការៈកំបាំងនៃធនធានធម្មជាតិដែលមិនសូវសំខាន់ ដែលបង្កឡើងដោយមូលហេតុអចេតនា ឬមូលហេតុដែលមិនអាច

---

[5] "សង្កាត់" សំដៅលើក្រុមសង្កាត់ជំរឿនមួយក្រុមដែលកំណត់ដោយក្រសួងជំរឿនសហរដ្ឋអាមេរិក (U.S. Census Bureau) ប៉ុន្តែមិនរាប់បញ្ចូលពលរដ្ឋដែលរស់នៅក្នុងអន្តេវាសិកដ្ឋានក្នុងមហាវិទ្យាល័យ ឬពលរដ្ឋស្ថិតក្រោមការថែមទាំងគ្រប់គ្រងនិងអនុវត្តផ្លូវច្បាប់ ឬស្ថិតក្រោមការឃុំខ្លួន (ឧ.ទា. ពន្ធនាគាររបស់រដ្ឋ ឬសហព័ន្ធ)។

[6] "ប្រាក់ចំណូលទាប" សំដៅលើប្រាក់ចំណូលគ្រួសារមធ្យមប្រចាំឆ្នាំ នៅត្រឹម ឬនៅក្រោម 65 ភាគរយនៃប្រាក់ចំណូលមធ្យមទូទាំងរដ្ឋសម្រាប់រដ្ឋម៉ាសាជូសេត យោងទៅតាមទិន្នន័យជំរឿនរបស់សហព័ន្ធ។

[7] "ប្រជាជនភាគតិច" សំដៅលើបុគ្គលនានាដែលកំណត់ខ្លួនឯងថាជា ជនជាតិឡាទីន/អេស្ប៉ាញ ជនជាតិស្បែកខ្មៅ/អាមេរិកាំងដើមកំណើតអាហ្វ្រិក ជនជាតិអាស៊ី ជនជាតិដើមភាគតិច និងពលរដ្ឋដែលកំណត់ថាខ្លួនឯងមិនមែនជាជនស្បែកស។

[8] "ការនៅដាច់ដោយឡែកខាងភាសាអង់គ្លេស" សំដៅលើគ្រួសារដែលត្រូវបាននៅដាច់ដោយឡែកដោយសារភាសាអង់គ្លេស យោងទៅតាមទម្រង់បែបបទជំរឿនសហព័ន្ធ ឬពុំមានមនុស្សពេញវ័យអាយុច្រើនជាង 14 ឆ្នាំ ដែលនិយាយតែភាសាអង់គ្លេស ឬនិយាយភាសាអង់គ្លេសបានល្អប្រសើរ។

ទាយទុកមុនបាន រួមមានជាអាទិ៍ បម្រែបម្រួលអាកាសធាតុ ការបំពុលខ្យល់ ការបំពុលទឹក ការបញ្ចេញទឹកស្អុយមិនត្រឹមត្រូវ ការចាក់បង្ហូរកាកសំណល់រឹង និងសារធាតុពុលដទៃផ្សេងទៀត សំឡេងឮខ្លាំង សកម្មភាពដែលរារាំងដល់ការទទួលបានធនធានធម្មជាតិ និងសំណង់បរិក្ខារនិងទីកន្លែងកម្សាន្តសប្បាយដែលបានសាងសង់នៅខាងក្រៅអគារ ការកែលម្អបំបាត់ការបំពុលមិនគ្រប់គ្រង ការកាត់បន្ថយកម្រិតទឹកក្រោមដី កង្វះគុណភាពទឹក កំណើនគ្រោះទឹកជំនន់ ឬលំហូរទឹកដោយសារខ្យល់ព្យុះ និងការបំផ្លាញផ្លូវទឹក និងបឹងបួរនៅលើកោះ ដីសើម ឆ្នេរសមុទ្រ ទឹក ព្រៃឈើ ទីលំហ និងកន្លែងលេងកម្សាន្តពីការបើកដំណើរការដោយឧស្សាហកម្មឯកជន ពាណិជ្ជកម្ម ឬរដ្ឋាភិបាល ឬសកម្មភាពដទៃផ្សេងទៀតដែលបំពុល ឬផ្លាស់ប្តូរគុណភាពបរិស្ថាន និងបង្កគ្រោះថ្នាក់ដល់សុខភាពបរិស្ថាន។

## បញ្ជីពាក្យកាត់ក្នុងឯកសារនេះ

| | |
|---|---|
| CZM: | ការិយាល័យគ្រប់គ្រងតំបន់ឆ្នេរ (Coastal Zone Management) |
| DCR: | នាយកដ្ឋានអភិរក្ស និងការកម្សាន្ត (Department of Conservation and Recreation) |
| DCS: | អង្គភាពសេវាអភិរក្សា (Division of Conservation Services) |
| DEP: | នាយកដ្ឋានការពារបរិស្ថាន (Department of Environmental Protection) |
| DFG: | នាយកដ្ឋានរុក្ខាប្រមាញ់ នេសាទ និងល្បែងកម្សាន្ត (Department of Fish and Game) |
| DOER: | នាយកដ្ឋានធនធានថាមពល (Department of Energy Resources) |
| DPU: | នាយកដ្ឋានសេវាសាធារណៈ (Department of Public Utilities) |
| EJ: | យុត្តិធម៌បរិស្ថាន (Environmental Justice) |
| ILC: | គណៈកម្មការដែនដីអន្តរទីភ្នាក់ងារ (Interagency Land Committee) |
| GWSA: | ច្បាប់ស្តីពីដំណោះស្រាយការកើនឡើងកំដៅផែនដី (Global Warming Solutions Act) |
| LAND: | កម្មវិធីលទ្ធកម្មនៅក្នុងមូលដ្ឋានសម្រាប់ពិពិធភាពធម្មជាតិនៃរដ្ឋម៉ាសាជូសេត (Massachusetts Local Acquisitions for Natural Diversity programs) |
| LEP: | សមត្ថភាពចំណេះដឹងភាសាអង់គ្លេសនៅមានកម្រិត (Limited English Proficiency) |
| MassCEC: | មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (Massachusetts Clean Energy Center) |
| MDAR: | នាយកដ្ឋានកសិកម្មរដ្ឋម៉ាសាជូសេត (Massachusetts Department of Agriculture) |
| MEP: | ប៉ូលិសបរិស្ថានរដ្ឋម៉ាសាជូសេត (Massachusetts Environmental Police) |
| MEPA: | ច្បាប់ស្តីពីគោលនយោបាយបរិស្ថានរដ្ឋម៉ាសាជូសេត (Massachusetts Environmental Policy Act) |
| MET: | កម្មវិធីទំនុកចិត្តបរិស្ថានរដ្ឋម៉ាសាជូសេត (Massachusetts Environmental Trust) |
| MVP: | កម្មវិធីត្រៀមរៀបចំចំពោះភាពងាយរងគ្រោះរបស់ក្រុង (Municipal Vulnerability Preparedness Program) |
| MWRA: | អាជ្ញាធរធនធានទឹករដ្ឋម៉ាសាជូសេត (Massachusetts Water Resources Authority) |
| OTA: | ការិយាល័យជំនួយបច្ចេកទេស (Office of Technical Assistance) |

PARC: កម្មវិធីលទ្ធកម្ម និងការកែលម្អទីចំណតសម្រាប់សហគមន៍ (Parkland Acquisitions and Renovations for Communities)

## លទ្ធភាពដែលអាចអនុវត្តបាន

ផ្អែកតាមលក្ខខណ្ឌតម្រូវនៃគោលនយោបាយយុត្តិធម៌បរិស្ថាន យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់ EEA នេះ អនុវត្តចំពោះការិយាល័យលេខាធិការដ្ឋាន និងគំនិតផ្តួចផ្តើម និងកម្មវិធីនានាដែលមានទីតាំងនៅក្នុងការិយាល័យនេះ៖ កម្មវិធីលទ្ធកម្ម និងការកែលម្អទីចំណតសម្រាប់សហគមន៍រដ្ឋម៉ាសាជូសេត (PARC) កម្មវិធីលទ្ធកម្មនៅក្នុងមូលដ្ឋានសម្រាប់ពិពិធភាពធម្មជាតិនៃរដ្ឋម៉ាសាជូសេត (LAND) កម្មវិធីទំនុកចិត្តបរិស្ថានរដ្ឋម៉ាសាជូសេត (MET) កម្មវិធីប្រាំងឆកសមុទ្ររដ្ឋម៉ាសាជូសេត គណៈកម្មាធិការធនធានទឹក ក្រុមប្រឹក្សាវិជ្ជាជីវៈនៅទីតាំងដែលទទួលបានអាជ្ញាប័ណ្ណ និងក្រុមប្រឹក្សាវិជ្ជាជីវៈសម្អាតទីតាំងកាកសំណល់គ្រោះថ្នាក់ គណៈកម្មការដែនដីអន្តរទីភ្នាក់ងារ (ILC) អង្គភាពសេវាអភិរក្ស (DCS) និងកម្មវិធីដទៃផ្សេងទៀត រួមមានជាអាទិ៍ កម្មវិធីដែលពាក់ព័ន្ធនឹងការសម្របខ្លួនទៅនឹងបម្រែបម្រួលអាកាសធាតុ ដូចជា កម្មវិធីត្រៀមរៀបចំចំពោះភាពងាយរងគ្រោះរបស់ក្រុង (MVP) និងការអនុវត្តច្បាប់ស្តីពីដំណោះស្រាយការកើនឡើងកំដៅផែនដី (GWSA)។

ការិយាល័យដែលមានទីតាំងនៅក្នុង EEA ដែលបានបង្កើតយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានផ្ទាល់ខ្លួន រួមមាន ច្បាប់ស្តីពីគោលនយោបាយបរិស្ថានរដ្ឋម៉ាសាជូសេត (MEPA) ការិយាល័យគ្រប់គ្រងតំបន់ឆ្នេរ (CZM) ការិយាល័យជំនួយបច្ចេកទេស (OTA) និង ប៉ូលិសបរិស្ថានរដ្ឋម៉ាសាជូសេត (MEP) អាចយោង និងអនុម័តយកលក្ខខណ្ឌជាច្រើននៃយុទ្ធសាស្ត្រនេះបញ្ចូលទៅក្នុងយុទ្ធសាស្ត្ររបស់ខ្លួន។

## យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាននៃការិយាល័យលេខាធិការដ្ឋានរបស់ EEA

### គំនិតផ្តួចផ្តើមយុត្តិធម៌បរិស្ថានបច្ចុប្បន្ន និងបន្តបន្ទាប់

គំនិតផ្តួចផ្តើមដូចខាងក្រោមនេះ បច្ចុប្បន្ននេះកំពុងអនុវត្ត និងបន្តជាផ្នែកមួយនៃយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានសម្រាប់ការិយាល័យលេខាធិការដ្ឋាន៖

- **កម្មវិធីយុត្តិធម៌បរិស្ថាន និងនាយកកម្មវិធីយុត្តិធម៌បរិស្ថាន** កម្មវិធីយុត្តិធម៌បរិស្ថាននេះត្រូវបានដឹកនាំដោយប្រធានកម្មវិធីយុត្តិធម៌បរិស្ថាន និងជ្រើសរើសបុគ្គលិកដោយអនុប្រធានកម្មវិធីយុត្តិធម៌បរិស្ថាន។ ប្រធានដើរតួជាបុគ្គលសម្រាប់ទំនាក់ទំនងដំបូងសម្រាប់បញ្ហាយុត្តិធម៌បរិស្ថាន ដឹកនាំក្រុមការងារយុត្តិធម៌បរិស្ថាន បង្កើតកម្មវិធី និងបណ្តុះបណ្តាលសម្រាប់ EEA និងទីភ្នាក់ងាររបស់ស្ថាប័ននេះ និងតាមដានវឌ្ឍនភាពឆ្ពោះទៅរកគោលដៅយុត្តិធម៌បរិស្ថាន និងជួយដល់ការិយាល័យ EEA ដទៃទៀត ដូចជាការិយាល័យច្បាប់ ក្នុងបញ្ហាពាក់ព័ន្ធនឹងយុត្តិធម៌បរិស្ថាន។

- **ក្រុមការងារយុត្តិធម៌បរិស្ថាន** ក្រុមការងារយុត្តិធម៌បរិស្ថាន រួមមានសមាសភាពពីបុគ្គលទំនាក់ទំនងខាងយុត្តិធម៌បរិស្ថានពីខាងទីភ្នាក់ងារនិងការិយាល័យរបស់ EEA ដូចខាងក្រោម៖ MDAR, DCR, DEP, DFG, DOER, DPU, CZM, MEPA MEP, OTA, MassCEC, និង MWRA។ ក្រុមការងារបាននឹងកំពុងបំពេញកិច្ចការដើម្បីបង្កើតនិងអនុវត្តយុទ្ធសា

ស្រ្តយុត្តិធម៌បរិស្ថាន ដូចមានតម្រូវដោយគោលនយោបាយយុត្តិធម៌បរិស្ថាន សម្រាប់ទីភ្នាក់ងារតំណាងរបស់ខ្លួន។ សមាជិកក្រុមការងារយុត្តិធម៌បរិស្ថានបំពេញមុខងារជាចំណុចទំនាក់ទំនងសំខាន់សម្រាប់បញ្ហាយុត្តិធម៌បរិស្ថាន ដោយធ្វើការវិភាគគោលនយោបាយទីភ្នាក់ងារ និងធ្វើការត្រួតពិនិត្យឡើងវិញនូវការអនុវត្តការចូលរួមរបស់សហគមន៍។

- **ការបណ្តុះបណ្តាល** បុគ្គលិកយុត្តិធម៌បរិស្ថានរបស់ EEA និងបុគ្គលិក GIS បានបង្កើត ហើយនឹងបន្តរៀបចំការបណ្តុះបណ្តាលសម្រាប់បុគ្គលិកលេខាធិការដ្ឋានទាំងមូលអំពីនិយមន័យថ្មីនៃក្រុមប្រជាជនយុត្តិធម៌បរិស្ថាន ហើយការផ្តល់សេវាកម្មភាសាសម្រាប់ទីភ្នាក់ងារ និងការិយាល័យនីមួយៗរបស់ EEA នឹងត្រូវរៀបចំធ្វើឡើងនៅទូទាំងរដូវរងា និងរដូវក្តៅនៃឆ្នាំ2022។

- **អង្គការយុត្តិធម៌បរិស្ថាន និងបញ្ជីប្រៃសណីយ៍** កម្មវិធីយុត្តិធម៌បរិស្ថានរបស់ EEA ត្រូវបន្តធ្វើការបំពេញបន្ថែម និងរក្សាបញ្ជីសហគមន៍ និងអង្គការគស្ស៊ីមតិផ្អែកយុត្តិធម៌បរិស្ថាន និង "បញ្ជីប្រៃសណីយ៍ផ្អែកយុត្តិធម៌បរិស្ថាន" ដែលរួមមានអង្គការយុត្តិធម៌បរិស្ថាន អង្គការយុត្តិធម៌សង្គម សមាជិកដែលចាប់អារម្មណ៍លើក្រុមប្រជាជនយុត្តិធម៌បរិស្ថាន សាជីវកម្មអភិវឌ្ឍន៍សហគមន៍ អង្គការក្នុងមូលដ្ឋាននិងអង្គការតាមសហគមន៍ សាលារៀន គ្លីនិកសុខភាព និងស្ថាប័នដទៃទៀត ដែលអាចចាប់អាម្មណ៍នឹងបញ្ហាយុត្តិធម៌បរិស្ថាន។ បញ្ជីនេះនឹងត្រូវចែកចាយដោយ EEA ទៅកាន់ទីភ្នាក់ងារ ការិយាល័យ និងកម្មវិធីរបស់ខ្លួន និងទៅកាន់លេខាធិការដ្ឋានដទៃទៀតទៅតាមការស្នើសុំ សម្រាប់ការប្រើប្រាស់នៅក្នុងការផ្ញើកាសែត និងការជូនដំណឹងអំពីឱកាសមូលនិធិជំនួយ និងព័ត៌មានផ្សព្វផ្សាយទូទៅដទៃផ្សេងទៀត។ បញ្ជីនេះក៏នឹងត្រូវប្រើប្រាស់ដើម្បីជួយដល់អ្នកស្នើគម្រោង MEPA និងស្ថាប័នដទៃផ្សេងទៀត ដែលស្នើសុំព័ត៌មាននៅក្នុងកិច្ចខិតខំផ្សព្វផ្សាយរបស់ពួកគេ។

- **ច្បាប់ស្តីពីអាកាសធាតុឆ្នាំ2021** លេខាធិការត្រូវបន្តគិតគូរពីគោលការណ៍យុត្តិធម៌បរិស្ថាន នៅក្នុងការអនុវត្តជំពូកទី 8 នៃច្បាប់ឆ្នាំ2021៖ *ជាច្បាប់មួយដែលបង្កើតផែនទីបង្ហាញផ្លូវដល់អ្នកជំនាន់ក្រោយសម្រាប់គោលនយោបាយធាតុអាកាសរដ្ឋម៉ាសាជូសេត (ច្បាប់ស្តីពីអាកាសធាតុឆ្នាំ2021)* រួមបញ្ចូលទាំងការកែប្រែបទបញ្ញត្តិ MEPA; ការបង្កើតក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន; ការបង្កើត និងការសម្រិតសម្រាំងផែនទីយុត្តិធម៌បរិស្ថានថ្មី; និងការអនុម័តទូទៅលេខាធិការដ្ឋាននូវដំណើរការនៃការចូលរួមជាសាធារណៈប្រកបដោយប្រសិទ្ធភាព។ លេខាធិការដ្ឋានត្រូវបង្កើតស្តង់ដានិងគោលការណ៍ណែនាំសម្រាប់ការអនុវត្ត ការគ្រប់គ្រង និងការត្រួតពិនិត្យឡើងវិញតាមពេលវេលាលើគោលការណ៍យុត្តិធម៌បរិស្ថាន ដោយការិយាល័យប្រតិបត្តិផ្អែកថាមពលនិងកិច្ចការបរិស្ថាន និងទីភ្នាក់ងារនៃការិយាល័យនេះ។

- **ច្បាប់ស្តីពីដំណោះស្រាយការកើនឡើងកំដៅផែនដី** នៅថ្ងៃទី30 ខែមិថុនា ឆ្នាំ2022 EEA បានដាក់ជូនផែនការថាមពលស្អាត និងអាកាសធាតុឆ្នាំ2025 និង 2030 ទៅកាន់សភា។ គ្រប់ទិដ្ឋភាពទាំងអស់នៃផែនការនេះ ត្រូវបានព្រៀងតាមរយៈកម្មវិធីយុត្តិធម៌បរិស្ថាន ការត្រួតពិនិត្យខាងយុត្តិធម៌ថាមពលនិងយុត្តិធម៌អាកាសធាតុ និងការកត់ចំណាំពី

អនុសាសន៍របស់ក្រុមការងារយុត្តិធម៌អាកាសធាតុនៃគណៈកម្មការប្រឹក្សាយោបល់អនុវត្តន៍។ បុគ្គលិកយុត្តិធម៌បរិស្ថានរបស់ EEA នឹងបន្តធ្វើការជាមួយក្រុមអាកាសធាតុ ដើម្បីបង្កើតឥទ្ធិពលដល់គ្រប់ទិដ្ឋភាពនៃការធ្វើផែនការសម្រាប់ការផ្លាស់ប្តូរដោយយុត្តិធម៌ទៅកាន់សេដ្ឋកិច្ចបៃតង រួមបញ្ចូលទាំងកិច្ចខិតខំប្រឹងប្រែងនៅក្នុងវិស័យអគ្គិសនី ការប្រើប្រាស់ដី ការដឹកជញ្ជូន សំណង់ប្រសិទ្ធភាពថាមពល និងការបង្កើតកម្លាំងការងារ។

- **កម្មវិធីត្រៀមរៀបចំចំពោះភាពងាយរងគ្រោះរបស់ក្រុង** EEA នឹងបន្តបង្កើតនិងអនុវត្តលក្ខខណ្ឌវិនិច្ឆ័យមូលនិធិជំនួយដើម្បីផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តដល់គម្រោងនានាដែលជួយដល់សង្កាត់យុត្តិធម៌បរិស្ថានដែលងាយរងគ្រោះបំផុត និងក្រុមប្រជាជនយុត្តិធម៌បរិស្ថាន ហើយនឹងបន្តលើកទឹកចិត្តថ្នាក់ដឹកនាំក្រុង និងភាគីពាក់ព័ន្ធឱ្យចូលរួមយ៉ាងសកម្មបំផុតជាមួយក្រុមប្រជាជនយុត្តិធម៌បរិស្ថាន។ បន្ថែមលើនេះ ដោយសារកម្មវិធី MVP បានធ្វើការកែតម្រូវដំណើរការនៃការធ្វើផែនការភាពធន់ទ្រាំអាកាសធាតុនៅកម្រិតទីក្រុង ដូច្នេះខ្លួននឹងធ្វើកិច្ចការដើម្បីបង្កើនសំឡេងក្រុមប្រជាជននិងតំណាងយុត្តិធម៌បរិស្ថាន និងអាកាសធាតុ នៅក្នុងដំណើរការនៃការធ្វើការ និងបង្កើតទំនាក់ទំនងកាន់តែរឹងមាំផ្អែកលើគម្រោង រវាងទីក្រុង និងក្រុមប្រជាជនយុត្តិធម៌បរិស្ថាន។

- **ក្រុមការងារផលប៉ះពាល់ប្រមូលផ្តុំ** EEA នឹងបន្តកោះប្រជុំក្រុមការងារផលប៉ះពាល់ប្រមូលផ្តុំនៃទីភ្នាក់ងារអន្តរក្រសួង ដើម្បីធ្វើការដោះស្រាយបញ្ហាផលប៉ះពាល់រួមនៅទូទាំងលេខាធិការដ្ឋាន និងដើម្បីប្រមូលព័ត៌មានពីលេខាធិការដ្ឋានដទៃផ្សេងទៀត ដែលពាក់ព័ន្ធនឹងផលប៉ះពាល់រួមគ្នា។ EEA នឹងបន្តកិច្ចសហប្រតិបត្តិការជាមួយក្រុមការងារផលប៉ះពាល់ប្រមូលផ្តុំផ្នែកគុណភាពខ្យល់របស់ DEP ដោយធ្វើការប្រកាសឱ្យប្រើប្រាស់បទបញ្ញត្តិថ្មីនៅក្នុងកម្មវិធីខ្យល់របស់ DEP ទៅតាមការតម្រូវដោយច្បាប់ស្តីពីអាកាសធាតុឆ្នាំ2021។

- **ការទទួលបានសេវាច្រើនភាសា** EEA នឹងបន្តការអភិវឌ្ឍផែនការទទួលបានសេវាកម្មភាសា ដូចមានតម្រូវនៅក្នុងព្រឹត្តិបត្រសារព័ត៌មាន #16 របស់ A&F។ យោងតាមព្រឹត្តិបត្រព័ត៌មាននោះ ការវាយតម្លៃធនធានភាសាត្រូវបានធ្វើឡើងដោយទីភ្នាក់ងារនិងការិយាល័យរបស់ EEA ក្នុងខែសីហា និងខែកញ្ញា ឆ្នាំ2021 ដោយផ្តល់ព័ត៌មានអំពីបុគ្គលិកទីភ្នាក់ងារពហុភាសា ដែលអាចសម្របសម្រួលដល់ការប្រាស្រ័យទាក់ទងជាមួយពលរដ្ឋម៉ាសាជូសេតដែលមានសមត្ថភាពចំណេះដឹងភាសាអង់គ្លេសមានកម្រិត។ EEA បានចាត់តាំងអ្នកសម្របសម្រួលការទទួលសេវាកម្មភាសាម្នាក់ ដែលមានទំនួលខុសត្រូវសម្រាប់ការអនុវត្តទីភ្នាក់ងារ និងអនុលោមភាពជាមួយផែនការទទួលបានសេវាកម្មភាសារបស់ EEA។ EEA បានកំណត់ដាក់ឱ្យប្រើប្រាស់នៅទូទាំងរដ្ឋនូវកិច្ចសន្យា PRF75៖ សេវាបកប្រែភាសាបរទេសជាឯកសារ និងផ្ទាល់មាត់[9] សម្រាប់គោលបំណងនៃការទទួល

[9] https://www.mass.gov/doc/prf75/download

បានអ្នកបកប្រែឯកសារ និងអ្នកបកប្រែផ្ទាល់មាត់ដែលមានជំនាញវិជ្ជាជីវៈ។ មានការផ្តល់ថវិកាសម្រាប់ការប្រើប្រាស់សេវាកម្មទាំងនេះ។

- **ផែនទីយុត្តិធម៌បរិស្ថាន** ដើម្បីកំណត់ពីក្រុមប្រជាជនយុត្តិធម៌បរិស្ថានដែលបានកំណត់នៅក្នុងគោលនយោបាយយុត្តិធម៌បរិស្ថាន EEA នឹងបន្តធ្វើការរៀបចំ និងកែប្រែផែនការលម្អិតផ្អែកលើទិន្នន័យសមស្របនិងថ្មីបំផុត ដែលមាននៅក្នុងក្រសួងជំរឿនសហរដ្ឋអាមេរិក។

- **គេហទំព័រយុត្តិធម៌បរិស្ថាន** EEA បានដាក់ឱ្យប្រើប្រាស់នូវគេហទំព័រយុត្តិធម៌បរិស្ថានដែលបានធ្វើបច្ចុប្បន្នហើយ នៅក្នុងខែមិថុនា ឆ្នាំ2021។ គេហទំព័រដែលបានធ្វើបច្ចុប្បន្នភាពនេះ រួមមាននិយមន័យថ្មីរបស់យុត្តិធម៌បរិស្ថាន និងតំណភ្ជាប់ទៅកាន់ផែនទីប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS)។ EEA នឹងបន្តថែទាំ និងធ្វើបច្ចុប្បន្នភាពលើគេហទំព័ររបស់ខ្លួនឱ្យក្លាយជាកន្លែងរក្សាទុកព័ត៌មានអនឡាញសម្រាប់ព័ត៌មានអំពីសកម្មភាពយុត្តិធម៌បរិស្ថានរបស់ខំមិនវែលនេះ ឧបករណ៍និងទិន្នន័យធ្វើផែនទី គំនិតផ្តួចផ្តើម ធនធាន និងមតិយោបល់ពីសាធារណជនដែលពាក់ព័ន្ធដែលទទួលបាន។ EEA ក៏នឹងរួមបញ្ចូលនូវការបកប្រែគេហទំព័រ និងព័ត៌មានទៅជាភាសាសំខាន់ៗដែលនិយាយនៅក្នុងរដ្ឋម៉ាសាជូសេតនេះផងដែរ។ បច្ចេកសព្ទដែលប្រើលើគេហទំព័រនេះ នឹងត្រូវត្រួតពិនិត្យឡើងវិញ ដើម្បីធានាថា បច្ចេកសព្ទនោះ អាចអានបានដោយអ្នកដែលមិនសូវមានចំណេះដឹងខាងបច្ចេកទេសភាសានៅក្នុងកិច្ចការបរិស្ថាន និងរដ្ឋាភិបាល។

- **សុខភាពសាធារណៈ** EEA និង MassDEP ត្រូវបន្តជួបប្រជុំគ្នាជាប្រចាំជាមួយនាយកដ្ឋានសុខភាពសាធារណៈរបស់ម៉ាសាជូសេត (DPH) ដើម្បីសម្របសម្រួលបញ្ហាបរិស្ថាន ដែលប៉ះពាល់ខ្លាំងដល់សុខភាពសាធារណៈ រួមបញ្ចូលទាំងបញ្ហាពាក់ព័ន្ធនឹងការប៉ះពាល់នឹងប្រភពនៃការបំពុលច្រើន និងមានលក្ខណៈប្រមូលផ្តុំ និងកិច្ចខិតខំផ្អែកលើសង្កាត់យុត្តិធម៌បរិស្ថាន បន្ថែមពីលើការបង្កើតឧបករណ៍ដែលជួបប្រសព្វគ្នាជាមួយដែនយុត្តាធិការនៃទីភ្នាក់ងារទាំងបី និងរួមចំណែកដល់ការបង្កើនចំណេះដឹងពាក់ព័ន្ធនឹងផលប៉ះពាល់ប្រមូលផ្តុំនៃប្រភពនៃការបំពុលច្រើន និងកត្តាសង្គម-សេដ្ឋកិច្ចនៅក្នុងសង្កាត់យុត្តិធម៌បរិស្ថាន។

- **មូលនិធិជំនួយ** EEA និងទីភ្នាក់ងាររបស់ខ្លួន ត្រូវបន្តធ្វើការពិចារណាអំពីយុត្តិធម៌បរិស្ថានក្នុងនាមជាលក្ខខណ្ឌវិនិច្ឆ័យសម្រាប់ការផ្តល់ជូនមូលនិធិជំនួយ និងការផ្តល់អាទិភាពដល់កម្មវិធីដែលផ្តល់មូលនិធិដល់ទទួលដែលស័ក្តិសម។ បន្ថែមលើនេះ EEA និងទីភ្នាក់ងាររបស់ខ្លួនត្រូវបន្តផ្តល់អាទិភាពដល់ក្រុមប្រជាជនយុត្តិធម៌បរិស្ថាន តាមរយៈការអនុវត្តការធ្វើផែនការដោយយកចិត្តទុកដាក់ និងការគិតពិចារណាជិតដល់ នៅពេលអនុញ្ញាតនិងធ្វើការអភិវឌ្ឍ។

- **ការកែប្រែដីអភិវឌ្ឍន៍ដែលត្រូវគេបោះបង់ចោលឱ្យមានភាពស្រស់ស្អាតឡើងវិញ** EEA ត្រូវបន្តកំណត់អាទិភាពក្រុមប្រជាជនយុត្តិធម៌បរិស្ថាននៅក្នុងកិច្ចការសហប្រតិបត្តិការជាមួយដៃគូរដ្ឋ មូលដ្ឋាន និងសហព័ន្ធ ដើម្បីកែលម្អបំបាត់ដីអភិវឌ្ឍន៍ដែលត្រូវគេបោះ

បង់ចោល និងកម្មវិធីអភិវឌ្ឍន៍សាជាថ្មី រួមបញ្ចូលទាំងកិច្ចការនៃនាយកដ្ឋានលំនៅដ្ឋាន និងការអភិវឌ្ឍន៍សេដ្ឋកិច្ច MassDevelopment ការិយាល័យអគ្គមេធាវីរដ្ឋម៉ាសាជូសេត នាយកដ្ឋានប្រាក់ចំណូល នាយកដ្ឋានដឹកជញ្ជូនរដ្ឋម៉ាសាជូសេត នាយកដ្ឋានធនធានថាមពល ក្រសួងការពារបរិស្ថានសហរដ្ឋអាមេរិក ក្រសួងអភិវឌ្ឍន៍លំនៅដ្ឋាននិងទីក្រុងរបស់សហរដ្ឋអាមេរិក និងភាគីពាក់ព័ន្ធមកពីទីក្រុង តំបន់ អង្គការមិនរកប្រាក់កម្រៃ និងវិស័យឯកជន។ ឧទាហរណ៍អំពីកម្មវិធីរបស់រដ្ឋដែលត្រូវបានរៀបចំឡើងដើម្បីគាំទ្រដល់សហគមន៍ងាយរងគ្រោះ ហើយនឹងផ្តល់អត្ថប្រយោជន៍ដល់ក្រុមប្រជាជនយុត្តិធម៌បរិស្ថាន មានដូចជា កម្មវិធីចំណតរបស់ Gateway City, កិច្ចព្រមព្រៀងក្រុមសហគមន៍របស់អភិបាលរងក្រុង, មូលនិធិបង្វិលរបស់រដ្ឋ (SRF), ប្រព័ន្ធទទួលបានព័ត៌មានបរិស្ថានពីសាធារណជន (EIPAS), របៀបវារៈទីក្រុងរបស់អភិបាល, គំនិតផ្តួចផ្តើមអភិវឌ្ឍន៍កែប្រែ (TDI) របស់ MassDevelopment, និងចលនា Mass in Motion របស់ MDPH។

- **ធនធានទីលំហគោលដៅ** EEA នឹងបន្តខិតខំប្រឹងប្រែងដើម្បីកំណត់គោលដៅនៃធនធានរបស់ខ្លួនដើម្បីបង្កើត រក្សាទុក និងថែទាំប្រកបដោយប្រសិទ្ធភាពនូវទីលំហ ដែលមានទីតាំងនៅក្នុងសង្កាត់ ដែលក្រុមប្រជាជនយុត្តិធម៌បរិស្ថានស្នាក់នៅ។

**បណ្តាញផ្សព្វផ្សាយព័ត៌មានក្នុងស្រុកជាភាសាផ្សេងក្រៅពីអង់គ្លេស** EEA បានបង្កើតបញ្ជីកន្លែងផ្សព្វផ្សាយព័ត៌មានមិនមែនបែបប្រពៃណី ដែលនឹងមានផ្តល់ជូនដល់ទីភ្នាក់ងារ EEA ក្នុងការស្វែងរកមតិយោបល់សាធារណៈ និងដើម្បីការពារអ្នកស្នើដែលអាចត្រូវបានគេស្នើឱ្យធ្វើការចុះផ្សាយការជូនដំណឹងសម្រាប់គម្រោងដែលមានការចូលរួម ឬអាចមានផលប៉ះពាល់ដល់ក្រុមប្រជាជនយុត្តិធម៌បរិស្ថាន។ EEA នឹងបន្តថែរក្សាបញ្ជីនេះ ដោយធ្វើការបន្ថែមកន្លែងថ្មីៗ ដោយរក្សាព័ត៌មានទំនាក់ទំនងនោះឱ្យថ្មីបំផុត ហើយលុបចោលកន្លែងណាដែលលែងបើកដំណើរការអាជីវកម្ម ឬដែលពាក់ព័ន្ធនឹងគោលបំណងនេះ។

## អនាគតគំនិតផ្តួចផ្តើមយុត្តិធម៌បរិស្ថាន

ខាងក្រោមនេះ គឺជាគំនិតផ្តួចផ្តើមដែលនឹងត្រូវដាក់ឱ្យដំណើរការសម្រាប់ការិយាល័យលេខាធិការដ្ឋាន៖

- **ក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន** EEA ត្រូវបើកកិច្ចប្រជុំក្រុមប្រឹក្សាយុត្តិធម៌បរិស្ថានដែលចាត់តាំងដោយរដ្ឋាភិបាលដូចតម្រូវដោយ ច្បាប់ស្តីពីអាកាសធាតុឆ្នាំ2021 ដើម្បីផ្តល់ការណែនាំ និងផ្តល់អនុសាសន៍សមស្របដល់លេខាធិការដ្ឋានថាមពលនិងកិច្ចការបរិស្ថាន ស្តីពីគោលនយោបាយនិងស្តង់ដាពាក់ព័ន្ធ ដើម្បីសម្រេចបាននូវគោលការណ៍យុត្តិធម៌បរិស្ថាន។ ត្រឹម ឬមុនថ្ងៃទី31 ខែកក្កដា ឆ្នាំ2022 EEA នឹងប្រឹក្សាយោបល់ជាមួយក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន ពាក់ព័ន្ធនឹងការវិភាគស៊ីជម្រៅ និងការបញ្ជាក់ពីនិយមន័យនៃ "ក្រុមប្រជាជនយុត្តិធម៌បរិស្ថាន"។
- **ខិត្តប័ណ្ណ** ក្នុងរយៈពេលប្រាំមួយខែបន្ទាប់ពីកាលបរិច្ឆេទចូលជាធរមាននៃយុទ្ធសាស្ត្រនេះ EEA ត្រូវបង្កើតខិត្តប័ណ្ណស្តីពី MEPA កម្មវិធីលទ្ធកម្ម និងការកែលម្អទីចំណតសម្រាប់សហគមន៍ (PARC) និងកម្មវិធីលទ្ធកម្មនៅក្នុងមូលដ្ឋានសម្រាប់ពិពិធភាព

ធម្មជាតិនៃរដ្ឋម៉ាសាជូសេត (LAND) កម្មវិធីទំនុកចិត្តបរិស្ថាននរដ្ឋម៉ាសាជូសេត និងកម្មវិធីដទៃផ្សេងទៀត ដែលរួមបញ្ចូលកម្មវិធីដែលពាក់ព័ន្ធនឹងការសម្របខ្លួនទៅនឹង បម្រែបម្រួលអាកាសធាតុ ដើម្បីជូនដំណឹងដល់សាធារណជននៅក្នុងសង្កាត់ដែលមានក្រុមប្រជាជនយុត្តិធម៌បរិស្ថាស្នាក់នៅ ដែលមានកម្មវិធីទាំងអស់នេះ និងពីមុខងារនៃកម្មវិធីទាំងអស់នេះ។ ដោយធ្វើការជាមួយទីភ្នាក់ងារនេះ ប្រធានត្រូវធ្វើការកំណត់ថាតើខិត្តប័ណ្ណនោះបោះពុម្ពផ្សាយជាភាសាណាមួយ។ ខិត្តប័ណ្ណនឹងអាចស្វែងរកបានក្នុងទម្រង់ជាឯកសារបោះពុម្ព ឬទម្រង់ឌីជីថលសម្រាប់ការចែកចាយ។

- **របាយការណ៍យុត្តិធម៌បរិស្ថានប្រចាំឆ្នាំ** EEA ត្រូវចេញរបាយការណ៍ប្រចាំឆ្នាំមួយដែលរៀបរាប់លម្អិតអំពីវិធីនានាដែលប្រើលក្ខខណ្ឌវិនិច្ឆ័យនេះសម្រាប់ការផ្តល់មូលនិធិ និងការកំណត់អាទិភាពការផ្តល់មូលនិធិកម្មវិធីសម្រាប់ឆ្នាំសារពើពន្ធមុន។ របាយការណ៍នេះនឹងបង្ហាញនៅត្រឹមកម្រិតក្រុមប្លុកជំរឿនអំពីមូលនិធិសារធារណៈ ឬមូលនិធិដែលប្រើប្រាស់ជាសាធារណៈ ដែលប្រើប្រាស់រួច និងសម្រេចគម្រោងណាខ្លះ។ របាយការណ៍នេះក៏ត្រូវរៀបរាប់អំពីខ្នាតវង្វាស់ជាច្រើនដើម្បីបង្ហាញថាតើត្រូវវាស់វែងពីការបែងចែកអត្ថប្រយោជន៍ដោយយុត្តិធម៌នៅក្នុងកម្មវិធីរបស់ខ្លួនដោយរបៀបណា។ របាយការណ៍ជាសាធារណៈនឹងត្រូវចេញផ្សាយមិនឱ្យលើសថ្ងៃទី15 ខែតុលា នៅក្នុងឆ្នាំនោះឡើយ ដើម្បីបង្ហាញពីព័ត៌មានស្តីពីឆ្នាំប្រតិទិនមុន ហើយរបាយការណ៍ទីមួយ នឹងត្រូវចេញផ្សាយនៅក្នុងឆ្នាំ 2023 ដោយធ្វើការរាយការណ៍ពីឆ្នាំ2022។ បន្ថែមលើនេះ EEA នឹងកោះប្រជុំជាសាធារណៈប្រចាំឆ្នាំ ដើម្បីរាយការណ៍ពីវឌ្ឍនភាពនៃគោលនយោបាយយុត្តិធម៌បរិស្ថាន។

- **ខ្នាតវង្វាស់** ដើម្បីតាមដានវឌ្ឍនភាពឆ្ពោះទៅរកគោលដៅយុត្តិធម៌បរិស្ថាន EEA នឹងបង្កើតខ្នាតវង្វាស់ដើម្បីតាមដានការបែងចែកអត្ថប្រយោជន៍ត្រឹមត្រូវនៅក្នុងកម្មវិធីរបស់ខ្លួន។ EEA នឹងចុះផ្សាយលទ្ធផលរកឃើញនៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន ហើយនឹងរួមបញ្ចូលខ្នាតវង្វាស់យុត្តិធម៌បរិស្ថាន និងវឌ្ឍនភាពសម្រាប់ទីភ្នាក់ងារ ការិយាល័យ និងកម្មវិធីរបស់ EEA។ លក្ខខណ្ឌវិនិច្ឆ័យមួយចំនួនដែលអាចយកមកពិចារណាបានមានដូចខាងក្រោមៈ
    - ការចំណាយរបស់ទីភ្នាក់ងារគិតតាមឆ្នាំសារពើពន្ធសម្រាប់សេវាបកប្រែឯកសារ និងសេវាបកប្រែផ្ទាល់មាត់។
    - ការចំណាយរបស់ទីភ្នាក់ងារ និងកម្មវិធីតាមឆ្នាំសារពើពន្ធទៅលើគម្រោងដែលផ្តល់ប្រយោជន៍ដល់សង្កាត់យុត្តិធម៌បរិស្ថាន
    - ចំនួនការបណ្តុះបណ្តាលយុត្តិធម៌បរិស្ថានដែលបានរៀបចំ និងចូលរួមដោយ EEA និងទីភ្នាក់ងាររបស់ខ្លួន
    - ព័ត៌មានប្រជាសាស្ត្រដែលបានជួល
    - ចំនួនកិច្ចប្រជុំជាសាធារណៈដែលរៀបចំដោយ EEA និងទីភ្នាក់ងាររបស់ខ្លួន នៅក្នុងសង្កាត់យុត្តិធម៌បរិស្ថាន

- **អនុលោមភាពគោលដៅ ការអនុវត្តច្បាប់ និងជំនួយ** ក្នុងពេលមួយឆ្នាំបន្ទាប់ពីកាលបរិច្ឆេទចូលជាធរមាននៃយុទ្ធសាស្ត្រនេះ EEA នឹងបង្កើតផែនការមួយដើម្បីជួយដល់ទីភ្នាក់ងារអនុលោមភាពបរិស្ថាន និងទីភ្នាក់ងារអនុវត្តច្បាប់ និងទីភ្នាក់ងារជំនួយ ដើម្បីបង្កើត

គំនិតផ្តួចផ្តើមអំពីអនុលោមភាពសម្រាប់សង្កាត់នានាដែលក្រុមប្រជាជនយុត្តិធម៌បរិស្ថានស្នាក់នៅ និងកន្លែងស្ថានភាពបរិស្ថានក្នុងមូលដ្ឋាននិងសុខភាពសាធារណៈ ត្រូវបង្កើនការយកចិត្តទុកដាក់។ កិច្ចខិតខំប្រឹងប្រែងនេះ ក៏នឹងដឹកនាំទីភ្នាក់ងារក្នុងការសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងជំនួយអនុលោមភាពរបស់ពួកគេ ជាមួយនឹងទីភ្នាក់ងារសហព័ន្ធ ក្រុមប្រឹក្សាសុខាភិបាលក្នុងមូលដ្ឋាន និងការិយាល័យទីក្រុងដទៃទៀត និងអង្គការមានមូលដ្ឋាននៅក្នុងសហគមន៍នៅក្នុងសង្កាត់ដែលក្រុមប្រជាជនយុត្តិធម៌បរិស្ថានស្នាក់នៅ។

- **ភាពជាដៃគូសេដ្ឋកិច្ច / ឱកាសការងារ** EEA ត្រូវបន្តធ្វើកិច្ចការជាមួយការិយាល័យប្រតិបត្តិផ្នែកអភិវឌ្ឍន៍លំនៅដ្ឋាន និងសេដ្ឋកិច្ច (HED) ផ្តោតលើការជំរុញភាពជាដៃគូសេដ្ឋកិច្ច និងការបង្កើនឱកាសការងារ។ ជាពិសេស EEA ត្រូវធ្វើកិច្ចការជាមួយ HED ដើម្បីលើកជំរុញគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ច ដែលរួមបញ្ចូលការអនុវត្តផលិតកម្មដែលមានអនាម័យជាងមុន និងការកាត់បន្ថយការប្រើប្រាស់សារជាតិពុល និងបង្កើតការងារនៅក្នុងសង្កាត់ដែលមានក្រុមប្រជាជនយុត្តិធម៌បរិស្ថានស្នាក់នៅ។ ចំណុចនេះរួមមានជាអាទិ៍ ការសហការគ្នាជាមួយទីភ្នាក់ងារសំខាន់ៗដូចខាងក្រោមៈ

- **ក្រុមប្រឹក្សាសម្របសម្រួលជំនួយសេដ្ឋកិច្ច (EACC)** ដោយមានការជួយជ្រោមជ្រែងពី HED, EEA ត្រូវធ្វើការស្នើសុំជាផ្លូវការឱ្យ EACC អនុម័តសំណើមួយដែលនឹងធ្វើការលើកទឹកចិត្តប្រតិបត្តិការផលិតថ្មី និងដែលមានស្រាប់ ដែលកំពុងស្វែងរកគំនិតផ្តួចផ្តើមតាមរយៈកម្មវិធីប្រាក់ឧបត្ថម្ភលើកទឹកចិត្តអភិវឌ្ឍន៍សេដ្ឋកិច្ច ដើម្បីធ្វើការប្រឹក្សាយោបល់ជាមួយ OTA អំពីការអនុវត្តផលិតកម្មផលិតផលដែលមានអនាម័យជាងមុន។

- **ការិយាល័យអភិវឌ្ឍន៍អាជីវកម្មនៃរដ្ឋម៉ាសាជូសេត (MOBD)** MOBD នឹងធ្វើការសម្របសម្រួលជាមួយ EEA ដើម្បីផ្សារភ្ជាប់ឱ្យកាន់តែមានប្រសិទ្ធភាពជាងមុននូវបញ្ហាយុត្តិធម៌សេដ្ឋកិច្ចនិងបរិស្ថាននៅកម្រិតសង្កាត់។

- **នាយកដ្ឋានអភិវឌ្ឍន៍លំនៅដ្ឋាន និងសហគមន៍ (DHCD)** EEA ត្រូវធ្វើការយ៉ាងជិតស្និទ្ធជាមួយ DHCD ដើម្បីបង្កើតអត្ថប្រយោជន៍ធនធានរបស់ខ្លួនជាអតិបរមា លើបញ្ហាកំណើន និងការអភិវឌ្ឍសហគមន៍។ ចំណុចនេះនឹងរួមបញ្ចូលជាអាទិ៍ ការពិភាក្សាជុំវិញបញ្ហាកំណើន និងការអភិវឌ្ឍលំនៅដ្ឋានដែលមានតម្លៃសមរម្យនៅក្នុងសង្កាត់ដែលមានក្រុមប្រជាជនយុត្តិធម៌បរិស្ថានស្នាក់នៅ។

- **ផ្លូវទឹក និង កម្មវិធីទំនុកចិត្តបរិស្ថានរដ្ឋម៉ាសាជូសេត (MET)** EEA នឹងធ្វើការជាមួយអង្គភាពស្តារអេកូឡូស៊ីនៃនាយកដ្ឋានរុក្ខាប្រមាញ់ នេសាទ និងល្បែងកម្សាន្ត និង MET ដើម្បីបង្កើតប្រព័ន្ធសម្រាប់ការដាក់បញ្ចូលបញ្ហាយុត្តិធម៌បរិស្ថានជាលក្ខខណ្ឌវិនិច្ឆ័យសម្រាប់ការផ្តល់មូលនិធិជំនួយ ដោយមានគោលដៅនៃការដាក់ឱ្យដំណើរការនូវប្រព័ន្ធទាំងនេះ នៅក្នុងវដ្តមូលនិធិបន្ទាប់សម្រាប់កម្មវិធីមូលនិធិជំនួយទាំងនេះ។

- **ការបណ្តុះបណ្តាល** ដើម្បីធ្វើការអប់រំបុគ្គលិកខ្លួនអំពីកំណើនមែកធាងនៃចំណេះដឹងពាក់ព័ន្ធយុត្តិធម៌បរិស្ថាន រួមមានឧបករណ៍ធ្វើផែនការ ការវិភាគផលប៉ះពាល់បង្ករ និង

ឧត្តមានុវត្តន៍សម្រាប់ការចូលរួមក្នុងសហគមន៍ និងការចូលរួមជាសាធារណៈ EEA នឹងធ្វើផែនការ និងធ្វើការសម្របសម្រួលលើការបណ្តុះបណ្តាលនៅក្នុងឆ្នាំទាំងមូលនេះ។ EEA នឹងធ្វើការបង្កើតផែនការដើម្បីបណ្តុះបណ្តាលបុគ្គលិកទីភ្នាក់ងារ EEA រួមបញ្ចូលទាំងមូលនិធិដែលបានបែងចែកសម្រាប់ការផ្តល់ជូនទីលំហ ការថែទាំនិងការស្តារទន្លេ ការអប់រំ និងជំនួយបច្ចេកទេស ការអប់រំ។ ប្រធានបទបណ្តុះបណ្តាលសម្រាប់សាធារណជន ក៏អាចយកមកធ្វើការពិចារណាបានផងដែរ។ ឧទាហរណ៍ ការបណ្តុះបណ្តាលអំពីដំណើរការនៃការត្រួតពិនិត្យស្ថិតក្រោមច្បាប់ស្តីពីគោលនយោបាយ បរិស្ថានរដ្ឋម៉ាសាជូសេត នឹងមានប្រយោជន៍ដល់ភាគីពាក់ព័ន្ធជាច្រើន ក៏ដូចជាការបណ្តុះបណ្តាលលើដំណើរការសម្រាប់ការផ្តល់មតិយោបល់ទៅកាន់ក្រុមប្រឹក្សាអាណត្តិផ្នែកសំណង់បរិក្ខារថាមពល (EFSB) ផងដែរ។

- **ការជួលបុគ្គលិក និងការត្រួតពិនិត្យសកម្មភាពការងារ** EEA ទទួលស្គាល់ពីសារៈសំខាន់នៃការមានកម្លាំងទីភ្នាក់ងារមួយដែលឆ្លុះបញ្ចាំងពីពិពិពភាពសង្គម-សេដ្ឋកិច្ច ជាតិសាសន៍ និងពូជសាសន៍នៃប្រជាជនក្នុងរដ្ឋម៉ាសាជូសេត រួមទាំងតួនាទីសំខាន់ដែលកម្លាំងនេះដើរតួក្នុងការធ្វើឱ្យប្រសើរឡើងនូវការធ្វើសេចក្តីសម្រេចចិត្តដែលមានសមភាព ពាក់ព័ន្ធនឹងការអនុញ្ញាតបរិស្ថាន និងថាមពល ទីតាំង ការបង្កើតបទបញ្ញត្តិ និងការបែងចែកមូលនិធិជំនួយ និងការអនុវត្តច្បាប់។ EEA ប្តេជ្ញាចិត្តថានឹងរួមបញ្ចូលការអនុវត្តការជ្រើសរើសបុគ្គលិកដែលមានពិពិធភាព និងដើម្បីផ្តល់នូវការបណ្តុះបណ្តាលដល់អ្នកគ្រប់គ្រងខាងជ្រើសរើសបុគ្គលិក ដើម្បីលើកកម្ពស់ការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយសមភាពនេះ រួមបញ្ចូលទាំងការប្រើប្រាស់លក្ខខណ្ឌវិនិច្ឆ័យក្នុងមុខតំណែងការងារ ដែលតម្រូវឱ្យបេក្ខជនជាប់ស្ពាពរបង្ហាញពីចំណេះដឹងនិងការយល់ដឹងពាក់ព័ន្ធនឹងតម្រូវការរបស់ប្រជាជនងាយរងគ្រោះ សង្កាត់យុត្តិធម៌បរិស្ថាន និងតំបន់ដែលមិនទទួលបានសេវាកម្មជិតដល់នៅក្នុងខំមិនវែលនេះ។ EEA នឹងពិចារណាធ្វើការត្រួតពិនិត្យឡើងវិញនូវសំណួរនានាដែលវាយតម្លៃដល់ចំណេះដឹងរបស់បេក្ខជន និងបទពិសោធពាក់ព័ន្ធនឹងប្រធានបទយុត្តិធម៌បរិស្ថាន។

## ការផ្សព្វផ្សាយដល់ភាគីពាក់ព័ន្ធ ការចូលរួមរបស់សហគមន៍ និងការចូលរួមជាសាធារណៈ

**ការចូលរួមជាសាធារណៈ:** ត្រឹមថ្ងៃទី30 ខែកញ្ញា ឆ្នាំ2022 EEA នឹងបង្កើតផែនការការផ្សព្វផ្សាយដល់ភាគីពាក់ព័ន្ធ ការចូលរួមរបស់សហគមន៍ និងការចូលរួមជាសាធារណៈ (PIP) ដើម្បីផ្តល់ការណែនាំដល់បុគ្គលិក EEA អំពីការចូលរួមជាសាធារណៈ និងការចូលរួមពីសហគមន៍ដែលមានប្រសិទ្ធភាព និងមានអត្ថន័យខ្លឹមសារ។

**ផែនការទទួលបានសេវាភាសា** ត្រឹមថ្ងៃទី30 ខែកញ្ញា ឆ្នាំ2022 EEA នឹងបង្កើតនិងអនុម័តផែនការទទួលបានសេវាភាសា (LAP) ឱ្យស្របទៅតាមព្រឹត្តិបត្រសារព័ត៌មាន #16 របស់ A&F។ បន្ថែមលើនេះ EEA បានបង្កើតដំណើរការមួយដែលនឹងត្រូវអនុម័តលើ LAPs ដោយទីភ្នាក់ងារ និងការិយាល័យនីមួយៗរបស់ EEA ហើយត្រូវបន្តធ្វើការជាមួយពួកគេដើម្បីធានានូវអនុលោមភាពនៅទូទាំងលេខាធិការដ្ឋានទាំងមូលជាមួយនឹងព្រឹត្តិបត្រសារព័ត៌មាន #16 របស់ A&F ដែលតម្រូវឱ្យមាន LAPs សម្រាប់នាយកដ្ឋាននីមួយៗ។ LAPs ទាំងអស់នេះ អនុវត្តនៅពេលដែលបុគ្គលិកទីភ្នាក់ងារកំពុងធ្វើការជាមួយសង្កាត់ ដែលក្នុងនោះមានបុគ្គលចំនួន 5% ឬច្រើន

ជាងនេះ ដែលមានសមត្ថភាពចំណេះដឹងភាសាអង់គ្លេសមានកម្រិត។ កម្មវត្ថុរបស់ LAP មានដូចជា៖ (a) លើកកម្ពស់ការទទួលបានសេវារដ្ឋ កម្មវិធី និងសកម្មភាពដែលមានគុណភាពសម្រាប់ជនដែលមិននិយាយភាសាអង់គ្លេស និងបុគ្គល LEP; (b) កាត់បន្ថយវិសមភាព និងការយឺតយ៉ាវ (ប្រសិនបើមាន) នៅក្នុងការផ្តល់ជូនសេវាកម្ម/កម្មវិធីរបស់រដ្ឋ ជូនដល់ជនដែលមិននិយាយភាសាអង់គ្លេស និងបុគ្គល LEP បើធៀបជាមួយនឹងបុគ្គលនិយាយភាសាអង់គ្លេសដែលមានសិទ្ធិទួលបានសេវា/កម្មវិធីនោះ; និង (c) បង្កើនប្រសិទ្ធភាពទីភ្នាក់ងារ និងការពេញចិត្តពីសាធារណជន។ ការអនុវត្តទៅតាម LAP នឹងជំរុញអនុលោមភាពជាមួយមាត្រា VI នៃច្បាប់ស្តីពីសិទ្ធិស៊ីវិល ឆ្នាំ1964 បទបញ្ជាអនុវត្តរបស់សហព័ន្ធលេខ 13166 និងបទបញ្ញត្តិពាក់ព័ន្ធនឹងមាត្រា VI និងការណែនាំប្រឆាំងនឹងការរើសអើងសញ្ជាតិកំណើត លក្ខន្តិកៈប្រឆាំងការរើសអើងរបស់រដ្ឋ– ជំពូក 151B នៃច្បាប់ទូទៅនិងបទបញ្ជាអនុវត្តលេខ 526 របស់រដ្ឋម៉ាសាជូសេត។

**ការចូលរួមរបស់ភាគីពាក់ព័ន្ធ និង ការផ្សព្វផ្សាយទៅដល់សហគមន៍** សម្រាប់សកម្មភាពទីភ្នាក់ងារសំខាន់ៗរបស់ EEA នោះ EEA នឹងបន្តផ្តល់មូលនិធិដែលចាំបាច់សម្រាប់ការបកប្រែផ្ទាល់ តាមប្រព័ន្ធវីដេអូនិងសំឡេង និងតាមទូរសព្ទ និងការបកប្រែសារនៃការផ្សព្វផ្សាយ ឯកសារ របាយការណ៍ និងឯកសារដទៃផ្សេងទៀត។

EEA នឹងស្វែងរកវិធីសាស្ត្រសម្រាប់ការបង្កើតទម្រង់នៃការផ្សព្វផ្សាយជាសាធារណៈឡើងវិញ និងការចូលរួមពីសហគមន៍ដើម្បីធ្វើឱ្យឱកាសនេះកាន់តែមានការចូលរួម និងកាន់តែមានឱកាសច្រើន។ យុទ្ធសាស្ត្រទាំងនេះរួមមាន៖

- ការធ្វើការផ្សព្វផ្សាយនៅកន្លែងសាធារណៈ និងព្រឹត្តិការណ៍នានា ដែលសហគមន៍ប្រមូលផ្តុំ ដូចជាតុ ទីផ្សារកសិករ ពិពរណ៍សង្កាត់ មជ្ឈមណ្ឌលសហគមន៍ បណ្ណាល័យ និងមជ្ឈមណ្ឌលចែកចាយអាហារ។
- ការប្រើប្រាស់ការពិភាក្សាក្រុមតូច សំណួរឆែកមើល ការស្ទង់មតិក្នុងអំឡុងកិច្ចប្រជុំជាសាធារណៈ និងព្រឹត្តិការណ៍នានា។
- ការទទួលយកការផ្តល់មតិយោបល់ជាសាធារណៈតាមប្រព័ន្ធរូបភាពនិងសំឡេង តាមទូរសព្ទ និងអ៊ីម៉ែល និងតាមរយៈសេវាប្រៃសណីយ៍
- ការរៀបចំពេលប្រជុំនៅពេលព្រឹក និងពេលរសៀលសម្រាប់កិច្ចប្រជុំជាសាធារណៈ ដើម្បីរៀបចំតារាងពេលវេលាខុសៗគ្នាសម្រាប់អ្នកចូលរួម
- ចែករំលែកឯកសារព័ត៌មាននៅមុនពេលកិច្ចប្រជុំ
- ការបង្ហោះឯកសារកិច្ចប្រជុំ និងឯកសារធ្វើបទបង្ហាញនៅ mass.gov
- អនុញ្ញាតឱ្យមានពេលវេលាគ្រប់គ្រាន់សម្រាប់ភាគីពាក់ព័ន្ធខាងយុត្តិធម៌បរិស្ថាន ដើម្បីធ្វើការត្រួតពិនិត្យ និងផ្តល់យោបល់លើឯកសារ និងគម្រោងដែលបានស្នើសុំណាមួយ
- ការបន្តស្វែងរកវិធីសាស្ត្រដើម្បីកែប្រែសារនិងឯកសារផ្សព្វផ្សាយរបស់ EEA ទៅជាភាសាមួយដែលគ្មានពាក្យបច្ចេកទេសសម្រាប់ក្រុមណាមួយ និងមានភាពងាយស្រួលយល់។

## ការអនុវត្តយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់ការិយាល័យប្រតិបត្តិផ្នែកថាមពល និងកិច្ចការបរិស្ថាន

ទីភ្នាក់ងារនិងមន្ត្រីរបស់ EEA បានបន្តខិតខំប្រឹងប្រែងជាបន្តបន្ទាប់ក្នុងការផ្តល់ជូននូវយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន និងរបៀបដែលយើងអនុវត្តយុទ្ធសាស្ត្រទាំងនោះ។ EEA ធ្វើការឆ្លើយតបទៅនឹងការសាកសួរជាសាធារណៈ និងបណ្តឹងនានា ដោយធ្វើការស៊ើបអង្កេតយ៉ាងល្អិតល្អន់ និងធ្វើការអនុវត្តវិធានការកែតម្រូវដែលចាំបាច់ និងផ្តល់យោបល់ត្រឡប់ និងការប្រាស្រ័យទាក់ទងជាមួយអ្នកដាក់ពាក្យបណ្តឹង។ ពាក់ព័ន្ធនឹងក្តីបារម្ភ ពាក្យបណ្តឹង ការបំពេញបន្ថែម ឬគំនិតផ្សេងៗពាក់ព័ន្ធនឹងចលនាយុត្តិធម៌បរិស្ថាន ឬដើម្បីស្វែងយល់បន្ថែមអំពីកិច្ចខិតខំប្រឹងប្រែងផ្នែកយុត្តិធម៌បរិស្ថាន ថាមពល និងអាកាសធាតុរបស់ទីភ្នាក់ងារយើង សូមទាក់ទង៖

Rishi P. Reddi
នាយកយុត្តិធ៌មបរិស្ថាន
ការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន
100 Cambridge St., Suite 900
Boston, MA 02114
អ៊ីម៉ែល៖ rishi.p.reddi@mass.gov

ឬ

Vallery B. Cardoso
អនុប្រធានចលនាយុត្តិធម៌បរិស្ថាន អ្នកសម្របសម្រួលអន្តរទីភ្នាក់ងារ
ការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន
100 Cambridge St., Suite 900
Boston, MA 02114
អ៊ីម៉ែល៖ vallery.b.cardoso@mass.gov

# ការិយាល័យគ្រប់គ្រងតំបន់ឆ្នេរ

Massachusetts Office of
Coastal Zone Management

# យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន

# តារាងមាតិកា


**ការិយាល័យគ្រប់គ្រងតំបន់ឆ្នេរ....................24**

សេចក្តីថ្លែងការណ៍បេសកកម្មរបស់ CZM ....................26

លក្ខខណ្ឌតម្រូវនៃយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់លេខាធិការដ្ឋានចេញគោលនយោបាយ យុត្តិធម៌បរិស្ថាននៃការិយាល័យ EEA....................26

យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន ....................26

*ការទំនាក់ទំនង....................27*

*ការគ្រប់គ្រងតាមបរិស្ថាន និងការស្ម័គ្រចិត្តរបស់ប្រជាជន ....................28*

*ជំនួយបច្ចេកទេស....................28*

*ការធ្វើផែនការកំពង់ផែ និងចំណតនាវា....................29*

*ការធ្វើផែនការមហាសមុទ្រ....................29*

*កម្មវិធីផ្តល់មូលនិធិជំនួយ ....................30*

*ផលិតផល និងឧបករណ៍....................31*

*ការជួលបុគ្គលិក ....................31*

ការអនុវត្តយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់ការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការ បរិស្ថាន....................31


ព្រាង

# ការិយាល័យគ្រប់គ្រងតំបន់ឆ្នេរ

## សេចក្តីថ្លែងការណ៍បេសកកម្មរបស់ CZM

បេសកកម្មនៃ ការិយាល័យគ្រប់គ្រងតំបន់ឆ្នេរ (CZM) គឺដើម្បីរក្សាតុល្យភាពផលប៉ះពាល់នៃសកម្មភាពមនុស្ស ជាមួយនឹងការការពារធនធានតំបន់ឆ្នេរ តាមរយៈការធ្វើផែនការ ការចូលរួមពីសារធារណជន ការអប់រំ ការស្រាវជ្រាវ និងការគ្រប់គ្រងធនធានឱ្យបានល្អ។

## លក្ខខណ្ឌតម្រូវនៃយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់លេខាធិការដ្ឋានចេញគោលនយោបាយយុត្តិធម៌បរិស្ថាននៃការិយាល័យ EEA

គោលនយោបាយយុត្តិធម៌បរិស្ថាន (EJ) នៃការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន (EEA) បានដឹកនាំគ្រប់ទីភ្នាក់ងារ EEA ទាំងអស់ ក្នុងការបង្កើតយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានផ្ទាល់ខ្លួនពួកគេ។ ទីភ្នាក់ងារ EEA ត្រូវពិចារណាថាតើត្រូវរួមបញ្ចូលការគិតគូរពីយុត្តិធម៌បរិស្ថានទៅក្នុងនាយកដ្ឋានរបស់ពួកគេ តាមរយៈគោលនយោបាយ កម្មវិធី ឬយុទ្ធសាស្ត្រដទៃទៀតដោយរបៀបណា។ ទីភ្នាក់ងារ EEA ត្រូវកំណត់អត្តសញ្ញាណ និងជំរុញគម្រោងដែលមានការឧបត្ថម្ភពីទីភ្នាក់ងារ ដោយផ្តល់ប្រាក់ឧបត្ថម្ភដល់ការធ្វើសេចក្តីសម្រេចចិត្ត ការកំណត់វិធាន ឬចំណាត់ការដទៃទៀតដែលមានបំណងក្នុងការលើកកម្ពស់យុត្តិធម៌បរិស្ថានបន្ថែមទៀតនៅទូទាំងខំមិនវែលទាំងមូល ដើម្បីបង្ហាញពីរបៀបនៃការវាស់វែងការបែងចែកអត្ថប្រយោជន៍ដែលត្រឹមត្រូវ។

## យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន

យុទ្ធសាស្ត្ររបស់ CZM ធ្វើគ្រោងឆ្អឹងសកម្មភាពនានាសម្រាប់លើកកម្ពស់ និងរួមបញ្ចូលគ្នានេះការគិតគូរដល់យុត្តិធម៌បរិស្ថាននៅក្នុងកម្មវិធី គោលនយោបាយ និងសកម្មភាពរបស់ CZM ទាំងមូល ក៏ដូចជាការសម្រេចបាននូវគោលដៅយុត្តិធម៌បរិស្ថានរបស់ EEA ដើម្បីធានាថា ពលរដ្ឋគ្រប់រូបដែលស្នាក់នៅក្នុងខំមិនវែលនេះ ទទួលបានបរិស្ថានស្អាតនិងមានសុខភាពល្អ ការការពារពីការប្រែប្រួលអាកាសធាតុ និងការបែកចែកអត្ថប្រយោជន៍ និងបន្ទុកបរិស្ថានស្មើភាពគ្នា។

យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន របស់ CZM កំណត់ពីសកម្មភាព និងកិច្ចខិតខំប្រឹងប្រែងដែល CZM នឹងត្រូវធ្វើឡើងដើម្បីអនុវត្តគោលនយោបាយយុត្តិធម៌បរិស្ថានរបស់ EEA។
យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន រួមមានសមាសភាពដែលបានកំណត់ដើម្បីៈ

- ជំរុញសកម្មភាពប្រាស្រ័យទាក់ទងគ្នា ដើម្បីពង្រីកការទទួលបានព័ត៌មានសម្រាប់ប្រជាជនយុត្តិធម៌បរិស្ថាន
- រួមបញ្ចូលគ្នានូវប្រជាជនយុត្តិធម៌បរិស្ថានឱ្យបានល្អទៅក្នុងសកម្មភាពផ្សព្វផ្សាយ គ្រប់គ្រងតាមដានបរិស្ថាន និងសកម្មភាពស្ម័គ្រចិត្តរបស់ប្រជាជន
- ពង្រឹងជំនួយបច្ចេកទេសដើម្បីដោះស្រាយបញ្ហាយុត្តិធម៌បរិស្ថានឱ្យបានកាន់តែសកម្ម និងគាំទ្រដល់ប្រជាជនយុត្តិធម៌បរិស្ថាន
- គាំទ្រដល់ការចូលរួមប្រកបដោយអត្ថន័យជាមួយប្រជាជនយុត្តិធម៌បរិស្ថាន និងធាតុចូលក្នុងអំឡុងការធ្វើផែនការ ការផ្តល់មតិយោបល់ជាសាធារណៈ សវនាការ និងកិច្ចផ្តល់ប្រជុំព័ត៌មានសម្រាប់សកម្មភាពកម្មវិធី។
- ពង្រឹងលក្ខខណ្ឌវិនិច្ឆ័យយុត្តិធម៌បរិស្ថានដែលប្រើនៅក្នុងការជ្រើសរើសមូលនិធិជំនួយ

- ចូលរួមដោយផ្ទាល់ជាមួយប្រជាជនយុត្តិធម៌បរិស្ថាន ដើម្បីពង្រឹងការទទួលបាន និងការប្រើប្រាស់ឧបករណ៍ និងផលិតផលរបស់ CZM និង
- គាំទ្រដល់ក្រុម CZM ដែលមានពិពិធភាព និងបរិយាបន្ន។

ព័ត៌មានលម្អិតបន្ថែមស្តីពីសកម្មភាពរបស់ CZM នៅក្នុងផ្នែកទាំងនេះ មានចែងដូចខាងក្រោម ។

### ការទំនាក់ទំនង

បន្ថែមពីលើការប្រើប្រាស់ការចូលរួមជាសាធារណៈរបស់ EEA និងផែនការការចូលរួមរបស់សហគមន៍ នៅក្នុងកិច្ចខិតខំផ្សព្វផ្សាយរបស់ខ្លួន CZM នឹងដាក់បញ្ចូលការគិតគូរពីយុត្តិធម៌បរិស្ថានទៅក្នុងកម្មវិធីប្រាស្រ័យទាក់ទងរបស់ CZM តាមរយៈមធ្យោបាយដូចខាងក្រោម៖

**វេបសាយរបស់ CZM** CZM ធ្វើបច្ចុប្បន្នភាពវេបសាយជាប្រចាំ ដើម្បីប្រាស្រ័យទាក់ទងជាមួយសាធារណជន និងភាគីពាក់ព័ន្ធអំពីកម្មវិធី គម្រោង សកម្មភាពរបស់ CZM និងឱកាសសម្រាប់សាធារណជនចូលរួម។ CZM នឹងបន្តធ្វើបច្ចុប្បន្នភាព និងប្រើប្រាស់វេបសាយនេះធ្វើជាយន្តការសម្រាប់ការប្រាស្រ័យទាក់ទង និងការចូលរួមជាមួយប្រជាជន EJ ជាមួយនឹងព័ត៌មានដូចជា៖

- ព័ត៌មានទំនាក់ទំនងផ្នែកយុត្តិធម៌បរិស្ថានរបស់ CZM
- ការិយាល័យក្នុងតំបន់របស់ CZM (ទីតាំង និងព័ត៌មានទំនាក់ទំនង)
- តំណភ្ជាប់ទៅកាន់ច្បាប់ និងបទបញ្ញត្តិរបស់រដ្ឋ និងសហព័ន្ធ
- ការជូនដំណឹងជាសាធារណៈពី CZM
- តំណភ្ជាប់ទៅកាន់ សៀវភៅនានា និង ឯកសារជាសំឡេងដែលសង្កត់ធ្ងន់លើបញ្ហាយុត្តិធម៌បរិស្ថាន និងយុត្តិធម៌អាកាសធាតុ។

**ព័ត៌មានបណ្តាញសង្គមរបស់ CZM** CZM នឹងធ្វើការវាយតម្លៃវិធីនៃការចែករំលែកព័ត៌មានជាមួយសហគមន៍ EJ ដោយប្រើប្រាស់វេទិកាព័ត៌មានបណ្តាញសង្គមផ្សេង រួមទាំង Twitter ផង និងព្រឹត្តិបត្រព័ត៌មានផ្សេងទៀត (ដែលផ្តោតលើប្រជាជនយុត្តិធម៌បរិស្ថាន) នឹងត្រូវស្ថិតក្នុងចំណោមវិធីសាស្ត្រថ្មីៗ ដែលត្រូវយកមកពិចារណា ដើម្បីបង្ហាញពីព័ត៌មានសំខាន់ និងមានឥទ្ធិពល។

**CZ-Mail** ព្រឹត្តិបត្រព័ត៌មានប្រចាំខែរបស់ CZM ផ្តល់ព័ត៌មានដែលមានប្រយោជន៍សម្រាប់ប្រជាជន EJ ដូចជា៖

- ការជូនដំណឹង និងព័ត៌មាន
- សកម្មភាព និងសមិទ្ធផល
- បច្ចុប្បន្នភាពកម្មវិធី និងគម្រោង
- ព្រឹត្តិការណ៍របស់ CZM និងព្រឹត្តិការណ៍ភាគីពាក់ព័ន្ធ
- ឱកាសទទួលបានជំនួយ និងមូលនិធិ

**ការផ្សព្វផ្សាយតាមប្រព័ន្ធរូបភាពនិងសំឡេង/ការចូលរួម** CZM នឹងបន្តប្រើវេទិកាទាក់ទងតាមប្រព័ន្ធរូបភាពនិងសំឡេង និងធនធាននានា (ឧ.ទា. កម្មវិធី Zoom, Microsoft Teams និងសេវាដទៃផ្សេងទៀត) ធ្វើជាសមាសធាតុដ៏មានតម្លៃនៃការចូលរួមពីសាធារណជន និងការ

រួមសហការគ្នាជាមួយភាគីពាក់ព័ន្ធ រួមមានការប្រើប្រាស់កិច្ចប្រជុំជាសាធារណៈតាមរយៈប្រព័ន្ធវីដេអូនិងសំឡេង និងតាមសិក្ខាសាលាអនឡាញផងដែរ។ CZM ក៏លើកទឹកចិត្តឱ្យមានការបញ្ចេញមតិជាសាធារណៈ និងសំណួរផ្សេងៗតាមរយៈអ៊ីម៉ែលផង និងតាមរយៈសំបុត្រផង ជាជម្រើសសម្រាប់ចូលរួមក្នុងសកម្មភាពសំខាន់ៗ។

- CZM នឹងបន្តប្រើប្រាស់ការផ្សព្វផ្សាយតាមប្រព័ន្ធវីដេអូនិងសំឡេង/ធនធានការចូលរួមរបស់សហគមន៍ ដើម្បីគាំទ្រដល់ប្រជាជនយុត្តិធម៌បរិស្ថាន។

## ការគ្រប់គ្រងតាមបរិស្ថាន និងការស្ម័គ្រចិត្តរបស់ប្រជាជន

ការគ្រប់គ្រងតាមដានការឈ្លានពានដែនសមុទ្រនិងព័ត៌មានដែលមានលក្ខណៈរួមសហការ (MIMIC) របស់ CZM នាំមកនូវការរួបរួមគ្នានៃអ្នកស្ម័គ្រចិត្ត និងអ្នកជំនាញវិទ្យាសាស្ត្រពីស្ថាប័នរដ្ឋ សហព័ន្ធ និងអង្គការមិនរកប្រាក់កម្រៃ ដើម្បីធ្វើការគ្រប់គ្រងតាមដានប្រភេទរាតត្បាតតាមសមុទ្រ នៅតាមបណ្ដោយឆ្នេរ New England។ CZM ក៏ឧបត្ថម្ភដល់ COASTSWEEP ដែលជាសកម្មភាពសម្អាតឆ្នេរនៅទូទាំងរដ្ឋជាប្រចាំឆ្នាំ ដែលមានអ្នកស្ម័គ្រចិត្តចូលរួមរាប់ពាន់នាក់ នៅទូទាំងរដ្ឋម៉ាសាជូសេតទាំងមូល។ អ្នកស្ម័គ្រចិត្ត ប្រមូលកម្ទេចកម្ទីតាមសមុទ្រ និងកត់ត្រាទុកអ្វីដែលពួកគេរកឃើញ។ បន្ទាប់មក ព័ត៌មាននេះ ត្រូវបានវិភាគ និងប្រើប្រាស់ដើម្បីកំណត់ពីប្រភពនៃកម្ទេចកម្ទីសមុទ្រ និងបង្កើតគំនិតផ្តួចផ្តើមអប់រំ និងគោលនយោបាយ ដើម្បីជួយកាត់បន្ថយកម្ទេចកម្ទីទាំងនោះ។

- ចូលរួមជាមួយអង្គការនៅតាមសហគមន៍ និងបុគ្គលនានានៅក្នុងសហគមន៍យុត្តិធម៌បរិស្ថាន ដោយសេវាផ្នែកភាសា (ប្រសិនបើចាំបាច់) ដើម្បីស្វាគមន៍ និងលើកកម្ពស់សកម្មភាពគ្រប់គ្រងតាមដាន និងសកម្មភាពស្ម័គ្រចិត្ត។
- ចូលរួមជាមួយថ្នាក់ដឹកនាំរបស់ MIMIC ដើម្បីគាំទ្រដល់ការចូលរួមក្នុងសកម្មភាព MIMIC ដែលចេះតែកើនឡើង សម្រាប់ប្រជាជនយុត្តិធម៌បរិស្ថាន នៅក្នុងតំបន់ពួកគេរៀងខ្លួន។
- បកប្រែឯកសារ និងធនធានគ្រប់គ្រងតាមដាន (ឧ.ទា. ពិធីសារគ្រប់គ្រងតាមដាន ប័ណ្ណកំណត់អត្តសញ្ញាណប្រភេទរាតត្បាត និងព័ត៌មានរបស់ MIMIC iNaturalist) នៅពេលកំណត់បានពីតម្រូវការ ឬនៅពេលស្នើសុំដោយប្រជាជនយុត្តិធម៌បរិស្ថាន។
- បកប្រែខ្លឹមសារបង្ហោះលើ Twitter និងឯកសារ COASTSWEEP ដទៃផ្សេងទៀត ដើម្បីគាំទ្រដល់ការចូលរួមរបស់ប្រជាជនយុត្តិធម៌បរិស្ថាននៅក្នុងការសម្អាតឆ្នេរនៅទូទាំងរដ្ឋប្រចាំឆ្នាំ។
- ចូលរួមជាមួយប្រជាជនយុត្តិធម៌បរិស្ថាន ដើម្បីចូលរួមជាមួយ COASTSWEEP និងផ្តល់អាទិភាពដល់ការគាំទ្រដល់ការសម្អាតឆ្នេរនៅក្នុងសហគមន៍យុត្តិធម៌បរិស្ថាន។
- បង្កើតកិច្ចខិតខំប្រឹងប្រែងជោគជ័យដើម្បីលើកទឹកចិត្តប្រជាជនយុត្តិធម៌បរិស្ថាន និងផ្ទេរការជោគជ័យនោះទៅដល់ការសម្អាតនៅពេលអនាគតទៀត។

## ជំនួយបច្ចេកទេស

CZM ផ្តោតសំខាន់លើការផ្តល់ជំនួយបច្ចេកទេសដល់អ្នកធ្វើសេចក្តីសម្រេចចិត្តក្នុងមូលដ្ឋាន និងពលរដ្ឋដែលចាប់អារម្មណ៍។ ក្រុមអ្នកជំនាញបច្ចេកទេសផ្នែកគោលនយោបាយ ការធ្វើផែនការ ការត្រួតពិនិត្យបទបញ្ញត្តិ វិទ្យាសាស្ត្រឆ្នេរ និងមហាសមុទ្រ ការគ្រប់គ្រងតាមដាន ការធ្វើផែនទី និងការប្រាស្រ័យទាក់ទងរបស់ CZM រួមជាមួយអ្នកសម្របសម្រួលក្នុងតំបន់ ដែលធ្វើជាអ្នកសម្របសម្រួលដល់ការប្រាស្រ័យជាមួយសហគមន៍ និងអង្គការក្នុងមូលដ្ឋាន ផ្តល់ជាជំនួយ

បច្ចេកទេសជាច្រើន រួមទាំងការប្រឹក្សាយោបល់មួយទល់នឹងមួយជាមួយមន្ត្រីក្នុងស្រុក តំណាងអាជីវកម្មតាមឆ្នេរ ម្ចាស់ផ្ទះតាមឆ្នេរ និងអ្នកដទៃ។

- ចូលរួមជាមួយប្រជាជនយុត្តិធម៌បរិស្ថាន ដើម្បីសិក្សាពីក្តីកង្វល់ផ្នែកបរិស្ថាន និងតម្រូវការជំនួយបច្ចេកទេស។
- រួមបញ្ចូលបញ្ហានិងការគិតគូរពីយុត្តិធម៌បរិស្ថានទៅក្នុងជំនួយបច្ចេកទេសផ្តល់ជូនទៅមន្ត្រីក្នុងមូលដ្ឋាន និងដៃគូដទៃទៀត។
- បកប្រែធនធានបច្ចេកទេសសម្រាប់ពលរដ្ឋ (ឧ.ទា. ខិត្តប័ណ្ណរបស់ StormSmart Properties) នៅពេលកំណត់បានពីតម្រូវការ ឬនៅពេលមានការស្នើសុំពីប្រជាជនយុត្តិធម៌បរិស្ថាន។

## ការធ្វើផែនការកំពង់ផែ និងចំណតនាវា

CZM គាំទ្រដល់សហគមន៍ឆ្នេរក្នុងការរក្សាតុល្យភាពការអភិវឌ្ឍសេដ្ឋកិច្ច និងការការពារបរិស្ថាននៅតំបន់កំពង់ផែ និងចំណតនាវា។ កម្មវិធី ការធ្វើផែនការកំពង់ផែ និងចំណតនាវារបស់ CZM ពាក់ព័ន្ធនឹងការធ្វើការជាមួយសហគមន៍ឆ្នេរ ដើម្បីធានាថា តំបន់មាត់ទឹកមានសុវត្ថិភាពបរិស្ថានល្អ និងមានវិបុលភាពសេដ្ឋកិច្ច និងតុល្យភាព មានសក្តានុពលប្រើប្រាស់ប្រកួតប្រជែងនៅក្នុងកំពង់ផែ ឬចំណតនាវា។

- ប្តេជ្ញាចិត្តក្នុងការចូលរួមជាមួយភាគីពាក់ព័ន្ធខាងយុត្តិធម៌បរិស្ថានដើម្បីធានានូវការចូលរួមដែលមានអត្ថន័យ និងធាតុចូលប្រជាជនយុត្តិធម៌បរិស្ថានក្នុងអំឡុងដំណើរការនៃការធ្វើផែនការចំណតនាវា។
- បកប្រែការជូនដំណឹងដែលបានប្រគល់ជូនទៅ *អ្នកតាមដានបរិស្ថាន* ដើម្បីផ្តល់ជាមតិយោបល់ជាសាធារណៈ សវនាការ ឬកិច្ចប្រជុំផ្តល់ព័ត៌មានសម្រាប់សកម្មភាពនៃការធ្វើផែនការចំណតនាវា នៅពេលកំណត់ឃើញមានប្រជាជនដែលចេះភាសាអង់គ្លេសតិចតួច (LEP) ឬនៅមានការស្នើសុំពីប្រជាជនយុត្តិធម៌បរិស្ថាន។
- ចុះផ្សព្វផ្សាយការជូនដំណឹងនៅក្នុងកាសែតដែលពាក់ព័ន្ធ ឬប្រភពសារព័ត៌មាន ដែលមានចេតនាជាពិសេសក្នុងការផ្សព្វផ្សាយទៅដល់ប្រជាជនចេះភាសាអង់គ្លេសតិចតួចសម្រាប់សកម្មភាពនៃការធ្វើផែនការចំណតនាវានៅក្នុងសហគមន៍ EJ។
- ផ្តល់ជូនអ្នកបកប្រែផ្ទាល់មាត់ និងសេវាបកប្រែសម្រាប់សវនាការជាសាធារណៈ និងកិច្ចប្រជុំផ្តល់ព័ត៌មាន នៅពេលកំណត់ឃើញមានប្រជាជនចេះភាសាអង់គ្លេសតិចតួច ឬនៅពេលមានការស្នើសុំពីប្រជាជនយុត្តិធម៌បរិស្ថាន។
- ពិគ្រោះដើម្បីរៀបចំពេលវេលាសម្រាប់ការផ្តល់យោបល់ជាសាធារណៈ សវនាការ និងកិច្ចប្រជុំផ្តល់ព័ត៌មាន នៅក្នុងពេលវេលា និងទីកន្លែងដែលរៀបចំដោយប្រជាជនយុត្តិធម៌បរិស្ថាន នៅពេលកំណត់ឃើញមានប្រជាជនយុត្តិធម៌បរិស្ថាន ឬនៅពេលប្រជាជនយុត្តិធម៌បរិស្ថានត្រូវរងផលប៉ះពាល់ដោយសារដំណើរការនៃការធ្វើផែនការចំណតនាវាដែលបានដាក់ស្នើ និងរួមបញ្ចូលលក្ខខណ្ឌនៃការផ្សព្វផ្សាយឱ្យស្របទៅតាមផែនការការចូលរួមជាសាធារណៈ និងផែនការការចូលរួមរបស់សហគមន៍។

## ការធ្វើផែនការមហាសមុទ្រ

CZM ដើរតួជាទីភ្នាក់ងារឈានមុខគេរបស់រដ្ឋសម្រាប់ផែនការគ្រប់គ្រងមហាសមុទ្រនៃរដ្ឋម៉ាសាជូសេត ដែលការពារទីជម្រកសំខាន់ៗក្នុងដែនសមុទ្រ និងការប្រើប្រាស់ពឹងផ្អែកលើទឹក និងបណ្តុំស្តង់ដាសម្រាប់គម្រោងនៅតាមមហាសមុទ្រថ្មីនៅក្នុងផ្ទៃទឹកតំបន់ឆ្នេររបស់រដ្ឋ។


Massachusetts Office of Coastal Zone Management

តាមរយៈការអនុវត្ត ការត្រួតពិនិត្យឡើងវិញ និងការធ្វើបច្ចុប្បន្នភាពផែនការមហាសមុទ្រ CZM ធ្វើការជាមួយទីភ្នាក់ងាររដ្ឋដទៃទៀត និងដៃគូក្នុងតំបន់ និងដៃគូរបស់សហព័ន្ធ ដើម្បីរក្សាលំនឹងនៃតម្រូវការនៃការប្រើប្រាស់បច្ចុប្បន្ន និងការប្រើប្រាស់ដែលកំពុងកើនឡើងនៃទឹកសមុទ្រ ហើយក្នុងពេលនោះដែរ ក៏ត្រូវការពារទីជម្រកសមុទ្រ និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាពផងដែរ។

តាមលទ្ធភាពដែលអាចអនុវត្តបាន និងអាស្រ័យលើអ្នកអាន និងតំបន់ភូមិសាស្ត្រដែលរងផលប៉ះពាល់៖

- បកប្រែការជូនដំណឹងដែលបានប្រគល់ជូនទៅ *អ្នកតាមដានបរិស្ថាន* ដើម្បីផ្តល់ជាមតិយោបល់ជាសាធារណៈអំពីសកម្មភាពនៃការធ្វើផែនការមហាសមុទ្រ។
- ចុះផ្សព្វផ្សាយការជូនដំណឹងនៅក្នុងកាសែតដែលពាក់ព័ន្ធ ឬប្រភពសារព័ត៌មាន ដែលមានចេតនាជាពិសេសក្នុងការផ្សព្វផ្សាយទៅដល់ប្រជាជនចេះភាសាអង់គ្លេសតិចតួច សម្រាប់ការបញ្ចេញមតិជាសាធារណៈអំពីសកម្មភាពផែនការមហាសមុទ្រ។
- ផ្តល់ជូនអ្នកបកប្រែផ្ទាល់មាត់ និងសេវាបកប្រែសម្រាប់សវនាការជាសាធារណៈ និងកិច្ចប្រជុំផ្តល់ព័ត៌មាន អំពីសកម្មភាពផែនការមហាសមុទ្រ។
- ពិគ្រោះដើម្បីរៀបចំពេលវេលាសម្រាប់ការផ្តល់យោបល់ជាសាធារណៈ និងកិច្ចប្រជុំផ្តល់ព័ត៌មាន នៅក្នុងពេលវេលា និងទីកន្លែងសមស្របសម្រាប់ប្រជាជនយុត្តិធម៌បរិស្ថាន ហើយរួមបញ្ចូលលក្ខខណ្ឌនៃការផ្សព្វផ្សាយឱ្យស្របទៅតាមផែនការការចូលរួមជាសាធារណៈរបស់ EEA និងផែនការការចូលរួមរបស់សហគមន៍។

## កម្មវិធីផ្តល់មូលនិធិជំនួយ

CZM គ្រប់គ្រង និងអនុវត្តកម្មវិធីមូលនិធិជំនួយចំនួនពីរ៖ កម្មវិធីមូលនិធិជំនួយភាពធន់ទ្រាំតំបន់ឆ្នេរ និងកម្មវិធីមូលនិធិជំនួយកែលម្អបំបាត់សារជាតិបំពុលតំបន់ឆ្នេរ។ កម្មវិធីទាំងពីរនេះ គាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់មូលដ្ឋានដើម្បីដោះស្រាយបញ្ហាទឹកជំនន់តំបន់ឆ្នេរ សំណឹក និងការកើនឡើងកម្ពស់ទឹកសមុទ្រ ក៏ដូចជាការកំណត់ និងការដោះស្រាយការបំពុលពីប្រភពមិនច្បាស់លាស់។ CZM ត្រូវធ្វើការពិនិត្យឡើងវិញ និងពង្រឹងលក្ខខណ្ឌវិនិច្ឆ័យយុត្តិធម៌បរិស្ថានសម្រាប់ធ្វើការវាយតម្លៃសំណើ និងកំណត់អាទិភាពការផ្តល់មូលនិធិជំនួយដល់អ្នកទទួលដែលសមស្រប។

- ធ្វើការត្រួតពិនិត្យពីអាទិភាពកម្មវិធីមូលនិធិជំនួយជារៀងរាល់ឆ្នាំ និងកំណត់ពីឱកាសក្នុងការពង្រឹង និងលើកទឹកចិត្តឱ្យមានការចូលរួមពីប្រជាជនយុត្តិធម៌បរិស្ថាន និងដើម្បីជាប្រយោជន៍ដល់ប្រជាជនយុត្តិធម៌បរិស្ថាននៅក្នុងដំណាក់កាលនៃការអភិវឌ្ឍគម្រោង។
- បន្តលើកទឹកចិត្តដល់ការកំណត់ពីភាពភ្ជាប់គ្នារវាងគម្រោងដែលបានស្នើ និងប្រជាជនយុត្តិធម៌បរិស្ថានក្នុងការដាក់សំណើ។
- គម្រោងប្រាក់ឧបត្ថម្ភលើកទឹកចិត្ត ដែលផ្តល់ប្រយោជន៍ដល់សហគមន៍យុត្តិធម៌បរិស្ថាន និងប្រជាជននៅក្នុងការត្រួតពិនិត្យ និងការដាក់ពិន្ទុសំណើ។
- កំណត់ពីឱកាសទទួលបានមូលនិធិជំនួយពីរដ្ឋនិងសហព័ន្ធសម្រាប់សហគមន៍យុត្តិធម៌បរិស្ថាន ដែលអាចគាំទ្រដល់គំនិតផ្តួចផ្តើមយុត្តិធម៌បរិស្ថាន (ឧ.ទា. រដ្ឋបាលជាតិផ្នែកមហាសមុទ្រនិងបរិយាកាស ទីភ្នាក់ងារការពារបរិស្ថាន ក្រុមប្រឹក្សាសេដ្ឋកិច្ចកំពង់ផែសមុទ្រ)។

### ផលិតផល និងឧបករណ៍

CZM បង្កើត និងគ្រប់គ្រងផលិតផល និងឧបករណ៍ទិន្នន័យតំបន់ឆ្នេរ និងមហាសមុទ្រ ដែលមានជូនដល់សាធារណជន។ ផលិតផលទាំងនេះគ្រប់ដណ្ដប់លើ៖ ផែនការតំបន់ឆ្នេរ ភូគព្ភសាស្ត្រ សំណឹកឆ្នេរ ជំនន់តំបន់ឆ្នេរនាពេលបច្ចុប្បន្ន និងទៅអនាគត ទីជម្រក ការធ្វើផែនការមហាសមុទ្រ ការធ្វើផែនការកំពង់ផែ និងចំណតនាវា ការចេញចូលពីសំណាក់សាធារណជនទៅកាន់តំបន់ឆ្នេរ ការធ្វើផែនទីបាតសមុទ្រ និងទីជម្រកបាតសមុទ្រ គុណភាពទឹក និងបញ្ហាតំបន់ឆ្នេរ និងបញ្ហាមហាសមុទ្រដទៃទៀតផ្សេងទៀត។

- ចូលរួមជាមួយប្រជាជនយុត្តិធម៌បរិស្ថានពាក់ព័ន្ធនឹងការបង្កើតឧបករណ៍ និងផលិតផល ឬផលិតផលដែលមានស្រាប់ (ឧ.ទា. មគ្គុទេសក៍តំបន់ឆ្នេរលើអនឡាញ) ដើម្បីធានាថា ធនធានទាំងនេះ អាចឱ្យប្រជាជនយុត្តិធម៌បរិស្ថានចូលទៅមើល និងទាញយកប្រយោជន៍បានផងដែរ។

### ការជួលបុគ្គលិក

CZM ទទួលស្គាល់ពីសារៈសំខាន់នៃការមានកម្លាំងទីភ្នាក់ងារមួយដែលឆ្លុះបញ្ចាំងពីពិពិធភាពសង្គម-សេដ្ឋកិច្ច ជាតិសាសន៍ និងពូជសាសន៍នៃប្រជាជនក្នុងរដ្ឋម៉ាសាជូសេត រួមទាំងតួនាទីសំខាន់ដែលកម្លាំងនេះដើរតួក្នុងការធ្វើឱ្យប្រសើរឡើងនូវការធ្វើសេចក្ដីសម្រេចចិត្តដែលមានសមភាព ពាក់ព័ន្ធនឹងការអនុញ្ញាតខាងបរិស្ថាន ទីតាំងបរិស្ថាន ការបង្កើតបទបញ្ញត្តិ និងការបែងចែកមូលនិធិជំនួយ។ CZM បានរួមគ្នាជាមួយ EEA ដោយប្ដេជ្ញាចិត្តក្នុងការរួមបញ្ចូលការអនុវត្តការជ្រើសរើសបុគ្គលិកដែលមានពិពិធភាព និងដើម្បីផ្ដល់នូវការបណ្ដុះបណ្ដាលសម្រាប់អ្នកគ្រប់គ្រងការជ្រើសរើសបុគ្គលិក ដើម្បីលើកកម្ពស់ការធ្វើសេចក្ដីសម្រេចចិត្តប្រកបដោយសមភាព រួមបញ្ចូលទាំងការប្រើប្រាស់លក្ខខណ្ឌវិនិច្ឆ័យក្នុងមុខតំណែងការងារ ដែលតម្រូវឱ្យបេក្ខជនជាប់ជាស្ថាពរបង្ហាញពីចំណេះដឹងនិងការយល់ដឹងពាក់ព័ន្ធនឹងតម្រូវការរបស់ប្រជាជនងាយរងគ្រោះ សង្កាត់យុត្តិធម៌បរិស្ថាន និងតំបន់ដែលមិនទទួលបានសេវាកម្មគ្រប់គ្រាន់ដល់នៅក្នុងខំមិនវែលនេះ។ CZM នឹងពិចារណាធ្វើការត្រួតពិនិត្យឡើងវិញនូវសំណួរនានាដែលវាយតម្លៃដល់ចំណេះដឹងរបស់បេក្ខជន និងបទពិសោធពាក់ព័ន្ធនឹងប្រធានបទយុត្តិធម៌បរិស្ថាន។

## ការអនុវត្តយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់ការិយាល័យប្រតិបត្តិផ្នែកថាមពល និងកិច្ចការបរិស្ថាន

ពាក់ព័ន្ធនឹងក្ដីបារម្ភ ពាក្យបណ្ដឹង ការបំពេញបន្ថែម ឬគំនិតផ្សេងៗពាក់ព័ន្ធនឹងយុត្តិធម៌បរិស្ថាន ឬដើម្បីស្វែងយល់បន្ថែមអំពីកិច្ចខិតខំប្រឹងប្រែងផ្នែកយុត្តិធម៌បរិស្ថានថាមពល និងអាកាសធាតុរបស់ទីភ្នាក់ងារយើង សូមទាក់ទងការិយាល័យយុត្តិធម៌បរិស្ថានរបស់ EEA ដែលមានចែងនៅទំព័រទី 19 នៃយុទ្ធសាស្ត្របរិស្ថានរបស់ EEA។

## ព័ត៌មានទំនាក់ទំនងផ្នែកយុត្តិធម៌បរិស្ថានរបស់ CZM៖

Tyler Soleau
ជំនួយការនាយក
Tyler.Soleau@mass.gov
(617) 626-1243

ព្រាង

# ការិយាល័យអនុវត្តច្បាប់រដ្ឋម៉ាសាជូសេត និងប៉ូលិសបរិស្ថានរដ្ឋម៉ាសាជូសេត

# យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន

# តារាងមាតិកា

**ការិយាល័យអនុវត្តច្បាប់រដ្ឋម៉ាសាជូសេត និងប៉ូលិសបរិស្ថានរដ្ឋម៉ាសាជូសេត.............................33**
សេចក្តីថ្លែងការណ៍បេសកកម្មរបស់ប៉ូលិសបរិស្ថានរដ្ឋម៉ាសាជូសេត (MEP)...............................35
លក្ខខណ្ឌតម្រូវនៃយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់លេខាធិការដ្ឋានចេញគោលនយោបាយយុត្តិធម៌បរិស្ថាននៃការិយាល័យ EEA.....................................................................................35
យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន ..................................................................................35
*និយមន័យ.........................................................................................................35*
*យុទ្ធសាស្ត្រ.......................................................................................................36*
*ការផ្សព្វផ្សាយទៅដល់សហគមន៍..........................................................................37*
*ការបណ្តុះបណ្តាល.............................................................................................39*
*ការជ្រើសរើសបុគ្គលិក ការជួលបុគ្គលិក និងការដំឡើងតំណែង ...............................40*
*បញ្ហាកុលសម្ព័ន្ធ ..............................................................................................41*
*ឱកាសទទួលបានមូលនិធិជំនួយ .........................................................................41*
*ខ្វាតរង្វាស់ .......................................................................................................41*
ការអនុវត្តយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់ការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន.......................................................................................................41

# ការិយាល័យអនុវត្តច្បាប់រដ្ឋម៉ាសាជូសេត និងប៉ូលិសបរិស្ថានរដ្ឋម៉ាសាជូសេត

*ការិយាល័យអនុវត្តច្បាប់រដ្ឋម៉ាសាជូសេត (OLE) គឺជាឈ្មោះផ្លូវការរបស់ទីភ្នាក់ងារ ដែលគេក៏ស្គាល់ផងដែរ ប៉ូលិសបរិស្ថានរដ្ឋម៉ាសាជូសេត (MEP) និងសេវារដ្ឋបាលរបស់ខ្លួន។ នៅក្នុងឯកសារនេះ យើងនឹងប្រើប្រាស់ពាក្យ "MEP" ដើម្បីតំណាងឱ្យសេវាកម្មទាំងអស់ដែលបានផ្តល់ជូន។*

## សេចក្តីថ្លែងការណ៍បេសកកម្មរបស់ប៉ូលិសបរិស្ថានរដ្ឋម៉ាសាជូសេត (MEP)

បេសកកម្មរបស់ប៉ូលិសបរិស្ថានរដ្ឋម៉ាសាជូសេត គឺដើម្បីការពារធនធានបរិស្ថាន និងធនធានធម្មជាតិរបស់ខំមិនវែលនេះ តាមរយៈការអនុវត្តច្បាប់ ការអប់រំ និងការផ្សព្វផ្សាយជាសាធារណៈ។

## លក្ខខណ្ឌតម្រូវនៃយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់លេខាធិការដ្ឋានចេញគោលនយោបាយយុត្តិធម៌បរិស្ថាននៃការិយាល័យ EEA

គោលនយោបាយយុត្តិធម៌បរិស្ថាន (EJ) នៃការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន (EEA) បានដឹកនាំគ្រប់ទីភ្នាក់ងារ EEA ទាំងអស់ ក្នុងការបង្កើតយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានផ្ទាល់ខ្លួនពួកគេ[1]។ ទីភ្នាក់ងារ EEA ត្រូវពិចារណាថាតើត្រូវរួមបញ្ចូលការគិតគូរពីយុត្តិធម៌បរិស្ថានទៅក្នុងនាយកដ្ឋានរបស់ពួកគេ តាមរយៈគោលនយោបាយ កម្មវិធី ឬយុទ្ធសាស្ត្រដទៃទៀត ដោយរបៀបណា។ ទីភ្នាក់ងារ EEA ត្រូវកំណត់អត្តសញ្ញាណ និងជំរុញគម្រោងដែលមានការឧបត្ថម្ភពីទីភ្នាក់ងារ ដោយផ្តល់ប្រាក់ឧបត្ថម្ភដល់ការធ្វើសេចក្តីសម្រេចចិត្ត ការកំណត់វិធាន ឬចំណាត់ការដទៃទៀតដែលមានបំណងក្នុងការលើកកម្ពស់យុត្តិធម៌បរិស្ថានបន្ថែមទៀតនៅទូទាំងខំមិនវែលទាំងមូល ដើម្បីបង្ហាញពីរបៀបនៃការវាស់វែងការបែងចែកអត្ថប្រយោជន៍ដែលត្រឹមត្រូវ។ EEA នឹងផ្តល់ការណែនាំដល់ទីភ្នាក់ងាររបស់ខ្លួនក្នុងការបំពេញតាមលក្ខខណ្ឌតម្រូវនៃយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន។

## យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន

យុទ្ធសាស្ត្រនេះ លើកឡើងពីសកម្មភាពចេតនានិងមានគិតគូរទុកសម្រាប់ការជំរុញ និងការរួមបញ្ចូលគោលការណ៍និងការគិតគូរពីយុត្តិធម៌បរិស្ថាន (EJ) នៅទូទាំងកម្មវិធី គោលនយោបាយសកម្មភាពរបស់ MEP ទាំងមូល។ យុទ្ធសាស្ត្រនេះ សំដៅលើបច្ចេកសព្ទខាងក្រោម ដូចមានចែងក្នុងជំពូកទី 8 នៃច្បាប់ឆ្នាំ2021 (*ច្បាប់ស្តីពីផែនទីបង្ហាញផ្លូវសម្រាប់អ្នកជំនាន់ក្រោយសម្រាប់គោលនយោបាយធាតុអាកាសរដ្ឋម៉ាសាជូសេត*) និងគោលនយោបាយយុត្តិធម៌បរិស្ថានរបស់ EEA។

### និយមន័យ

"យុត្តិធម៌បរិស្ថាន (EJ)" ត្រូវបានកំណត់និយមន័យថាជាការការពារស្មើភាពគ្នា និងការចូលរួមប្រកបដោយអត្ថន័យពីសំណាក់ពលរដ្ឋ និងសហគមន៍ពាក់ព័ន្ធនឹងការអភិវឌ្ឍ ការអនុវត្ត និង

[1] https://www.mass.gov/doc/environmental-justice-policy6242021-update/download

ការពង្រឹងការអនុវត្តច្បាប់ បទបញ្ញត្តិ និងគោលនយោបាយស្តីពីថាមពល បម្រែបម្រួលអាកាសធាតុ និងបរិស្ថាន និងការបែងចែកដោយស្មើភាពគ្នានូវអត្ថប្រយោជន៍និងបន្ទុកបរិស្ថាន និងថាមពល។ យុត្តិធម៌បរិស្ថាន គឺផ្អែកលើគោលការណ៍ដែលមនុស្សរាល់គ្នាមានសិទ្ធិទទួលបានការការពារពីគ្រោះថ្នាក់បរិស្ថាន និងដើម្បីរស់នៅ និងទទួលបានបរិស្ថានស្អាត និងមានសុខភាពល្អ ដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ សញ្ជាតិកំណើត ប្រាក់ចំណូល ឬចំណេះដឹងភាសាអង់គ្លេសឡើយ។

"គោលការណ៍យុត្តិធម៌បរិស្ថាន" គឺជាគោលការណ៍ដែលគាំទ្រដល់ការការពារពីការបំពុលបរិស្ថាន និងសមត្ថភាពក្នុងការរស់នៅ និងទទួលបានបរិស្ថានស្អាត និងមានសុខភាពល្អ ដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ប្រាក់ចំណូល វណ្ណៈ ពិការភាព អត្តសញ្ញាណភេទ ទំនោរផ្លូវភេទ សញ្ជាតិកំណើត ជាតិពន្ធ ឬដូនតា ជំនឿសាសនា ឬចំណេះដឹងភាសាអង់គ្លេសនោះទេ ដែលក្នុងរួមបញ្ចូលនូវៈ (i) ការចូលរួមប្រកបដោយអត្ថន័យរបស់ពលរដ្ឋពាក់ព័ន្ធនឹងការអភិវឌ្ឍ ការអនុវត្ត និងការពង្រឹងការអនុវត្តច្បាប់ បទបញ្ញត្តិ និងគោលនយោបាយស្តីពីបរិស្ថាន និង (ii) ការបែងចែកដោយស្មើភាពគ្នានូវអត្ថប្រយោជន៍បរិស្ថាននិងថាមពល និងបន្ទុកបរិស្ថាន។

"ក្រុមប្រជាជនយុត្តិធម៌បរិស្ថាន"[2] ត្រូវបានកំណត់និយមន័យថាជាសង្កាត់ដែលបានបំពេញតាមលក្ខខណ្ឌវិនិច្ឆ័យមួយឬច្រើនដូចខាងក្រោមៈ

- ប្រាក់ចំណូលគ្រួសារមធ្យមប្រចាំឆ្នាំ គឺមិនលើសពី 65 ភាគរយនៃប្រាក់ចំណូលគ្រួសារមធ្យមប្រចាំឆ្នាំទូទាំងរដ្ឋ
- ប្រជាជនភាគតិចមានចំនួន 40 ភាគរយឡើងទៅក្នុងចំណោមក្រុមប្រជាជនចូលរួម
- សមាជិកគ្រួសារចាប់ពី 25 ភាគរយ ឬច្រើនជាងនេះ ខ្វះសមត្ថភាពជំនាញផ្នែកភាសាអង់គ្លេស
- ប្រជាជនភាគតិចមានចំនួន 25 ភាគរយឡើងទៅ ហើយប្រាក់ចំណូលគ្រួសារមធ្យមប្រចាំឆ្នាំនៃទីក្រុងដែលសង្កាត់នោះមានទីតាំងស្ថិតនៅ គឺមិនលើសពី 150 ភាគរយនៃប្រាក់ចំណូលគ្រួសារមធ្យមប្រចាំឆ្នាំទូទាំងរដ្ឋ
- សង្កាត់ដែលត្រូវកំណត់ទៅជាក្រុមប្រជាជនយុត្តិធម៌បរិស្ថានដោយលេខាធិការនៃ EEA ស្របទៅតាមនីតិវិធីដែលមានចែងក្នុងជំពូកទី 8 នៃច្បាប់ឆ្នាំ2021 និងគោលនយោបាយយុត្តិធម៌បរិស្ថានរបស់ EEA។

## យុទ្ធសាស្ត្រ

យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់ MEP នេះ កំណត់ពីសកម្មភាពសំខាន់នានាដែលអាចជួយដល់ការអនុវត្តគោលនយោបាយយុត្តិធម៌បរិស្ថានរបស់ EEA។ យុទ្ធសាស្ត្រនេះ រួមមានសមាសធាតុដែលកំណត់ដើម្បីដោះស្រាយប្រធានបទដូចខាងក្រោមៈ

- ការប្រាស្រ័យទាក់ទង និងការផ្សព្វផ្សាយៈ លើកកម្ពស់ការប្រាស្រ័យទាក់ទងពាក់ព័ន្ធនឹងយុត្តិធម៌បរិស្ថាន រួមមានការទទួលបានសេវាភាសា និងការផ្សព្វផ្សាយ និងការចូលរួម

[2] https://www.mass.gov/info-details/environmental-justice-populations-in-massachusetts

- ការបណ្តុះបណ្តាលៈ លើកកម្ពស់ការយល់ដឹងរបស់ទីភ្នាក់ងារ (បុគ្គលិក) និងពាក្យស្នើសុំគោលការណ៍យុត្តិធម៌បរិស្ថាននៅក្នុងកិច្ចការរបស់ MEP។
- ការជ្រើសរើសបុគ្គលិក និងការជួលបុគ្គលិកៈ សម្របសម្រួលឱ្យមានបុគ្គលិកគាំទ្រ និងបុគ្គលិកតំណាងដែលស្វែងចូលកាន់តំណែងដែលមានពិពិធភាព និងបរិយាបន្ន។
- សិទ្ធិជនជាតិដើមភាគតិច ឧ.ទា. កុលសម្ព័ន្ធ អង្គការកុលសម្ព័ន្ធ និងសមាជិកពួកគេៈ រុករកបញ្ហា និងបន្តស្វែងរកដំណោះស្រាយដែលពាក់ព័ន្ធនឹងសមាគម និងការអនុវត្តសកម្មភាពនៃការអនុវត្តច្បាប់ស្តីពីការអភិរក្ស និងរដ្ឋបាលសាធារណៈ។
- ឱកាសទទួលបានមូលនិធិជំនួយៈ ពិគ្រោះ និងដាក់បញ្ចូលភាសាយុត្តិធម៌បរិស្ថានក្នុងពាក្យស្នើសុំមូលនិធិជំនួយដែលពាក់ព័ន្ធ។
- ខ្នាតរង្វាស់ៈ កំណត់ពិលក្ខខណ្ឌកម្មវត្ថុសមស្របដើម្បីវាស់ស្ទង់ប្រសិទ្ធភាពកម្មវិធីតាមរយៈទស្សនៈវិស័យផលប្រយោជន៍យុត្តិធម៌បរិស្ថាន។

## ការផ្សព្វផ្សាយទៅដល់សហគមន៍

ស្ថិតក្រោម គោលនយោបាយយុត្តិធម៌បរិស្ថានរបស់ EEA "ការចូលរួមប្រកបដោយអត្ថន័យ គឺមានន័យថា គ្រប់សង្កាត់ទាំងអស់ មានសិទ្ធិនិងឱកាសក្នុងការចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តពាក់ព័ន្ធនឹងថាមពល បម្រែបម្រួលអាកាសធាតុ និងបរិស្ថាន ដែលក្នុងនោះរួមមាន ការវាយតម្លៃពីតម្រូវការ ការធ្វើផែនការ ការអនុវត្ត អនុលោមភាពនិងការអនុវត្តច្បាប់ ហើយការវាយតម្លៃនិងសង្កាត់នានា ទទួលបានការបណ្តុះសមត្ថភាព និងជំនួយផ្នែកកិច្ចការរដ្ឋបាល ដើម្បីចូលរួមពេញលេញនៅក្នុងការអប់រំ និងការបណ្តុះបណ្តាលទាំងមូល ហើយទទួលបានតម្លាភាព/គណនេយ្យភាពពីរដ្ឋាភិបាលពាក់ព័ន្ធនឹងមតិចូលរួមពីសហគមន៍ និងទទួលបានការលើកទឹកចិត្តក្នុងការបង្កើតការគ្រប់គ្រងប្រកបដោយការយកចិត្តទុកដាក់និងទំនួលខុសត្រូវលើបញ្ហាបរិស្ថាន ថាមពល និង បម្រែបម្រួលអាកាសធាតុ"។[3]

**គេហទំព័រប៉ូលិសបរិស្ថានរដ្ឋម៉ាសាជូសេត**[4] MEP នឹងធ្វើបច្ចុប្បន្នភាពគេហទំព័ររបស់ខ្លួន ដើម្បីដាក់បញ្ចូលព័ត៌មានតម្រង់ទិសស្តីពីយុត្តិធម៌បរិស្ថាន។ បន្ថែមលើនេះ MEP នឹងពិចារណា និងវាយតម្លៃលើវិធីនៃការចែករំលែកព័ត៌មាន តាមរយៈគេហទំព័រយុត្តិធម៌បរិស្ថានរបស់ EEA។ គេហទំព័រយុត្តិធម៌បរិស្ថានបច្ចុប្បន្នរបស់ MEP ផ្តល់ព័ត៌មានសំខាន់ៗនិងប្រយោជន៍ដូចជាៈ

- ព័ត៌មានសម្រាប់ទំនាក់ទំនងនៃអ្នកសម្របសម្រួលយុត្តិធម៌បរិស្ថានរបស់ MEP
- ព័ត៌មានសម្រាប់ទំនាក់ទំនងរបស់នាយកទីភ្នាក់ងាររបស់ MEP
- តំណភ្ជាប់ទៅកាន់ផ្នែកដូចខាងក្រោមៈ
    - ព័ត៌មានសម្រាប់ទំនាក់ទំនងនៃអ្នកសម្របសម្រួលយុត្តិធម៌បរិស្ថានរបស់ EEA
    - គោលនយោបាយយុត្តិធម៌បរិស្ថានរបស់ EEA
    - គេហទំព័រយុត្តិធម៌បរិស្ថានរបស់ EEA
- ស្ថិតិក្រុមប្រជាជនយុត្តិធម៌បរិស្ថានក្នុងខំមិនវែល

[3] គោលនយោបាយយុត្តិធម៌បរិស្ថាន ទំព័រ 4 https://www.mass.gov/service-details/environmental-justice-policy

[4] គេហទំព័រ OLE https://www.mass.gov/orgs/massachusetts-environmental-police

- ព័ត៌មានសំខាន់ៗដែលអាចស្វែងរកបាននៅក្នុងភាសាចំនួន 10 ផ្សេងទៀតដែលនិយាយនៅក្នុងខំមិនវែលនេះ ក្រៅពីភាសាអង់គ្លេស។

**សុវត្ថិភាព/សុខភាពសាធារណៈ** ចូលរួមនៅក្នុងការផ្សព្វផ្សាយទៅដល់សង្កាត់យុត្តិធម៌បរិស្ថាន និងសង្កាត់ដែលមានសមត្ថភាពចំណេះដឹងភាសាអង់គ្លេសទាប ជាពិសេសនៅពេលដោះស្រាយបញ្ហាការពារសុខភាព និងការគំរាមកំហែងសុវត្ថិភាពនៅក្នុងដែនសមត្ថកិច្ចរបស់ MEP។

**ការអប់រំ** MEP នឹងធ្វើការលើកកម្ពស់គុណភាពនៃការទទួលបានសេវាកម្មរបស់ខ្លួន។ សេវាកម្មទាំងនេះ រួមបញ្ចូលនូវ៖

- ការផ្សព្វផ្សាយអប់រំអំពីការបើកបរទូក និងសុវត្ថិភាពយានជំនិះនៅក្រៅផ្លូវហាយវេ
- ការចុះបញ្ជី និងប័ណ្ណកម្មសិទ្ធិសម្រាប់ទូក និងយានជំនិះកម្សាន្ត ដូចជាម៉ូតូព្រៃ ទូកម៉ាស៊ីន ។ល។

បន្ថែមលើនេះ MEP ប្តេជ្ញាចិត្តធ្វើការត្រួតពិនិត្យផ្ទៃក្នុងដើម្បីកំណត់ថាតើកូនសៀវភៅណែនាំ ទម្រង់បែបបទ និងអត្ថបទមួយណា គួរតែប្បីធ្វើការបកប្រែទៅជាភាសាដែលសមស្រប យោងទៅតាម ព្រឹត្តិបត្រសារព័ត៌មានរដ្ឋបាល និងហិរញ្ញវត្ថុ (A&F) #16 (គោលនយោបាយស្តីពីការទទួលបានសេវាភាសា "LAP")[5]។ គោលនយោបាយនេះ ព្យាយាមធ្វើយ៉ាងណាឱ្យបុគ្គលដែលមានសមត្ថភាពចំណេះដឹងភាសាមានកម្រិតទទួលបានព័ត៌មាននិងសេវាកម្ម។ MEP នឹងធ្វើការសម្របសម្រួលជាមួយអង្គភាពរុក្ខាប្រមាញ់ នេសាទ និងល្បែងកម្សាន្ត នៅក្នុងនាយកដ្ឋានរុក្ខាប្រមាញ់ នេសាទ និងសត្វព្រៃ និងទីភ្នាក់ងាររដ្ឋដទៃផ្សេងទៀត ក្នុងការផ្តល់ជូននូវសេវាកម្មនានាក្នុងលក្ខណៈស្មើភាពគ្នា។

**ទំនាក់ទំនងភាគីពាក់ព័ន្ធ**

- បង្កើតបញ្ជីក្រុមសហគមន៍/ក្រុមតស៊ូមតិទៅតាមទីកន្លែងក្នុងតំបន់ផ្អែកលើកត្តាជំរុញរួមគ្នា ដើម្បីឱ្យបុគ្គលិកទាំងអស់អាចចូលមើលបាន និងប្រើប្រាស់បញ្ជី EEA ទៅតាមតម្រូវការ។
- បន្តកសាងទំនាក់ទំនងនៅក្នុងសហគមន៍ និងរក្សាការប្រាស្រ័យទាក់ទងជាប្រចាំជាមួយក្រុមសហគមន៍/ក្រុមតស៊ូមតិ និងមន្ត្រីក្រុង ដោយធ្វើការចែករំលែកព័ត៌មានពាក់ព័ន្ធនឹងគម្រោង សកម្មភាពនានាក្នុងក្រុមប្រជាជនយុត្តិធម៌បរិស្ថាន និងចុះផ្សាយព័ត៌មាននោះនៅលើគេហទំព័ររបស់ MEP
- គិតគូរដល់ឱកាសសម្រាប់ការប្រើប្រាស់កិច្ចប្រជុំសហគមន៍ដើម្បីកសាងទំនាក់ទំនង ដោយប្រើសេវាកម្មភាសាទៅតាមតម្រូវការ ដើម្បីជំរុញការអនុវត្តច្បាប់ស្តីពីការអភិរក្ស និងបញ្ហាដែលពាក់ព័ន្ធ។ បង្កើតនិងអនុវត្តវិធីសាស្ត្រណាមួយ ដើម្បីរុករកប្រសិនបើមានឧបសគ្គណាមួយនៅក្នុងសហគមន៍យុត្តិធម៌បរិស្ថាន ដើម្បីទាក់ទងជាមួយ MEP
- បង្កើតផែនការទីភ្នាក់ងារមួយ និងគោលនយោបាយ ក៏ដូចជានីតិវិធីដើម្បីដោះស្រាយពាក្យបណ្តឹងពាក់ព័ន្ធយុត្តិធម៌បរិស្ថាន ឬស្នើសុំឱ្យមានការអនុវត្តច្បាប់។

---

[5] https://www.mass.gov/administrative-bulletin/language-access-policy-and-guidelines-af-16

### ការផ្សព្វផ្សាយតាមប្រព័ន្ធវីដេអូនិងសំឡេង និងការផ្សព្វផ្សាយពីចម្ងាយ

- MEP នឹងផ្តួចផ្តើមគំនិតនៃការប្រើប្រាស់វេទិកាតាមវីដេអូ (កម្មវិធី Zoom, Go To Meeting, Skype for Business, Microsoft Teams) និងសេវាកម្មដទៃផ្សេងទៀត ដែលអនុវត្តឱ្យមានការបណ្តុះបណ្តាល និងកិច្ចប្រជុំឱ្យធ្វើឡើងដោយពុំចាំបាច់ឱ្យអ្នកចូលរួមទាំងអស់មានទីតាំងនៅកន្លែងតែមួយ ហើយនឹងត្រូវប្រើសេវាភាសាពីចម្ងាយ (អ្នកបកប្រែផ្ទាល់មាត់) ទៅតាមតម្រូវការ។

### សមត្ថភាពចំណេះដឹងភាសាអង់គ្លេសនៅមានកម្រិត

- យោងទៅតាមព្រឹត្តិបត្រសារព័ត៌មាន A&F #16៖ ពាក់ព័ន្ធនឹង *គោលនយោបាយស្តីពីការទទួលបានសេវាភាសា* MEP ប្តេជ្ញាចិត្តក្នុងការធ្វើការត្រួតពិនិត្យផ្ទៃក្នុង ដើម្បីកំណត់ពីឯកសារសំខាន់ៗ ដែលគួរបកប្រែសម្រាប់ធ្វើការផ្សព្វផ្សាយទៅកាន់បុគ្គលដែលមានសមត្ថភាពចំណេះដឹងភាសាអង់គ្លេសនៅមានកម្រិត (LEP)
- MEP នឹងធ្វើការដើម្បីតម្រង់ទិសសេវាភាសារបស់ខ្លួនឱ្យស្របជាមួយនឹងលក្ខខណ្ឌតម្រូវនៃព្រឹត្តិបត្រសារព័ត៌មាន A&F #16
- MEP នឹងប្រើប្រាស់កិច្ចសន្យារបស់រដ្ឋ សេវាបកប្រែភាសាបរទេសជាឯកសារ និងផ្ទាល់មាត់ (PRF 75)[6]ដើម្បីទទួលបានសេវាបកប្រែឯកសារ និងសេវាបកប្រែផ្ទាល់មាត់ដូចមានតម្រូវនៅក្នុងព្រឹត្តិបត្រសារព័ត៌មាន A&F #16
- MEP នឹងសន្សំថវិកាមួយចំណែកសម្រាប់ការបកប្រែឯកសារ និងអ្នកបកប្រែផ្ទាល់មាត់ស្ថិតក្រោមកិច្ចសន្យារដ្ឋ PRF 75
- MEP នឹងធ្វើការបកប្រែសម្ភារៈផ្សព្វផ្សាយសំខាន់ៗដែលកំណត់ដោយការិយាល័យពាក់ព័ន្ធ
- តាមលទ្ធភាពដែលអាចអនុវត្តបាន និងអាស្រ័យលើអ្នកអាន និងតំបន់ភូមិសាស្ត្រដែលរងផលប៉ះពាល់ MEP នឹងរៀបចំឱ្យមានកាបណ្តុះបណ្តាលអ្នកបកប្រែផ្ទាល់មាត់ពាក់ព័ន្ធនឹងសុវត្ថិភាពសាធារណៈ សុខភាព និងកម្មវិធីដទៃផ្សេងទៀត ទៅតាមតម្រូវការ ធ្វើឡើងជាភាសាដែលសមស្រប ឬទៅតាមសេចក្តីតម្រូវនៃព្រឹត្តិបត្រសារព័ត៌មាន A&F #16 ឬគោលនយោបាយយុត្តិធម៌បរិស្ថានរបស់ EEA

### ការបណ្តុះបណ្តាល

MEP ប្តេជ្ញាចិត្តធ្វើការជំរុញលើកកម្ពស់យុត្តិធម៌បរិស្ថាន តាមរយៈការរៀបចំដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត ដែលអាចបង្ការប្រសិទ្ធភាពសុខភាព បរិស្ថាន សង្គម និងសេដ្ឋកិច្ចគ្មានសមមាត្រ ចំពោះពលរដ្ឋនៅក្នុងខំមិនវែលនេះ។ ដើម្បីសម្រេចបានលទ្ធផលនេះ យើងខិតខំប្រឹងប្រែងផ្តល់ជូននូវការបណ្តុះបណ្តាល ដែលផ្តល់ឱកាសប្រកបដោយអត្ថន័យសម្រាប់ការចូលរួមជាសាធារណៈ និងការចូលរួមពីសហគមន៍។ MEP នឹងផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់ការបណ្តុះបណ្តាលផ្តោតសំខាន់លើយុត្តិធម៌បរិស្ថាន ហើយនឹងធានាថា បុគ្គលិកទីភ្នាក់ងារសមស្រប ទទួលបានការណែនាំអំពីបញ្ហាយុត្តិធម៌បរិស្ថាន លក្ខខណ្ឌតម្រូវទំនួលខុសត្រូវ និងឱកាសតាមរយៈការបណ្តុះបណ្តាលនេះ។

---

[6] https://www.mass.gov/doc/prf75/download

**ការបណ្តុះបណ្តាលរបស់ MEP សម្រាប់បុគ្គលិក MEP** MEP នឹងផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់ការបណ្តុះបណ្តាល EJ។ ប្រធានបទអាចមានដូចជា៖

- ការបណ្តុះបណ្តាលស្តីពីការដាក់បញ្ចូលយុត្តិធម៌បរិស្ថានទៅក្នុងការងាររបស់ MEP។
- ការបណ្តុះបណ្តាលអំពីការចូលរួមរបស់សហគមន៍ប្រកបដោយប្រសិទ្ធភាព និងការសម្របសម្រួលពីឧត្តមានុវត្តន៍។

**បុគ្គលិក MEP នឹងចូលរួមក្នុងការបណ្តុះបណ្តាល EEA** MEP ប្តេជ្ញាចិត្តក្នុងការបញ្ចូលបុគ្គលិកទៅចូលរួមក្នុងការបណ្តុះបណ្តាលអំពីយុត្តិធម៌បរិស្ថាន ដោយរៀបចំដោយក្រុមយុត្តិធម៌បរិស្ថានរបស់ EEA។ ការបណ្តុះបណ្តាលទាំងនេះ រួមបញ្ចូលនូវការបណ្តុះបណ្តាលអំពី៖

- ការប្រើប្រាស់ឧបករណ៍ធ្វើផែនទីយុត្តិធម៌បរិស្ថាន ដូចជា EEA's GIS (Geographic Information Systems) EJ Viewer[7]
- សេវាបកប្រែផ្ទាល់មាត់ និងសេវាបកប្រែឯកសារ និងលក្ខខណ្ឌតម្រូវផ្សេងៗ
- ការផ្សព្វផ្សាយជាសាធារណៈ និងការដាក់បញ្ចូលនូវឧត្តមានុវត្តន៍។

## ការជ្រើសរើសបុគ្គលិក ការជួលបុគ្គលិក និងការដំឡើងតំណែង

MEP ទទួលស្គាល់ពីសារៈសំខាន់នៃការមានកម្លាំងការងារមួយដែលឆ្លុះបញ្ចាំងពីពិពិធភាពសង្គម-សេដ្ឋកិច្ច ជាតិសាសន៍ និងពូជសាសន៍នៃប្រជាជនក្នុងរដ្ឋម៉ាសាជូសេត រួមទាំងតួនាទីសំខាន់ដែលកម្លាំងនេះដើរតួក្នុងការធ្វើឱ្យប្រសើរឡើងនូវការធ្វើសេចក្តីសម្រេចចិត្តដែលមានសមភាព ពាក់ព័ន្ធនឹងការអនុវត្តច្បាប់ និងការការពារសុខភាពសាធារណៈ និងសេវាកម្មដែលពាក់ព័ន្ធ។

MEP ប្តេជ្ញាចិត្តនឹងខ្លួនឯងថានឹងរួមបញ្ចូលការអនុវត្តការជ្រើសរើសបុគ្គលិកដែលមានពិពិធភាព និងដើម្បីផ្តល់នូវការបណ្តុះបណ្តាលដល់អ្នកគ្រប់គ្រងខាងជ្រើសរើសបុគ្គលិក ដើម្បីលើកកម្ពស់ការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយសមភាព រួមបញ្ចូលទាំងការប្រើប្រាស់លក្ខខណ្ឌវិនិច្ឆ័យក្នុងមុខតំណែងការងារ ដែលតម្រូវឱ្យបេក្ខជនជាប់ជាស្ថាពរបង្ហាញពីចំណេះដឹងនិងការយល់ដឹងពាក់ព័ន្ធនឹងតម្រូវការរបស់ប្រជាជនងាយរងគ្រោះ សង្កាត់យុត្តិធម៌បរិស្ថាន និងតំបន់ដែលមិនទទួលបានសេវាកម្មដិតដល់នៅក្នុងខំមិនវែលនេះ។

- MEP ពិគ្រោះដើម្បី៖
  - ចូលរួមក្នុងពិពរណ៍ការងារ/អាជីព និងមជ្ឈមណ្ឌលវប្បធម៌ ដើម្បីជំរុញលើកកម្ពស់ អប់រំ លើកទឹកចិត្ត និងកៀងគរអ្នកដាក់ពាក្យឱ្យចូលរួមជាមួយ MEP ធ្វើជាបុគ្គលិកស្បថចូលកាន់តំណែង ដែលមានប្រភពមកពីសង្កាត់យុត្តិធម៌បរិស្ថាន ឬដែលមានចំណេះដឹង និងមានការចាប់អារម្មណ៍ខ្លាំងចំពោះបញ្ហាយុត្តិធម៌បរិស្ថាន។
  - ដដែកជាមួយសិស្សនិស្សិតនៅគ្រប់កម្រិតអប់រំ ដើម្បីជូនដំណឹងដល់ពួកគេអំពីឱកាសការងារក្នុងផ្នែកអនុវត្តច្បាប់ស្តីពីការអភិរក្ស

[7] https://mass-eoeea.maps.arcgis.com/apps/MapSeries/index.html?appid=535e4419dc0545be980545a0eeaf9b53

  - o ដាក់បញ្ចូលការយល់ដឹងរបស់បុគ្គលិកអំពីបញ្ហានិងការងាររបស់ក្រុមប្រជាជនយុត្តិធម៌បរិស្ថាន និងធ្វើកិច្ចការនៅក្នុងសហគមន៍យុត្តិធម៌បរិស្ថាន នៅក្នុងលក្ខខណ្ឌវិនិច្ឆ័យត្រួតពិនិត្យការបំពេញការងារ។

### បញ្ហាកុលសម្ព័ន្ធ

- MEP ប្ដេជ្ញាចិត្តក្នុងការត្រួតពិនិត្យអំពីពិធីសារជាលាយលក្ខណ៍អក្សរផ្ទៃក្នុងពាក់ព័ន្ធនឹងផលប្រយោជន៍របស់ ជនជាតិដើមភាគតិចនៅក្នុងមជ្ឈដ្ឋានអនុវត្តច្បាប់ស្ដីពីការអភិរក្សនាពេលបច្ចុប្បន្ន។

### ឱកាសទទួលបានមូលនិធិជំនួយ

- ស្វែងរកយ៉ាងសកម្មដើម្បីទទួលបានមូលនិធិសម្រាប់គំនិតផ្ដួចផ្ដើមដែលនឹងផ្ដល់ប្រយោជន៍ដល់ក្រុមប្រជាជនយុត្តិធម៌បរិស្ថាននៅក្នុងខំមិនវែលនេះ។

### ខ្នាតរង្វាស់

គោលនយោបាយយុត្តិធម៌បរិស្ថាន តម្រូវឱ្យទីភ្នាក់ងារធ្វើការវាស់ស្ទង់ និងតាមដានវឌ្ឍនភាពជាមួយនឹងគោលដៅយុត្តិធម៌បរិស្ថាន ហើយបន្ទាប់មកទៀត ត្រូវធ្វើការកត់ត្រាទុកនៅក្នុងឯកសារចុងឆ្នាំដែលចេញដោយ EEA។ ខ្នាតរង្វាស់ដែល MEP នឹងធ្វើការតាមដាន មានដូចជា៖

- កញ្ចប់ថវិកាចំណាយលើសេវាភាសា
- ចំនួនឯកសារច្រើនប៉ុនណាដែលត្រូវបកប្រែ
- ចំនួនអ្នកបកប្រែផ្ទាល់មាត់ប៉ុន្មាននាក់ដែលបានប្រើ
- ការបណ្ដុះបណ្ដាលដែលធ្វើឡើងផ្ទៃក្នុង
- ការបណ្ដុះបណ្ដាលដែលរៀបចំដោយ MEP ស្ដីពីប្រធានបទ MEP ក្នុងសហគមន៍
- វត្តមានចូលរួមរបស់បុគ្គលិក MEP នៅក្នុងការបណ្ដុះបណ្ដាលយុត្តិធម៌បរិស្ថាន
- ចំនួនប្រជាសាស្ត្រដែលជួល[8]

## ការអនុវត្តយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់ការិយាល័យប្រតិបត្តិផ្នែកថាមពល និងកិច្ចការបរិស្ថាន

ពាក់ព័ន្ធនឹងក្ដីបារម្ភ ពាក្យបណ្ដឹង ការបំពេញបន្ថែម ឬគំនិតផ្សេងៗពាក់ព័ន្ធនឹងយុត្តិធម៌បរិស្ថាន ឬដើម្បីស្វែងយល់បន្ថែមអំពីកិច្ចខិតខំប្រឹងប្រែងផ្នែកយុត្តិធម៌បរិស្ថាន ថាមពល និងអាកាសធាតុរបស់ទីភ្នាក់ងារយើង សូមទាក់ទងការិយាល័យយុត្តិធម៌បរិស្ថានរបស់ EEA ដែលមានចែងនៅទំព័រទី 19 នៃយុទ្ធសាស្ត្របរិស្ថានរបស់ EEA។

### ព័ត៌មានទំនាក់ទំនងផ្នែកយុត្តិធម៌បរិស្ថានរបស់ OLE៖

លោកវរសេនីយត្រី Kevin L. Clayton
ប្រធានផ្នែកអនុវត្តច្បាប់
kevin.clayton@mass.gov
508-630-431

[8] https://www.mass.gov/info-details/state-employee-diversity-dashboard

# ការិយាល័យច្បាប់គោលនយោបាយបរិស្ថានរដ្ឋម៉ាសាជូសេត
# យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន

ព្រាង

# តារាងមាតិកា

**ការិយាល័យច្បាប់គោលនយោបាយបរិស្ថានរដ្ឋម៉ាសាជូសេត ........................................................42**
សេចក្តីផ្តើម ........................................................................................................................44
សារតារ ..............................................................................................................................45
យុទ្ធសាស្រ្តយុត្តិធម៌បរិស្ថានរបស់ MEPA ..............................................................................46
*ធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌតម្រូវនៃការចូលរួមជាសាធារណៈសម្រាប់គម្រោងដែលមានទីតាំងនៅជិតក្រុមប្រជាជនយុត្តិធម៌បរិស្ថាន ..........................................................................46*
*ការវិភាគផលប៉ះពាល់លើក្រុមប្រជាជនយុត្តិធម៌បរិស្ថានដែលធ្វើឱ្យប្រសើរឡើង.................48*
*ការទទួលបានសេវាភាសា ...................................................................................................48*
*កិច្ចខិតខំសម្រាប់ការចូលរួមជាសាធារណៈពីការិយាល័យ MEPA .............................................50*
*ការបណ្តុះបណ្តាល និងការជួលបុគ្គលិក....................................................................................50*
*ខ្នាតរង្វាស់ ...........................................................................................................................51*
ការអនុវត្តយុទ្ធសាស្រ្តយុត្តិធម៌បរិស្ថានរបស់ការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន ........................................................................................................................51

# យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាននៃការិយាល័យ ច្បាប់គោលនយោបាយបរិស្ថានរដ្ឋម៉ាសាជូសេត

## សេចក្តីផ្តើម

ការិយាល័យច្បាប់ស្តីពីគោលនយោបាយបរិស្ថានរដ្ឋម៉ាសាជូសេត (MEPA) គឺជាផ្នែក ការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន (EEA) ដែលជាទីភ្នាក់ងារមួយនៃខំមិនវែលរដ្ឋម៉ាសាជូសេត។

ការិយាល័យ MEPA បានធ្វើការត្រួតពិនិត្យលើផលប៉ះពាល់បរិស្ថាននៃគម្រោងអភិវឌ្ឍន៍ និងសកម្មភាពផងទៃទៀតដែលតម្រូវឱ្យមានចំណាត់ការ ដូចជា ការផ្តល់លិខិតអនុញ្ញាត ការកំណត់ទីតាំង ឬការផ្តល់មូលនិធិ ពីសំណាក់ទីភ្នាក់ងាររដ្ឋ និងអាជ្ញាធរក្រុងជាក់លាក់មួយចំនួន (ជារួមហៅកាត់ថា "ទីភ្នាក់ងារ")។ គោលបំណងនៃដំណើរការត្រួតពិនិត្យលើ MEPA នេះ គឺដើម្បីផ្តល់ឱកាសដែលមានន័យខ្លឹមសារសម្រាប់ការត្រួតពិនិត្យជាសាធារណៈលើផលប៉ះពាល់បរិស្ថានធំដុំនៅពេលចាត់វិធានការរបស់ទីភ្នាក់ងារលើគម្រោងនោះ។

ការិយាល័យ MEPA ប្តេជ្ញាចិត្តក្នុងការដាក់បញ្ចូលគោលការណ៍យុត្តិធម៌បរិស្ថាន (EJ) ទៅក្នុងកម្មវិធី គោលនយោបាយ និងសកម្មភាពរបស់ខ្លួន។ ដើម្បីសម្រេចបែបនេះបាន យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់ MEPA មានរៀបរាប់ពីគ្រោងការមួយដើម្បីអនុវត្តផ្នែក 56-60 នៃជំពូកទី 8 នៃច្បាប់ឆ្នាំ2021។ *ជាច្បាប់មួយដែលបង្កើតផែនទីបង្ហាញផ្លូវដល់អ្នកជំនាន់ក្រោយសម្រាប់គោលនយោបាយធាតុអាកាសរដ្ឋម៉ាសាជូសេត* (ហៅកាត់ថា "ច្បាប់ផែនទីបង្ហាញផ្លូវអាកាសធាតុ" ឬ "ច្បាប់នេះ")។ ជាពិសេស MEPA ខិតខំដើម្បីបង្កើនឱកាសសម្រាប់ក្រុមប្រជាជនយុត្តិធម៌បរិស្ថានដើម្បីផ្តល់មតិចូលរួមដែលមានន័យខ្លឹមសារលើការត្រួតពិនិត្យ MEPA និងដើម្បីកែលម្អវិធីសាស្ត្រសម្រាប់ការវិភាគផលប៉ះពាល់គម្រោងដែលប៉ះពាល់ដល់ក្រុមប្រជាជនយុត្តិធម៌បរិស្ថាន។ MEPA ក៏មានគោលបំណងក្នុងការអនុវត្តជាជំហានដើម្បីដាក់បញ្ចូលគោលការណ៍យុត្តិធម៌បរិស្ថានទៅក្នុងមុខងារផ្ទៃក្នុងនៃការិយាល័យ MEPA តាមរយៈការកែលម្អការអប់រំសាធារណៈ ការទទួលបានសេវាភាសា និងការបណ្តុះបណ្តាលបុគ្គលិក និងការអនុវត្តការជួលបុគ្គលិក។

យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់ MEPA រួមបញ្ចូលនូវធាតុខាងក្រោម ដែលមានចែងលម្អិតបន្ថែមទៀតនៅក្នុងផ្នែកខាងក្រោមនេះ៖

- លើកកម្ពស់លក្ខខណ្ឌតម្រូវនៃការចូលរួមជាសាធារណៈសម្រាប់គម្រោងនានាដែលអនុវត្តការត្រួតពិនិត្យរបស់ MEPA ហើយមានទីតាំងនៅជិតក្រុមប្រជាជនយុត្តិធម៌បរិស្ថាន។
- លើកកម្ពស់ការវិភាគផលប៉ះពាល់គម្រោងចំពោះក្រុមប្រជាជនយុត្តិធម៌បរិស្ថាន រួមមានការវាយតម្លៃលើបន្ទុកបរិស្ថានដែលមានស្រាប់ និងផលប៉ះពាល់ចំពោះសុខភាពសាធារណៈ និងការវិភាគអំពីផលប៉ះពាល់បន្ថែមនៃគម្រោងនោះ។
- លើកកម្ពស់ការទទួលបានសេវាបកប្រែឯកសារ/បកប្រែផ្ទាល់មាត់ ដែលពាក់ព័ន្ធនឹងចំណាត់ការសំខាន់ៗដែលធ្វើឡើងដោយការិយាល័យ MEPA

- លើកកម្ពស់ការចូលរួមជាសាធារណៈផ្ទាល់ខ្លួនរបស់ការិយាល័យ MEPA និងកិច្ចខិតខំប្រឹងប្រែងក្រៅពីការត្រួតពិនិត្យលើគម្រោងនីមួយៗ
- អនុវត្តការបណ្តុះបណ្តាលបុគ្គលិក និងការអនុវត្តការជួលបុគ្គលិកដែលបានធ្វើបច្ចុប្បន្នភាព ដើម្បីឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តចំពោះគោលការណ៍យុត្តិធម៌បរិស្ថាន
- បង្កើតខ្នាតរង្វាស់ដើម្បីតាមដានវឌ្ឍនភាពលើការអនុវត្តប្រកបដោយជោគជ័យលើយុទ្ធសាស្ត្រនេះ
- កែប្រែបទបញ្ញត្តិ សេចក្តីណែនាំ និងនីតិវិធីដទៃទៀតរបស់ MEPA ទៅតាមតម្រូវការ ដើម្បីសម្រេចគោលដៅខាងលើ

## សាវតារ

ដូចបានកំណត់និយមន័យនៅក្នុងគោលនយោបាយយុត្តិធម៌បរិស្ថានរបស់ EEA (បានធ្វើបច្ចុប្បន្នភាពឆ្នាំ2021)[1] "យុត្តិធម៌បរិស្ថាន" សំដៅលើការការពារស្មើភាពគ្នា និងការចូលរួមប្រកបដោយអត្ថន័យពីសំណាក់ពលរដ្ឋ និងសហគមន៍ពាក់ព័ន្ធនឹងការអភិវឌ្ឍ ការអនុវត្ត និងការពង្រឹងការអនុវត្តច្បាប់ បទបញ្ញត្តិ និងគោលនយោបាយស្តីពីថាមពល បម្រែបម្រួលអាកាសធាតុ និងបរិស្ថាន និងការបែងចែកដោយស្មើភាពគ្នានូវអត្ថប្រយោជន៍និងបន្ទុកបរិស្ថាន និងថាមពល។

ច្បាប់ផែនទីបង្ហាញផ្លូវអាកាសធាតុ រួមបញ្ចូលនូវការការពារកាន់តែច្រើនសម្រាប់ក្រុមប្រជាជនយុត្តិធម៌បរិស្ថាន។ ច្បាប់នេះបានបង្គាប់ច្បាស់ៗឱ្យ MEPA ធ្វើការអនុវត្តពិធីសារនៃការចូលរួមជាសាធារណៈដែលបានកែលម្អឱ្យប្រសើរឡើង និងបង្កើតដំណើរការនៃការត្រួតពិនិត្យផលប៉ះពាល់បរិស្ថានកាន់តែលម្អិតស៊ីជម្រៅសម្រាប់គម្រោងដែលមានទីតាំងនៅក្បែរក្រុមប្រជាជនយុត្តិធម៌បរិស្ថាន។ ច្បាប់នេះបង្គាប់ឱ្យមានការត្រួតពិនិត្យទាំងអស់នេះ ដើម្បីកំណត់ពីបន្ទុកបរិស្ថានមិនយុត្តិធម៌ ឬមិនស្មើភាពគ្នា និងបន្ទុកផលប៉ះពាល់សុខភាពសាធារណៈដែលពាក់ព័ន្ធដែលក្រុមប្រជាជនយុត្តិធម៌បរិស្ថានរងការប៉ះពាល់ និងធ្វើការដោះស្រាយថាតើប៉ះពាល់បន្ថែមនៃគម្រោង អាចបង្កផលប៉ះពាល់ធ្ងន់ធ្ងរមិនសមាមាត្រគ្នា ឬបង្កើនហានិភ័យនៃបម្រែបម្រួលអាកាសធាតុលើក្រុមប្រជាជនយុត្តិធម៌បរិស្ថានដោយរបៀបណា។

បទបញ្ជាអនុវត្តលេខ 552[2] បានណែនាំឱ្យ EEA ធ្វើបច្ចុប្បន្នភាពគោលនយោបាយយុត្តិធម៌បរិស្ថានឆ្នាំ2002 និងបានណែនាំដល់គ្រប់លេខាធិការដ្ឋានទាំងអស់ឱ្យធ្វើការតែងតាំងប្រធានយុត្តិធម៌បរិស្ថាន និងអនុវត្តយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន។ បទបញ្ជាអនុវត្តនេះ ក៏បានតម្រូវឱ្យក្រុមការងារយុត្តិធម៌បរិស្ថានអន្តរទីភ្នាក់ងារ មានការយល់ដឹង ដើម្បីធ្វើការសម្របសម្រួលដល់កិច្ចខិតខំប្រឹងប្រែងយុត្តិធម៌បរិស្ថាននៅទូទាំងលេខាធិការដ្ឋានទាំងមូលផងដែរ។

គោលនយោបាយយុត្តិធម៌បរិស្ថានរបស់ EEA (បានធ្វើបច្ចុប្បន្នភាពឆ្នាំ2021) ក៏បានធ្វើការណែនាំដូចគ្នាឱ្យគ្រប់ទីភ្នាក់ងារទាំងអស់របស់ EEA ធ្វើការបង្កើតយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានផ្ទាល់ខ្លួន ដើម្បីដាក់បញ្ចូលគោលការណ៍យុត្តិធម៌បរិស្ថានទៅក្នុងកម្មវិធី គោលនយោបាយ និងសកម្មភាពរបស់ពួកគេ។ គោលនយោបាយយុត្តិធម៌បរិស្ថានរបស់ EEA តម្រូវឱ្យគម្រោងដែលទាមទារឱ្យមាន "កម្រិតត្រួតពិនិត្យ" នៅក្នុងបទបញ្ញត្តិរបស់ MEPA ផ្តល់ឱកាសសម្រាប់ "

[1] https://www.mass.gov/executive-orders/no-552-executive-order-on-environmental-justice
[2] https://www.mass.gov/executive-orders/no-552-executive-order-on-environmental-justice

ការចូលរួមជាសាធារណៈដែលបានកែលម្អឱ្យប្រសើរ” ដោយក្រុមប្រជាជនយុត្តិធម៌បរិស្ថាននៅជុំវិញ និងដើម្បីអនុវត្ត “ការវិភាគផលប៉ះពាល់បរិស្ថាន និងការកាត់បន្ថយផលប៉ះពាល់ដែលបានកែលម្អឱ្យប្រសើរ”។ បច្ចុប្បន្ន លក្ខខណ្ឌតម្រូវទាំងនេះ នឹងត្រូវយកមកអនុវត្តតាមរយៈបទប្បញ្ញត្តិ និងសេចក្តីណែនាំរបស់ MEPA ដោយត្រូវចេញផ្សាយស្របទៅតាមច្បាប់ផែនទីបង្ហាញផ្លូវអាកាសធាតុ។

## យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់ MEPA

ដោយមានការតម្រូវពីច្បាប់ផែនទីបង្ហាញផ្លូវអាកាសធាតុ ការិយាល័យ MEPA បានប្រកាសដាក់ឱ្យប្រើប្រាស់បទប្បញ្ញត្តិដែលបានកែប្រែរួច ដើម្បីអនុវត្តលក្ខខណ្ឌនៃច្បាប់នេះ ដែលពាក់ព័ន្ធនឹង MEPA ហើយបានចេញផ្សាយឯកសារណែនាំដែលពាក់ព័ន្ធ។ លក្ខខណ្ឌតម្រូវថ្មីៗដែលពាក់ព័ន្ធនឹងយុត្តិធម៌បរិស្ថានសម្រាប់ឯកសារគម្រោងថ្មីៗ ត្រូវដាក់ឱ្យចូលជាធរមាននៅថ្ងៃទី1 ខែមករា ឆ្នាំ2022។ ការិយាល័យ MEPA កំពុងពិចារណាលើដំណាក់កាលទីពីរនៃការបង្កើតបទបញ្ញត្តិនៅក្នុងឆ្នាំ2022 ផ្អែកលើលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរបស់ភាគីពាក់ព័ន្ធ ដែលដឹកនាំដោយ នាយកដ្ឋានការពារបរិស្ថាននៃរដ្ឋម៉ាសាជូសេត (MassDEP) ស្ថិតក្រោមផ្នែក 102C នៃច្បាប់ផែនទីបង្ហាញផ្លូវអាកាសធាតុ។

សមាសធាតុសំខាន់ៗនៃយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានមានដូចខាងក្រោម៖

### ធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌតម្រូវនៃការចូលរួមជាសាធារណៈសម្រាប់គម្រោងដែលមានទីតាំងនៅជិតក្រុមប្រជាជនយុត្តិធម៌បរិស្ថាន

ការិយាល័យ MEPA ប្តេជ្ញាចិត្តក្នុងការធានានូវឱកាសនៃការផ្តល់មតិចូលរួមដែលមានន័យនៅក្នុងដំណើរការនៃការត្រួតពិនិត្យរបស់ MEPA តាមរយៈពិធីសារនៃការចូលរួមជាសាធារណៈដែលបានធ្វើឱ្យប្រសើរឡើង សម្រាប់គម្រោងដែលមានទីតាំងនៅជិតក្រុមប្រជាជនយុត្តិធម៌បរិស្ថាន។ ការិយាល័យ MEPA នឹងកែតម្រូវពិធីសារនេះឱ្យស្របទៅតាមលក្ខខណ្ឌតម្រូវនៃច្បាប់ផែនទីបង្ហាញផ្លូវអាកាសធាតុនេះ។

នៅពេលប្រកាសដាក់ឱ្យប្រើប្រាស់បទប្បញ្ញត្តិនេះ ដែលតម្រូវដោយច្បាប់ផែនទីបង្ហាញផ្លូវអាកាសធាតុ ការិយាល័យ MEPA នឹងតម្រូវឱ្យគម្រោងទាំងអស់ធ្វើការត្រួតពិនិត្យ MEPA (ដោយការលើកលែងតិចតួច) ដើម្បីចូលរួមក្នុងការផ្សព្វផ្សាយ និងកិច្ចខិតខំសម្រាប់ការចូលរួមរបស់សហគមន៍នៅមុនពេលដាក់បញ្ជូនមកការិយាល័យ MEPA។ រាល់គម្រោងទាំងអស់នឹងត្រូវរំពឹងថានឹងផ្តល់ការជូនដំណឹងជាមុនអំពីគម្រោងនោះ ទៅកាន់អង្គការក្នុងសហគមន៍ (CBO) និងកុលសម្ព័ន្ធ ដែលមាននៅក្នុងបញ្ជីឯកសារយោង ដែលរក្សាទុកដោយប្រធានយុត្តិធម៌បរិស្ថានរបស់ EEA។

ពិធីសារនៃការចូលរួមជាសាធារណៈដែលបានកែលម្អឱ្យប្រសើរដោយ MEPA បង្គាប់ឱ្យអ្នកស្នើនោះអនុវត្តតាមឧត្តមានុវត្តន៍ក្នុងការចូលរួមរបស់សហគមន៍ រួមមានជាអាទិ៍ វិធានការដូចខាងក្រោមនេះ៖

- រៀបចំកិច្ចប្រជុំសហគមន៍ទៅតាមការស្នើសុំដោយបុគ្គលណាម្នាក់ដែលបានទាក់ទងមកតាមរយៈការជូនដំណឹងជាមុន ឬនៅពេលមានផ្សព្វផ្សាយបន្ថែមទៀតអំពីខ្លឹមសារសង្ខេបជាលាយលក្ខណ៍អក្សរនៃគម្រោងនោះ ដូចមានយោងខាងក្រោម

- ការផ្សព្វផ្សាយទូលំទូលាយអំពីខ្លឹមសារសង្ខេបជាលាយលក្ខណ៍អក្សរនៃគម្រោងណាមួយ (ដោយមានការបកប្រែទៅជាភាសាដែលពាក់ព័ន្ធ) ដែលមានខ្លឹមសារលម្អិតអំពីគម្រោងគោល
- បង្កើតគេហទំព័រគម្រោង ឬធ្វើយ៉ាងណាឱ្យព័ត៌មានគម្រោងអាចស្វែងរកបានតាមរយៈមធ្យោបាយអេឡិចត្រូនិកស្រដៀងគ្នា
- ធានាថាការផ្សព្វផ្សាយទៅដល់សាធារណជនមានលក្ខណៈច្បាស់លាស់ ប្រើភាសាអាចយល់បាន និងក្នុងទម្រង់ដែលសមស្របសម្រាប់អ្នកអាន។
- ចូលរួមក្នុងការផ្សព្វផ្សាយប្រកបដោយការច្នៃប្រឌិត ដោយធ្វើការប្រើប្រាស់ក្រុមដែលមានស្រាប់ពីមុន (ដូចជា អង្គការក្នុងមូលដ្ឋាន ក្រុមវិទ្យាល័យ និងតំបន់ធម្មជាតិដែលមានការជួបជុំគ្នា ដូចជាកន្លែងថ្វាយបង្គំព្រះ បណ្ណាល័យ ទីផ្សារកសិករ) ដើម្បីធ្វើការផ្សព្វផ្សាយព័ត៌មានអំពីគម្រោងថ្មីៗ ក៏ដូចជានៅតាមទីកន្លែងចាស់ៗដូចជា បណ្ណាល័យ និងការិយាល័យរដ្ឋាភិបាលជាដើម។
- ប្រើប្រាស់បណ្តាញផ្សព្វផ្សាយព័ត៌មានជាក់លាក់ក្នុងសង្គមនិង/ឬមធ្យោបាយផ្សេងៗ ដើម្បីប្រកាសឱ្យសាធារណជនដឹងឮពីគម្រោង រួមបញ្ចូលទាំងស្ថានីយផ្សាយ កាសែតឯកទេស បណ្តាញសារព័ត៌មានសង្គម និងកាសែតសហគមន៍ និងសារព័ត៌មានជាភាសាផ្សេង
- រៀបចំកិច្ចប្រជុំសាលាក្រុង ឬកិច្ចប្រជុំផ្តោតលើសហគមន៍ ដែលរៀបចំទៅតាមប្រធានបទ សង្កាត់ និងក្រុមផលប្រយោជន៍
- រៀបចំកិច្ចប្រជុំសហគមន៍ក្នុងអំឡុងពេលចុងសប្តាហ៍ ឬម៉ោងពេលល្ងាច នៅទីតាំងដែលអាចចេញចូលបាន នៅជិតកន្លែងដឹកជញ្ជូនសាធារណៈ និង/ឬតាមរយៈកម្មវិធី Zoom ឬសេវាតាមអនឡាញស្រដៀងគ្នា ប្រសិនបើមានការស្នើសុំ ឬកំណត់ថាមានប្រសិទ្ធភាពជាងសម្រាប់ការផ្សព្វផ្សាយទៅដល់ក្រុមប្រជាជនយុត្តិធម៌បរិស្ថាន។ បន្ថែមលើនេះ អាចពិចារណាប្រើ “ទម្រង់កូនកាត់” ដែលអនុញ្ញាតឱ្យសមាជិកជាសាធារណជនចូលរួមដោយផ្ទាល់ តាមកម្មវិធី Zoom ឬតាមទូរសព្ទ និងធ្វើយ៉ាងណាឱ្យខ្លឹមសារកិច្ចប្រជុំអាចស្វែងរកបាននៅក្រោយពីនោះ សម្រាប់អ្នកដែលមិនអាចចូលរួមបាន។
- រៀបចំកិច្ចខិតខំអប់រំសាធារណៈសម្រាប់ទិដ្ឋភាពបច្ចេកទេសនៃគម្រោងនោះ ដូចជាខិត្តប័ណ្ណដែលមានរូបភាព ដែលរួមបញ្ចូលខ្លឹមសារសង្ខេបអំពីគម្រោង និងបច្ចេកវិទ្យានិងដំណើរការដែលពាក់ព័ន្ធ ដោយប្រើប្រាស់ភាសា និងបច្ចេកសព្ទសាមញ្ញ ដើម្បីខំប្រឹងធានាយ៉ាងណាឱ្យសហគមន៍យល់ពីផលប៉ះពាល់ធ្ងន់ធ្ងរនៃគម្រោងនោះ និងអាចផ្តល់មតិចូលរួមដែលមានន័យខ្លឹមសារ និងធ្វើបទបង្ហាញដែលមាន “ភាពត្រឹមត្រូវបែបវិទ្យាសាស្ត្រ” ឬការបង្រៀនក្រៅផ្លូវការទៅតាមប្រធានបទ។
- ពិចារណាលើកិច្ចខិតខំប្រឹងប្រែងអប់រំពីផ្ទះមួយទៅផ្ទះមួយ តាមរយៈការប្រើប្រាស់ខិត្តប័ណ្ណចែកជូន ឬវិធីសាស្ត្រស្ទង់មតិតាមផ្ទះ។
- កំណត់អត្តសញ្ញាណសង្កាត់ ពលរដ្ឋ ឬសហគមន៍ដែលនៅជុំវិញទីតាំងគម្រោង ដែលអាចរងផលប៉ះពាល់ និងពិចារណាការផ្សព្វផ្សាយទៅកាន់គោលដៅ និងយុទ្ធសាស្ត្រនៃការចូលរួម ដែលដឹកនាំនៅតំបន់ទាំងនោះ
- បង្កើតបណ្តាញព័ត៌មានក្នុងមូលដ្ឋានដែលមានភាពងាយស្រួល និងអាចចូលទៅមើលបានសម្រាប់ក្រុមប្រជាជនយុត្តិធម៌បរិស្ថាន ដែលនៅទីនោះអាចប្រមូលព័ត៌មានដែលទាក់ទងនឹងគម្រោងបាន

### ការវិភាគផលប៉ះពាល់លើក្រុមប្រជាជនយុត្តិធម៌បរិស្ថានដែលធ្វើឱ្យប្រសើរឡើង

តាមការតម្រូវដោយច្បាប់ផែនទីបង្ហាញផ្លូវអាកាសធាតុ ការិយាល័យ MEPA ក៏នឹងពង្រីកការត្រួតពិនិត្យគម្រោងនៅក្នុង ឬនៅជិតក្រុមប្រជាជនយុត្តិធម៌បរិស្ថាន និងការវិភាគផលប៉ះពាល់លើក្រុមប្រជាជនយុត្តិធម៌បរិស្ថានដែលធ្វើឱ្យប្រសើរឡើង។ សម្រាប់គម្រោងដែលស្ថិតក្រោមដែនយុត្តាធិការរបស់ MEPA ដែលបំពេញតាម ឬលើសពីកម្រិតត្រួតពិនិត្យរបស់ MEPA ច្បាប់ផែនទីបង្ហាញផ្លូវអាកាសធាតុ តម្រូវឱ្យមានការរៀបចំរបាយការណ៍អំពីផលប៉ះពាល់បរិស្ថាន (EIR) ប្រសិនបើគម្រោងនោះមានទីតាំងក្នុងចម្ងាយ 1 ម៉ាយពីក្រុមប្រជាជនយុត្តិធម៌បរិស្ថាន ឬ 5 ម៉ាយ ប្រសិនបើគម្រោងនឹងបង្កផលប៉ះពាល់ដល់គុណភាពខ្យល់។ ស្ថិតក្រោមបទបញ្ញត្តិដែលបានស្នើថ្មី គម្រោងណាមួយនឹងត្រូវកំណត់ថាបង្កផលប៉ះពាល់ដល់គុណភាពខ្យល់ ប្រសិនបើគម្រោងនោះបំពេញតាមកម្រិត ឬលើសពីកម្រិតនៃការត្រួតពិនិត្យរបស់ MEPA ស្ថិតក្រោម 301 CMR 11.03(8)(a)-(b) ឬបង្កើតឱ្យមានការធ្វើដំណើរប្រចាំថ្ងៃជាមធ្យមពី 150 ដង ឬច្រើនជាងនេះ នៃចរាចរណ៍យានជំនិះប្រើឥន្ធនៈក្នុងអំឡុងពេល 1 ឆ្នាំ ឬច្រើនជាង។

ស្របតាមច្បាប់ផែនទីបង្ហាញផ្លូវអាកាសធាតុ របាយការណ៍ EIR ដែលប្រគល់ជូនសម្រាប់គម្រោងណាមួយដែលមានទីតាំងចម្ងាយ 1 ឬ 5 ម៉ាយពីក្រុមប្រជាជនយុត្តិធម៌បរិស្ថាន ត្រូវរួមបញ្ចូលការវាយតម្លៃ "បន្ទុកបរិស្ថានមិនយុត្តិធម៌ ឬមិនស្មើភាពគ្នា និងផលប៉ះពាល់សុខភាពសាធារណៈ" ដែលមានស្រាប់ ដែលក្រុមប្រជាជនយុត្តិធម៌បរិស្ថានកំពុងរងការប៉ះពាល់។ របាយការណ៍ EIR ក៏ត្រូវធ្វើការវិភាគពីផលប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សុខភាពសាធារណៈនៃគម្រោងនោះផងដែរ ដើម្បីកំណត់ថាតើគម្រោងនោះនឹងមាន "ផលប៉ះពាល់ធ្ងន់ធ្ងរមិនសមាមាត្រគ្នា" ដល់ប្រជាជនយុត្តិធម៌បរិស្ថាន ឬបង្កើន ឬបន្ថយហានិភ័យនៃបម្រែបម្រួលអាកាសធាតុ។

ការិយាល័យ MEPA បានកំណត់វិធីសាស្ត្រនៅក្នុងសេចក្តីណែនាំសម្រាប់ការធ្វើការវាយតម្លៃដូចបានរៀបរាប់ខាងលើនេះ។ ក្នុងការសម្របសម្រួលជាមួយប្រធានយុត្តិធម៌បរិស្ថានរបស់ EEA ការិយាល័យ MEPA បានប្រឹក្សាយោបល់ជាមួយទីភ្នាក់ងារ និងការិយាល័យសំខាន់ៗជាមួយជំនាញឯកទេសពាក់ព័ន្ធនឹងការវិភាគផលប៉ះពាល់យុត្តិធម៌បរិស្ថាន និងផលប៉ះពាល់សុខភាពសាធារណៈ រួមមាន នាយកដ្ឋានការពារបរិស្ថានរដ្ឋម៉ាសាជូសេត (MassDEP) នាយកដ្ឋានសុខភាពសាធារណៈរដ្ឋម៉ាសាជូសេត (DPH) អាជ្ញាធរធនធានទឹករដ្ឋម៉ាសាជូសេត ( MWRA) ការិយាល័យជំនួយបច្ចេកទេស (OTA) ការិយាល័យគ្រប់គ្រងតំបន់ឆ្នេររដ្ឋម៉ាសាជូសេត (CZM) និងក្រុមអាកាសធាតុរបស់ EEA។ ការិយាល័យ MEPA ក៏បានស្វែងរក និងបន្តស្វែងរកមតិចូលរួមពីភាគីពាក់ព័ន្ធពីខាងក្រៅជាច្រើនទៀត តាមរយៈគណៈកម្មការប្រឹក្សាយោបល់សមាជិក 20+ ដែលបានបង្កើតឡើងក្នុងឆ្នាំ2021។

### ការទទួលបានសេវាភាសា

ការិយាល័យ MEPA ប្តេជ្ញាចិត្តក្នុងការពង្រីកការទទួលបានសេវាភាសា និងសេវាកម្មបកប្រែឯកសារ/បកប្រែផ្ទាល់មាត់សម្រាប់ចំណាត់ការសំខាន់ៗដែលធ្វើឡើងដោយការិយាល័យនេះ។ ដូចបានកត់ចំណាំពីខាងលើ ការិយាល័យ MEPA បានចេញផ្សាយពិធីសារនៃការពាក់ព័ន្ធជាសាធារណៈក្នុងយុត្តិធម៌បរិស្ថាន ដែលនឹងរួមបញ្ចូលនូវព័ត៌មានស្តីពីរបៀបក្នុងការកំណត់ពីភាសាដែលពាក់ព័ន្ធសម្រាប់គោលបំណងនៃការផ្តល់សេវាបកប្រែឯកសារ និងបកប្រែផ្ទាល់មាត់។ សេវា

ភាសាទាំងនេះ នឹងអនុវត្តចំពោះការជូនដំណឹង ឯកសារ និងកិច្ចប្រជុំសហគមន៍ ដែលពាក់ព័ន្ធនឹងគម្រោងដែលបានស្នើសុំ។ ការិយាល័យ MEPA ក៏មានបំណងក្នុងការស្វែងរកដំណោះស្រាយ IT ដើម្បីសម្របសម្រួលដល់ការទទួលបានសេវាភាសាផងដែរ ដូចជាការទិញគណនេយ្យ Zoom ដែលអនុញ្ញាតឱ្យកន្លែងសម្រាប់បកប្រែ និងរុករកការប្រើប្រាស់សេវាបកប្រែនៅតាមអនឡាញ។ ការិយាល័យ MEPA ប្ដេជ្ញាចិត្តក្នុងការធានានូវសេវាបកប្រែ "តាមការស្នើសុំ" សម្រាប់កិច្ចការប្រចាំថ្ងៃ មិនថាធ្វើឡើងដោយឯករាជ្យ ឬដោយមានទីភ្នាក់ងារ ឬអង្គភាព EEA នោះទេ។

ឯកសារជាលាយលក្ខណ៍អក្សរខាងក្រោមដែលបង្កើតឡើងដោយការិយាល័យ MEPA នេះ ផ្តល់ឱកាសឱ្យសេវាបកប្រែជួយដល់អ្នកដែលមានសមត្ថភាពចំណេះដឹងភាសាអង់គ្លេសមានកម្រិត ដើម្បីចូលរួមយ៉ាងពេញលេញក្នុងដំណើរការរបស់ MEPA៖

| | **ឯកសារ** | **អង្គភាព ទទួលខុសត្រូវ** |
|---|---|---|
| **1** | សម្ភារៈប្រើប្រាស់សម្រាប់ការប្រកាសការផ្សព្វផ្សាយ និងការចូលរួមរបស់សហគមន៍ (រួមមានខ្លឹមសារសង្ខេបរបស់គម្រោងជាលាយលក្ខណ៍អក្សរ) | អ្នកស្នើ |
| **2** | ទម្រង់បែបបទជូនដំណឹងខាងបរិស្ថាន (ENF ឬការដាក់គម្រោង) ដាក់ជូនទៅការិយាល័យ MEPA | អ្នកស្នើ |
| **3** | ការជូនដំណឹងអំពីគម្រោងដែលបានចុះផ្សាយក្នុង ការតាមដានបរិស្ថាន (ឯកសារបោះពុម្ពផ្សាយ គ្រប់គ្រងដោយការិយាល័យ MEPA) | MEPA |
| **4** | កាលបរិច្ឆេទក្រោយ/ពេលវេលា/ទីកន្លែងនៃ ការចុះពិនិត្យទីតាំង នៅក្នុងការតាមដានបរិស្ថាន | MEPA |
| **5a** | ព័ត៌មានបន្ថែមដាក់ជូនទៅកាន់ការិយាល័យ MEPA *(ប្រសិនបើអនុវត្តបាន)* | អ្នកស្នើ |
| **5b** | ការជូនដំណឹងតាមអ៊ីម៉ែលអំពីការពន្យារពេលផ្តល់មតិយោបល់ និងព័ត៌មានបន្ថែមដាក់ជូនទៅកាន់ទីភ្នាក់ងារ/ទីក្រុង/អង្គការតាមសហគមន៍/បុគ្គល ដែលបានចូលរួមពិនិត្យទីតាំង *(ប្រសិនបើអនុវត្តបាន)* | MEPA |
| **6** | ចេញវិញ្ញាបនបត្រ MEPA និងចុះផ្សាយក្នុងការតាមដានបរិស្ថាន | MEPA |
| **7** | ចេញវិធានប្រឹក្សារបស់ MEPA | MEPA |
| **8** | ចេញការកំណត់សុវត្ថិភាពមិនងាយខូចខាតរបស់ MEPA | MEPA |

## កិច្ចខិតខំសម្រាប់ការចូលរួមជាសាធារណៈពីការិយាល័យ MEPA

បន្ថែមពីលើការតម្រូវឱ្យកិច្ចខិតខំសម្រាប់ការចូលរួមជាសាធារណៈដែលបានធ្វើឱ្យប្រសើរឡើងដោយអ្នកស្នើគម្រោង ការិយាល័យ MEPA ប្តេជ្ញាចិត្តក្នុងការកែលម្អការចូលរួមផ្ទាល់ខ្លួនជាមួយក្រុមប្រជាជនយុត្តិធម៌បរិស្ថាន ក្នុងពេលនៃការអនុវត្តសកម្មភាពរបស់ទីភ្នាក់ងារនៅក្រៅការត្រួតពិនិត្យគម្រោងដាច់ដោយឡែក។ កិច្ចខិតខំប្រឹងប្រែងបន្ថែមដែលត្រូវពិចារណាដោយការិយាល័យ MEPA រួមមានដូចខាងក្រោម៖

- ក្នុងការប្រឹក្សាយោបល់ជាមួយ EEA ប្រធានយុត្តិធម៌បរិស្ថានរក្សាបញ្ជី CBO និងកុលសម្ព័ន្ធដែលបានធ្វើបច្ចុប្បន្នភាពរួច ដើម្បីផ្តល់ធនធានសម្រាប់អ្នកស្នើគម្រោង។
- ធ្វើការបណ្តុះបណ្តាលពេលវេលា និង/ឬបទបង្ហាញដល់សាធារណជន (ដោយមានវីដេអូថតទុក ដែលអាចឱ្យអ្នកដែលមិនបានចូលរួមចូលទៅមើលបាន) ដោយមានការផ្សព្វផ្សាយច្រើនទៅដល់ក្រុមប្រជាជនយុត្តិធម៌បរិស្ថាន ពាក់ព័ន្ធនឹងគោលបំណង និងវិធីរបស់ MEPA ដើម្បីធ្វើការចូលរួមប្រកបដោយអត្ថន័យខ្លឹមសារ និងបង្កើតឥទ្ធិពលដល់ដំណើរការ MEPA។ ការបណ្តុះបណ្តាលនេះនឹងត្រូវរៀបចំដោយមានការប្រឹក្សាយោបល់ជាមួយប្រធានយុត្តិធម៌បរិស្ថានរបស់ EEA។
- ស្វែងរកការធ្វើឱ្យប្រសើរឡើងនូវគេហទំព័របញ្ចេញមតិជាសាធារណៈរបស់ MEPA ដើម្បីអនុញ្ញាតឱ្យមានការដាក់សំណើដើម្បីទទួលបានការជូនដំណឹងជាបន្តបន្ទាប់អំពីការអភិវឌ្ឍគម្រោង
- ធ្វើការកែប្រែទម្រង់បែបបទនៃការជូនដំណឹងបរិស្ថាន (ENF) ដើម្បីដាក់បញ្ចូលលក្ខខណ្ឌតម្រូវនៃការចូលរួមជាសាធារណៈក្នុងចលនាយុត្តិធម៌បរិស្ថាន។
- ធ្វើបច្ចុប្បន្នភាពគេហទំព័ររបស់ MEPA និងធ្វើយ៉ាងណាឱ្យសហគមន៍នៅទូទាំងខំមិនវែលទាំងមូលអាចចូលទៅមើលបាន។

ការិយាល័យ MEPA នឹងអនុវត្តតាមលក្ខខណ្ឌតម្រូវនៃផែនការចូលរួមជាសាធារណៈ (PIP) ដែលពាក់ព័ន្ធនឹងប្រតិបត្តិការផ្ទៃក្នុងរបស់ MEPA។ ដោយពាក់ព័ន្ធនឹងការត្រួតពិនិត្យគម្រោង ពិធីសារនៃការចូលរួមជាសាធារណៈរបស់ MEPA (អនុវត្តចំពោះអ្នកស្នើគម្រោង) ត្រូវប្រើឱ្យត្រូវតាមលក្ខខណ្ឌតម្រូវនៃផែនការ PIP របស់ EEA។

## ការបណ្តុះបណ្តាល និងការជួលបុគ្គលិក

ការិយាល័យ MEPA ប្តេជ្ញាចិត្តក្នុងការផ្តល់ការបណ្តុះបណ្តាលបុគ្គលិកដើម្បីធានាថា អ្នកវិភាគ និងបុគ្គលិក យល់ពីយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់ MEPA និងបទបញ្ញត្តិ និងសេចក្តីណែនាំដែលពាក់ព័ន្ធ ដើម្បីឱ្យពួកគេអាចអនុវត្តលក្ខខណ្ឌតម្រូវយុត្តិធម៌បរិស្ថានដោយខ្លួនឯងបានក្នុងអំឡុងដំណើរការនៃការត្រួតពិនិត្យ MEPA។ ការបណ្តុះបណ្តាលបែបនេះ នឹងត្រូវធ្វើឡើងជាចាំបាច់ ដោយរួមបញ្ចូលការណែនាំដោយផ្ទាល់ ហើយត្រូវឆ្លុះបញ្ចាំងនៅក្នុងការវាយតម្លៃបុគ្គលិកដើម្បីធានានូវការបញ្ចប់ការបណ្តុះបណ្តាល។

បន្ថែមលើនេះ ការិយាល័យ MEPA នឹងធ្វើការជាមួយការិយាល័យធនធានមនុស្សរបស់ EEA ដើម្បីជំរុញពិពិធភាពក្នុងការជួល និងការអនុវត្តការដំឡើងតំណែង។ MEPA ទទួលស្គាល់ពីសារៈសំខាន់នៃការមានកម្លាំងទីភ្នាក់ងារមួយដែលឆ្លុះបញ្ចាំងពីពិពិធភាពសង្គម-សេដ្ឋកិច្ច ជាតិសាសន៍ និងពូជសាសន៍នៃប្រជាជនក្នុងរដ្ឋម៉ាសាជូសេត រួមទាំងតួនាទីសំខាន់ដែល

កម្លាំងនេះដើរតួក្នុងការធ្វើឱ្យប្រសើរឡើងនូវការធ្វើសេចក្តីសម្រេចចិត្តដែលមានសមភាព ពាក់ព័ន្ធនឹងការផ្តល់លិខិតអនុញ្ញាតបរិស្ថាន និងថាមពល កំណត់ទីតាំង និងការបង្កើតបទបញ្ញត្តិ។ MEPA ប្តេជ្ញាចិត្តថានឹងរួមបញ្ចូលការអនុវត្តការជ្រើសរើសបុគ្គលិកដែលមានពិពិធភាព ដោយរួមបញ្ចូលទាំងការប្រើប្រាស់លក្ខខណ្ឌវិនិច្ឆ័យក្នុងមុខតំណែងការងារ ដែលតម្រូវឱ្យបេក្ខជនជាប់ជាស្ថាពរបង្ហាញពីចំណេះដឹងនិងការយល់ដឹងពាក់ព័ន្ធនឹងតម្រូវការរបស់ប្រជាជនងាយរងគ្រោះ សង្កាត់យុត្តិធម៌បរិស្ថាន និងតំបន់ដែលទទួលបានសេវាកម្មមិនជិតដល់។

### ខ្នាតរង្វាស់

ដោយមានការតម្រូវនៅក្នុងគោលនយោបាយយុត្តិធម៌បរិស្ថានរបស់ EEA (ធ្វើបច្ចុប្បន្នភាពឆ្នាំ2021) នឹងបង្កើតខ្នាតរង្វាស់ ដើម្បីតាមដានវឌ្ឍនភាពយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន ដែលមានចែងនៅក្នុងឯកសារនេះ។ នៅក្នុងឆ្នាំដំបូង ខ្នាតរង្វាស់នេះ នឹងផ្តោតសំខាន់លើវឌ្ឍនភាពក្នុងការអនុវត្តតាមលក្ខខណ្ឌតម្រូវប្រកបដោយជោគជ័យនូវច្បាប់ផែនទីបង្ហាញផ្លូវអាកាសធាតុ ហើយនឹងរួមបញ្ចូលតាមសមិទ្ធិលទ្ធភាពនូវ៖

- ចំនួនគម្រោង MEPA ដែលមានចម្ងាយក្នុងរង្វង់ 1 និង 5 ម៉ាយ ពីក្រុមប្រជាជនយុត្តិធម៌បរិស្ថាន រួមគ្នាជាមួយការបំបែក “ENF” និងគម្រោង “EIR ដែលចាំបាច់”
- ចំនួនគម្រោង MEPA ដែលបានអនុវត្តកិច្ចខិតខំប្រឹងប្រែងសម្រាប់ការចូលរួមពីសហគមន៍
- ចំនួនគម្រោង MEPA ដែលផ្តល់ការបន្ធូរបន្ថយផលប៉ះពាល់ជាក់លាក់លើផលប៉ះពាល់យុត្តិធម៌បរិស្ថាន
- ចំនួនគម្រោង MEPA ដែលផ្តល់សេវាភាសា

ការិយាល័យ MEPA នឹងធ្វើការពិចារណាអំពីខ្នាតរង្វាស់បន្ថែម ដើម្បីតាមដានពីវឌ្ឍនភាពផ្ទាល់ខ្លួនក្នុងការអនុវត្តយុទ្ធសាស្ត្រនេះ រួមមាន៖

- ចំនួន និងប្រភេទឯកសារដែលបង្កើតឡើងដោយការិយាល័យ MEPA ដែលត្រូវធ្វើការបកប្រែ
- ចំនួននៃការបណ្តុះបណ្តាលយុត្តិធម៌បរិស្ថានដែលធ្វើឡើងសម្រាប់បុគ្គលិក
- ចំនួននៃការបណ្តុះបណ្តាលសាធារណៈ ឬសិក្ខាសាលាដែលបានថតទុក ឬផលិតឡើងពាក់ព័ន្ធនឹងនីតិវិធី និងវិធីត្រួតពិនិត្យ MEPA ដើម្បីចូលរួមក្នុងការត្រួតពិនិត្យរបស់ MEPA

## ការអនុវត្តយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់ការិយាល័យប្រតិបត្តិផ្នែកថាមពល និងកិច្ចការបរិស្ថាន

ពាក់ព័ន្ធនឹងក្តីបារម្ភ ពាក្យបណ្តឹង ការបំពេញបន្ថែម ឬគំនិតផ្សេងៗពាក់ព័ន្ធនឹងយុត្តិធម៌បរិស្ថាន ឬដើម្បីស្វែងយល់បន្ថែមអំពីកិច្ចខិតខំប្រឹងប្រែងផ្នែកយុត្តិធម៌បរិស្ថានថាមពល និងអាកាសធាតុរបស់ទីភ្នាក់ងារយើង សូមទាក់ទងការិយាល័យយុត្តិធម៌បរិស្ថានរបស់ EEA ដែលមានចែងនៅទំព័រទី 19 នៃយុទ្ធសាស្ត្របរិស្ថានរបស់ EEA។

## ព័ត៌មានទំនាក់ទំនងផ្នែកយុត្តិធម៌បរិស្ថានរបស់ MEPA៖

Tori Kim
ជំនួយការលេខា/ប្រធាន MEPA
Tori.Kim@mass.gov

(857) 207-2996

ឬ

Page Czepiga
ជំនួយការប្រធាន MEPA
Page.Czepiga@mass.gov
(857) 408-7049

# ការិយាល័យជំនួយបច្ចេកទេសរដ្ឋម៉ាសាជូសេត

OFFICE OF TECHNICAL ASSISTANCE & TECHNOLOGY

## យុទ្ធសាស្រ្តយុត្តិធម៌បរិស្ថាន

ព្រាង

# តារាងមាតិកា

**ការិយាល័យជំនួយបច្ចេកទេសរដ្ឋម៉ាសាជូសេត ....... 53**

សេចក្តីថ្លែងការណ៍បេសកកម្ម និងសាវតាររបស់ OTA ....... 55

លក្ខខណ្ឌយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន (EJ) របស់លេខាធិការដ្ឋានពីគោលនយោបាយ EEA EJ .55

យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន ....... 55

*សកម្មភាពសំខាន់ៗរបស់ទីភ្នាក់ងារ ....... 56*

*ការកាត់បន្ថយការប្រើប្រាស់សារធាតុពុលទូទាំងរដ្ឋ ....... 56*

*សកម្មភាពជំនួយបច្ចេកទេស ....... 57*

*ការផ្សព្វផ្សាយទូទៅ ....... 58*

*សុវត្ថិភាពគីមី & ភាពធន់នឹងបម្រែបម្រួលអាកាសធាតុ៖ ....... 59*

*ការបញ្ជូនការស្រាវជ្រាវ/ពិសោធន៍/ផ្តល់ជំនួយ TURI បន្ត ....... 60*

*សមិទ្ធផលរបស់ OTA ក្នុងឆ្នាំកន្លងមក ....... 60*

*ផែនការអនាគតសម្រាប់សកម្មភាពបន្ថែម ....... 61*

*ការទំនាក់ទំនង ....... 62*

*ការប្តេជ្ញាចិត្តរបស់ OTA លើការជួលបុគ្គលិកថ្មី ....... 63*

ការអនុវត្តយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់ការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន ....... 63

# ការិយាល័យជំនួយបច្ចេកទេសរដ្ឋម៉ាសាជូសេត (OTA)

## សេចក្តីថ្លែងការណ៍បេសកកម្ម និងសាវតាររបស់ OTA

ការិយាល័យជំនួយបច្ចេកទេសរដ្ឋម៉ាសាជូសេត (OTA) គឺជាទីភ្នាក់ងារទូទាំងរដ្ឋនៅក្នុងការិយាល័យប្រតិបត្តិកិច្ចការថាមពល និងបរិស្ថាន (EEA) ដែលត្រូវបានបង្កើតឡើងដោយ និងជាទីភ្នាក់ងារមួយក្នុងចំណោមភ្នាក់ងារទាំងបីដែលអនុវត្ត ច្បាប់កាត់បន្ថយការប្រើប្រាស់ជាតិពុល (TURA)។ តួនាទីរបស់ OTA គឺផ្តល់ការបង្ការការបំពុលដោយឥតគិតថ្លៃ និងដោយរក្សាការសម្ងាត់ និងផ្តល់ជំនួយក្នុងការកាត់បន្ថយការប្រើប្រាស់សារធាតុពុលដល់អាជីវកម្មផ្សេងៗក្នុងរដ្ឋម៉ាសាជូសេត។ ទីភ្នាក់ងារជាប្អូនស្រីរបស់យើង គឺ វិទ្យាស្ថានកាត់បន្ថយការប្រើប្រាស់សារធាតុពុល (TURI) នៅ UMass Lowell ដែលត្រូវបានបង្កើតឡើងដោយ TURA ក៏មានផ្តល់ឱ្យសហគមន៍និង អ្នកប្រើប្រាស់ជាតិពុល នូវការស្រាវជ្រាវ សេវាមន្ទីរពិសោធន៍ និងជំនួយសហគមន៍/ឧស្សាហកម្ម/អាជីវកម្មខ្នាតតូច សម្រាប់កិច្ចខិតខំប្រឹងប្រែង កាត់បន្ថយការប្រើប្រាស់សារធាតុពុល។ MassDEP គឺជាផ្នែកគ្រប់គ្រង និងអនុវត្តច្បាប់របស់ TURA។ ទីភ្នាក់ងារទាំងនេះធ្វើការរួមគ្នាក្នុងភាពជាដៃគូដើម្បីអនុវត្តកម្មវិធី TURA និងកាត់បន្ថយការប្រើប្រាស់សារធាតុគីមីពុលនៅក្នុងសហគមន៍ ខំមិនវែល។ អ្នករៀបចំឯកសារ TURA ជាច្រើន និងអ្នកប្រើប្រាស់សារធាតុពុលដទៃទៀត មានទីតាំងនៅក្នុងសហគមន៍យុត្តិធម៌បរិស្ថាន។

## លក្ខខណ្ឌយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន (EJ) របស់លេខាធិការដ្ឋានពីគោលនយោបាយ EEA EJ

ការិយាល័យប្រតិបត្តិកិច្ចការថាមពល និងបរិស្ថាន (EEA) គោលនយោបាយយុត្តិធម៌បរិស្ថាន (EJ) ឆ្នាំ2017 បានដឹកនាំទីភ្នាក់ងារ EEA ទាំងអស់អនុវត្តយុទ្ធសាស្ត្រ EJ ផ្ទាល់ខ្លួនរបស់ពួកគេ។ ទីភ្នាក់ងារ EEA ត្រូវពិចារណាថាតើត្រូវរួមបញ្ចូលការគិតគូរពីយុត្តិធម៌បរិស្ថានទៅក្នុងនាយកដ្ឋានរបស់ពួកគេ តាមរយៈគោលនយោបាយ កម្មវិធី ឬយុទ្ធសាស្ត្រដទៃទៀត ដោយរបៀបណា។ ទីភ្នាក់ងារ EEA ត្រូវកំណត់អត្តសញ្ញាណ និងជំរុញគម្រោងដែលមានការឧបត្ថម្ភពីទីភ្នាក់ងារ ដោយផ្តល់ប្រាក់ឧបត្ថម្ភដល់ការធ្វើសេចក្តីសម្រេចចិត្ត ការកំណត់វិធាន ឬចំណាត់ការដទៃទៀត ដែលមានបំណងក្នុងការលើកកម្ពស់យុត្តិធម៌បរិស្ថានបន្ថែមទៀតនៅទូទាំងខំមិនវែលទាំងមូល ដើម្បីបង្ហាញពីរបៀបនៃការវាស់វែងការបែងចែកអត្ថប្រយោជន៍ដែលត្រឹមត្រូវ។

## យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន

OTA ផ្តល់នូវការបង្ការការបំពុលដោយឥតគិតថ្លៃ និងរក្សាការសម្ងាត់ និងជំនួយកាត់បន្ថយការប្រើប្រាស់សារធាតុពុលដល់អាជីវកម្មផ្សេងៗនៅក្នុងរដ្ឋម៉ាសាជូសេត ដោយកំណត់នូវឱកាសដើម្បីកាត់បន្ថយការប្រើប្រាស់សារធាតុពុល និងកាកសំណល់ ដោយកំណត់វិធីអភិរក្សថាមពល និងធនធានផ្សេងទៀត និងដោយផ្តល់ជំនួយដល់ក្រុមហ៊ុននានាក្នុងការអនុលោមតាមបទបញ្ញត្តិ។

ការកាត់បន្ថយវត្ថុមានសារធាតុគីមីពុលក្នុងផលិតកម្ម ផ្តល់អត្ថប្រយោជន៍ដល់សហគមន៍ដែលរោងចក្រទាំងនេះស្ថិតនៅ។ ក្នុងឆ្នាំ2019 ចំនួន 44% នៃក្រុមហ៊ុនផលិត និងអាជីវកម្មដែល OTA បានផ្តល់ជំនួយបច្ចេកទេសគឺស្ថិតនៅក្នុង ឬនៅក្នុងចម្ងាយប្រមាណជាកន្លះម៉ាយ នៃសហគមន៍ EJ។ ដើម្បីផ្តល់ធនធានឱ្យកាន់តែមានប្រសិទ្ធភាពសម្រាប់សហគមន៍ទាំងនេះ OTA នឹងរួមបញ្ចូលគោលការណ៍ EJ នៅទូទាំងកម្មវិធី ការផ្សព្វផ្សាយ និងគំនិតផ្តួចផ្តើមជាយុទ្ធសាស្ត្ររបស់ខ្លួន។ ការងាររបស់ OTA នឹងរួមបញ្ចូលការចូលមើលគេហទំព័ររបស់ក្រុមហ៊ុន ដើម្បីផ្តល់ឱ្យក្រុមហ៊ុនដែលមានស្រាប់នៅជិតៗ EJ នូវជំនួយបច្ចេកទេសដើម្បីអភិរក្សថាមពល និងធនធាន ហើយ កាត់បន្ថយការប្រើប្រាស់សារធាតុ និងកាកសំណល់ពុល ព្រមទាំងណែនាំ ឬពង្រីកអាជីវកម្មថ្មីៗដែលស្វែងរកការអនុញ្ញាតថ្មី ឬការចាប់ផ្តើមប្រតិបត្តិការផលិតកម្មថ្មី ដើម្បីពិចារណាដល់ការទប់ស្កាត់ការបំពុល និងការអភិរក្សធនធាន ខណៈពេលដែលគម្រោងនានាកំពុងស្ថិតក្នុងដំណាក់កាលធ្វើផែនការនៅឡើយ។ សេវាកម្មរបស់ OTA ផ្តល់អត្ថប្រយោជន៍ដល់សហគមន៍ EJ ដោយការកែលម្អសុខភាពសាធារណៈ និងការបង្កើនសុវត្ថិភាពបរិស្ថាន សម្រាប់អ្នកប្រើប្រាស់សារធាតុពុលតាមរយៈសកម្មភាពដូចខាងក្រោម៖

- កំណត់ឱកាសដើម្បីកាត់បន្ថយហានិភ័យដែលទាក់ទងនឹងការប្រើប្រាស់ ការផលិត និងការកែច្នៃសារធាតុគីមីគ្រោះថ្នាក់។
- កំណត់អត្តសញ្ញាណ និងវាយតម្លៃដំណើរការ និងគីមីសាស្ត្រដែលមានសុវត្ថិភាពជាងមុន។
- កំណត់អត្តសញ្ញាណ និងចូលប្រើឧបករណ៍ ធនធាន និងគ្រឿងលើកទឹកចិត្តរដ្ឋ និងសហព័ន្ធ។
- ដោះស្រាយបញ្ហាសុវត្ថិភាពដែលអាចកើតមាន និងលើកកម្ពស់ការអនុលោមតាមបទបញ្ញត្តិផ្សេងៗ។
- កាត់បន្ថយការប៉ះពាល់របស់និយោជិតទៅនឹងសារធាតុគីមីគ្រោះថ្នាក់ និងផ្តល់កន្លែងធ្វើការដែលមានសុវត្ថិភាពជាងមុន។
- បង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ថាមពលដំណើរការ។
- អនុវត្តប្រតិបត្តិការ និងការថែទាំល្អបំផុត ដើម្បីអភិរក្សទឹកនិងសម្ភារៈផ្សេងៗទៀត។
- អនុវត្តការកាត់បន្ថយការប្រើប្រាស់សារធាតុពុល ដើម្បីកាត់បន្ថយហានិភ័យនៃឧបទ្ទវហេតុឧស្សាហកម្មធ្ងន់ធ្ងរដែលទាក់ទងនឹងអាកាសធាតុនៅក្នុងតំបន់ងាយរងគ្រោះពីបម្រែបម្រួលអាកាសធាតុ ដែលជារឿយៗកើតឡើងដោយឥតព្រាងទុកចំពោះសហគមន៍យុត្តិធម៌បរិស្ថាន។

## សកម្មភាពសំខាន់ៗរបស់ទីភ្នាក់ងារ

OTA មានការប្តេជ្ញាចិត្តជាបន្តបន្ទាប់ក្នុងការជំរុញ EJ នៅក្នុងការងាររបស់យើង ហើយផ្តោតលើវិស័យអាទិភាពដូចខាងក្រោម៖

### ការកាត់បន្ថយការប្រើប្រាស់សារធាតុពុលទូទាំងរដ្ឋ

បច្ចុប្បន្ន OTA ធ្វើការនៅក្នុងសហគមន៍ EJ ដោយសារតែសហគមន៍ទាំងនេះមានបន្ទុកអសមាមាត្រជាមួយនឹងសារធាតុពុល និងការប៉ះពាល់នឹងសារធាតុគីមី។

OTA នឹងផ្តល់អាទិភាពដល់ការផ្សព្វផ្សាយដល់អ្នកប្រើប្រាស់សារធាតុពុលនៅក្នុង និងនៅជិតសហគមន៍ EJ ហើយផ្តល់ការបន្តផ្តល់ធនធានផ្សេងៗ។ OTA នឹងកត់សម្គាល់ពីភាពជោគជ័យនៃការកាត់បន្ថយការប្រើប្រាស់សារធាតុពុលនៅក្នុងតំបន់ EJ ហើយនឹងបន្តស្វែងរកឱកាសក្នុងការអភិវឌ្ឍន៍ករណីសិក្សា និងធនធានផ្សេងទៀតដែលទាក់ទងនឹងភាពជោគជ័យទាំងនេះ ដែលអាចធ្វើជាគំរូសម្រាប់គ្រឿងបរិក្ខារនៅក្នុងសហគមន៍ EJ ផ្សេងទៀត។ OTA ក៏នឹងធ្វើការផ្សព្វផ្សាយទៅកាន់កន្លែងនានាដែលស្ថិតនៅក្នុង ឬនៅជិតតំបន់ EJ ដើម្បីជួយគាំទ្របន្ថែមដល់ការកាត់បន្ថយការប្រើប្រាស់សារធាតុពុលនៅក្នុងតំបន់ទាំងនេះ ជាពិសេសនៅក្នុងការកំណត់ទីកន្លែង ដែលមានឱកាសច្បាស់លាស់សម្រាប់ការកាត់បន្ថយការប្រើប្រាស់សារធាតុពុល ឬកន្លែងដែលបង្ហាញចំណាប់អារម្មណ៍ ឬមានតម្រូវការសម្រាប់ កាត់បន្ថយការប្រើប្រាស់សារធាតុពុល។

### សកម្មភាពជំនួយបច្ចេកទេស

មុនពេល OTA ធ្វើទស្សនកិច្ចនៅក្រុមហ៊ុនមួយ សមាជិកបុគ្គលិក OTA ដែលជួយក្រុមហ៊ុន ផ្ញើកម្រងសំណួរជាមុនទៅកាន់បណ្តាញទំនាក់ទំនងរបស់ក្រុមហ៊ុន ដើម្បីប្រមូលព័ត៌មានមូលដ្ឋានអំពីកន្លែងនោះ។ OTA នឹងធ្វើវិសោធនកម្មកម្រងសំណួរនេះដើម្បីបន្ថែមសំណួរវាយតម្លៃការយល់ដឹងរបស់ក្រុមហ៊ុនអំពីយុត្តិធម៌បរិស្ថាន និងវិសាលភាព អាទិភាពរបស់ក្រុមហ៊ុនដែលមានស្រាប់រួមបញ្ចូលជាមួយ EJ (ឧទាហរណ៍ ថាតើក្រុមហ៊ុនមានយុត្តិធម៌បរិស្ថានដែលមានស្រាប់ ការចូលរួមក្នុងសហគមន៍ ទំនួលខុសត្រូវសង្គមរួម ឬសេចក្តីថ្លែងការណ៍អំពីការគ្រប់គ្រងបរិស្ថានដែរឬទេ)។ ប្រសិនបើយុត្តិធ៌មបរិស្ថាន (ច្បាស់លាស់ ឬដោយប្រយោល) ជាអាទិភាពដែលមានស្រាប់សម្រាប់ក្រុមហ៊ុន តាមរយៈនេះវានឹងផ្តល់ឱកាសមួយសម្រាប់បុគ្គលិក OTA ដើម្បីបង្កើតអនុសាសន៍របស់ខ្លួននៅក្នុង បរិបទនៃអាទិភាពដែលមានស្រាប់របស់ក្រុមហ៊ុនទាក់ទងនឹងយុត្តិធម៌បរិស្ថាន។ ប្រសិនបើ EJ មិនមែនជាអាទិភាពរបស់ក្រុមហ៊ុនទេនោះ ក្នុងអំឡុងពេលចូលរួមរបស់ OTA ជាមួយក្រុមហ៊ុន បុគ្គលិក OTA នឹងផ្តល់ ព័ត៌មានបន្ថែមអំពីទំនាក់ទំនងរវាងការកាត់បន្ថយការប្រើប្រាស់សារធាតុពុល និងយុត្តិធម៌បរិស្ថាន។ ក្នុងករណីទាំងពីរ OTA នឹងពិចារណា ហើយបញ្ចូលគោលការណ៍ EJ ទៅក្នុងជំនួយនិងអនុសាសន៍របស់ខ្លួន។

ក្រុមហ៊ុននីមួយៗដែល OTA ចុះទៅត្រួតពិនិត្យ ទទួលបានរបាយការណ៍ លាយលក្ខណ៍អក្សរជាលក្ខណ:បុគ្គលដែលរៀបរាប់អំពីការកាត់បន្ថយការប្រើប្រាស់សារធាតុពុល ការទប់ស្កាត់ការបំពុល និងការណែនាំអំពីការអភិរក្សធនធាន រួមជាមួយនិងការកំណត់ពេលវេលានៃការពិនិត្យមើលដើម្បីផ្តល់ជាជំនួយក្នុងការអនុវត្ត។ របាយការណ៍នានានឹងរួមបញ្ចូលភាសាខាងក្រោម ដើម្បីទាក់ទាញ ការយកចិត្តទុកដាក់ចំពោះការពិតដែលថា អាជីវកម្មនេះស្ថិតនៅ ក្នុងសហគមន៍យុត្តិធម៌បរិស្ថាន រួមជាមួយនិងសារ:សំខាន់នៃការការពារ សុខភាពសាធារណ:នៅក្នុងតំបន់ទាំងនេះ៖

"កន្លែងរបស់អ្នកស្ថិតនៅចម្ងាយមួយម៉ាយល៍ពីសហគមន៍យុត្តិធម៌បរិស្ថាន។ យុត្តិធម៌បរិស្ថានត្រូវបានកំណត់នាពេលថ្មីៗនេះនៅក្នុងច្បាប់រដ្ឋម៉ាសាជូសេត ក្នុង ជំពូកទី 8 ផ្នែកទី 56 នៃច្បាប់ឆ្នាំ2021។ នៅក្នុងច្បាប់នេះ ប្រជាជនយុត្តិធម៌បរិស្ថានត្រូវបានកំណត់ថាជាតំបន់ដែល បំពេញតាមលក្ខណៈវិនិច្ឆ័យជំរឿនមួយ ឬច្រើន ឬរួមបញ្ចូលគ្នាដោយផ្អែកលើប្រាក់ចំណូល ពូជសាសន៍ និងជំនាញភាសាអង់គ្លេស ដោយមានករណីលើកលែងជាក់លាក់មួយចំនួន។ យុត្តិធម៌បរិស្ថានគឺផ្អែកលើគោលការណ៍ដែលបានពិពណ៌នានៅក្នុង គោលនយោបាយយុត្តិធម៌បរិស្ថានឆ្នាំ2017 របស់ការិយាល័យប្រតិបត្តិកិច្ចការថាមពល និងបរិស្ថាន (EEA) "ប្រជាជនទាំងអស់មានសិទ្ធិទទួលបានការការពារពីគ្រោះថ្នាក់បរិស្ថាន និងរស់នៅក្នុងបរិស្ថានស្អាត និងមានសុខភាពល្អ ដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ សញ្ជាតិ ចំណូល ឬជំនាញភាសាអង់គ្លេស" ឡើយ។

"ដោយសារយុត្តិធម៌មបរិស្ថានគឺជាអាទិភាពដែលកំពុងកើនឡើងសម្រាប់រដ្ឋ OTA ចង់ពិភាក្សាអំពីរបៀបដែលតំបន់របស់អ្នកអាចរួមបញ្ចូលយុត្តិធម៌បរិស្ថាន និង/ឬសហគមន៍ចូលទៅក្នុងសកម្មភាពរបស់អ្នក។ យើងរីករាយក្នុងការផ្តល់ជូន/បំផុសគំនិតអំពីធនធានដើម្បីបង្កើនការចូលរួមក្នុងសហគមន៍។

## ការផ្សព្វផ្សាយទូទៅ

OTA ព្យាយាមធ្វើជាធនធានសម្រាប់អ្នកគស្ស៊មតិផ្នែកយុត្តិធម៌បរិស្ថាន ហើយនឹងលើកកម្ពស់ការយល់ដឹងដោយៈ

- កំណត់អត្តសញ្ញាណសម្ព័ន្ធមិត្ត និងការព្យាយាមឱ្យទទួលបានការបញ្ចូលទៅក្នុងរបៀបវារៈនៃយុត្តិធម៌បរិស្ថាន និងសង្គម ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងអង្គការមិនស្វែងរកប្រាក់ចំណេញដែលផ្តល់តម្លៃដល់ការកាត់បន្ថយការប្រើប្រាស់សារធាតុពុល និងការផ្សព្វផ្សាយអាជីវកម្មបៃតង ដើម្បីទទួលបានការបញ្ជូនបន្ត និងពង្រីកសេវាកម្មរបស់ OTA។
    - OTA នឹងប្រមូលនិងកត់ត្រាអន្តរកម្មតាមរយៈមូលដ្ឋានទិន្នន័យដែលរក្សាទុកនៅលើ HubSpot។
- កំណត់អត្តសញ្ញាណ ប្រមូល និងចែករំលែកធនធានប្រព័ន្ធផ្សព្វផ្សាយសហគមន៍ដែលត្រូវបានបោះពុម្ព ឬផ្សព្វផ្សាយជាភាសាផ្សេងក្រៅពីភាសាអង់គ្លេសជាមួយ EEA និង TURI តាមរយៈមូលដ្ឋានទិន្នន័យដែលរក្សាទុកនៅលើ HubSpot ។
- បង្កើតការផ្សព្វផ្សាយ និងសម្ភារៈអប់រំ ដែលបំពេញតម្រូវការរបស់សហគមន៍ និងកម្មកររបស់ EJ
    - OTA នឹងចែករំលែក TURA ផ្នែកទី 18៖ ការចូលរួមពាក់ព័ន្ធរបស់ពលរដ្ឋ (MGL c.21I ផ្នែកទី 18) ជាមួយភាគីពាក់ព័ន្ធ និងជួយភាគីពាក់ព័ន្ធបកស្រាយសេចក្តីសង្ខេប និងផលប៉ះពាល់បច្ចេកទេស ជាពិសេសផ្នែក A និង B ដូចតទៅ៖

*ផ្នែកទី 18. ប្រជាពលរដ្ឋនៅក្នុងរដ្ឋម៉ាសាជូសេត អាចចូលរួមក្នុងការត្រួតពិនិត្យ និងអនុវត្តនីតិវិធីដូចខាងក្រោម៖*

*(A) នាយកដ្ឋានត្រូវរៀបចំឱ្យមាន សម្រាប់របាយការណ៍ត្រួតពិនិត្យប្រជាពលរដ្ឋ ដែលតម្រូវឱ្យស្ថិតនៅក្រោមផ្នែកទីដប់ និងសេចក្តីសង្ខេបផែនការ ដែលទាមទារនៅក្នុងផ្នែកទី ដប់មួយ។ ទោះជាយ៉ាងនេះក្តី ប្រសិនបើមានភាពអាចរកបាន (នូវរបាយការណ៍) បែបនេះត្រូវស្ថិតនៅក្រោមបទបញ្ញត្តិនៃផ្នែកទីម្ភៃ ។*

*(B) ប្រជាពលរដ្ឋចំនួនដប់នាក់ណាក៏ដោយ ដែលរស់នៅក្នុងចម្ងាយដប់ម៉ាយល៍ពីកន្លែងដែលត្រូវការដើម្បីរៀបចំផែនការកាត់បន្ថយការប្រើប្រាស់សារធាតុពុលអាចដាក់ញត្តិទៅនាយកដ្ឋានដើម្បីឱ្យនាយកដ្ឋានពិនិត្យមើលផែនការ សេចក្តីសង្ខេបផែនការ និងទិន្នន័យបម្រុងទុកដែលត្រូវការ និងកំណត់ភាពគ្រប់គ្រាន់របស់ពួកគេ។ នាយកដ្ឋានត្រូវកំណត់ថាតើផែនការ សេចក្តីសង្ខេបផែនការ និងទិន្នន័យបម្រុងទុកណាមួយត្រូវនឹងស្តង់ដារដែលបានបង្កើតឡើងស្របតាមជំពូកនេះ។ នាយកដ្ឋានត្រូវរាយការណ៍ពីការប្តេជ្ញាចិត្តរបស់ខ្លួនទៅកាន់អ្នកដាក់ញត្តិ និងអ្នកប្រើប្រាស់សារធាតុពុលជាលាយលក្ខណ៍អក្សរក្នុងរយៈពេលសមស្របណាមួយ។*

- ការរៀបចំថវិកាសម្រាប់ឯកសារដែលមានជាភាសាផ្សេងក្រៅពីភាសាអង់គ្លេស និងផ្តល់ការបកស្រាយផ្ទាល់មាត់ និងការបកប្រែជាលាយលក្ខណ៍អក្សរសមស្រប ត្រូវផ្អែកលើប្រជាសាស្ត្រ កម្លាំងពលកម្ម ឬការចូលរួមសហគមន៍។
- ការរៀបចំ EJ ទៅក្នុងកម្មវិធី TURA ដោយៈ
    - ការបញ្ចូលការផ្សព្វផ្សាយ EJ និងការទប់ស្កាត់ការបំពុលទៅក្នុងការត្រួតពិនិត្យការអនុវត្តការងាររបស់បុគ្គលិក OTA
    - ការបម្រុងតួនាទី EJ ក្នុងគណៈកម្មាធិការប្រឹក្សា និងធានាឱ្យមានតំណាងចម្រុះក្នុងគ្រប់ការតែងតាំងទាំងអស់
    - ការផ្តល់វគ្គបណ្តុះបណ្តាលជាចាំបាច់អំពី EJ សម្រាប់បុគ្គលិក OTA ដែលរៀបចំដោយកម្មវិធី EEA / OTA / TURA និង/ឬអ្នកប្រឹក្សាខាងក្រៅ ដែលមានជំនាញសមស្រប ព្រមទាំងការបណ្តុះបណ្តាលដែលផ្តល់ដោយសិក្ខាសាលា និងធនធានរបស់ភ្នាក់ងារខាងក្រៅ។
- ការប្រើប្រាស់ផែនការផ្សព្វផ្សាយសហគមន៍ EEA/ផែនការការចូលរួមសាធារណៈ។

## សុវត្ថិភាពគីមី & ភាពធន់នឹងបម្រែបម្រួលអាកាសធាតុៈ

- បង្កើតផែនការ/យុទ្ធសាស្ត្រផ្សព្វផ្សាយដែលកំណត់គោលដៅអ្នកប្រើប្រាស់សារធាតុពុលនៅក្នុងសហគមន៍ដែលងាយរងគ្រោះពីអាកាសធាតុ ដូចដែលបានកែសម្រួលតាមកម្មវិធីសុវត្ថិភាពគីមី និងភាពធន់នឹងបម្រែបម្រួលលអាកាសធាតុរបស់ OTA ។
- ការធ្វើការជាមួយភ្នាក់ងារ EEA ផ្សេងទៀតដើម្បីធ្វើទីផ្សារ OTA ជាធនធានដើម្បីជួយឧស្សាហកម្មនៅក្នុងតំបន់កំពង់ផែដែលបានកំណត់ (DPAs) ឬតំបន់ហានិភ័យគ្រោះទឹកជំនន់ដើម្បីកាត់បន្ថយការប្រើប្រាស់សារធាតុគីមីពុលរបស់ពួកគេ។
- ធ្វើបច្ចុប្បន្នភាពលក្ខណៈវិនិច្ឆ័យត្រួតពិនិត្យការអនុវត្តការងាររបស់បុគ្គលិក ដើម្បីសង្កត់ធ្ងន់លើការផ្សព្វផ្សាយទៅកាន់កន្លែងនានា

ដែលមានទីតាំងនៅក្នុងតំបន់យុត្តិធម៌បរិស្ថាន រួមទាំងទាក់ទងនឹងសុវត្ថិភាពគីមីរបស់ OTA និងការផ្តល់ជូនភាពធន់នឹងបម្រែបម្រួលអាកាសធាតុ។

- សហការជាមួយ DPH ដើម្បីជានានូវស្រទាប់ទិន្នន័យស្របគ្នារវាងផែនទីធន់នឹងអាកាសធាតុនិងសុវត្ថិភាពគីមីរបស់ OTA និង ឧបករណ៍គូសផែនទីយុត្តិធម៌បរិស្ថានរបស់ DPH។

## ការបញ្ជូនការស្រាវជ្រាវ/ពិសោធន៍/ផ្តល់ជំនួយ TURI បន្ត

- ការបញ្ជូនអាជីវកម្មផ្សេងៗបន្តទៅកាន់សេវាកម្មកម្មវិធី TURA រួមបញ្ចូលសកម្មភាពដូចខាងក្រោម៖
- ការពិនិត្យឡើងវិញ និងការដាក់ផ្តល់ជំនួយ៖
    - ចែករំលែកព័ត៌មាននៃការដាក់ផ្តល់ជំនួយតាមរយៈអង្គការដែលបានកំណត់អត្តសញ្ញាណថ្មីនៅក្នុងសហគមន៍ EJ។
    - ផ្តល់ការបណ្តុះបណ្តាលដើម្បីគាំទ្រដល់អ្នកទទួលជំនួយពី TURI។
    - បញ្ចូលការដាក់ពិន្ទុ EJ ទៅក្នុងជំនួយ TURI។
    - កំណត់ធនធានជំនួយផ្សេងទៀត ដើម្បីជួយបង្កើតកម្មវិធីផ្សេងៗប្រកបដោយនិរន្តរភាព និងភាពជាដៃគូ
- បញ្ចូល EJ ទៅក្នុងសន្និសីទអប់រំបន្តក្នុងការធ្វើផែនការកាត់បន្ថយការប្រើប្រាស់សារធាតុពុល (Toxics Use Reduction Planning Continuing Education Conferences)។
- កំណត់ក្រុមយុត្តិធម៌បរិស្ថាន សាជីវកម្មអភិវឌ្ឍន៍សេដ្ឋកិច្ច ក្រុមសហគមន៍ ភ្នាក់ងារមិនស្វែងរកកម្រៃ និងដៃគូផ្សេងទៀតនៅក្នុងមូលដ្ឋានទិន្នន័យដែលបានចែករំលែកជាមួយ EEA និង TURI។
- រៀបចំវគ្គបណ្តុះបណ្តាលដដែលៗជុំវិញកម្មវិធី TURA ទាក់ទងនឹងបន្ទុកនៃសារធាតុគីមីពុលនៅក្នុងសហគមន៍ EJ ។

## សមិទ្ធផលរបស់ OTA ក្នុងឆ្នាំកន្លងមក

- បានជួលអ្នកហាត់ការ EJ ដែលបានបង់ប្រាក់ដើម្បីជួយយើងក្នុងការធ្វើទីផ្សារ និងការផ្តល់សេវាកាត់បន្ថយការប្រើប្រាស់សារធាតុពុល និងធនធានរបស់យើងដល់សហគមន៍យុត្តិធម៌បរិស្ថាន ដោយកំណត់អត្តសញ្ញាណដៃគូ និងអាជីវកម្មដែលមានសក្តានុពល និងបង្កើតការផ្សព្វផ្សាយ និងសម្ភារៈអប់រំ។ អ្នកហាត់ការផ្នែកយុត្តិធម៌បរិស្ថានបានជួយ OTA ក្នុងការបង្កើតវិធីសាស្ត្រមួយ ដើម្បីចូលរួមជាមួយសហគមន៍យុត្តិធម៌បរិស្ថាន និង អាជីវកម្មដែលគ្រប់គ្រងដោយជនជាតិភាគតិចតាមរយៈសកម្មភាពដូចខាងក្រោម៖
    - បង្កើតមូលដ្ឋានទិន្នន័យអាជីវកម្មដែលគ្រប់គ្រងដោយជនជាតិភាគតិចដែលនឹងទទួលបានអត្ថប្រយោជន៍ពីជំនួយ OTA និងផែនការផ្សព្វផ្សាយដើម្បីកំណត់គោលដៅចំពោះអាជីវកម្មទាំងនេះ។
    - បង្កើតមូលដ្ឋានទិន្នន័យក្រុមយុត្តិធម៌បរិស្ថាន សាជីវកម្មអភិវឌ្ឍន៍សេដ្ឋកិច្ច ក្រុមសហគមន៍ អង្គការមិនស្វែងរកកម្រៃ និងអង្គការផ្សេងទៀតដើម្បីធ្វើជាដៃគូជាមួយ និងការស្នើសុំឱ្យបញ្ចូលទៅក្នុងរបៀបវារៈប្រជុំនិងសិក្ខាសាលាលើបណ្តាញអ៊ីនធឺណេតដើម្បីទីផ្សារសេវាកម្មរបស់ OTA ។

- ○ កំណត់អត្តសញ្ញាណអ្នកតំណាង EJ សម្រាប់គណៈកម្មាធិការប្រឹក្សាយោបល់របស់ TURA ។
- ○ បង្កើតផែនការផ្សព្វផ្សាយដើម្បីកំណត់គោលដៅអ្នកប្រើប្រាស់សារធាតុពុលនៅក្នុងសហគមន៍ដែលងាយរងគ្រោះដោយបម្រែបម្រួលអាកាសធាតុ និងព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ ស្របតាម កម្មវិធីភាពធន់នឹងបម្រែបម្រួលអាកាសធាតុ និងសុវត្ថិភាពគីមីរបស់ OTA។
  សកម្មភាពផ្សេងៗនាពេលអនាគតនឹងប្រើប្រាស់ធនធានដូចជា ផែនទីបម្រែបម្រួលអាកាសធាតុរបស់ OTA ដែលរួមបញ្ចូលស្រទាប់ EJ ដើម្បីកំណត់តំបន់ផ្តោតជាអាទិភាព និងពិចារណាពីរបៀបដែលធនធានរបស់ OTA អាចផ្តល់អត្ថប្រយោជន៍ដល់សកម្មភាពនានា នៅក្នុងតំបន់កំពង់ផែដែលបានកំណត់ ដូចជាបូស្តុនខាងកើតជាដើម។
- អ្នកហាត់ការ EJ បានធ្វើការស្ទង់មតិបុគ្គលិករបស់ OTA លើការយល់ឃើញ គំនិត និងតម្រូវការរបស់ EJ ដើម្បីបង្កើត ការបណ្តុះបណ្តាលសម្រាប់បុគ្គលិកដែលរួមបញ្ចូលនូវប្រវត្តិនៃការរៀបចំឡើងវិញ និងការរៀបចំកន្លែងប្រើប្រាស់សារធាតុគីមីពុលនៅក្នុងតំបន់ដែលក្រីក្រ និងជាជនជាតិភាគតិច។ ការបណ្តុះបណ្តាលនេះត្រូវបានកែសម្រួលតាម ដើម្បីបង្កើត ការបណ្តុះបណ្តាលទូលំទូលាយក្នុងកម្មវិធី TURA ។
- អ្នករៀបចំផែនការកាត់បន្ថយការប្រើប្រាស់ជាតិពុល (TURP) សន្និសិទអប់រំបន្តនៅរដូវរំហើយ ឆ្នាំ2021 [Spring 2021 Conference Education (CE) Conference] បានបង្ហាញវាគ្មិនសំខាន់មួយរូបរបស់ EJ ឈ្មោះ Ana Mascarenas ដែលជានាយិកាសមធ៌មបរិស្ថាននៃ នាយកដ្ឋានការពារបរិស្ថាន គ្រប់គ្រងសារធាតុពុលរបស់រដ្ឋកាលីហ្វ័រញ៉ា (Environmental Equity Director of the California's Environmental Protection Department of Toxic Substance Control) ដើម្បីពិភាក្សា អំពីចំនុចប្រសព្វនៃយុត្តិធម៌បរិស្ថាន និងកាត់បន្ថយការប្រើប្រាស់សារធាតុគីមីពុល។ តំណភ្ជាប់ទៅការកត់ត្រាបទបង្ហាញអាចត្រូវបានរកឃើញ នៅត្រង់នេះ។
- ការបណ្តុះបណ្តាលមួយត្រូវបានផ្តល់ជូនដល់ម្ចាស់ហាង និងនិយោជិតរបស់ក្រុង Lawrence ដែលជាផ្នែកមួយនៃជំនួយ TURI ដែលត្រូវបានប្រគល់ជូន នាយកដ្ឋានអគ្គិភ័យក្រុង Lawrence។ ការបកប្រែជាភាសាអេស្ប៉ាញមាននៅក្នុងព្រឹត្តិការណ៍នេះ ហើយកម្មវិធីសិក្សា Massachusetts Clean Auto Repair (MassCAR) ត្រូវបានបកប្រែជាភាសា អេស្ប៉ាញ។

## ផែនការអនាគតសម្រាប់សកម្មភាពបន្ថែម

- បង្កើតរង្វាស់វាស់វែង ដើម្បីតាមដានសកម្មភាព EJ រួមទាំងស្ថិតិខាងក្រោមនៅក្នុងរបាយការណ៍ចុងឆ្នាំរបស់អភិបាលៈ
  - ○ ភាគរយនៃការចូលមើលគេហទំព័រដែលបានធ្វើឡើងនៅក្នុងសហគមន៍ EJ ។
  - ○ សារធាតុគីមីជាច្រើនរួមទាំង VOCs និងសារធាតុពុលត្រូវបានកាត់បន្ថយនៅក្នុងសហគមន៍ EJ ។
  - ○ ការអភិរក្សទឹក និងថាមពលសម្រេចបាននៅក្នុងសហគមន៍ EJ ។
  - ○ ការសម្រេចចិត្តផ្តល់មូលនិធិ ដូចជាជំនួយ TURI ត្រូវទទួលបានក្នុងសហគមន៍ EJ ។

- ចំនួននៃការបញ្ជូនបន្តដែល OTA នឹងត្រូវបានទទួលពីភ្នាក់ងារផ្សេងទៀតដូចជា DEP ក្រុមប្រឹក្សាសុខភាពមូលដ្ឋាន ឬនាយកដ្ឋានពន្លត់អគ្គីភ័យនៅក្នុងសហគមន៍ EJ ។
- ចំនួនបទបង្ហាញជាច្រើនដែលធ្វើឡើងចំពោះក្រុម ឬសហគមន៍ EJ ។
- ឧបករណ៍វិភាគផលប៉ះពាល់ជាបន្តបន្ទាប់ត្រូវបានបង្កើតឡើង។

- គោលបំណងសម្រាប់ភាសាសាមញ្ញ សម្ភារៈផ្សព្វផ្សាយដែលអាចចូលប្រើប្រាស់បានដើម្បីរៀបចំដំណើរការបទបញ្ញត្តិ និងពេលវេលាសម្រាប់ការបញ្ចូល និងបញ្ចេញមតិយោបល់របស់សហគមន៍ ដើម្បីបង្កើនការចូលរួមពីសហគមន៍ EJ ។ ការផ្សព្វផ្សាយដែលអាចចូលប្រើប្រាស់បាន អាចរួមបញ្ចូលមិនត្រឹមតែឯកសារដែលបានបកប្រែរួចប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពន្យល់អំពី គោលគំនិតក្នុងកម្រិតនៃការអានដែលអាចយល់បានដោយទស្សនិកជនកាន់តែទូលំទូលាយ កាត់បន្ថយការប្រើប្រាស់អក្សរកាត់ រួមបញ្ចូលធាតុក្រាហ្វិកបន្ថែមទៀត និងលើកទឹកចិត្តឱ្យមានសំណួរនិងការទំនាក់ទំនងជាមួយនឹងចំណុចច្បាស់លាស់។
- ស្វែងរកលទ្ធភាពនៃការផ្លាស់ប្តូរការប្រជុំសាធារណៈទៅកាន់ទីតាំង និងពេលវេលាដែលអាចចូលដំណើរការបានកាន់តែច្រើន ដើម្បីពង្រីកការចូលរួម និងពង្រីកការផ្សព្វផ្សាយជាសាធារណៈទៅកាន់ទីកន្លែងដែលមិនមែនជាប្រពៃណី នៅទីដែលសាធារណជនប្រមូលផ្តុំរួចហើយ ដូចជាព្រឹត្តិការណ៍ក្នុងតំបន់ មជ្ឈមណ្ឌលដឹកជញ្ជូនសាធារណៈ និងមជ្ឈមណ្ឌលសកម្មភាពសហគមន៍។

## ការទំនាក់ទំនង

OTA ផ្តល់ជំនួយបច្ចេកទេសដោយឥតគិតថ្លៃ និងដោយរក្សាការសម្ងាត់ដល់ក្រុមហ៊ុនផលិតក្នុងរដ្ឋម៉ាសាជូសេត ដែលជាផ្នែកមួយនៃច្បាប់កាត់បន្ថយការប្រើប្រាស់សារធាតុពុល (TURA)។ ខណៈពេលដែលយើងធ្វើការផ្សព្វផ្សាយទៅកាន់សហគមន៍ EJ យើងក៏ចង់បញ្ជាក់ពីសារៈសំខាន់នៃ EJ ក្នុងការទំនាក់ទំនងរបស់យើងទៅកាន់ក្រុមហ៊ុនផងដែរ។

**ប្រព័ន្ធផ្សព្វផ្សាយសង្គម និងសារព័ត៌មានរបស់ OTA** យើងនឹងប្រើប្រាស់ LinkedIn, Twitter និងសារព័ត៌មានប្រចាំត្រីមាសរបស់យើង ដើម្បីផ្សព្វផ្សាយបញ្ហាយុត្តិធម៌បរិស្ថាន និងធ្វើឱ្យក្រុមហ៊ុននានាយល់ដឹងពីឱកាសដើម្បីបន្តយុត្តិធម៌បរិស្ថានបន្ថែមទៀត នៅក្នុងសហគមន៍ដែលពួកគេស្ថិតនៅ។

**គេហទំព័រ TURA** កម្មវិធី TURA នឹងបង្កើតគេហទំព័រ EJ នៅលើ mass.gov ។ គេហទំព័រនេះនឹងពន្យល់ពីកម្មវិធី TURA ហើយរួមបញ្ចូលកម្មវិធីដូចខាងក្រោម៖

- ពិពណ៌នាអំពីរបៀបប្រើ និងបកប្រែ ផ្ទាំងគ្រប់គ្រងទិន្នន័យ TURA (TURA Data Dashboard) រួមបញ្ចូលទាំងរបៀបស្វែងរកព័ត៌មានអំពីមធ្យោបាយជាក់លាក់ និងផ្តល់ការណែនាំសម្រាប់ការបកប្រែទិន្នន័យនៅក្នុងបរិបទនៃយុត្តិធម៌បរិស្ថាន។
- របៀបដែល OTA, TURI, និង DEP អាចចូលរួមជាមួយ ហើយផ្តល់ធនធានដល់សហគមន៍ EJ ។
- តំណភ្ជាប់ទៅកាន់ ផ្ទាំងគ្រប់គ្រងទិន្នន័យ TURA និង ផែនទីសុវត្ថិភាពគីមី និងបម្រែបម្រួលអាកាសធាតុរបស់ OTA។

- រួមបញ្ចូលព័ត៌មានអំពី [ជំនួយរបស់ TURI] និងព័ត៌មានអំពីកម្មវិធី TURA និងធនធាន EEA ដែលមានទាំងអស់។

**គេហទំព័រ OTA៖** OTA ក៏នឹងធ្វើបច្ចុប្បន្នភាពគេហទំព័ររបស់ខ្លួនផងដែរ ដើម្បីបង្ហាញពីរបៀបដែល OTA អាចផ្តល់អត្ថប្រយោជន៍ដល់សហគមន៍ EJ និងឯកសារនៅក្នុងគេហទំព័រទាំងនោះ៖ រំលេចសកម្មភាព EJ បច្ចុប្បន្នរបស់ OTA និងរួមបញ្ចូលឯកសារបកប្រែដែលមានរួច។

### ការប្តេជ្ញាចិត្តរបស់ OTA លើការជួលបុគ្គលិកថ្មី

OTA ទទួលស្គាល់ពីសារៈសំខាន់នៃការមានកម្លាំងការងាររបស់ទីភ្នាក់ងារដែលឆ្លុះបញ្ចាំងពីភាពចម្រុះជាតិសាសន៍ ជាតិពន្ធុ និងសេដ្ឋកិច្ចសង្គមរបស់អ្នករស់នៅក្នុងរដ្ឋម៉ាសាជូសេត រួមទាំងតួនាទីសំខាន់ដែលកម្លាំងពលកម្មបែបនេះមាន ក្នុងការជំរុញការសម្រេចចិត្តប្រកបដោយសមធម៌ទាក់ទងនឹងការអនុញ្ញាត្ត ការជ្រើសរើសបរិស្ថាន និងថាមពល ការបង្កើតបទបញ្ញត្តិ ផ្តល់ជំនួយ និងការអនុវត្តច្បាប់។ OTA ប្តេជ្ញាក្នុងការរួមបញ្ចូលការអនុវត្តការជួលចម្រុះជាតិសាសន៍ និង ផ្តល់ការបណ្តុះបណ្តាលសម្រាប់អ្នកគ្រប់គ្រងការជួល ដើម្បីលើកកម្ពស់ការសម្រេចចិត្តប្រកបដោយសមធម៌នេះ រួមទាំងការប្រើប្រាស់លក្ខណៈវិនិច្ឆ័យក្នុងការប្រកាសរើសបុគ្គលិកដែលតម្រូវឱ្យបេក្ខជនជោគជ័យបង្ហាញចំណេះដឹង និងការយល់ដឹងអំពីតម្រូវការរបស់ប្រជាជនដែលងាយរងគ្រោះ តំបន់យុត្តិធម៌បរិស្ថាន និងតំបន់ដែលមិនទាន់មានការផ្តល់សេវាគ្រប់គ្រាន់ក្នុងសហគមន៍ខំមិនវែល។

## ការអនុវត្តយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់ការិយាល័យប្រតិបត្តិផ្នែកថាមពល និងកិច្ចការបរិស្ថាន

ពាក់ព័ន្ធនឹងក្តីបារម្ភ ពាក្យបណ្តឹង ការបំពេញបន្ថែម ឬគំនិតផ្សេងៗពាក់ព័ន្ធនឹង យុត្តិធម៌បរិស្ថាន ឬដើម្បីស្វែងយល់បន្ថែមអំពីកិច្ចខិតខំប្រឹងប្រែងផ្នែកយុត្តិធម៌បរិស្ថាន ថាមពល និងអាកាសធាតុរបស់ទីភ្នាក់ងារយើង សូមទាក់ទងការិយាល័យយុត្តិធម៌បរិស្ថានរបស់ EEA ដែលមានចែងនៅទំព័រទី 19 នៃយុទ្ធសាស្ត្របរិស្ថានរបស់ EEA។

### ចំណុចទាក់ទង EJ របស់ការិយាល័យជំនួយបច្ចេកទេស (OTA)៖

[Kari Sasportas]
អ្នកវិភាគគោលនយោបាយ និងផ្សព្វផ្សាយ
[kari.sasportas@mass.gov]
(617) 429-5454

ឬ

[Tiffany Skogstrom]
នាយក
[tiffany.skogstrom@mass.gov]
(857) 275-1561

# នាយកដ្ឋានធនធានកសិកម្មរដ្ឋម៉ាសាជូសេត

## យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន

# តារាងមាតិកា


**នាយកដ្ឋានធនធានកសិកម្មរដ្ឋម៉ាសាជូសេត........................................................66**

សេចក្តីថ្លែងការណ៍បេសកកម្ម MDAR........................................................68

លក្ខខណ្ឌតម្រូវនៃយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់លេខាធិការដ្ឋានចេញគោលនយោបាយយុត្តិធម៌បរិស្ថាននៃការិយាល័យ EEA........................................................69

យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន........................................................69

គោលនយោបាយយុត្តិធម៌បរិស្ថាន MDAR........................................................70

*បានធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងដែលទាក់ទងនឹងយុត្តិធម៌បរិស្ថាន........................................................71*

*ការបណ្តុះបណ្តាល........................................................73*

*ឱកាសផ្តល់មូលនិធិជំនួយ........................................................74*

*ផែនការអនាគតសម្រាប់សកម្មភាព/គម្រោងបន្ថែម........................................................74*

*ខ្នាតរង្វាស់........................................................74*

*ការពិនិត្យឡើងវិញនូវការបំពេញការងារ និងការជួលបុគ្គលិក........................................................75*

ការអនុវត្តយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់ការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន........................................................75


ព្រាង



# យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន
# នាយកដ្ឋានធនធានកសិកម្មរដ្ឋម៉ាសាជូសេត

## សេចក្តីថ្លែងការណ៍បេសកកម្ម MDAR

មាត្រា 97 នៃរដ្ឋធម្មនុញ្ញរដ្ឋម៉ាសាជូសេត ធានាប្រជាជនមានសិទ្ធិក្នុងការសម្អាតខ្យល់ និងទឹក សេរីភាពពីសំលេងរំខានហួសហេតុ និងមិនចាំបាច់ និងគុណភាពធម្មជាតិ ទេសភាព ប្រវត្តិសាស្ត្រ និងសោភ័ណភាពបរិស្ថានរបស់ពួកគេ និងការការពារប្រជាពលរដ្ឋចំពោះសិទ្ធិរបស់ពួកគេក្នុងការអភិរក្ស អភិវឌ្ឍន៍ និងការប្រើប្រាស់រ៉ែ ព្រៃឈើ ទឹក ខ្យល់កសិកម្ម ហើយធនធានធម្មជាតិផ្សេងទៀតត្រូវបានប្រកាសថាជាគោលបំណងសាធារណៈ។
បេសកកម្មរបស់នាយកដ្ឋានធនធានកសិកម្មរបស់រដ្ឋម៉ាសាជូសេត (MDAR) គឺដើម្បីជួយរក្សាការផ្គត់ផ្គង់ស្បៀងអាហាររបស់រដ្ឋម៉ាសាជូសេត ប្រកបដោយសុវត្ថិភាព និងសុវត្ថិភាព និងធ្វើការដើម្បីរក្សាកសិកម្មរបស់រដ្ឋម៉ាសាជូសេត ប្រកបដោយលក្ខណៈសេដ្ឋកិច្ច និងបរិស្ថាន។ MDAR ធានានូវលទ្ធភាពជោគជ័យយូរអង្វែងផ្នែកកសិកម្មនៅក្នុងរដ្ឋម៉ាសាជូសេត។ តាមរយៈផ្នែកទាំងបួនរបស់ខ្លួន គឺ – ជំនួយបច្ចេកទេសនិងអភិរក្ស (Agricultural Conservation and Technical Assistance), ទីផ្សារកសិកម្ម (Agricultural Markets), បសុព្យាបាល (Animal Health), និង សេវាដំណាំនិងកំចាត់សត្វល្អិត (Crop and Pest Services) – MDAR ខិតខំគាំទ្រ គ្រប់គ្រង និងលើកម្ពស់ភាពសម្បូរបែបនៃសហគមន៍ កសិកម្មរបស់ប្រទេសសមាជិកខំមិនវែល ដើម្បីលើកវិធានការណ៍បសុព្យាបាលនិងសុវត្ថិភាពចំណីអាហារតាមលក្ខណៈសេដ្ឋកិច្ចនិងបរិស្ថាន ព្រមទាំងបំពេញតួនាទីរបស់កសិកម្មក្នុងការអភិរក្សថាមពល និងផលិតកម្ម។ តាមរយៈការបង្កើតគោលនយោបាយ និងការផ្សព្វផ្សាយបទបញ្ញត្តិផ្សេងៗសម្រាប់បសុព្យាបាល សុវត្ថិភាពចំណីអាហារ និងថ្នាំសម្លាប់សត្វល្អិត និងតាមរយៈការចែកចាយធនធានដែលត្រូវការ

តាមរយៈកម្មវិធីជំនួយ និងការត្រួតពិនិត្យស្តង់ដាទាក់ទងនឹងកសិដ្ឋាន និង ទីផ្សារចំណីអាហារនៅក្នុងតំបន់ជាយក្រុង និងជនបទ ផ្នែករបស់នាយកដ្ឋានកំពុងធ្វើការ ដើម្បីបំពេញបេសកកម្មនេះតាមរយៈកម្មវិធី និងសេវាកម្ម 60+ ដែលខ្លួនផ្តល់ជូន។

## លក្ខខណ្ឌតម្រូវនៃយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់លេខាធិការដ្ឋានចេញ គោលនយោបាយយុត្តិធម៌បរិស្ថាននៃការិយាល័យ EEA

គោលនយោបាយយុត្តិធ៌មបរិស្ថាន (EJ) របស់ការិយាល័យប្រតិបត្តិកិច្ចការថាមពល និងបរិស្ថាន (EEA) បានដឹកនាំទីភ្នាក់ងារ EEA ទាំងអស់បង្កើតយុទ្ធសាស្ត្រ EJ ផ្ទាល់ខ្លួនរបស់ពួកគេ។ ទីភ្នាក់ងារ EEA ត្រូវពិចារណាថាតើត្រូវរួមបញ្ចូលការគិតគូរពីយុត្តិធម៌បរិស្ថានទៅក្នុងនាយកដ្ឋានរបស់ពួកគេ តាមរយៈគោលនយោបាយ កម្មវិធី ឬយុទ្ធសាស្ត្រដទៃទៀត ដោយរបៀបណា។ ទីភ្នាក់ងារ EEA ត្រូវកំណត់អត្តសញ្ញាណ និងផ្សព្វផ្សាយគម្រោងដែលឧបត្ថម្ភដោយទីភ្នាក់ងារ ការសម្រេចចិត្តផ្តល់មូលនិធិ ការធ្វើបទបញ្ញត្តិ ឬសកម្មភាពផ្សេងទៀតដែលមានបំណងបន្ត បន្ថែមទៀតនូវយុត្តិធម៌បរិស្ថាននៅទូទាំងសហគមន៍ខំមិនវែល ដើម្បីបង្ហាញពីរបៀបដែលការបែងចែកផលប្រយោជន៍ដោយយុត្តិធម៌ត្រូវបានវាស់វែង។[1]

## យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន

យុទ្ធសាស្ត្ររបស់ MDAR គូសបញ្ជាក់ពីសកម្មភាពសម្រាប់ការលើកកម្ពស់ និងរួមបញ្ចូលហេតុផល EJ នៅទូទាំងកម្មវិធី គោលនយោបាយ និងសកម្មភាពរបស់ MDAR ដើម្បីធានាបាននូវការចូលប្រើប្រាស់ស្មើភាព និងការចូលរួមប្រកបដោយអត្ថន័យរបស់មនុស្សទាំងអស់ ដែលរស់នៅក្នុងសហគមន៍ ខំមិនវែល ទាក់ទងទៅនឹងនិរន្តរភាពសេដ្ឋកិច្ច កសិកម្ម និងបរិស្ថាន និងការអភិវឌ្ឍប្រកបដោយសមធម៌ ការអនុវត្ត និងលទ្ធភាពប្រើប្រាស់ព័ត៌មាន និងធនធាន។

យុទ្ធសាស្ត្ររបស់ MDAR កំណត់សកម្មភាពដែលនឹងអនុវត្តគោលនយោបាយ EJ របស់ EEA ។ យុទ្ធសាស្ត្រនេះមានបញ្ជីធាតុផ្សំដែលបានរៀបចំឡើងដើម្បីៈ

- បង្កើនការប្រាស្រ័យទាក់ទងអំពីធនធាន និងព័ត៌មាន ការកំណត់គោលដៅប្រព័ន្ធផ្សព្វផ្សាយដែលមិនមែនជាភាសាអង់គ្លេស ក៏ដូចជាអង្គការសហគមន៍ មូលដ្ឋានដើម្បីផ្សព្វផ្សាយព័ត៌មាន។
- បង្កើនការចូលប្រើភាសាដែលមានកាន់តែច្រើនសម្រាប់ឯកសារសាធារណៈដែលមានការបកប្រែ ក៏ដូចជាសេវាកម្មបកប្រែសម្រាប់ការប្រជុំសាធារណៈ (ដោយផ្ទាល់ ឬដោយប្រព័ន្ធអេឡិចត្រូនិក);
- វាយតម្លៃក្រុមប្រឹក្សា គណៈកម្មាធិការ និងក្រុមប្រឹក្សាពិគ្រោះយោបល់ ដើម្បីធានាបាននូវឱកាសស្មើគ្នាសម្រាប់ការចូលរួមពីសហគមន៍ EJ ដោយធ្វើការជាមួយដៃគូដើម្បីធានាការយល់ដឹងអំពីឱកាសនានា និងផ្តល់ជំនួយផ្នែកភាសានៅពេលចាំបាច់។
- បង្កើតក្រុមការងារ EJ នៅក្នុង MDAR ដែលមានបុគ្គលិកមកពីផ្នែកនីមួយៗ ដើម្បីបង្កើតពិភាក្សា និងធានាថាគោលនយោបាយត្រូវបានអនុវត្ត ក៏ដូចជាការបណ្តុះបណ្តាល EJ ផ្ទៃក្នុងសម្រាប់បុគ្គលិកទាំងអស់;

[1] www.mass.gov/service-details/environmental-justice-policy, ទំព័រ 9

- បង្កើនកិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់ក្នុងការរួមបញ្ចូលការអនុវត្តការជួលបុគ្គលិកចម្រុះជាតិសាសន៍ និងផ្តល់ការបណ្តុះបណ្តាលសម្រាប់អ្នកគ្រប់គ្រងការជួលបុគ្គលិក ដើម្បីលើកកម្ពស់ការសម្រេចចិត្តប្រកបដោយសមធម៌នេះ។
- បង្កើនការគាំទ្រដល់កសិករ BIPOC ក្នុងការទទួលបានដីស្រែចំការ ក្នុងកម្មវិធីផ្តល់អាជ្ញាប័ណ្ណដីរបស់ MDAR,
- ផ្តល់ឱ្យសហគមន៍ EJ នូវការគាំទ្រ និងការអប់រំនៃធនធានសម្រាប់ការគ្រៀវ និងបន្សាបសត្វឆ្កែ និងឆ្មាកុំឱ្យមានកូន ព្រមទាំងការចំណាយលើពេទ្យសត្វដែល MDAR ទទួលរ៉ាប់រងលើការចាក់វ៉ាក់សាំងសេះសម្រាប់ EEE ។
- ចូលរួម និងផ្តល់ការគាំទ្រដល់កសិករ និងអ្នកផលិតដែលជួបការលំបាកក្នុងសង្គម ដោយផ្តល់ជំនួយបច្ចេកទេស ការត្រួតពិនិត្យ ការអប់រំអ្នកដាំដុះ និងផ្តល់ការគាំទ្របន្ថែមណាមួយតាមរយៈកម្មវិធីត្រួតពិនិត្យសុវត្ថិភាពផលិតកម្មរបស់ MDAR ។
- ធ្វើការដើម្បីធានាបាននូវគំនិតផ្តួចផ្តើមទេសចរណ៍ធ្វើម្ហូប (ឱកាសអ្នកលក់និងការលក់រាយ) ដែលរួមមានការអប់រំ និងការផ្សព្វផ្សាយគម្រោងធ្វើម្ហូប ត្រូវបានដាក់លក់ទៅកាន់សហគមន៍ EJ ដើម្បីផ្សព្វផ្សាយអាហារសមស្របតាមវប្បធម៌។
- បង្កើនការផ្សព្វផ្សាយសម្រាប់ឱកាសនៃការលក់រាយផ្នែកសេដ្ឋកិច្ច (Economic Retail Sales) នៅអគារ Mass Building សម្រាប់ "Big E" ដោយផ្តោតលើសហគមន៍ EJ សម្រាប់អ្នកលក់ដែលចូលរួម។
- បង្កើតការណែនាំ និងការអនុវត្តល្អបំផុតសម្រាប់បង្កើនការចូលរួមជាសាធារណៈ និងឱកាសចូលប្រើប្រាស់នៅក្នុងសហគមន៍ EJ ។

## គោលនយោបាយយុត្តិធម៌បរិស្ថាន MDAR

គោលនយោបាយផ្សេងៗដែលត្រូវអនុវត្តៈ

- ពិនិត្យមើលឱកាសដើម្បីពង្រឹងការប្តេជ្ញាចិត្តរបស់ MDAR ក្នុងការគាំទ្រសហគមន៍ EJ ។
- ហេតុផលសម្រាប់លក្ខណៈវិនិច្ឆ័យ EJ ដែលត្រូវប្រើសម្រាប់ផ្តល់អាទិភាពដល់ឱកាសផ្តល់ជំនួយសម្រាប់អាជីវកម្មកសិកម្ម និងម្ហូបអាហារ។
- ផ្សព្វផ្សាយការយល់ដឹងទូលំទូលាយអំពីគោលការណ៍ EJ សម្រាប់កម្មវិធីរបស់ MDAR;
- ធានាឱ្យមានការចូលរួមប្រកបដោយអត្ថន័យសម្រាប់មនុស្សទាំងអស់ដែលរស់នៅក្នុងសហគមន៍ EJ ។
- ក្រុមប្រឹក្សា គណៈកម្មាធិកា និងក្រុមប្រឹក្សាយោបល់ MDAR ប្តេជ្ញាផ្តល់ឱកាសស្មើគ្នាសម្រាប់ការចូលរួមពីសហគមន៍ EJ ។
- ការប្តេជ្ញាចិត្តធ្វើការជាមួយកសិករ BIPOC*[2] ដើម្បីទទួលបានដី និងជួយសម្រួលដល់ការផ្លាស់ប្តូរដោយជោគជ័យរបស់ពួកគេពីតំបន់ជាយក្រុងទៅកសិដ្ឋានខ្នាតធំ តាមរយៈកម្មវិធីណែនាំ និងភាពជាដៃគូរបស់អង្គការកសិកម្មក្នុងស្រុក។
- MDAR នឹងប្រកាន់ខ្ជាប់នូវការពិនិត្យឡើងវិញនូវការដាក់ពាក្យសុំ សម្រាប់កម្មវិធីរបស់ខ្លួនតាមរយៈការឆ្លុះបញ្ចាំង EJ ដើម្បីធានាបាននូវសមធម៌

[2] បេក្ខជន គឺជា កសិករ ដែលមិនបានទទួលរងជាប្រវត្តិសាស្ត្រ ដូចបានកំណត់ក្នុង វិក្កយបត្រ USDA Farm Bill ឆ្នាំ2018។ នេះរួមបញ្ចូលទាំងកសិករពីដើមដំបូង កសិករដែលមានបញ្ហាសង្គម កសិករធនធានមានកម្រិត និង កសិករជើងចាស់។

ហើយការចូលប្រើប្រាស់ធនធានត្រូវបានពិចារណា យ៉ាងខ្លាំងនៅក្នុងដំណើរការត្រួតពិនិត្យការផ្តល់ជំនួយ។

- ប្តេជ្ញាផ្តោតលើឱកាសក្នុងការធ្វើជាដៃគូជាមួយអង្គការដែលពឹងផ្អែកលើកសិដ្ឋាន ដើម្បីផ្តល់ជំនួយបន្ថែមដល់កសិករអន្តោប្រវេសន៍ និង កសិករ BIPOC ដើម្បីអភិវឌ្ឍមូលដ្ឋានចំណេះដឹង (ឧទាហរណ៍៖ ការធ្វើផែនការអាជីវកម្ម ការសរសេរផ្តល់ជំនួយ ការទិញដី)។
- MDAR នឹងបន្តពង្រីកធនធានផ្សព្វផ្សាយ/ចូលរួមជាមួយសហគមន៍ទៅកាន់ប្រជាជនយុត្តិធម៌បរិស្ថាន ដែលជាការប្តេជ្ញាចិត្តក្នុងការផ្តល់សិទ្ធិចូលដំណើរការពេញលេញទៅកាន់កម្មវិធី និងសកម្មភាពរបស់ MDAR ។
- ការប្តេជ្ញាចិត្តក្នុងការផ្តល់ព័ត៌មានសម្រាប់ កម្មការដែលមានប័ណ្ណអនុញ្ញាតប្រភេទ H2A (H2A Permit Workers) (កម្មវិធីសហព័ន្ធមួយ) ដែលមានតំណភ្ជាប់នៅគេហទំព័ររបស់ MDAR (“ដឹងពីសិទ្ធិរបស់អ្នក”, របៀបដាក់ពាក្យបណ្តឹង ។ល។)
    - ទិដ្ឋាការប្រភេទ H-2A អនុញ្ញាតឱ្យពលករបរទេសចូលសហរដ្ឋអាមេរិកសម្រាប់ការងារកសិកម្មបណ្តោះអាសន្ន។ និយោជកប្រភេទ H-2A គឺជាក្រុមនិយោជកតែមួយគត់ដែលត្រូវបង់ថ្លៃដឹកជញ្ជូនក្នុង និងក្រៅប្រទេស ផ្ទះស្នាក់នៅដោយឥតគិតថ្លៃ និងផ្តល់អាហារសម្រាប់កម្មកររបស់ពួកគេ។
- សន្យាប្រើប្រាស់ទិន្នន័យយុត្តិធម៌បរិស្ថានដែលផ្តល់ដោយការិយាល័យជំរឿនសហរដ្ឋអាមេរិក កំណត់ត្រាផ្ទៃក្នុងនៃទីតាំងផ្តល់ជំនួយ និងទិន្នន័យបន្ថែមផ្សេងទៀត ដើម្បីជួយកំណត់អត្តសញ្ញាណសហគមន៍ទាំងនោះ និងណែនាំដល់នាយកដ្ឋាន។
- គាំទ្រការអនុវត្តការគ្រប់គ្រងល្អបំផុត (BPM) សម្រាប់ការផ្សព្វផ្សាយជាសាធារណៈជាមួយដៃគូសម្រាប់គំនិតផ្តួចផ្តើម MDAR នៅក្នុងសហគមន៍ EJ ។

## បានធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងដែលទាក់ទងនឹងយុត្តិធម៌បរិស្ថាន

MDAR ប្តេជ្ញាពង្រីកលទ្ធភាពរបស់យើងតាមរយៈបណ្តាញប្រព័ន្ធផ្សព្វផ្សាយចម្រុះ និងដៃគូប្រចាំសហគមន៍នៅក្នុងតំបន់ EJ ។ លទ្ធភាពដែលបានកើនឡើងរបស់យើងរួមមានការបកប្រែភាសាសរសេរនិងផ្ទាល់មាត់ ហើយនឹងបង្កើនលទ្ធភាពទទួលបានធនធាន និងព័ត៌មានទាំងអស់។

**គេហទំព័រ MDAR** MDAR នឹងធ្វើបច្ចុប្បន្នភាពទំព័រយុត្តិធម៌បរិស្ថានរបស់ខ្លួន ដែលមានផ្នែកបកប្រែ។

គេហទំព័រ EJ បច្ចុប្បន្នរបស់ MDAR ផ្តល់ព័ត៌មានមានសារៈប្រយោជន៍ដូចជា៖

- ទំនាក់ទំនងរបស់អ្នកផ្តល់ព័ត៌មាន (Point Person) អំពី EJ របស់ MDAR
- ទំនាក់ទំនងរបស់នាយក EJ EEA
- បច្ចុប្បន្ន គោលនយោបាយ EEA EJ ឆ្នាំ2017 និង 2002
- តំណភ្ជាប់ទៅកាន់ច្បាប់សហព័ន្ធ និងបទបញ្ជាប្រតិបត្តិ
- ផែនទី EJ និងអ្នកពិនិត្យ EJ របស់ EEA
- ព័ត៌មានអំពីជំនួយបកប្រែភាសាសរសេរ/ផ្ទាល់មាត់ របស់ MDAR

MDAR នឹងបន្តធ្វើបច្ចុប្បន្នភាពគេហទំព័រ EJ របស់យើងជាឧបករណ៍សម្រាប់សាធារណជនក្នុងការទាក់ទងជាមួយបុគ្គលិក MDAR និងមានសិទ្ធិចូលប្រើឯកសារជាច្រើនភាសា។

យើងខិតខំគាំទ្រសហគមន៍ EJ និងក្រុមតស៊ូមតិ ក៏ដូចជាផ្តល់ព័ត៌មានសមស្របពាក់ព័ន្ធទាក់ទងនឹងកម្មវិធី គម្រោង និងសកម្មភាពនានានៅក្នុងវិស័យកសិកម្ម។

**ពង្រឹងការផ្សព្វផ្សាយសាធារណៈ/ការផ្សព្វផ្សាយសហគមន៍** MDAR ប្តេជ្ញាលើកកម្ពស់យុត្តិធម៌បរិស្ថានដោយធានាការផ្សព្វផ្សាយព័ត៌មានដល់សហគមន៍ EJ ដើម្បីកែលម្អសុខភាពមនុស្ស និងសត្វ ក៏ដូចជាការដោះស្រាយផលប៉ះពាល់សង្គម និងសេដ្ឋកិច្ចចំពោះមនុស្សក្នុងសហគមន៍ ខំមិនវែល។ ដើម្បីធ្វើដូច្នេះ MDAR នឹងធ្វើការដើម្បីផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិករបស់ខ្លួនអំពីឱកាសដ៏មានអត្ថន័យសម្រាប់ការចូលរួមជាសាធារណៈ និងការចូលរួមសហគមន៍។

នៅក្រោមគោលការណ៍ EJ របស់សហគមន៍ ខំមិនវែល គឺ "ការចូលរួមប្រកបដោយអត្ថន័យមានន័យថាតំបន់ទាំងអស់ មានសិទ្ធិ និងឱកាសក្នុងការចូលរួមក្នុងថាមពល បម្រែបម្រួលអាកាសធាតុ និងការសម្រេចចិត្តបរិស្ថាន រួមទាំងការវាយតម្លៃតម្រូវការ ការធ្វើផែនការ ការអនុវត្ត ការអនុលោមតាម និងការអនុវត្ត និងការវាយតម្លៃ ហើយតំបន់ទាំងនេះត្រូវបានជួយនិងសម្រួលផ្នែករដ្ឋបាល ដើម្បីចូលរួមយ៉ាងពេញលេញតាមរយៈការអប់រំ និងការបណ្តុះបណ្តាល ហើយត្រូវបានផ្តល់តម្លាភាព/ទំនួលខុសត្រូវរួម ដោយរដ្ឋាភិបាលទាក់ទងនឹងធាតុចូលសហគមន៍ និងត្រូវបានលើកទឹកចិត្តឱ្យអភិវឌ្ឍការគ្រប់គ្រងបរិស្ថាន ថាមពល និងបម្រែបម្រួលអាកាសធាតុ។[3]

MDAR នឹងធ្វើការជាមួយសហគមន៍ អង្គការដៃគូ ភ្នាក់ងារសហការី និងមន្ត្រីមូលដ្ឋាន ដើម្បីពង្រឹងការចូលរួម និងពាក់ព័ន្ធរបស់សហគមន៍។ ចំណុចបន្តបន្ទាប់គឺជាអនុសាសន៍/សំណូមពរ ប៉ុន្តែមិនត្រូវបានកំណត់ចំពោះវិធីសាស្ត្រដែល MDAR នឹងប្រើដើម្បីផ្តល់នូវការចូលរួមក្នុងសហគមន៍ប្រកបដោយអត្ថន័យ និងការចូលរួមជាសាធារណៈនោះឡើយ។

- បង្កើត និងធ្វើបច្ចុប្បន្នភាពជាប្រចាំនូវបញ្ជីក្រុមសហគមន៍ និងអង្គការដៃគូតាមតំបន់ និងទីកន្លែងនៅលើដ្រាយ (Drive) រួម ដែលអាចចូលដំណើរការបានសម្រាប់បុគ្គលិក MDAR ទាំងអស់ ដើម្បីផ្សព្វផ្សាយព័ត៌មានសាធារណៈទាំងអស់។
- កំណត់បណ្តាញផ្សព្វផ្សាយដែលមិនមែនជាភាសាអង់គ្លេស ដើម្បីពង្រីកលទ្ធភាពរបស់ MDAR ដើម្បីផ្តល់សិទ្ធិទទួលបានព័ត៌មានស្មើគ្នា សម្រាប់ប្រជាពលរដ្ឋទាំងអស់។
- ត្រូវប្រាកដថា កម្មវិធីជំនួយទាំងអស់ត្រូវបានផ្សព្វផ្សាយតាមរយៈដៃគូ និងប្រព័ន្ធផ្សព្វផ្សាយទៅកាន់សហគមន៍ EJ ។
- បន្តពង្រឹងទំនាក់ទំនង និងរក្សាការប្រាស្រ័យទាក់ទងជាប្រចាំជាមួយអង្គការសហគមន៍ ក្រុមឧស្សាហកម្ម និងមន្ត្រីក្រុងដោយការចែករំលែកព័ត៌មានទាក់ទងនឹងសកម្មភាពផ្សេងៗ និងផ្តល់ឱកាសនៅក្នុងចំណោមប្រជាជន EJ និងដោយការបង្ហោះព័ត៌មាន នៅលើគេហទំព័រ EJ របស់ MDAR ក៏ដូចជាប្រព័ន្ធផ្សព្វផ្សាយជា ភាសាអង់គ្លេស និងមិនមែនជាភាសាអង់គ្លេស។
- ការចូលរួម/ផ្សព្វផ្សាយតាមអ៊ីនធឺណិត ប៉ុន្តែមិនកំណត់ចំពោះវេទិកាវីដេអូដូចជា ( Zoom, Go to Meeting, Skype សម្រាប់អាជីវកម្ម, Microsoft Teams និងសេវាកម្មផ្សេងទៀតដែលអនុញ្ញាតឱ្យការប្រជុំប្រព្រឹត្តទៅដោយមិនមានអ្នកចូលរួមទាំងអស់នៅទីតាំងតែមួយ);

- MDAR នឹងបន្តប្រើប្រាស់ការចូលប្រើទូរស័ព្ទសម្រាប់អ្នកដែលគ្មានអ៊ីនធឺណិតក្នុងសកម្មភាពទាំងអស់។

## ប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម / បច្ចេកវិទ្យាព័ត៌មាន

- MDAR ក៏នឹងវាយតម្លៃវិធីនៃការអនុវត្តបច្ចេកវិទ្យាថ្មីៗ និងអង្គការប្រព័ន្ធផ្សព្វផ្សាយដើម្បីចែករំលែកព័ត៌មាន EJ ជាបន្តបន្ទាប់ (ឧ. ប្រព័ន្ធផ្សព្វផ្សាយសង្គម និងពង្រីកការផ្សព្វផ្សាយជាមួយបណ្តាញផ្សព្វផ្សាយចម្រុះ និងទូលំទូលាយ) ត្រឹមរដូវក្តៅឆ្នាំ2022។
- បន្តធ្វើបច្ចុប្បន្នភាព និងកែលម្អគេហទំព័រយុត្តិធម៌បរិស្ថាន។

## សមត្ថភាពចំណេះដឹងភាសាអង់គ្លេសនៅមានកម្រិត

- ប្រើកិច្ចសន្យារដ្ឋ - សេវាបកប្រែភាសាសរសេរ និងផ្ទាល់មាត់;
- ការប្តេជ្ញាចិត្តក្នុងការបែងចែកធនធានហិរញ្ញវត្ថុដែលត្រូវការសម្រាប់សេវាភាសា។
- បន្តការបកប្រែរបស់ទីភ្នាក់ងារដែលបានរកឃើញឯកសារសំខាន់ៗជាច្រើនភាសា។
- អនុវត្ត និងចែកចាយផ្ទាំងរូបភាពបកប្រែភាសា "ខ្ញុំនិយាយ" ទៅកាន់ការិយាល័យ MDAR ទាំងអស់ និងទីតាំងតុខាងមុខ ហើយធានាថាបុគ្គលិកទាំងអស់ដឹងពីតម្រូវការ EJ ។
- ធ្វើឱ្យអ្នកបកប្រែ និងសេវាបកប្រែមាននៅពេលដែលចំនួនមនុស្ស ដែលមានជំនាញភាសាអង់គ្លេស (LEP) មានកម្រិត ត្រូវបានកំណត់អត្តសញ្ញាណ ឬនៅពេលដែលបានស្នើសុំដោយប្រជាជន EJ ។
- MDAR ប្តេជ្ញាអនុវត្តតាមព្រឹត្តិបត្រ A&F លេខ 16 ស្តីអំពីគោលនយោបាយប្រើប្រាស់ភាសា (Language Access Policy) ក្នុងការធ្វើអោយប្រសើរឡើងនូវការចូលប្រើសេវាកម្ម កម្មវិធី និងសកម្មភាពរដ្ឋ ចំពោះមនុស្សដែលមានជំនាញភាសាអង់គ្លេសនៅមានកម្រិត (LEP) ។

### ការបណ្តុះបណ្តាល

MDAR នឹងធានាថាបុគ្គលិករបស់ទីភ្នាក់ងារយល់ពីបញ្ហា EJ លក្ខខណ្ឌទំនួលខុសត្រូវ និងឱកាសតាមរយៈការបណ្តុះបណ្តាលដែលទាក់ទងនឹង EJ ។

ព្រឹត្តិការណ៍បណ្តុះបណ្តាលជាក់លាក់នឹងរួមបញ្ចូលៈ

- ការបន្តផ្តល់ផែនទី GIS & ការបណ្តុះបណ្តាលទូទាំងទីភ្នាក់ងារអ្នកពិនិត្យ EJ អំពីរបៀបដែលកម្មវិធីគួរប្រើការត្រួតដណ្តប់លើផែនទី EJ ។
- ការរៀបចំវគ្គបណ្តុះបណ្តាលតាមតំបន់អំពី EJ ដែលត្រូវបានផ្តល់ជូនជាដំបូងដល់បុគ្គលិក MDAR ។
- ការបណ្តុះបណ្តាលពីរបៀបបញ្ចូលយុត្តិធម៌បរិស្ថានទៅក្នុងការងាររបស់ MDAR (ការចូលរួមរបស់អ្នកពាក់ព័ន្ធនិងនិយមន័យនៃសហគមន៍ EJ);
- ការបណ្តុះបណ្តាលស្តីពីលទ្ធកម្មសេវាភាសា និងដំណើរការចូលប្រើប្រាស់។

### ឱកាសផ្តល់មូលនិធិជំនួយ

- បញ្ចូលគោលនយោបាយ EJ របស់ EEA ទៅក្នុងជំនួយ MDAR ទាំងអស់ ដើម្បីបង្កើនឱកាសនៅក្នុងសហគមន៍ EJ ដើម្បីបង្កើតឱកាស កាន់តែច្រើនសម្រាប់ការផលិតអាហារពាណិជ្ជកម្ម ការទទួលបានដី និងឱកាសទីផ្សារ។

- ត្រូវប្រាកដថាជំនួយ MDAR ដែលមានស្រាប់ទាំងអស់ត្រូវបានចែកចាយដល់ប្រជាជន EJ រួមទាំងសមាជិកសហគមន៍ បុគ្គលិកក្រុង បណ្តាញផ្សព្វផ្សាយ។ល។ ដែលអាចចាប់អារម្មណ៍នឹងឱកាសផ្តល់ជំនួយទាំងនេះដើម្បីបង្កើនគោលដៅ EJ ។
- ផ្តល់ការចូលប្រើភាសាទៅកាន់ RFR ទាំងអស់ជាច្រើនភាសា និងផ្តល់សេវាបកប្រែតាមការស្នើសុំ។

## ផែនការអនាគតសម្រាប់សកម្មភាព/គម្រោងបន្ថែម

- ស្វែងរកឱកាសក្នុងការវិនិយោគនៅក្នុងតំបន់ EJ តាមរយៈការសហការជាមួយកម្មវិធីក្នុងតំបន់ពាក់ព័ន្ធ។
- បន្តគាំទ្រ BIPOC និងកសិករអន្តោប្រវេសន៍ ដោយប្រើធនធានបន្ថែមសម្រាប់ការគាំទ្រផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងកន្លែងដែលអាចប្រើប្រាស់បានដើម្បីបង្កើនផលិតកម្ម និងទីផ្សារនៃដំណាំវប្បធម៌;
- ថាមពលដែលអាចកកើតឡើងវិញនៅក្នុងសហគមន៍ EJ – MDAR អាចស្វែងរកការងារនេះ និងពិភាក្សាអំពីកិច្ចសហប្រតិបត្តិការជាមួយ DPU, DOER និងភ្នាក់ងារ EEA ដទៃទៀត។
- ស្វែងរកពីសមត្ថភាពក្នុងការបង្កើនកន្លែងលំហ និងទីតាំងផលិតអាហារនៅក្នុងចំណោមប្រជាជន EJ

## ខ្នាតរង្វាស់

MDAR នឹងរចនា និងធ្វើឱ្យមាននៅលើទំព័រ EJ របស់ខ្លួន ដែលជាផែនទីបង្ហាញពីឥទ្ធិពលនៃការផ្តល់ជំនួយរបស់ខ្លួន ដោយបង្ហាញពីការទៅដល់នៃកម្មវិធីរបស់ខ្លួននៅក្នុងសហគមន៍ EJ ។

ដូចដែលបានទាមទារនៅក្រោមគោលនយោបាយ EJ របស់ EEA MDAR នឹងបង្កើតវិធានការដើម្បីតាមដានវឌ្ឍនភាពនៃយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានដែលខ្លួនបានដាក់ឱ្យដំណើរការ។

វិធានការទាំងនោះរួមមាន៖

a. ការតាមដានសំណើបកប្រែ និងការបំពេញតាមសំណើ;
b. ចំនួនអ្នកដាក់ពាក្យសុំថ្មីសម្រាប់កម្មវិធីជំនួយពីសហគមន៍ EJ និងកសិករ BIPOC;
c. ចំនួនឯកសារដែលបានបកប្រែ;
d. វគ្គបណ្តុះបណ្តាលដែលរៀបចំឡើងសម្រាប់បុគ្គលិកដោយ EEA ឬ NGO;
e. ចំនួនប្រព័ន្ធផ្សព្វផ្សាយថ្មី ដែលមិនមែនជាភាសាអង់គ្លេស ដើម្បីផ្សព្វផ្សាយព័ត៌មាននៅក្នុងសហគមន៍ EJ;
f. ការតាមដានភាពជាដៃគូតាមសហគមន៍ដែលបានធ្វើឡើងសម្រាប់ការពង្រីកទំនាក់ទំនងធនធាន និងព័ត៌មានដែលមាន។
g. ការតាមដានប្រចាំត្រីមាសតាមរយៈធនធានមនុស្សអំពីការជួលបុគ្គលិកចម្រុះជាតិសាសន៍។

MDAR នឹងតាមដាន និងចងក្រងព័ត៌មាន ដើម្បីអនុលោមតាមរបាយការណ៍ចុងឆ្នាំដែលតម្រូវដោយរដ្ឋ។

### ការពិនិត្យឡើងវិញនូវការបំពេញការងារ និងការជួលបុគ្គលិក

MDAR ទទួលស្គាល់ពីសារៈសំខាន់នៃកម្លាំងពលកម្មរបស់ទីភ្នាក់ងារដែលឆ្លុះបញ្ចាំងពីភាពចម្រុះជាតិសាសន៍ ជាតិពន្ធ និងសេដ្ឋកិច្ចសង្គមរបស់អ្នករស់នៅក្នុងរដ្ឋម៉ាសាជូសេត រួមទាំងតួនាទីសំខាន់ដែលកម្លាំងពលកម្មបែបនេះមាន ក្នុងការជំរុញការសម្រេចចិត្តប្រកបដោយសមធម៌ទាក់ទងនឹងការបង្កើតកម្មវិធីបរិស្ថាន និងសេដ្ឋកិច្ចកសិកម្ម ការបង្កើតបទបញ្ញត្តិ និងការចែកចាយការផ្តល់ជំនួយ។  MDAR ប្តេជ្ញាបង្កើនកិច្ចប្រឹងប្រែងជាបន្តបន្ទាប់របស់ខ្លួន ក្នុងការរួមបញ្ចូលការអនុវត្តការជួលចម្រុះជាតិសាសន៍ និងផ្តល់ការបណ្តុះបណ្តាលសម្រាប់អ្នកគ្រប់គ្រងការជួលបុគ្គលិក ដើម្បីលើកកម្ពស់ការសម្រេចចិត្តប្រកបដោយសមធម៌នេះ រួមទាំងការប្រើប្រាស់លក្ខណៈវិនិច្ឆ័យក្នុងការប្រកាសរើសបុគ្គលិកដែលតម្រូវឱ្យបេក្ខជនជោគជ័យបង្ហាញចំណេះដឹង និងការយល់ដឹងអំពីតម្រូវការរបស់ប្រជាជនដែលងាយរងគ្រោះ តំបន់យុត្តិធម៌បរិស្ថាន និងតំបន់ដែលមិនទាន់មានការផ្តល់សេវាគ្រប់គ្រាន់នៃសហគមន៍ ខំមិនវែល។

- រៀបចំពិព័រណ៍ការងារនៅតាមសាលារៀនមួយចំនួននៅក្នុងចំណោមប្រជាជន EJ;
- បន្ថែមទៅនឹងសំណួរសំភាសន៍ស្តង់ដាររបស់ទីភ្នាក់ងារថាតើយុត្តិធម៌បរិស្ថានមានន័យយ៉ាងណាចំពោះបេក្ខជននៅក្នុងមុខងាររបស់ទីភ្នាក់ងារនេះ;
- MDAR នឹងធ្វើការដើម្បីបង្កើតលក្ខណៈវិនិច្ឆ័យត្រួតពិនិត្យការអនុវត្តការងាររបស់និយោជិតដែលនឹងរួមបញ្ចូលក្តីកង្វល់របស់និយោជិត ចំពោះបញ្ហាចំនួនប្រជាជន EJ ការងារនៅក្នុងសហគមន៍ EJ ។ល។

## ការអនុវត្តយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់ការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន

MDAR តាមរយៈគោលនយោបាយ EJ របស់ EEA ធានានូវការការពារស្មើៗគ្នា និងការចូលរួមប្រកបដោយអត្ថន័យរបស់មនុស្ស និងសហគមន៍ទាំងអស់ទាក់ទងនឹងការអភិវឌ្ឍន៍ ការអនុវត្ត និងប្រតិបត្តិការថាមពល បម្រែបម្រួលអាកាសធាតុ និងច្បាប់ បទបញ្ជា និងគោលនយោបាយបរិស្ថាន និងការចែកចាយថាមពល និងអត្ថប្រយោជន៍បរិស្ថានប្រកបដោយសមភាព និងបន្ទុកនានា ចំពោះក្តីកង្វល់អំពីយុត្តិធម៌បរិស្ថាន ការត្អូញត្អែរ ការសរសើរ ឬគំនិតយោបល់ ឬដើម្បីស្វែងយល់បន្ថែមអំពីកិច្ចខិតខំប្រឹងប្រែងផ្នែកយុត្តិធម៌បរិស្ថាន ថាមពល និងបម្រែបម្រួលអាកាសធាតុរបស់ទីភ្នាក់ងាររបស់យើង សូមទាក់ទងការិយាល័យយុត្តិធម៌បរិស្ថានរបស់ EEA ដូចដែលបានរៀបរាប់នៅទំព័រទី 19 នៃយុទ្ធសាស្ត្រ EJ របស់ EEA នេះ។

### ទំនាក់ទំនងអ្នកផ្តល់ព័ត៍មាន (Point Person) អំពី EJ របស់ MDAR

Rebecca Davidson
អ្នកដឹកនាំយុត្តិធ៌មបរិស្ថាន/អ្នកគ្រប់គ្រងគំនិតផ្តួចផ្តើមយុទ្ធសាស្ត្រ
កម្មវិធីអាហារូបត្ថម្ភទីផ្សាររបស់កសិករ
Rebecca.davidson@mass.gov
857-202-7699

# នាយកដ្ឋានអភិរក្ស និងកម្សាន្ត

Massachusetts

# យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន

# តារាងមាតិកា

**នាយកដ្ឋានអភិរក្ស និងកម្សាន្ត ....................................................................................... 74**
សេចក្តីថ្លែងការណ៍បេសកកម្ម DCR ........................................................................................76
សារតារ ..........................................................................................................................76
សេចក្តីណែនាំរបស់ EEA សម្រាប់បង្កើតយុទ្ធសាស្ត្រយុត្តិធ៌មបរិស្ថានរបស់ទីភ្នាក់ងារ EJ .............77
យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់ DCR ................................................................................77
*ពង្រីកលទ្ធភាពប្រើប្រាស់ និងការចូលរួម ...............................................................................79*
*ជម្រុញតម្លាភាពនិងការប្រាស្រ័យទាក់ទង .............................................................................80*
*ផ្តល់អាទិភាពដល់ការវិនិយោគ និងការបែងចែកធនធាន .......................................................80*
*ផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិក .....................................................................................83*
ការអនុវត្តយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់ការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន ..........................................................................................................................84

# នាយកដ្ឋានអភិរក្ស និងកម្សាន្ត យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន

## សេចក្តីថ្លែងការណ៍បេសកកម្ម DCR

នាយកដ្ឋានអភិរក្ស និងកម្សាន្ត (DCR) ស្វែងរកការការពារ ផ្សព្វផ្សាយ និងលើកកម្ពស់ធនធានធម្មជាតិ វប្បធម៌ និងការកម្សាន្តរបស់ប្រទេស សមាជិកសហគមន៍ ខំមិនវែល របស់យើងដើម្បីសុខុមាលភាពទាំងអស់គ្នា។

ក្នុងការបំពេញទំនួលខុសត្រូវបច្ចុប្បន្ន និងផែនការសម្រាប់ថ្ងៃស្អែក ការយកចិត្តទុកដាក់របស់ DCR គឺផ្តោតទៅលើ៖

- ការកែលម្អឱកាសកម្សាន្តក្រៅផ្ទះ និងការអភិរក្សធនធានធម្មជាតិ
- ការស្តារ និងកែលម្អគ្រឿងបរិក្ខាររបស់យើង។
- ការពង្រីកការចូលរួមជាសាធារណៈក្នុងការអនុវត្តបេសកកម្មរបស់ DCR និង
- ការបង្កើតប្រព័ន្ធគ្រប់គ្រងដ៏ល្អឥតខ្ចោះ និងការអនុវត្ត។

សុខភាព និងសុភមង្គលរបស់មនុស្សនៅទូទាំងរដ្ឋម៉ាសាជូសេត អាស្រ័យលើភាពងាយស្រួល និងគុណភាពនៃហេដ្ឋារចនាសម្ព័ន្ធបៃតងរបស់យើង គឺធនធានធម្មជាតិ កន្លែងកម្សាន្ត និងទេសភាពប្រវត្តិសាស្ត្រដ៏ឧត្តុង្គឧត្តមរបស់យើង។ DCR បន្តធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងដ៏សំខាន់រវាងមនុស្ស និងបរិស្ថាន។

## សាវតារ

ការិយាល័យប្រតិបត្តិកិច្ចការថាមពល និងបរិស្ថាន រដ្ឋម៉ាសាជូសេត (EEA) បានបង្កើតគោលនយោបាយយុត្តិធម៌បរិស្ថាន (EJ) ដើម្បីជួយដោះស្រាយចំណែកអសមាមាត្រនៃបន្ទុក បរិស្ថានដែលជួបប្រទះដោយអ្នកដែលមានប្រាក់ចំណូលទាប និងសហគមន៍ដែលមានពណ៌សម្បុរ ដែលក្នុងពេលជាមួយគ្នានេះ ជារឿយៗពួកគេខ្វះទ្រព្យសម្បត្តិបរិស្ថាន នៅក្នុងតំបន់របស់ពួកគេ។ គោលនយោបាយនេះត្រូវបានរៀបចំឡើងដើម្បីជួយធានាការការពារពីការបំពុលបរិស្ថាន ក៏ដូចជាលើកកម្ពស់ការចូលរួមរបស់សហគមន៍ក្នុងការធ្វើផែនការ និងការសម្រេចចិត្តបរិស្ថាន ដើម្បីរក្សា និង/ឬលើកកម្ពស់គុណភាពបរិស្ថាននៃតំបន់ទាំងនេះ។

គោលនយោបាយ EJ (ធ្វើបច្ចុប្បន្នភាពឆ្នាំ2021) រួមបញ្ចូលនិយមន័យដូចខាងក្រោម "យុត្តិធម៌បរិស្ថាន គឺផ្អែកលើគោលការណ៍ដែលប្រជាជនទាំងអស់មានសិទ្ធិទទួលបានការការពារពីគ្រោះថ្នាក់បរិស្ថាន និងរស់នៅក្នុងបរិស្ថានស្អាត និងមានសុខភាពល្អ ដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ សញ្ជាតិដើម ចំណូល ឬជំនាញភាសាអង់គ្លេសនោះឡើយ"។ យុទ្ធសាស្ត្រយុត្តិធ៌មបរិស្ថាន គឺជាកិច្ចការពារស្មើភាពគ្នា និងជាការចូលរួមពេញលេញរបស់ប្រជាជននិងសហគមន៍ទាំងអស់ ពាក់ព័ន្ធនឹងការអភិវឌ្ឍ ការអនុវត្ត និងការអនុវត្តច្បាប់ បទបញ្ញត្តិ និងគោលនយោបាយ ស្តីពីថាមពល បម្រែបម្រួល

អាកាសធាតុ និងបរិស្ថាន និង បំណែងចែកដោយសមធម៌នូវផលប្រយោជន៍និងបន្ទុកផ្នែកថាមពលនិងបរិស្ថាន។"

## សេចក្តីណែនាំរបស់ EEA សម្រាប់បង្កើតយុទ្ធសាស្ត្រយុត្តិធ៌មបរិស្ថានរបស់ទីភ្នាក់ងារ EJ

គោលនយោបាយយុត្តិធម៌បរិស្ថានរបស់ការិយាល័យប្រតិបត្តិថាមពល និងកិច្ចការបរិស្ថានដឹកនាំទីភ្នាក់ងារ EEA ទាំងអស់ឱ្យបង្កើតយុទ្ធសាស្ត្រ EJ រៀងខ្លួន។ ក្នុងការធ្វើដូច្នេះ ភ្នាក់ងារ EEA ត្រូវ ពិចារណាអំពីរបៀបបញ្ចូលហេតុផលអំពីយុត្តិធម៌បរិស្ថានឱ្យសមស្របទៅក្នុងនាយកដ្ឋានរបស់ពួកគេ តាមរយៈគោលនយោបាយ កម្មវិធី ឬយុទ្ធសាស្ត្រផ្សេងទៀត។ ទីភ្នាក់ងារ EEA ត្រូវកំណត់អត្តសញ្ញាណ និងផ្សព្វផ្សាយគម្រោងដែលឧបត្ថម្ភដោយទីភ្នាក់ងារ ការសម្រេចចិត្តផ្តល់មូលនិធិ ការធ្វើបទបញ្ញត្តិ ឬសកម្មភាពផ្សេងទៀតដែលមានបំណងបន្តបន្ថែមទៀតនូវយុត្តិធម៌បរិស្ថាននៅទូទាំងសហគមន៍ខំមិនវែល ដើម្បីបង្ហាញពីរបៀបដែលការបែងចែកផលប្រយោជន៍ដោយយុត្តិធម៌ត្រូវបានវាស់វែង។

## យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់ DCR

DCR គ្រប់គ្រង និងមើលការខុសត្រូវលើផ្ទៃដីជាង 450,000 អារ នៅទូទាំងរដ្ឋម៉ាសាជូសេត និងផ្តល់ឱ្យសាធារណៈជននូវភាពសម្បូរបែបនៃឱកាសកម្សាន្ត។ នេះរួមបញ្ចូលដោយមិនកំណត់ចំពោះ ឧទ្យាន ព្រៃឈើ ឆ្នេរខ្សាច់ វាលទឹក ទីលានបាល់បោះនិងទីលានប្រកួត សួនកុមារ កន្លែងបោះជំរុំ អាងហែលទឹក កន្លែងបាញ់ថ្នាំ កន្លែងជិះស្គីចុះទួល ផ្លូវលំ និងកន្លែងជិះស្គីលើទឹកកក។ ក្នុងនាមជាភ្នាក់ងារកាន់កាប់ដីធ្លីដ៏ធំបំផុតមួយនៅក្នុងសហគមន៍ខំមិនវែល ដែលមានកន្លែងនិងសួនកម្សាន្តជាច្រើនក្នុងសហគមន៍ទូទាំងរដ្ឋ DCR អាចដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាឱ្យមានសិទ្ធិទទួលបានដោយសមធម៌ក្នុងការចូលប្រើប្រាស់ធនធានធម្មជាតិ វប្បធម៌ និងកម្សាន្ត និងការចូលរួមដ៏មានអត្ថន័យរបស់មនុស្ស និងសហគមន៍ទាំងអស់ក្នុងការគ្រប់គ្រងរបស់ពួកគេ។

រូបថតលម្អិតបន្ថែមទៀតពីមូលដ្ឋានទិន្នន័យគ្រប់គ្រងទ្រព្យសកម្មរបស់ DCR បង្ហាញថា DCR កាន់កាប់ ឬគ្រប់គ្រងអគារ និងបសិដ្ឋកម្មជាង 3,996 នៅទូទាំងសហគមន៍ខំមិនវែល។ ជិត 25% (981) នៃអគារទាំងនេះស្ថិតនៅក្នុងក្រុមប្លុកដែលត្រូវ នឹងការចាត់ថ្នាក់របស់ EEA នៃក្រុមប្លុកយុត្តិធម៌បរិស្ថាន[1]។ ក្រៅពីក្រុមអគារទាំងនេះ 15%

---

[1]នៅរដ្ឋម៉ាសាជូសេត តំបន់មួយត្រូវបានកំណត់ថាជាតំបន់ប្រជាជនយុត្តិធម៌បរិស្ថាន ប្រសិនបើចំណុចណាមួយខាងក្រោមជាការពិត៖

- ប្រាក់ចំណូលគ្រួសារមធ្យមប្រចាំឆ្នាំ គឺមិនលើសពី 65 ភាគរយនៃប្រាក់ចំណូលគ្រួសារមធ្យមប្រចាំឆ្នាំទូទាំងរដ្ឋ
- ប្រជាជនភាគតិចមានចាប់ពី 40 ភាគរយឡើងទៅនៃចំនួនប្រជាជន។
- គ្រួសារចំនួន 25 ភាគរយឡើងទៅ ពុំមានចំណេះដឹងភាសាអង់គ្លេស ឬ

ការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន (EEA) នៃគោលនយោបាយយុត្តិធម៌បរិស្ថាន (EJ) បានដឹកនាំទីភ្នាក់ងារទាំងអស់របស់ EEA ដើម្បីបង្កើតយុទ្ធសាស្រ្តយុត្តិធម៌បរិស្ថានរបស់ខ្លួនផ្ទាល់។ ទីភ្នាក់ងារ EEA ត្រូវពិចារណាថាតើត្រូវរួមបញ្ចូលការគិតគូរពីយុត្តិធម៌បរិស្ថានទៅក្នុងនាយកដ្ឋានរបស់ពួកគេ តាមរយៈគោលនយោបាយ កម្មវិធី ឬយុទ្ធសាស្រ្តដទៃទៀត ដោយរបៀបណា។ ទីភ្នាក់ងារ EEA ត្រូវកំណត់អត្តសញ្ញាណ និងផ្សព្វផ្សាយគម្រោងដែលឧបត្ថម្ភដោយទីភ្នាក់ងារ ការសម្រេចចិត្តផ្តល់មូលនិធិ ការធ្វើបទបញ្ញត្តិ ឬសកម្មភាពផ្សេងទៀតដែលមានបំណងបន្ថែមទៀតនូវយុត្តិធម៌បរិស្ថាននៅទូទាំងសហគមន៍ខំមិនវែល ដើម្បីបង្ហាញពីរបៀបដែលការបែងចែកផលប្រយោជន៍ដោយយុត្តិធម៌ត្រូវបានវាស់វែង។[1] EEA នឹងផ្តល់ការណែនាំដល់ទីភ្នាក់ងាររបស់ខ្លួនក្នុងការបំពេញតាមលក្ខខណ្ឌតម្រូវនៃយុទ្ធសាស្រ្តយុត្តិធម៌បរិស្ថាន។

## យុទ្ធសាស្រ្តយុត្តិធម៌បរិស្ថាន
នាយកដ្ឋានរុក្ខាប្រមាញ់ នេសាទ និងល្បែងកម្សាន្ត រួមមានអង្គភាពចំនួន4 ដែលអង្គភាពនីមួយៗមានការទទួលខុសត្រូវជាច្រើន។ អង្គភាពជលផលសមុទ្រ (DMF) ចាត់ចែងនិងគ្រប់គ្រងដែនទឹកតំបន់ឆ្នេរនៃខំមិនវែល ដោយចេញបទបញ្ញត្តិតាមរយៈគណៈកម្មាធិការប្រឹក្សាយោបល់ជលផលសមុទ្រ (MFAC) ដើម្បីគ្រប់គ្រងការនេសាទសម្រាប់ការកំសាន្ត និងពាណិជ្ជកម្ម។ អង្គភាពជលផលនិងសត្វព្រៃ (DFW) ផ្តោតលើការការពាររុក្ខជាតិនៅលើដី និងថែរក្សាបេតិកភណ្ឌធម្មជាតិ និងកម្មវិធីពពួកសត្វជិតផុតពូជ (NHESP)។ DWF ចេញបទបញ្ញាតាមរយៈក្រុមប្រឹក្សាជលផលនិងសត្វព្រៃ។ បេសកកម្មរបស់អង្គភាពស្តារឡើងវិញប្រព័ន្ធបរិស្ថាន (DER) គឺត្រូវស្តារនិងការពារទន្លេ ដីសើម និងរបាក់ទឹក ដើម្បីបម្រើផលប្រយោជន៍ប្រជាជន និងបរិស្ថាន។ DER ធ្វើការជាមួយសាលាក្រុង អង្គការក្រៅរដ្ឋាភិបាល ទីភ្នាក់ងារ និងម្ចាស់ដី ដើម្បីធ្វើផែនការនិងអនុវត្តគម្រោង មានដូចជាការរុះរើទំនប់ កែលម្អប្រព័ន្ធបង្ហូរទឹក ការស្តារឡើងវិញតំបន់ដីសើមជាប់មាត់សមុទ្រ និងគម្រោងដទៃទៀត។ DER ក៏ផ្តល់ឱកាសមូលនិធិតាមរយៈកម្មវិធីជំនួយផងដែរ។ នាយកដ្ឋានរុក្ខាប្រមាញ់ នេសាទ និងល្បែងកម្សាន្ត ក៏ជាប្រភពនៃការិយាល័យជលផលនិងទូកនេសាទ (OFBA)។ OFBA

---

[1] Theoharides, Kathleen. "គោលនយោបាយយុត្តិធម៌បរិស្ថានរបស់ EEA (ធ្វើបច្ចុប្បន្នភាពឆ្នាំ2021)"។ *យុត្តិធម៌បរិស្ថាន* https://www.mass.gov/doc/environmental-justice-policy6242021-update/download

ផ្តល់ឱកាសសំខាន់សម្រាប់វិស័យការនេសាទកម្សាន្ត និងទីតាំងទូកកម្សាន្ត និងជាដៃគូជាមួយ DMF ដើម្បីសាងសង់ផែនេសាទតាមតំបន់ឆ្នេរ។ OFBA មានឥទ្ធិពលផ្ទាល់លើសិទ្ធិចូលទៅកាន់តំបន់ទឹករបស់សហគមន៍។

យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់ DFG គ្រប់ដណ្តប់លើកម្មវិធី នីតិវិធី គោលនយោបាយ និងសកម្មភាពសំខាន់ៗរបស់ទីភ្នាក់ងារនៅតាមអង្គភាពនីមួយៗ។ យុទ្ធសាស្ត្រនេះត្រូវបានបង្កើតឡើងដើម្បីធានាឱ្យបានថា សកម្មភាពទាំងអស់របស់អង្គភាព ត្រូវបានផ្តល់ជូនទៅពលរដ្ឋទាំងអស់របស់ខំមិនវែល យ៉ាងស្មើភាពគ្នានិងប្រកបដោយសមធម៌។

យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់នាយកដ្ឋានរុក្ខាប្រមាញ់ នេសាទ និងល្បែងកម្សាន្ត នឹងបង្ហាញផ្លូវដល់នាយកដ្ឋាននិងអង្គភាពរបស់យើងឆ្ពោះទៅកាន់ការអនុវត្តគោលនយោបាយយុត្តិធម៌បរិស្ថានរបស់ EEA។ យុទ្ធសាស្ត្ររបស់យើងរួមមានគោលបំណងសំខាន់ៗដូចខាងក្រោមៈ

- ការចាត់វិធានការដើម្បីធានាឱ្យបានថាសារធារណជនអាចមានទំនាក់ទំនងយ៉ាងងាយស្រួលជាមួយបុគ្គលិក DFG ទាក់ទងនឹងការព្រួយបារម្ភអំពីយុត្តិធម៌បរិស្ថាន និងការបង្កើតដំណើរការនៃការដោះស្រាយបណ្តឹងឬសំណើរយ៉ាងត្រឹមត្រូវ
- ការធានាឱ្យមានការដាក់បញ្ចូលសហគមន៍យុត្តិធម៌បរិស្ថាន និងការជម្នះឱ្យបាននូវឧបសគ្គផ្នែកភាសា នៅក្នុងដំណើរការបទបញ្ជា កម្មវិធីអប់រំ ឱកាសទទួលបានជំនួយ និងទទួលបានទីតាំងសាធារណៈថ្មី។
- ផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិករបស់ DFG ដើម្បីលើកកំពស់ការយល់ដឹងលើបញ្ហាយុត្តិធម៌បរិស្ថាន និងដើម្បីជួយឧបត្ថមគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្ររបស់យើង និងប្រមែប្រមូលក្រុមយុត្តិធម៌បរិស្ថានរបស់ DFG សម្រាប់គោលបំណងនេះ។
- អង្គភាពស្តារឡើងវិញប្រព័ន្ធបរិស្ថាននឹងសហការជាមួយ EEA ដើម្បីបង្កើតប្រព័ន្ធសម្រាប់ការដាក់បញ្ចូលយុត្តិធម៌បរិស្ថានជាលក្ខខណ្ឌសម្រាប់ការផ្តល់មូលនិធិ និងជ្រើសរើសគម្រោងអាទិភាព។

## ក្រុមយុត្តិធម៌បរិស្ថានរបស់ DFG

- អ្នកសម្របសម្រួលយុត្តិធម៌បរិស្ថានរបស់ DFG- Mark Reil and James Rossignol
- DER- Beth Lambert នាយក
- DMF- Kevin Creighton CFO
- DFW- Sarah Maier អ្នកគ្រប់គ្រប់ព័ត៌មាន NHESP និង Marison Larson ប្រធានផ្នែកព័ត៌មាននិងអប់រំ
- OFBA Doug Cameron នាយក

ក្រុមយុត្តិធម៌បរិស្ថានរបស់ DFG នឹងឆ្លើយតបរៀងរាល់ឆមាស ដើម្បីដោះស្រាយបញ្ហាដែលបានរៀបរាប់ខាងលើ និងពិគ្រោះយោបល់ជាមួយបុគ្គលិកដ៏សមស្រប ក្នុងការតាក់តែងគោលដៅនិងពេលវេលាជាក់លាក់សម្រាប់អនុវត្តគោលដៅទាំងអស់នោះ។

ព័ត៌មានលម្អិតបន្ថែមលើសកម្មភាព DFG ត្រូវបានរៀបរាប់នៅខាងក្រោមនេះ។

## ការបណ្តុះបណ្តាល

នាយកដ្ឋាននឹងកំណត់អត្តសញ្ញាណបុគ្គលិកមួយក្រុមតូចពីនាយកដ្ឋាននីមួយៗ ដើម្បីធានាឱ្យបានថាបុគ្គលិកនាយកដ្ឋានទាំងអស់បានទទួលការបណ្តុះបណ្តាលត្រឹមត្រូវលើបញ្ហាយុត្តិធម៌បរិស្ថាន និងវិធីសាស្ត្រប្រសើរបំផុតសម្រាប់ការច្របាច់បញ្ចូលការពិនិត្យពិចារណាយុត្តិធម៌បរិស្ថានទៅក្នុងកិច្ចការរបស់ទីភ្នាក់ងារ។ ក្រុមនេះនឹងទទួលខុសត្រូវរៀបចំការបណ្តុះបណ្តាល និងសហការជាមួយកម្មវិធីយុត្តិធម៌បរិស្ថានរបស់ EEA ដើម្បីទទួលបាននូវកម្មវិធីសិក្សាសម្រាប់ឧបករណ៍ផែនទីរបស់យុត្តិធម៌បរិស្ថាន ការចូលរួមរបស់សហគមន៍ និងការបញ្ញត្តិទៅលើសេវាកម្មភាសាសម្រាប់អ្នកដែលមានកម្រិតផ្នែកភាសាអង់គ្លេស។ ការបណ្តុះបណ្តាលនឹងមានសារៈសំខាន់ដើម្បីធានាឱ្យបានថា នាយកដ្ឋានមានលទ្ធភាពអនុវត្តផែនការយុទ្ធសាស្ត្រនេះប្រកបដោយប្រសិទ្ធភាព។ ក្រុមនេះក៏មានតួនាទីក្នុងការធានាឱ្យបានថាផែនការយុទ្ធសាស្ត្របន្តអភិវឌ្ឍជាច្រើនដងទៀត ហើយកម្រិតរង្វាស់ត្រូវបានធ្វើបច្ចុប្បន្នភាព ព្រមទាំងគោលដៅត្រូវបានឆ្លើយតបពីឆ្នាំមួយទៅឆ្នាំមួយទៀត។

## ការទំនាក់ទំនង

DFG ត្រូវបានតម្រូវឱ្យគោរពតាម A&F ព្រឹត្តប័ត្រលេខ16 (គោលនយោបាយទទួលបានភាសា) និងបង្កើតគោលនយោបាយភាសារបស់ខ្លួន ដើម្បីទំនាក់ទំនងជាមួយអ្នកដែលមានកម្រិតផ្នែកភាសាអង់គ្លេស ក្នុងរយៈពេល 6ខែ ចាប់ពីថ្ងៃចូលជាធរមាននៃគោលនយោបាយនេះ ក្រៅពីនេះយុទ្ធសាស្ត្រទំនាក់ទំនង ដែលត្រូវបានគូសបញ្ជាក់នៅខាងក្រោម។

នាយកដ្ឋាននឹងផ្តល់ព័ត៌មានទំនាក់ទំនងស្តីពីយុត្តិធម៌បរិស្ថាន ព្រមទាំងទីតាំងកណ្តាលដើម្បីផ្សព្វផ្សាយស្តីពីសវនាការសាធារណៈ និងការជួបប្រជុំជាសាធារណៈ ដើម្បីធានាឱ្យបានថា សហគមន៍យុត្តិធម៌បរិស្ថានអាចត្រួតពិនិត្យការពិភាក្សាគោលនយោបាយនាពេលខាងមុខ ដែលអាចប៉ះពាល់ដល់សហគមន៍។ នាយកដ្ឋាននឹងផ្តោតលើភាពប្រសើរឡើងនៃទំនាក់ទំនងជាមួយក្រុមសហគមន៍យុត្តធម៌បរិស្ថាន ដែលអាចមានទំនាក់ទំនងផ្ទាល់ជាងមុនជាមួយសហគមន៍មួយចំនួន។

- គេហទំព័រយុត្តិធម៌បរិស្ថាននឹងត្រូវបានបង្កើតឡើងនៅក្នុងគេហទំព័ររបស់នាយកដ្ឋាន នៅត្រឹមថ្ងៃទី1 ខែតុលា ឆ្នាំ2022 ដែលនឹងផ្តល់ជូនសាធារណជននូវព័ត៌មានទំនាក់ទំនងស្តីពីយុត្តិធម៌បរិស្ថាន ការផ្សព្វផ្សាយកិច្ចប្រជុំសាធារណៈទាំងអស់របស់ DFG (ដោយមានជម្រើសប្រែសម្រួល) យុត្តិសាស្ត្រយុត្តិធម៌បរិស្ថានរបស់ DFG និងការភ្ជាប់ព័ត៌មានយុត្តិធម៌បរិស្ថានដ៏សមស្របរបស់ EEA។
- គេហទំព័រនឹងផ្តល់តំណរភ្ជាប់សម្រាប់សាធារណជនដើម្បីដាក់ពាក្យបណ្តឹង ឬទំរង់សំណើសុំព័ត៌មាន ទៅកាន់ខ្សែទំនាក់ទំនងយុត្តិធម៌បរិស្ថាន។

នៅត្រឹមខែកក្កដា ឆ្នាំ2022 DFG ប្តេជ្ញាចិត្តចំពោះការត្រួតពិនិត្យកម្មវិធីរបស់ខ្លួន ដើម្បីបញ្ជាក់ថាតើក្រុមអ្នកយុត្តិធម៌បរិស្ថាន

មានប្រទាក់ក្រឡាគ្នាជាមួយតួនាទីសំខាន់របស់អង្គភាពនីមួយៗ (អង្គភាពចំនួន4) ក្រុមបុគ្គលិកនឹងទទួលការចាត់តាំងសម្រាប់គោលបំណងនោះ។ នៅពេលដែលក្រុមអ្នកយុត្តិធម៌បរិស្ថានទាំងនោះត្រូវបានកំណត់អត្តសញ្ញាណរួចហើយ តម្រូវការផ្នែកភាសានឹងត្រូវវាយតម្លៃ។ ការត្រួតពិនិត្យនេះនឹងជួយអនុវត្តការផ្សព្វផ្សាយរបស់ DFG ទៅកាន់ប្រជាជនទាំងអស់នោះ និងក៏ផ្តល់មគ្គុទ្ទេសក៍ដល់កិច្ចប្រឹងប្រែងរបស់ DFG លើផ្នែកបទបញ្ញា ការផ្តល់មូលនិធិ ការអប់រំ គម្រោងស្តារប្រព័ន្ធបរិស្ថាន និង ទីតាំងសាធារណៈ។

## ការផ្សព្វផ្សាយទៅដល់សហគមន៍យុត្តិធម៌បរិស្ថាន

- បង្កើតនិងប្រើប្រាស់បញ្ជីអង្គការបរិស្ថានសម្រាប់ផ្សព្វផ្សាយ ប្រការនេះនឹងត្រូវបង្កើតឡើង ដោយប្រើប្រាស់បញ្ជីរបស់ EEA ព្រមទាំងការយល់ដឹងនៅក្នុងអង្គភាពនីមួយៗ។
- DFG នឹងប្រើប្រាស់បច្ចេកទេសផ្សព្វផ្សាយខាងក្រោមឱ្យបានសមស្រប ក្នុងការទំនាក់ទំនងអំពីសកម្មភាពអនុម័តបទបញ្ញា មូលនិធិដែលអាចរកបាន និងកម្មវិធីអប់រំ។

    - ការជូនដំណឹងពីកិច្ចប្រជុំសាធារណៈ និងឱកាសទទួលបានមូលនិធិតាមរយៈមធ្យោបាយមិនមែនប្រពៃណី មានដូចជាទីកន្លែងគោរពប្រតិបត្តិសាសនា មជ្ឈមណ្ឌលសហគមន៍ គេហទំព័រសហគមន៍ និងទីតាំងប្រពៃណី មានដូចជាបណ្ណាល័យនិងការិយាល័យរដ្ឋាភិបាលជាដើម។
    - ការប្រើប្រាស់ព្រឹត្តិប័ត្រសារព័ត៌មានផ្តោតលើសហគមន៍និងឬតាមជម្រើសដទៃទៀត ដើម្បីផ្សព្វផ្សាយគម្រោង មានដូចជាស្ថានីយ៍ផ្សាយសម្លេងសាធារណៈនៅមូលដ្ឋាន កាសែតឯកទេស បណ្តាញសង្គម និងកាសែតសហគមន៍ និងប្រព័ន្ធឃោសនាមិនមែនភាសាអង់គ្លេស
    - រៀបចំកិច្ចប្រជុំសាលាក្រុង ឬកិច្ចប្រជុំផ្តោតលើសហគមន៍ ដែលរៀបចំទៅតាមប្រធានបទ សង្កាត់ និងក្រុមផលប្រយោជន៍
    - បើកកិច្ចប្រជុំសហគមន៍ក្នុងអំឡុងចុងសប្តាហ៍ឬពេលល្ងាច នៅតាមទីតាំងណាដែលងាយស្រួល នៅក្បែរមធ្យោបាយធ្វើដំណើរសាធារណៈ និងឬតាមប្រព័ន្ធហ្សូម ឬសេវាប្រហាក់ប្រហែលនេះនៅលើបណ្តាញអ៊ីនធឺណិត ប្រសិនបើមានការស្នើរសុំឬកំណត់ថាមានប្រសិទ្ធភាពខ្លាំងជាងមុនក្នុងការទំនាក់ទំនងដល់ប្រជាជនយុត្តិធម៌បរិស្ថាន
    - ការរៀបចំកិច្ចប្រឹងប្រែងអប់រំសាធារណៈ និងការប្រើប្រាស់ភាសា និងពាក្យពេជន៍របស់ជនសមញ្ញ ដើម្បីធានាឱ្យបានថាសហគមន៍យល់ពីឥទ្ធិពលខ្លាំងនៃគម្រោងនេះ និងអាចផ្តល់លទ្ធផលប្រកបដោយអត្ថន័យ និងធ្វើបទបង្ហាញក្នុងទម្រង់ “ពិព័រណ៍វិទ្យាសាស្ត្រ” ឬការបង្រៀនដែលបំបែកតាមប្រធានបទ។
    - បង្កើតការរក្សាទុកព័ត៌មានមូលដ្ឋាន (បណ្ណាល័យសាធារណៈ ឬមជ្ឈមណ្ឌលសហគមន៍)

ដែលមានភាពងាយស្រួលនិងងាយរកបានសម្រាប់ប្រជាជនយុត្តិធម៌មូលដ្ឋាន ដែលព័ត៌មានពាក់ព័ន្ធនឹងបញ្ហានេះ អាចរកបាន។

- o ការចែកចាយព័ត៌មានដែលសហគមន៍បានប្រមូលរួចហើយ មានដូចជាទីផ្សារកសិករ ទីកន្លែងគោរពប្រតិបត្តិសាសនា ឬពិព័រណ៍នៅក្នុងសង្កាត់។
- o ចែកចាយព័ត៌មានតាមរយៈបណ្តាញសង្គម

- ប្រើប្រាស់បញ្ជីប្រព័ន្ធឃោសនាតាមជម្រើសរបស់យុត្តិធម៌បរិស្ថាន នៅពេលចាំបាច់។ កិច្ចការនេះនឹងត្រូវបង្កើតឡើង ដោយប្រើប្រាស់បញ្ជីរបស់ EEA និងចំណេះដឹងនៅក្នុងអង្គភាពនីមួយៗផង។
- នៅថ្ងៃទី30 ខែមិថុនា ឆ្នាំ2022 DFG នឹងប្រែសម្រួល(ជាភាសាចំនួន10 ក្រៅពីភាសាអង់គ្លេស នៅក្នុងរដ្ឋម៉ាសាជូសេត) នូវឯកសារផ្សព្វផ្សាយសំខាន់ៗ នៅក្នុងកម្មវិធីបរបាញ់សត្វ និងអាជ្ញាបណ្ណជិះទូកនេសាទ។
- នៅត្រឹមថ្ងៃទី30 ខែមិថុនា ឆ្នាំ2022 DFG នឹងគោរពតាមគោលនយោបាយទទួលបានភាសារបស់ A&F ព្រឹត្តិប័ត្រលេខ16[2] ដែលផ្តល់ជូនសេវាកម្មភាសាសម្រាប់ប្រជាជននៅក្នុងខំមិនវែល ដែលមានភាពកម្រិតផ្នែកភាសាអង់គ្លេស។
- ស្របតាមមគ្គុទ្ទេសក៍នៃគោលនយោបាយសិទ្ធិទទួលបានភាសារបស់ A&F ព្រឹត្តិប័ត្រលេខ16 អង្គភាពជលផលសមុទ្រ នឹងធ្វើបច្ចុប្បន្នភាពលើសញ្ញាតំបន់មានគ្រុំ ដោយមាន QR កូដ ដែលផ្តល់ជម្រើសសញ្ញាបកប្រែនៅក្នុងសហគមន៍ដែលមានប្រជាជនមិនចេះនិយាយភាសាអង់គ្លេស (សហការជាមួយ MEP និង DPH) ទីកន្លែងដែល QR កូដមិនមានភាសារបស់ខ្លួននឹងមានសញ្ញាថ្មីជាភាសារបស់វា។ យើងរំពឹងថានឹងមានលទ្ធភាពសម្រេចកិច្ចការនេះនៅត្រឹមពាក់កណ្តាលឆ្នាំ2023។

### ការធ្វើឱ្យមានភាពប្រសើរឡើងនូវការចូលរួមរបស់សហគមន៍យុត្តិធម៌បរិស្ថាន

នាយកដ្ឋានរុក្ខាប្រមាញ់ នេសាទ និងល្បែងកម្សាន្ត ចូលរួមក្នុងការអភិវឌ្ឍន៍បទបញ្ញត្តិ ការគ្រប់គ្រងការផ្តល់ជំនួយ កម្មវិធីអប់រំ គម្រោងការស្តារឡើងវិញនូវប្រព័ន្ធអេកូឡូស៊ី និងទិញ្ជាអង្គុយជាសាធារណៈ។

ដោយសារនាយកដ្ឋានជលផល និងសត្វព្រៃ និងជលផលសមុទ្រ អនុម័តបទបញ្ញត្តិ ទីភ្នាក់ងារនឹងប្រកាន់ខ្ជាប់នូវការអនុវត្តន៍បែបនេះ ដើម្បីធានាឱ្យបានថាប្រជាជនយុត្តិធម៌បរិស្ថានគឺជាអ្នកចូលរួមសកម្មភាពយ៉ាងក្លៀវក្លា នៅក្នុងដំណើរការត្រួតពិនិត្យការអនុម័តបទបញ្ញានេះ។ ការត្រួតពិនិត្យនេះរួមបញ្ចូលការពិនិត្យពិចារណាអំពីរបៀបដែលបទបញ្ញត្តិជាក់លាក់នេះអាចជះឥទ្ធិពលផ្សព្វផ្សាយតាមគោលដៅនិងតាមរបាយប្រជាជន ទៅលើប្រជាជនយុត្តិធម៌បរិស្ថាន

---

[2] ការិយាល័យស្តីពីសិទ្ធិទទួលបាននិងឱកាស។ "គោលនយោបាយទទួលបានភាសានិងមគ្គុទ្ទេសក៍អនុវត្តន៍"។ https://www.mass.gov/doc/language-access-guidelines/download

ដែលទទួលរងផលប៉ះពាល់។ ដំណើរការនេះនឹងរាប់បញ្ចូលទាំងការវិភាគអំពី
របៀបដែលបទបញ្ញត្តិថ្មីនឹងផ្តល់ផលប្រយោជន៍
ឬជះឥទ្ធិពលអវិជ្ជមានលើសង្កាត់យុត្តិធម៌បរិស្ថាន។

ដំណើរការរដ្ឋបាលមូលនិធិ ត្រូវបានអនុវត្តដោយអង្គភាព3 ក្នុងចំណោម4
អង្គភាពនៅក្នុងនាយកដ្ឋាន។
ការពិនិត្យឡើងវិញនូវរដ្ឋបាលមូលនិធិនឹងត្រូវបំពេញដោយក្រុមយុត្តិធម៌បរិស្ថានរបស់ DFG
ដោយមានជំនួយពីកម្មវិធីយុត្តិធម៌បរិស្ថានរបស់ EEA
ដើម្បីធានាឱ្យបានថាដំណើរការនៃការផ្តល់នេះអនុវត្តតាមវិធីសាស្រ្តដ៏ល្អបំផុត
ដើម្បីធានាថាសហគមន៍យុត្តិធម៌បរិស្ថាននឹងមិនទទួលបានគុណវិបត្តិណាមួយទេ
នៅពេលដាក់ពាក្យស្នើសុំកម្មវិធីមូលនិធិរបស់យើង។
ការត្រួតពិនិត្យឡើងវិញនឹងផ្តោតលើលក្ខខណ្ឌតម្រូវពិន្ទុសម្រាប់ពាក្យស្នើសុំ
ព្រមទាំងផ្តល់ពិន្ទុបន្ថែមសម្រាប់អ្នកស្នើសុំទាំងអស់នោះ
ដែលមានឥទ្ធិពលជាវិជ្ជមានដល់ប្រជាជនយុត្តិធម៌មូលដ្ឋាន
និងដៃគូជាមួយអង្គការយុត្តិធម៌បរិស្ថាន នៅក្នុងការអនុវត្តន៍របស់ខ្លួន។

កម្មវិធីអប់រំត្រូវបានគ្រប់គ្រងដោយនាយកដ្ឋានចំនួន3 ក្នុងចំណោម4 និងអាចរកបាននៅតាមវិស័យសាធារណៈ។ នាយកដ្ឋាននឹងសហការជាមួយផ្នែកនានាដើម្បីធានាឱ្យបានថា
កម្មវិធីអប់រំរបស់យើងបានកំណត់គោលដៅច្បាស់លាស់ចំពោះសហគមន៍យុត្តិធម៌បរិស្ថាននៅពេលចាំបាច់ ដើម្បីធានាថាគ្រប់គ្នាទទួលបានឱកាសស្មើគ្នានៅទូទាំងខំមិនវែល។
ការផ្សព្វផ្សាយភាសាសម្រាប់កម្មវិធីទាំងអស់នេះ
នឹងមានភាពស៊ីចង្វាក់គ្នាជាមួយនឹងផែនការទទួលបានភាសារបស់ A&F និងចំណងទី VI
នៃច្បាប់សិទ្ធិពលរដ្ឋសហរដ្ឋអាមេរិក ឆ្នាំ1964។
កម្មវិធីអប់រំដែលត្រូវបានផ្តល់ជូនរាប់បញ្ចូលដោយមិនកំណត់ពី ការអប់រំអំពីការបរបាញ់សត្វ (Hunter Education) ការអប់រំពីការប្រើព្រួញ (Arcgery Education) ការអប់រំអំពីការរៀបអន្ទាក់ (Trapping Edducation) ការអប់រំអំពីសន្ទូច (Angler Education) ការអប់រំពីសន្ទូចទឹកប្រៃ (Saltwater Angler Education) និងការបង្រៀនដោយប្រើសត្វត្រីត្រៅ (Teaching with Trout)។

អង្គភាពស្តារប្រព័ន្ធបរិស្ថានធ្វើការជាដៃគូជាមួយសាលាក្រុង សង្គមស៊ីវិល ទីភ្នាក់ងារ ម្ចាស់ដី
និងអ្នកដទៃទៀត ដើម្បីរៀបចំផែនការ
និងអនុវត្តគម្រោងស្តារដែនជម្រកក្នុងទឹកតាមរយៈកម្មវិធីរបស់គម្រោងអាទិភាព របស់ខ្លួន។
ប្រភេទគម្រោងរាប់បញ្ចូលទាំង ការរំលាយទំនប់ ការធ្វើឱ្យប្រព័ន្ធបង្ហូរទឹកប្រសើរឡើង
ការស្តារឡើងវិញតំបន់ដីសើមតំបន់ឆ្នេរ និងការស្តារឡើងវិញតំបន់ដីសើមទឹកសាប។
នាយកដ្ឋាននិង DER ធ្វើការរួមគ្នាដើម្បីធ្វើបច្ចុប្បន្នភាពស្តីពី
របៀបនៃការពិចារណាលើយុត្តិធម៌បរិស្ថានត្រូវបានត្រួតពិនិត្យ និងផ្តល់ពិន្ទុ
ក្នុងអំឡុងដំណើរការជ្រើសរើសគម្រោងអាទិភាព។

ទីតាំងសាធារណៈសម្រាប់គម្រោងនេះមានដូចជាជម្រាលទូក និងផែនេសាទ ត្រូវបំពេញដោយ
ការិយាល័យផ្តល់សិទ្ធិនេសាទ និងទូក (Office of Fishing and Boating Access)
ព្រមទាំងអង្គភាពជនផលសមុទ្រ (Division of Marine Fisheries)។

គណៈកម្មាធិការអភិវឌ្ឍន៍សកម្មភាពកម្សាន្តជលផលសមុទ្រ
បានដើរតួនាទីសំខាន់នៅក្នុងទីតាំងសាធារណៈ។
នាយកដ្ឋាននឹងសហការណ៍ជាមួយគណៈកម្មាធិការនេះ
ដើម្បីធានាឱ្យបានថាដំណើរការនៅមានជាអត្ថិភាព ដើម្បីធានាថាប្រជាជនយុត្តិធម៌បរិស្ថាន
ទទួលផលប្រយោជន៍ស្មើៗគ្នាពីទីតាំងនៃគម្រោងទាំងអស់នេះ។

នាយកដ្ឋានរុក្ខាប្រមាញ់ នេសាទ និងល្បែងកម្សាន្ត
អនុវត្តបទបញ្ញត្តិដែលជះឥទ្ធិពលផ្ទាល់ទៅលើជនជាតិដើមរបស់ខំមិនវែល។ នាយកដ្ឋាននេះ
និងអង្គភាពបទបញ្ញត្តិរបស់យើងទទួលស្គាល់ថា
ច្បាប់សហព័ន្ធនិងរដ្ឋការពារសិទ្ធិរបស់ជនជាតិដើម។
យើងនឹងបន្តធ្វើការជាមួយមេដឹកនាំកុលសម្ព័ន្ធ
ដែលកុលសម្ព័ន្ធនោះទទួលស្គាល់ដោយសហព័ន្ធនិងរដ្ឋផង ដោយសារបទបញ្ញត្តិត្រូវបានអនុម័ត
ដែលបានជះឥទ្ធិពលលើសកម្មភាពបរបាញ់និងនេសាទនៅក្នុងដែនទឹក និងនៅលើគោក
ដែលត្រូវបាននិយ័ត្តកម្មដោយនាយកដ្ឋានជលផលនិងសត្វព្រៃ (The Division of Fisheries and Wildlife) ព្រមទាំងអង្គភាពជលផលសមុទ្រ (The Division of Marine Fisheries)។
បញ្ជីទំនាក់ទំនងរបស់កុលសម្ព័ន្ធនឹងត្រូវបានបង្កើតឡើង
ដោយមានជំនួយពីកម្មវិធីយុត្តិធម៌បរិស្ថានរបស់ EEA
និងត្រូវបានប្រើប្រាស់ដើម្បីសម្រួលដល់ការទាក់ទងគ្នាទៅវិញទៅមក។

## ការជួលបុគ្គលិក

DFG ទទួលស្គាល់អំពីសារៈសំខាន់នៃកម្លាំងការងាររបស់ទីភ្នាក់ងារ
ដែលឆ្លុះបញ្ចាំងពីភាពចម្រុះនៃសាសន៍ ជនជាតិភាគតិច
និងសេដ្ឋកិច្ចសង្គមរបស់ពលរដ្ឋនៃរដ្ឋម៉ាសាជូសេត ដោយរាប់
បញ្ចូលទាំងតួនាទីស្នូលដែលកម្លាំងការងារបានធ្វើដើម្បីលើកកំពស់ការសម្រេចចិត្តប្រកប
ដោយភាពស្មើភាពគ្នា ទាក់ទងនឹងការអនុញ្ញាត ទីតាំង ការបង្កើតបទបញ្ជារ
និងការបែងចែកនិងការអនុវត្តមូលនិធិ។ DFG
ប្តេជ្ញាក្នុងការបញ្ចូលការអនុវត្តការជួលភាពចម្រុះ
និងផ្តល់ការបណ្តុះបណ្តាលសម្រាប់អ្នកគ្រប់គ្រងការជួល។
ការធ្វើបែបនេះនឹងជំរុញឱ្យមានការសម្រេចចិត្តស្មើភាពគ្នា
ដោយប្រើប្រាស់លក្ខខណ្ឌតម្រូវសម្រាប់ការផ្សព្វផ្សាយការងារ
ដែលទាមទាឱ្យអ្នកដាក់ពាក្យជំដោគជ័យបង្ហាញចំណេះដឹងនិងការយល់ដឹងអំពីតម្រូវការរបស់
ប្រជាជនងាយទទួលរងគ្រោះ សង្កាត់យុត្តិធម៌បរិស្ថាន និងតំបន់ក្រីក្ររបស់ខំមិនវែល។

## រង្វាស់សម្រាប់ភាពជោគជ័យ

- នាយកដ្ឋានរុក្ខាប្រមាញ់ នេសាទ និងល្បែងកម្សាន្ត នឹងអនុវត្តយុទ្ធសាស្ត្រនេះដោយចាប់ផ្តើមពីឆ្នាំសារពើពន្ធ23 (FY23) និងប្រើប្រាស់រង្វាស់ម៉ែត្រខាងក្រោមដើម្បីកំណត់ថានាយកដ្ឋាននាយកដ្ឋានកំពុងដំណើរការ។
    - តាមដាននូវរាល់សំណើរសុំព័ត៌មានទាំងអស់ ឬពាក្យបណ្តឹង ដែលទទួលបានតាមរយៈខ្សែបណ្តាញរបស់យុត្តិធម៌បរិស្ថានរបស់ DFG។

- តាមដានចំនួនថវិកាដែលបានចំណាយលើការប្រែសម្រួលភាសា/បកប្រែផ្ទាល់មាត់ នៅក្នុងកិច្ចប្រជុំសាធារណៈ
- តាមដានចំនួនមូលនិធិ ដែលផ្តល់ជូនដើម្បីជាប្រយោជន៍សម្រាប់សហគមន៍យុត្តិធម៌បរិស្ថាន។
- តាមដានថាតើស្លាកសញ្ញាតំបន់សំបកខ្យង (shellfish area) ត្រូវបានធ្វើបច្ចុប្បន្នភាព។
- តាមដានការជួលបុគ្គលិកមកបម្រើការងារដែលអាចនិយាយភាសាបានច្រើន និងឆ្លុះបញ្ចាំងពីភាពចម្រុះនៃជាតិសាសន៍ ជនជាតិភាគតិច និងសេដ្ឋកិច្ចសង្គមនៃពលរដ្ឋរបស់រដ្ឋម៉ាសាជូសេត។
- តាមដានមើលពីទីតាំងនៃតំបន់ថ្មី ដែលបានកំណត់ដោយសហគមន៍យុត្តិធម៌បរិស្ថាន។
- DER នឹងរួមបញ្ចូលការពិនិត្យពិចារណារបស់យុត្តិធម៌បរិស្ថានទៅក្នុងកម្មវិធីជំនួយមូលនិធិជំនួសប្រព័ន្ធបង្ហូរទឹករបស់សាលាក្រុង ព្រមទាំងចែករំលែកមេរៀនដែលទទួលបានពីអង្គភាពផ្សេងទៀត។
- ក្រុមយុត្តិធម៌បរិស្ថានផ្ទៃក្នុងរបស់ DFG នឹងត្រូវបានបង្កើតឡើងដោយសមាជិកម្នាក់ពីអង្គភាពនីមួយៗ និងការបណ្តុះបណ្តាលទូទាំងនាយកដ្ឋានយ៉ាងតិចម្តង នឹងត្រូវបញ្ចប់នៅត្រឹមថ្ងៃទី1 ខែមីនា ឆ្នាំ2022 ដោយមានការបណ្តុះបណ្តាលបន្តនាពេលអនាគត។

## ការអនុវត្តយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់ការិយាល័យប្រតិបត្តិផ្នែកថាមពល និងកិច្ចការបរិស្ថាន

ពាក់ព័ន្ធនឹងក្តីបារម្ភ ពាក្យបណ្តឹង ការបំពេញបន្ថែម ឬគំនិតផ្សេងៗពាក់ព័ន្ធនឹង យុត្តិធម៌បរិស្ថាន ឬដើម្បីស្វែងយល់បន្ថែមអំពីកិច្ចខិតខំប្រឹងប្រែងផ្នែកយុត្តិធម៌បរិស្ថាន ថាមពល និងអាកាសធាតុរបស់ទីភ្នាក់ងារយើង សូមទាក់ទងការិយាល័យយុត្តិធម៌បរិស្ថានរបស់ EEA ដែលមានចែងនៅទំព័រទី 19 នៃយុទ្ធសាស្ត្របរិស្ថានរបស់ EEA។

### ទំនាក់ទំនងមកកាន់យុត្តិធម៌បរិស្ថានរបស់ DFG៖

James “Jimmy” Rossignol
អ្នកជីវសាស្ត្រផ្នែកទឹក
james.rossignol@mass.gov
774-849-0133

# នាយកដ្ឋានធនធានថាមពល

DOER

Massachusetts Department of Energy Resources

# យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន

ព្រាង

# តារាងមាតិកា

**នាយកដ្ឋានធនធានថាមពល ... 111**

សេចក្តីផ្តើម ... 113

សារតារនៃយុត្តិធម៌បរិស្ថាន ... 113

*លក្ខខណ្ឌតម្រូវរបស់លេខាធិការដ្ឋានដែលចេញពីគោលនយោបាយ EEA EJ ... 113*

*សិទ្ធិអំណាចតាមផ្លូវច្បាប់ ... 113*

និយមន័យសំខាន់ៗ ... 114

សារតាររបស់ DOER ... 115

យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន ... 117

*ផែនការអនុវត្តន៍ ... 120*

*ការជួលបុគ្គលិក ... 120*

*សន្និដ្ឋាន ... 120*

ការអនុវត្តយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់ការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន ... 121

# នាយកដ្ឋានធនធានថាមពល

## សេចក្តីផ្តើម

បេសកកម្មរបស់នាយកដ្ឋានធនធានថាមពលរដ្ឋម៉ាសាជូសេត (DOER ឬនាយកដ្ឋាន) គឺត្រូវបង្កើតឡើងដើម្បីអភិវឌ្ឍនិងអនុវត្តគោលនយោបាយនិងកម្មវិធី ដែលសំដៅដល់ការធានាបាននូវភាពគ្រប់គ្រាន់ សន្តិសុខ ភាពចម្រុះ និងប្រសិទ្ធភាពនៃការចំណាយលើការផ្គត់ផ្គង់ថាមពលរបស់ខំមិនវែល ដើម្បីបង្កើតឡើងនូវថាមពលស្អាត តម្លៃសមរម្យ សមភាព និងមានភាពធន់សម្រាប់ពលរដ្ឋ វិស័យជំនួញ សហគមន៍ និងស្ថាប័ននានាក្នុងពេលអនាគត។

## សារតារនៃយុត្តិធម៌បរិស្ថាន

### លក្ខខណ្ឌតម្រូវរបស់លេខាធិការដ្ឋានដែលចេញពីគោលនយោបាយ EEA EJ

ការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន (EEA) នៃគោលនយោបាយយុត្តិធម៌បរិស្ថាន (EJ) បានដឹកនាំទីភ្នាក់ងារទាំងអស់របស់ EEA ដើម្បីបង្កើតយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់ខ្លួនផ្ទាល់។ ទីភ្នាក់ងារ EEA ត្រូវពិចារណាថាតើត្រូវរួមបញ្ចូលការគិតគូរពីយុត្តិធម៌បរិស្ថានទៅក្នុងនាយកដ្ឋានរបស់ពួកគេ តាមរយៈគោលនយោបាយ កម្មវិធី ឬយុទ្ធសាស្ត្រដទៃទៀតដោយរបៀបណា។  ទីភ្នាក់ងារ EEA ត្រូវកំណត់អត្តសញ្ញាណ និងជំរុញគម្រោងដែលមានការឧបត្ថម្ភពីទីភ្នាក់ងារ ដោយផ្តល់ប្រាក់ឧបត្ថម្ភដល់ការធ្វើសេចក្តីសម្រេចចិត្ត ការកំណត់វិធាន ឬចំណាត់ការដទៃទៀតដែលមានបំណងក្នុងការលើកកម្ពស់យុត្តិធម៌បរិស្ថានបន្ថែមទៀតនៅទូទាំងខំមិនវែលទាំងមូល ដើម្បីបង្ហាញពីរបៀបនៃការវាស់វែងការបែងចែកអត្ថប្រយោជន៍ដែលត្រឹមត្រូវ។

### សិទ្ធិអំណាចតាមផ្លូវច្បាប់

ទីភ្នាក់ងារ EEA ទីភ្នាក់ងារ ការិយាល័យ និងកម្មវិធីផ្សេងៗទៀតរបស់ខ្លួនតម្រូវឱ្យគោរពលក្ខខណ្ឌផ្សេងទៀតរបស់រដ្ឋ ដែលធានាបាននូវសមភាពក្នុងការអនុវត្តគោលនយោបាយ កម្មវិធី និងគំនិតផ្តួចផ្តើមរបស់នាយកដ្ឋាន។
អាជ្ញាធរទាំងអស់នេះរួមមានដោយមិនកំណត់ចំពោះ៖គោលនយោបាយយុត្តិធម៌បរិស្ថាន EEA, ជំពូកទី8 នៃច្បាប់ឆ្នាំ2021៖ *ច្បាប់ស្តីពីការបង្កើតផែនទីបង្ហាញផ្លូវជំនាន់ក្រោយសម្រាប់គោលនយោបាយបរិយាកាសរដ្ឋម៉ាសាជូសេត*, បទបញ្ជាផ្នែកប្រតិបត្តិរបស់រដ្ឋម៉ាសាជូសេត EO 526 និង EO 552, និង ការិយាល័យប្រតិបត្តិផ្នែកគោលនយោបាយសិទ្ធិទទួលភាសារបស់រដ្ឋបាលនិងហិរញ្ញវត្ថុ (ព្រឹត្តិប័ត្រលេខ16)។ ក្រៅពីនេះ ដោយសារតែបាន:ជាអ្នកទទួលមូលនិធិពីរដ្ឋាភិបាលសហព័ន្ធ នាយកដ្ឋានត្រូវធានាឱ្យបានថាកម្មវិធីយុត្តិធម៌បរិស្ថានស្របគ្នាជាមួយគោលការណ៍ណែនាំចំណងជើងលេខ VI របស់សហព័ន្ធ ដែលហាមឃាត់មិនឱ្យមានការរើសអើងលើជាតិសាសន៍ ពណ៌សម្បុរ ឬដើមកំណើតឡើយ។[1]

[1] សូមមើលចំណងជើងច្បាប់ទី VI ស្ថិតក្រោមច្បាប់ស្តីពីសិទ្ធិស៊ីវិលឆ្នាំ1964 [https://www.epa.gov/ocr/title-vi-laws-and-regulations], គោលការណ៍ណែនាំ [https://www.epa.gov/ogc/ecrco-guidance-and-policies]

## និយមន័យសំខាន់ៗ

ច្បាប់ស្តីពីការបង្កើតផែនទីបង្ហាញផ្លូវជំនាន់ក្រោយសម្រាប់គោលនយោបាយបរិយាកាសរដ្ឋម៉ាសាជូសេត ដែលបានចែងអំពីនិយមន័យចំនួន 5 ដូចខាងក្រោម។

"យុត្តិធម៌បរិស្ថាន" គឺផ្អែកលើគោលការណ៍ដែលមនុស្សរាល់គ្នាមានសិទ្ធិទទួលបានការការពារពីគ្រោះថ្នាក់បរិស្ថាន និងដើម្បីរស់នៅ និងទទួលបានបរិស្ថានស្អាត និងមានសុខភាពល្អ ដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ សញ្ជាតិកំណើត ប្រាក់ចំណូល ឬសមត្ថភាពចំណេះដឹងភាសាអង់គ្លេសឡើយ។ យុត្តិធម៌បរិស្ថាន គឺជាការការពារស្មើភាពគ្នា និងការចូលរួមប្រកបដោយអត្ថន័យពីសំណាក់ពលរដ្ឋ និងសហគមន៍ពាក់ព័ន្ធនឹងការអភិវឌ្ឍ ការអនុវត្ត និងការពង្រឹងការអនុវត្តច្បាប់ បទបញ្ញត្តិ និងគោលនយោបាយស្តីពីថាមពល បម្រែបម្រួលអាកាសធាតុ និងបរិស្ថាន និងការបែងចែកដោយស្មើភាពគ្នានូវអត្ថប្រយោជន៍និងបន្ទុកបរិស្ថាន និងថាមពល។

"គោលការណ៍យុត្តិធម៌បរិស្ថាន" គាំទ្រដល់ការការពារពលរដ្ឋពីការបំពុលបរិស្ថាន និងសមត្ថភាពក្នុងការរស់នៅ និងទទួលបានបរិស្ថានស្អាត និងមានសុខភាពល្អ ដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ប្រាក់ចំណូល វណ្ណៈ ពិការភាព អត្តសញ្ញាណភេទ ទំនោរផ្លូវភេទ សញ្ជាតិកំណើត ជាតិពន្ធ ឬដូនតា ជំនឿសាសនា ឬសមត្ថភាពចំណេះដឹងភាសាអង់គ្លេសនោះទេ ដែលក្នុងនោះរួមបញ្ចូលនូវ៖ (i) ការចូលរួមប្រកបដោយអត្ថន័យរបស់ពលរដ្ឋពាក់ព័ន្ធនឹងការអភិវឌ្ឍ ការអនុវត្ត និងការពង្រឹងការអនុវត្តច្បាប់ បទបញ្ញត្តិ និងគោលនយោបាយស្តីពីបរិស្ថាន និង (ii) ការបែងចែកដោយស្មើភាពគ្នានូវអត្ថប្រយោជន៍បរិស្ថាននិងថាមពល និងបន្ទុកបរិស្ថាន។

"ក្រុមអ្នកចូលរួមចលនាយុត្តិធម៌បរិស្ថាន" សង្កាត់[2]ដែលបំពេញតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោមចាប់ពី1 ឡើងទៅ៖

- ប្រាក់ចំណូលគ្រួសារជាមធ្យមប្រចាំឆ្នាំគឺមិនលើសពី 65 ភាគរយនៃប្រាក់ចំណូលគ្រួសារជាមធ្យមប្រចាំឆ្នាំរបស់រដ្ឋ[3]
- ជនជាតិភាគតិចមាន 40 ភាគរយឬច្រើនជាងនេះនៃចំនួនប្រជាជន[4]
- សមាជិកគ្រួសារចាប់ពី 25 ភាគរយ ឬច្រើនជាងនេះ ខ្វះសមត្ថភាពជំនាញផ្នែកភាសាអង់គ្លេស[5]

---

[2] "សង្កាត់" សំដៅលើក្រុមសង្កាត់ជំរឿនមួយក្រុមដែលកំណត់ដោយក្រសួងជំរឿនសហរដ្ឋអាមេរិក (U.S. Census Bureau) ប៉ុន្តែមិនរាប់បញ្ចូលពលរដ្ឋដែលរស់នៅក្នុងអន្តេវាសិកដ្ឋានក្នុងមហាវិទ្យាល័យ ឬពលរដ្ឋស្ថិតក្រោមការថែទាំងគ្រប់គ្រងនិងអនុវត្តផ្លូវច្បាប់ ឬស្ថិតក្រោមការឃុំខ្លួន (ឧ.ទា. ពន្ធនាគាររបស់រដ្ឋ ឬសហព័ន្ធ)។

[3] "ប្រាក់ចំណូលទាប" សំដៅលើប្រាក់ចំណូលគ្រួសារមធ្យមប្រចាំឆ្នាំ នៅត្រឹម ឬនៅក្រោម 65 ភាគរយនៃប្រាក់ចំណូលមធ្យមទូទាំងរដ្ឋសម្រាប់រដ្ឋម៉ាសាជូសេត យោងទៅតាមទិន្នន័យជំរឿនរបស់សហព័ន្ធ។

[4] "ប្រជាជនភាគតិច" សំដៅលើបុគ្គលនានាដែលកំណត់ខ្លួនឯងថាជា ជនជាតិឡាទីន/អេស្ប៉ាញ ជនជាតិស្បែកខ្មៅ/អាមេរិកាំងដើមកំណើតអាហ្វ្រិក ជនជាតិអាស៊ី ជនជាតិដើមភាគតិច និងពលរដ្ឋដែលកំណត់ថាខ្លួនឯងមិនមែនជាជនស្បែកស។

[5] "ការនៅដាច់ដោយឡែកខាងភាសាអង់គ្លេស" សំដៅលើគ្រួសារដែលត្រូវបាននៅដាច់ដោយឡែកដោយសារភាសាអង់គ្លេស យោងទៅតាមទម្រង់បែបបទជំរឿនសហព័ន្ធ ឬពុំមានមនុស្សពេញវ័យអាយុច្រើនជាង 14 ឆ្នាំ ដែលនិយាយតែភាសាអង់គ្លេស ឬនិយាយភាសាអង់គ្លេសបានល្អប្រសើរ។

- ប្រជាជនភាគតិចមានចំនួន 25 ភាគរយឡើងទៅ ហើយប្រាក់ចំណូលគ្រួសារមធ្យមប្រចាំឆ្នាំនៃទីក្រុងដែលសង្កាត់នោះមានទីតាំងស្ថិតនៅ គឺមិនលើសពី 150 ភាគរយនៃប្រាក់ចំណូលគ្រួសារមធ្យមប្រចាំឆ្នាំទូទាំងរដ្ឋ។ ឬ
- ចំណែកភូមិសាស្ត្រនៃសង្កាត់មួយដែលបានកំណត់ដោយលេខាធិការជាក្រុមប្រជាជនយុត្តិធម៌បរិស្ថាន ស្របទៅតាមច្បាប់នេះ។

“អត្ថប្រយោជន៍ថាមពល” សំដៅលើការទទួលបានមូលនិធិ ការបណ្តុះបណ្តាល ថាមពលកកើតឡើងវិញ ឬថាមពលផ្សេង ប្រសិទ្ធភាពថាមពល ឬធនធានអត្ថប្រយោជន៍ដទៃផ្សេងទៀត ដែលបានបែកចែកដោយ EEA ទីភ្នាក់ងារ និងការិយាល័យរបស់ខ្លួន។

“អត្ថប្រយោជន៍បរិស្ថាន” សំដៅលើការទទួលបានធនធានធម្មជាតិស្អាត រួមមានខ្យល់អាកាស ធនធានទឹក ទីលំហ ទីធ្លាលេងកម្សាន្តដែលសាងសង់ និងសំណង់បរិក្ខារ និងទីកន្លែងកម្សាន្តសប្បាយនៅក្រៅអគារ វគ្គសិក្សាអំពីថាមពលស្អាតកកើតឡើងវិញ ការអនុវត្តច្បាប់បរិស្ថាន ការបណ្តុះបណ្តាល និងការទទួលបានមូលនិធិដែលបែងចែក និងគ្រប់គ្រងដោយ EEA។

“បន្ទុកបរិស្ថាន” សំដៅលើការបំផ្លាញ ការខូចខាត ឬវិការៈកំបាំងនៃធនធានធម្មជាតិដែលមិនសូវសំខាន់ ដែលបង្កឡើងដោយមូលហេតុអចេតនា ឬមូលហេតុដែលមិនអាចទាយទុកមុនបាន រួមមានជាអាទិ៍ បម្រែបម្រួលអាកាសធាតុ ការបំពុលខ្យល់ ការបំពុលទឹក ការបញ្ចេញទឹកស្អុយមិនត្រឹមត្រូវ ការចាក់បង្ហូរកាកសំណល់រឹង និងសារធាតុពុលដទៃផ្សេងទៀត សំឡេងឮខ្លាំង សកម្មភាពដែលរារាំងដល់ការទទួលបានធនធានធម្មជាតិ និងសំណង់បរិក្ខារនិងទីកន្លែងកម្សាន្តសប្បាយដែលបានសាងសង់នៅខាងក្រៅអគារ ការកែលម្អបំបាត់ការបំពុលមិនគ្រប់គ្រង ការកាត់បន្ថយកម្រិតទឹកក្រោមដី កង្វះគុណភាពទឹក កំណើនគ្រោះទឹកជំនន់ ឬលំហូរទឹកដោយសារខ្យល់ព្យុះ និងការបំផ្លាញផ្លូវទឹក និងបឹងបួរនៅលើកោះ ដីសើម ឆ្នេរសមុទ្រ ទឹក ព្រៃឈើ ទីលំហ និងកន្លែងលេងកម្សាន្តពីការបើកដំណើរការដោយឧស្សាហកម្មឯកជន ពាណិជ្ជកម្ម ឬរដ្ឋាភិបាល ឬសកម្មភាពដទៃផ្សេងទៀតដែលបំពុល ឬផ្លាស់ប្តូរគុណភាពបរិស្ថាន និងបង្កគ្រោះថ្នាក់ដល់សុខភាពបរិស្ថាន។

## សាវតាររបស់ DOER

ខំមិនវែលនៃនាយកដ្ឋានធនធានថាមពលរបស់រដ្ឋម៉ាសាជូសេត គឺជាទីភ្នាក់ងារនៃការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន។
នាយកដ្ឋានបង្កើតនិងអនុវត្តគោលនយោបាយនិងកម្មវិធី
ដែលសំដៅធានាបាននូវភាពគ្រប់គ្រាន់ សន្តិសុខ ភាពចម្រុះ
និងប្រសិទ្ធភាពនៃការចំណាយលើការផ្គត់ផ្គង់ថាមពលរបស់ខំមិនវែល
នៅក្នុងបរិបទនៃការបង្កើតឱ្យមានអនាគតថាមពលស្អាតជាងមុន។
ដើម្បីសម្រេចគោលបំណងនេះ DOER ព្យាយាមៈ

- ធានាឱ្យបាននូវការប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាពលើការចំណាយ
- ខិតខំឱ្យបានជាអតិបរមាក្នុងការបង្កើតធនធានថាមពលស្អាត
- បង្កើតនិងអនុវត្តយុទ្ធសាស្ត្រថាមពលដើម្បីធានាបាននូវការផ្គត់ផ្គង់ដ៏គួរឱ្យទុកចិត្តបាន និងធ្វើឱ្យប្រសើរឡើងនូវតម្លៃនៃថាមពលស្អាត ដែលទាក់ទងនឹងជំនាន់ប្រេងផូស៊ីល។

- គាំទ្រក្រុមហ៊ុនថាមពលស្អាតរបស់រដ្ឋម៉ាសាជូសេត និងជំរុញអត្រាការងារផ្នែកថាមពលស្អាតរបស់រដ្ឋម៉ាសាជូសេត។

មានការទទួលស្គាល់យូរមកហើយដែលថា ការធ្វើអន្តរកាលប្រព័ន្ធថាមពលពីប្រេងផូស៊ីលនិងឆ្ពោះទៅកាន់ថាមពលស្អាតនិងកកើតឡើងវិញមានភាពចាំបាច់ដើម្បីឆ្លើយតបទៅនឹងគោលដៅបរិយាកាស។ តែទោះយ៉ាងណា ការជំនួសធនធានប្រេងផូស៊ីលដោយថាមពលស្អាតនិងកកើតឡើងវិញនឹងមិនកាត់បន្ថយផលប៉ះពាល់យ៉ាងធំធេង ដែលបណ្តាលមកពីចំនួនប្រជាជនខ្វះលទ្ធភាពនិងមានបន្ទុកធ្ងន់មានដូចជាជនជាតិភាគតិច ប្រជាជនមានប្រាក់ចំណូលទាប អ្នកដែលនិយាយភាសាអង់គ្លេសមិនសូវស្ទាត់ជំនាញ កុលសម្ព័ន្ធ និងជនជាតិដើមដែលជួបប្រទះបន្ទុកថាមពលខ្ពស់ជាងមុន[6] អត្រាខ្ពស់ជាងមុននៃអសន្តិសុខថាមពល[7] ហើយថាសហគមន៍ទាំងនេះនឹងទទួលរងគ្រោះនូវផលប៉ះពាល់លើការបម្រែបម្រួលបរិយាកាស។ ដើម្បីកាត់បន្ថយផលប៉ះពាល់ដល់ប្រជាជនទាំងអស់នេះ DOER គាំទ្រសិទ្ធិចំពោះដំណើរការនៃការសម្រេចចិត្ត ដោយរាប់បញ្ចូលទាំងការលើកកម្ពស់តម្លាភាពសិទ្ធិទទួលបានព័ត៌មាន និងការចូលរួមជាសាធារណៈលើគោលនយោបាយ កម្មវិធី និងគំនិតផ្តួចផ្តើមរបស់នាយកដ្ឋាន។

នាយកដ្ឋានមានគោលនយោបាយនិងផ្នែកកម្មវិធីចំនួន 6 ដែលត្រួតពិនិត្យលើគោលនយោបាយ កម្មវិធី និងសកម្មភាពជាច្រើនដែលនឹងពណ៌នាបន្ថែមនៅខាងក្រោម។

- បច្ចេកវិទ្យាថ្មីៗ (Emerging Technology) លើកកំពស់នូវការលេចឡើងនូវបច្ចេកវិទ្យាថ្មីៗសម្រាប់ថាមពលស្អាតនិងវិស័យដឹកជញ្ជូនតាមជម្រើសនៅទូទាំងខំមិនវែល។
- ប្រសិទ្ធភាពថាមពល (Energy Efficiency) បង្កើត អភិវឌ្ឍ អនុវត្ត និងត្រួតពិនិត្យលើកិច្ចប្រឹងប្រែងលើប្រសិទ្ធភាពថាមពលនៅក្នុងខំមិនវែល ស្របជាមួយរដ្ឋនិងទីភ្នាក់ងារសហព័ន្ធផ្សេងទៀត។
- គោលនយោបាយ ផែនការ និងការវិភាគថាមពល (Energy Policy, Planning, and Analysis) ប្រមែប្រមូលនិងវិភាគទិន្នន័យថាមពល ដើម្បីធ្វើការពិនិត្យជាក់លាក់ទៅលើតម្លៃថាមពល ទីផ្សារដែលប្រកួតប្រជែង ភាពធន់ផ្នែកថាមពល និងកិច្ចការផ្សេងទៀតសម្រាប់ខំមិនវែល។
- សហគមន៍បៃតង (Green Communities) ផ្តល់មូលនិធិ ជំនួយបច្ចេកទេស និងការគាំទ្រថ្នាក់មូលដ្ឋានដើម្បីជួយសាលាក្រុងឱ្យកាត់បន្ថយការប្រើប្រាស់និងការចំណាយលើថាមពល តាមរយៈការអនុវត្តគម្រោងថាមពលស្អាត និងប្រសិទ្ធភាពថាមពលនៅតាមអាគារសាលាក្រុង ទីតាំងនានា និងសាលារៀន។
- ថាមពលកកើតឡើងវិញនិងថាមពលជំនួស (Renewable and Alternative Energy) គាំទ្រការអនុវត្តគោលនយោបាយថាមពលរបស់ DOER តាមរយៈកម្មវិធី

[6] បន្ទុកថាមពលត្រូវបានកំណត់ថាជាភាគរយនៃប្រាក់ចំណូលសរុបរបស់គ្រួសារ ដែលបានចំណាយលើការបង់ថាមពល។

[7] អសន្តិសុខថាមពលត្រូវបានកំណត់ថាជាអសមត្ថភាពនៃក្រុមគ្រួសារនីមួយៗដែលមិនអាចឆ្លើយតបតាមសេចក្តីត្រូវការថាមពលជាមូលដ្ឋាន។

និងការជំរុញឱ្យបច្ចេកវិទ្យាថាមពលស្អាតនិងតាមជម្រើស មានដូចជាខ្យល់ ពន្លឺព្រះអាទិត្យ ជីកំប៉ុស និងស្រូបកម្ដៅ។

- ដឹកនាំតាមរយៈធ្វើជាគំរូ សហការជាមួយទីភ្នាក់ងាររដ្ឋ និងសកលវិទ្យាល័យ រួមទាំងមហាវិទ្យាល័យសាធារណៈ ដើម្បីលើកកម្ពស់ថាមពលស្អាត និងការអនុវត្តប្រកបដោយនិរន្តរភាព ដែលកាត់បន្ថយផលប៉ះពាល់បរិស្ថានសម្រាប់ប្រតិបត្តិការរបស់រដ្ឋាភិបាលនៃរដ្ឋនោះ។

## យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន

យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន គឺជាផែនការយុទ្ធសាស្ត្ររបស់នាយកដ្ឋានដើម្បីលើកកម្ពស់យុត្តិធម៌បរិស្ថាន។ កម្មវត្ថុនៃយុទ្ធសាស្ត្រនេះគឺធ្វើឱ្យប្រសើរឡើងនូវលទ្ធផលស្មើភាពគ្នាសម្រាប់សហគមន៍ដែលខ្វះលទ្ធភាព និងមានបន្ទុកធ្ងន់ ដោយរាប់បញ្ចូលដោយមិនកម្រិតនៅត្រឹមចំនួនជនជាតិភាគតិចដែលទទួលផលប៉ះពាល់យ៉ាងខ្លាំង ប្រជាជនមានប្រាក់ចំណូលទាប ប្រជាជនដែលមិនអាចនិយាយភាសាអង់គ្លេសស្ទាត់ជំនាញ កុលសម្ព័ន្ធ និងជនជាតិដើម។ នាយកដ្ឋានប្ដេជ្ញាចិត្តចំពោះគោលការណ៍យុត្តិធម៌បរិស្ថាននៅក្នុងកម្មវិធី គោលនយោបាយ និងសកម្មភាពរបស់ទីភ្នាក់ងារ។ ការប្រព្រឹត្តដោយស្មើភាពគ្នានិងការចូលរួមប្រកបដោយអត្ថន័យគឺជាគោលការណ៍នាំផ្លូវសម្រាប់យុទ្ធ សាស្ត្ររបស់នាយកដ្ឋាន យុទ្ធសាស្ត្រខាងក្រោមគូសបញ្ជាក់ពីចក្ខុវិស័យរបស់នាយកដ្ឋានសម្រាប់យុត្តិធម៌បរិស្ថាន ដោយបង្កើតគោលដៅយុទ្ធសាស្ត្រ និងចងក្រងបញ្ជីឧទាហរណ៍សកម្មភាពសំខាន់ៗ ដែលនាយកដ្ឋានអាចយកមកអនុវត្ត ដើម្បីធ្វើឱ្យមានភាពលូតលាស់នូវគោលដៅដូចខាងក្រោម។

### គោលដៅទី 1៖ *បង្កើនការយល់ដឹងអំពីការពិនិត្យពិចារណាផ្នែកយុត្តិធម៌បរិស្ថានរបស់នាយកដ្ឋានដែលបណ្ដាលមកពីកម្មវិធី គោលនយោបាយ និងសកម្មភាពរបស់ DOER។*

- លើកកម្ពស់ការយល់ដឹងពីបញ្ហាយុត្តិធម៌បរិស្ថានតាមរយៈការបង្កើតឱ្យមានការបណ្ដុះបណ្ដាល អប់រំ និងឱកាសនៃការយល់ដឹងផ្នែកយុត្តិធម៌បរិស្ថាន ដើម្បីធានាឱ្យបានថាបុគ្គលិកបានយល់ដឹងយ៉ាងច្បាស់ពីការទទួលខុសត្រូវរបស់ខ្លួនស្របទៅតាមបទបញ្ញត្តិប្រតិបត្តិនៃរដ្ឋម៉ាសាជូសេត EO 526 និង EO 552។ អប់រំនាយកដ្ឋានដោយប្រើប្រាស់ការបណ្ដុះបណ្ដាលដែលបង្កើតឡើងដោយ EEA ស្ដីពីធនធានយុត្តិធម៌បរិស្ថានដែលអាចរកបាន (ដោយរាប់បញ្ចូលទាំងឧបករណ៍ផែនទីផង) ដើម្បីជួយបុគ្គលិកឱ្យយល់អំពីដំណើរការ និងឧបករណ៍ដែលអាចរកបានដើម្បីជួយឱ្យមានការគោរពតាមគោលនយោបាយយុត្តិធម៌បរិស្ថានរបស់ EEA។
- បង្កើតយុទ្ធសាស្ត្ររបស់នាយកដ្ឋានដើម្បីកំណត់អត្តសញ្ញាណ និងដោះស្រាយការព្រួយបារម្ភផ្នែកយុត្តិធម៌បរិស្ថាន នៅក្នុងកម្មវិធី គោលនយោបាយ និងសកម្មភាពរបស់នាយកដ្ឋាន តាមរយៈការចូលរួមក្នុងក្រុមការងារពិសេសផ្នែកយុត្តិធម៌បរិស្ថានមកពីទីភ្នាក់ងារច្រើនផ្សេងគ្នា ដែលដឹកនាំដោយ EEA។ ផ្ដល់បច្ចុប្បន្នភាពដល់បុគ្គលិកនាយកដ្ឋាន


DOER Massachusetts Department of Energy Resources

ទាក់ទងនឹងសកម្មភាពសំខាន់ៗរបស់លេខាធិការដ្ឋាន ដើម្បីលើកកម្ពស់គោលការណ៍យុត្តិធម៌បរិស្ថាន។

សម្រេចបានលទ្ធផលយុត្តិធម៌បរិស្ថានឱ្យបានល្អជាងមុន និងការកាត់បន្ថយទុរគត៌ភាពដែលអាចវាស់វែងបាន ដែលត្រូវបានបណ្ដុះបណ្ដាលនិងត្រៀមដោះស្រាយបញ្ហាយុត្តិធម៌បរិស្ថានដ៏ស្មុគស្មាញ។ ការបើកការបណ្ដុះបណ្ដាល អប់រំ និងឱកាសយល់ដឹងសម្រាប់បុគ្គលិកទីភ្នាក់ងារ បង្កើនការយល់ដឹងពីបន្ទុកថាមពល និងផលប្រយោជន៍ថាមពលដាច់ដោយឡែកពីគ្នា ដែលប្រជាជនផ្សេងៗគ្នាអាចជួបប្រទះ។ តាមរយៈការបង្កើតចំណេះដឹងមូលដ្ឋាន បុគ្គលិកទីភ្នាក់ងារនឹងត្រៀមខ្លួនបានល្អជាងមុនក្នុងការវិភាគ ពិចារណា និងដោះស្រាយការព្រួយបារម្ភផ្នែកយុត្តិធម៌បរិស្ថាន ក្នុងកម្រិតដែលអាចយកមកអនុវត្តន៍និងគាំទ្រដោយច្បាប់។

*គោលដៅទី 2៖ បញ្ចូលគោលការណ៍យុត្តិធម៌បរិស្ថានទៅក្នុងប្រតិបត្តិការ DOER ដោយរាប់បញ្ចូលទាំងការបង្កើតនិងអនុវត្តគោលនយោបាយ កម្មវិធី និងសកម្មភាព។*

- បង្កើតនិងផ្សព្វផ្សាយព័ត៌មាន និងធនធានដែលគូសបញ្ជាក់ពីឱកាសដើម្បីលើកកម្ពស់គោលការណ៍យុត្តិធម៌បរិស្ថាន នៅក្នុងគោលនយោបាយ កម្មវិធី និងសកម្មភាពរបស់នាយកដ្ឋាន។ បន្តវាយតម្លៃនិងកំណត់ថា តើគោលការណ៍យុត្តិធម៌បរិស្ថានត្រូវបានដាក់បញ្ចូលឱ្យល្អិតល្អន់ ទៅក្នុងសកម្មភាពរបស់នាយកដ្ឋានដែរឬទេ។
- ផ្តល់អាទិភាពគាំទ្រដល់ថាមពលស្អាត និងកិច្ចប្រឹងប្រែងប្រកបដោយចីរភាពនៅក្នុងសហគមន៍យុត្តិធម៌បរិស្ថាន និងសហគមន៍ដែលខ្វះលទ្ធភាព និងមានបន្ទុកធ្ងន់ធ្ងរផ្សេងទៀត នៅពេលដែលកម្មវិធីនិងការពិចារណាលើគោលនយោបាយ និងកត្តាផ្សេងទៀតគឺសមមូលក្នុងអំឡុងពេលនៃការអភិវឌ្ឍកម្មវិធីនិងគោលនយោបាយបែបនេះ។
- ប្រើប្រាស់ឧបករណ៍និងធនធាន មានដូចជាឧបករណ៍មើលផែនទីយុត្តិធម៌បរិស្ថាន របស់ EEA និងនាយកដ្ឋានសុខភាពសាធារណៈនៃរដ្ឋម៉ាសាជូសេត ឧបករណ៍ផែនទីយុត្តិធម៌បរិស្ថាន ដើម្បីលើកម្ពស់ផែនការសហគមន៍រួមគ្នាសម្រាប់ការវាយតម្លៃលើយុត្តិធម៌បរិស្ថាន និងដើម្បីជួយកំណត់ផលប៉ះពាល់ដែលបានកើតឡើង។

ការដាក់បញ្ចូលគោលការណ៍យុត្តិធម៌បរិស្ថាននៅក្នុងដំណើរការនៃការសម្រេចចិត្តរបស់នាយកដ្ឋាន នឹងពង្រឹងសមត្ថភាពរបស់ DOER ដើម្បីដោះស្រាយជាមុននូវរាល់បញ្ហាយុត្តិធម៌បរិស្ថានដ៏ស្មុគស្មាញ និងធានាឱ្យបានថាបុគ្គលិកអាចប្រើប្រាស់នូវការអនុវត្តនិងយុទ្ធសាស្ត្រដ៏ប្រសើរបំផុត ដើម្បីលើកកម្ពស់គោលការណ៍យុត្តិធម៌បរិស្ថាន នៅក្នុងការសម្រេចចិត្តនិងទីតាំងដែលមានសកម្មភាព និងធ្វើឱ្យប្រសើរឡើងនូវលទ្ធផលជាក់ស្តែងសម្រាប់សហគមន៍ដែលមានបន្ទុកធ្ងន់ធ្ងរ។

*គោលដៅទី 3៖ ពង្រឹងការផ្សព្វផ្សាយដល់សហគមន៍និងអ្នកពាក់ព័ន្ធ តាមរយៈការចូលរួមជាសាធារណៈ*

- លើកកម្ពស់ការចូលរួមជាសាធារណៈនៅក្នុងការសម្រេចចិត្តរបស់នាយកដ្ឋាន តាមរយៈការផ្តល់ធនធាន និងជំនួយបច្ចេកទេសដល់អ្នកពាក់ព័ន្ធដើម្បីចូលរួមប្រកបដោយផ្លែផ្កា នៅក្នុងដំណើរការចូលរួមជាសាធារណៈរបស់នាយកដ្ឋាន។
- ធ្វើឱ្យប្រសើរឡើងនូវប្រភពធនធាននៃសិទ្ធិទទួលបានភាសារបស់នាយកដ្ឋាន តាមរយៈការអភិវឌ្ឍផែនការនៃសិទ្ធិទទួលបានភាសានៅទូទាំងនាយកដ្ឋាន ទទួលបានសេវាកម្មភាសា និងកំណត់អត្តសញ្ញាណ និងប្រែសម្រួលឯកសារសំខាន់របស់ទីភ្នាក់ងារឱ្យទៅជាភាសាដែលពាក់ព័ន្ធ។
- រៀបចំកាលវិភាគសម្រាប់សវនាការសាធារណៈ នៅតាមទីតាំងផ្សេងៗគ្នាតាមបែបភូមិសាស្ត្រ នៅទូទាំងខំមិនវែល។

ការបង្កើតឱកាសដើម្បីឱ្យមានការចូលរួមប្រកបដោយអត្ថន័យនៅក្នុងដំណើរការសាធារណៈ គឺជាសមាសភាពមូលដ្ឋាននៃយុត្តិធម៌បរិស្ថាន។ នៅពេលដែលឱកាសចូលរួមប្រកបដោយអត្ថន័យកើតឡើង សហគមន៍មានសិទ្ធិអំណាចក្នុងចាត់វិធានការជាវិជ្ជមាន ដើម្បីសម្រេចបាននូវលទ្ធផលស្មើភាពជាងមុន នៅក្នុងសហគមន៍។ នាយកដ្ឋាននឹងព្យាយាមគាំទ្រការចូលរួមជាសាធារណៈ តាមរយៈការកាត់បន្ថយឧបសគ្គដល់អ្នកចូលរួមក្នុងកម្រិតអតិបរមា។

*គោលដៅទី 4៖ ពង្រីកកិច្ចសហការនិងការចែករំលែកចំណេះដឹងជាមួយដៃគូនៃទីភ្នាក់ងារផ្សេងៗ និងសហគមន៍ ដើម្បីផ្តោតលើធនធានប្រកបដោយប្រសិទ្ធភាព និងជំនួយបច្ចេកទេសរបស់ DOER។*

- សហការជាមួយទីភ្នាក់ងារ EEA ផ្សេងទៀត ដើម្បីកាត់បន្ថយជារួមនូវបន្ទុកបរិស្ថានដែលពាក់ព័ន្ធនឹងថាមពលនិងបង្កើនផលប្រយោជន៍ថាមពលនៅក្នុងសង្កាត់យុត្តិធម៌បរិស្ថាន តំបន់ខ្វះលទ្ធភាព និងសហគមន៍ដែលមានបន្ទុកធ្ងន់ធ្ងរ។ គាំទ្រដល់គំនិតផ្តួចផ្តើម ដែលផ្តោតលើការកសាងសមត្ថភាពរបស់អន្តរទីភ្នាក់ងារ។ កំណត់អត្តសញ្ញាណនិងចែករំលែកមេរៀន និងការអនុវត្តប្រសើរបំផុតជាមួយបុគ្គលិកនាយដ្ឋានស្តីពី របៀបដោះស្រាយការព្រួយបារម្ភលើយុត្តិធម៌បរិស្ថានដែលទទួលបានពីកិច្ចសហការពីអន្តរទីភ្នាក់ងារ។
- តាមរយៈកិច្ចប្រឹងប្រែងផ្សព្វផ្សាយរបស់អ្នកពាក់ព័ន្ធនៅ DOER និង EEA ការស្វែងរកការចូលរួមពីអ្នកពាក់ព័ន្ធ ដើម្បីបង្កើតមគ្គុទ្ទេសយុត្តិធម៌បរិស្ថាន សម្រាប់កម្មវិធីនិងសកម្មភាពដែលផ្តល់មូលនិធិដោយនាយកដ្ឋាន។
- តាមរយៈភាពជាតំណាងនៃ ក្រុមការងារយុត្តិធម៌បរិស្ថាន (EJ Task Force ) របស់ DOER រក្សាឱ្យបាននូវការទំនាក់ទំនងជាមួយបុគ្គលិកយុត្តិធម៌បរិស្ថានរបស់ EEA ស្តីពីគំនិតផ្តួចផ្តើមយុត្តិធម៌បរិស្ថានរបស់ DOER និងផ្តល់នូវរង្វាស់ពាក់ព័ន្ធនឹងយុត្តិធម៌បរិស្ថាន

និងទិន្នន័យដទៃទៀតសម្រាប់ការដាក់បញ្ចូលរបាយការណ៍យុត្តិធម៌បរិស្ថានប្រចាំឆ្នាំរបស់ EEA។

ការពង្រឹងកិច្ចសហការនិងសម្របសម្រួលលើបញ្ហាយុត្តិធម៌បរិស្ថានរវាងទីភ្នាក់ងារ EEA និងអ្នកពាក់ព័ន្ធជាសាធារណៈ ដែលអាចនាំឱ្យមានលទ្ធផលប្រកបដោយសមភាពជាងមុន និងការកាត់បន្ថយបន្ទុកបរិស្ថានដែលកើនឡើង ខណៈបង្កើនផលប្រយោជន៍ថាមពលដែលអាចអនុវត្តនិងផ្តល់ការប្រឹក្សាយោបល់បាន។

## ផែនការអនុវត្តន៍

នាយកដ្ឋាននឹងអភិវឌ្ឍផែនការអនុវត្តន៍ ដែលរាប់បញ្ចូលការណែនាំផ្នែកសម្ភារៈសម្រាប់យុទ្ធសាស្ត្រ ដែលបានគូសបញ្ជាក់នៅក្នុងឯកសារនេះ។ ផែនការអនុវត្តន៍អាចរាប់បញ្ចូលលំហូរពេលវេលាសម្រាប់ធ្វើសកម្មភាព ដែលពិចារណាលើការទទួលខុសត្រូវផ្នែកកម្មវិធី ច្បាប់ និងទំនួលខុសត្រូវលើបទបញ្ញត្តិ។

## ការជួលបុគ្គលិក

DOER ទទួលស្គាល់សារៈសំខាន់នៃកម្លាំងការងាររបស់ទីភ្នាក់ងារ ដែលឆ្លុះបញ្ចាំងពីភាពចម្រុះនៃពលរដ្ឋម៉ាសាជូសេត ដោយផ្អែកលើជាតិសាសន៍ ជាតិពន្ធុ និងសេដ្ឋកិច្ចសង្គម ដោយរាប់បញ្ចូលទាំងតួនាទីសំខាន់ដែលកម្លាំងការងារបែបនេះអាចលើកកម្ពស់ការសម្រេចចិត្តប្រកបដោយសមភាព ទាក់ទងនឹងការអនុវត្តច្បាប់ បទបញ្ញា និងគោលនយោបាយថាមពល បម្រែបម្រួលអាកាសធាតុ និងបរិស្ថាន។ EEA និង DOER ប្តេជ្ញាចិត្តដាក់បញ្ចូលការអនុវត្ត ការជួលបុគ្គលិកពីក្រុមមនុស្សផ្សេងៗគ្នា និងផ្តល់ការបណ្តុះបណ្តាលសម្រាប់ការជួលអ្នកចាត់ចែងការងារ ដើម្បីលើកកម្ពស់ការធ្វើការសម្រេចចិត្តប្រកបដោយសមភាព ទាក់ទងនឹងការជួល ដោយរាប់បញ្ចូលទាំងការប្រើប្រាស់លក្ខខណ្ឌការផ្សព្វផ្សាយជ្រើសរើសបុគ្គលិក ដែលតម្រូវឱ្យអ្នកដាក់ពាក្យបង្ហាញចំណេះដឹង និងការយល់ដឹងពីតម្រូវការរបស់ក្រុមមនុស្សយុត្តិធម៌បរិស្ថាន និងសហគមន៍ដែលមិនមានលទ្ធភាព និងមានបន្ទុកធ្ងន់ធ្ងរនៅក្នុងខំមិនវែល។

## សន្និដ្ឋាន

យុទ្ធសាស្ត្ររបស់នាយកដ្ឋានឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់ខ្លួន ក្នុងការផ្តោតលើក្រុមអ្នកយុត្តិធម៌បរិស្ថាន តាមរយៈការធានាឱ្យបាននូវការប្រព្រឹត្តសមស្រប និងការចូលរួមប្រកបដោយអត្ថន័យសម្រាប់មនុស្សគ្រប់រូប ដោយមិនគិតពីជាតិសាសន៍ ពណ៌សម្បុរ ដើមកំណើត ឬលទ្ធផល ទាក់ទងនឹងការបង្កើតនិងអនុវត្តកម្មវិធី គោលនយោបាយ និងសកម្មភាព។ ការសម្រាលបន្ទុកបរិស្ថាន និងបង្កើនផលប្រយោជន៍ថាមពលនៅក្នុងសង្កាត់យុត្តិធម៌បរិស្ថាន នឹងក្លាយជាដំណើរការបន្តនិងវិវត្តន៍។ នាយកដ្ឋាននឹងតាមដានដំណើរលូតលាស់ ដើម្បីឆ្លើយតបតាមគោលដៅដូចបានគូសបញ្ជាក់នៅក្នុងយុទ្ធសាស្ត្រនេះ តាមរយៈការប្រមូលទិន្នន័យ ដែលត្រូវបានរាយការណ៍នៅក្នុងរបាយការណ៍យុត្តិធម៌បរិស្ថានប្រចាំឆ្នាំរបស់ EEA។ DOER

នឹងត្រួតពិនិត្យយុទ្ធសាស្ត្ររបស់ខ្លួនពីរដងក្នុងមួយឆ្នាំ និងសម្របសម្រួល និងពិគ្រោះយោបល់ជាមួយការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន។

*អំពីគោលនយោបាយនេះ៖ នាយកដ្ឋាននឹងអនុវត្តគោលនយោបាយនេះឱ្យមានភាពស៊ីសង្វាក់ និងស្របទៅតាមកម្រិត ដែលត្រូវបានអនុញ្ញាតដោយច្បាប់ដែលមានស្រាប់ និងបទបញ្ញត្តិដែលអាចអនុវត្តបាន។ គោលនយោបាយនេះមានគោលដៅច្របាច់បញ្ចូលការពិនិត្យពិចារណាលើយុត្តិធម៌បរិស្ថាន ទៅក្នុងគោលនយោបាយ កម្មវិធី និងយុទ្ធសាស្ត្រផ្សេងទៀតរបស់នាយកដ្ឋាន និងមិនមានបំណងបង្កើតសិទ្ធិត្រួតពិនិត្យតាមតុលាការទៅលើការគោរពឬមិនគោរពរបស់នាយកដ្ឋានទេ។ គោលនយោបាយនេះក៏មិនបង្កើតឱ្យមានសិទ្ធិ ផលប្រយោជន៍ ឬការទទួលខុសត្រូវលើទំនុកចិត្ត ដែលជាសារធាតុឬនីតិវិធី ដែលអាចអនុវត្តន៍បាននៅក្នុងច្បាប់ ឬសមភាពដោយភាគីណាមួយ ទៅលើនាយកដ្ឋាន ការចាត់ចែង និយោជិក ឬបុគ្គលផ្សេងៗទៀត។*

## ការអនុវត្តយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់ការិយាល័យប្រតិបត្តិផ្នែកថាមពល និងកិច្ចការបរិស្ថាន

ពាក់ព័ន្ធនឹងក្តីបារម្ភ ពាក្យបណ្តឹង ការបំពេញបន្ថែម ឬគំនិតផ្សេងៗពាក់ព័ន្ធនឹង យុត្តិធម៌បរិស្ថាន ឬដើម្បីស្វែងយល់បន្ថែមអំពីកិច្ចខិតខំប្រឹងប្រែងផ្នែកយុត្តិធម៌បរិស្ថាន ថាមពល និងអាកាសធាតុរបស់ទីភ្នាក់ងារយើង សូមទាក់ទងការិយាល័យយុត្តិធម៌បរិស្ថានរបស់ EEA ដែលមានចែងនៅទំព័រទី 19 នៃយុទ្ធសាស្ត្របរិស្ថានរបស់ EEA។

### ទំនាក់ទំនងមកភ្នាក់ងារយុត្តិធម៌បរិស្ថានរបស់ DOER៖

Danilo Morales
អ្នកចាត់ចែងកម្មវិធីថាមពលស្អាត និងការផ្សព្វផ្សាយ
Danilo.morales@mass.gov

# នាយកដ្ឋានសេវាសាធារណៈ

# យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន

# តារាងមាតិកា

**នាយកដ្ឋានសេវាសាធារណៈ ........ 125**

និយមន័យ ........ 127

សេចក្តីថ្លែងការណ៍បេសកកម្ម ........ 129

សេចក្តីថ្លែងការណ៍របស់អាជ្ញាធរ ........ 129

នាយកដ្ឋានយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន ........ 130

*ការចូលពាក់ព័ន្ធរបស់សាធារណជន និងការចូលរួមរបស់សហគមន៍ ........ 130*

*នាយកដ្ឋានការវិភាគយុត្តិធម៌បរិស្ថាន ........ 132*

*នាយកដ្ឋានក្រុមយុត្តិធម៌បរិស្ថាន ........ 132*

*ខ្នាតរង្វាស់ ........ 132*

*ការបណ្តុះបណ្តាល ឬការបែងចែកធនធាន ........ 132*

*ការអនុវត្តចំពោះភាពទីទៃពីគ្នា និងការជួលបុគ្គលិក ........ 133*

*សំណួរ ........ 133*

ការអនុវត្តយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់ការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន ........ 134

# និយមន័យ

“នាយកដ្ឋាន” ឬ “DPU” មានន័យថា នាយកដ្ឋានសេវាសាធារណៈរដ្ឋម៉ាសាជូសេត។

“អង្គភាព” មានន័យថាជាសាខារបស់នាយកដ្ឋានដែលទទួលខុសត្រូវលើការត្រួតពិនិត្យមើលការងារជាក់លាក់របស់ក្រសួង។

“យុត្តិធម៌បរិស្ថាន”[1] គឺផ្អែកលើគោលការណ៍ដែលមនុស្សរាល់គ្នាមានសិទ្ធិទទួលបានការការពារពីគ្រោះថ្នាក់បរិស្ថាន និងដើម្បីរស់នៅ និងទទួលបានបរិស្ថានស្អាត និងមានសុខភាពល្អ ដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ សញ្ជាតិកំណើត ប្រាក់ចំណូល ឬសមត្ថភាពចំណេះដឹងភាសាអង់គ្លេសឡើយ។ យុត្តិធម៌បរិស្ថាន គឺជាការការពារស្មើភាពគ្នា និងការចូលរួមប្រកបដោយអត្ថន័យពីសំណាក់ពលរដ្ឋ និងសហគមន៍ពាក់ព័ន្ធនឹងការអភិវឌ្ឍ ការអនុវត្ត និងការពង្រឹងការអនុវត្តច្បាប់ បទបញ្ញត្តិ និងគោលនយោបាយស្តីពីថាមពល បម្រែបម្រួលអាកាសធាតុ និងបរិស្ថាន និងការបែងចែកដោយស្មើភាពគ្នានូវអត្ថប្រយោជន៍និងបន្ទុកបរិស្ថាន និងថាមពល។

“ប្រជាជនយុត្តិធម៌បរិស្ថាន (“EJ”)”[2] មានន័យថា៖ (1) សង្កាត់ដែលបំពេញតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោមចាប់ពី 1 ឡើងទៅ៖ (a) ប្រាក់ចំណូលតាមគ្រួសារជាមធ្យមប្រចាំឆ្នាំមិនលើសពី 65 ភាគរយនៃប្រាក់ចំណូលតាមគ្រួសារជាមធ្យមប្រចាំឆ្នាំទូទាំងរដ្ឋ (b) ជនជាតិភាគតិចមានចំនួន 40 ភាគរយឬច្រើនជាងនេះនៃចំនួនប្រជាជន (c) 25 ភាគរយឬច្រើនជាងនេះនៃក្រុមគ្រួសារគ្មានភាពស្ទាត់ជំនាញផ្នែកភាសាអង់គ្លេស ឬ (d) ជនជាតិភាគតិចមានចំនួន 25 ភាគរយឬច្រើនជាងនេះនៃប្រជាជន និងប្រាក់ចំណូលតាមគ្រួសារជាមធ្យមប្រចាំឆ្នាំនៃសាលាក្រុង ដែលសង្កាត់ស្ថិតនៅមិនលើសពី150 ភាគរយនៃប្រាក់ចំណូលតាមគ្រួសារជាមធ្យមប្រចាំឆ្នាំនៅទូទាំងរដ្ឋ ឬ (2) ផ្នែកភូមិសាស្ត្ររបស់សង្កាត់ដែលកំណត់ដោយរដ្ឋមន្ត្រីរបស់ EEA ក្នុងនាមជាប្រជាជនយុត្តិធម៌បរិស្ថានស្របតាមច្បាប់។

“មន្ត្រីសវនាការ” មានន័យថាជាមេធាវី ដែលត្រូវបានចាត់តាំងដោយគណៈកម្មាធិការ[3] ស្របទៅតាម G.L. c. 25, § 4 ដើម្បីធ្វើជាប្រធាននៃនីតិវិធីរបស់នាយកដ្ឋាន។

---

[1] ការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថានរបស់ម៉ាសាជូសេត គោលនយោបាយយុត្តិធម៌បរិស្ថាននៃការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន (“គោលនយោបាយយុត្តិធម៌បរិស្ថាន” ដែលត្រូវបានធ្វើបច្ចុប្បន្នភាពនៅក្នុងឆ្នាំ2021) នៅចំណុចទី3 (ឆ្នាំ2017 បច្ចុប្បន្នភាពនៅថ្ងៃទី24 ខែមិថុនា ឆ្នាំ2021) ដែលអាចរកបាននៅលើគេហទំព័រ www.mass.gov/doc/environmental-justice-policy6242021-update/download។

[2] គោលនយោបាយយុត្តិធម៌បរិស្ថាន (ដែលធ្វើបច្ចុប្បន្នភាពនៅឆ្នាំ2021) នៅទំព័រ4។

[3] នាយកដ្ឋានត្រូវបានត្រួតពិនិត្យដោយសមាជិកគណៈកម្មាធិការចំនួនបីរូប-ដែលតែងតាំងដោយរដ្ឋមន្ត្រីរបស់ EEA ដោយមានការអនុម័តពីអភិបាលរដ្ឋ។ រដ្ឋមន្ត្រីចាត់តាំងស្នងការម្នាក់ធ្វើជាប្រធាន *គណៈកម្មការ DPU* ខំមិនវែល នៃរដ្ឋម៉ាសាជូសេត https://www.mass.gov/guides/the-dpu-commission ( បានចូលមើលចុងក្រោយថ្ងៃទី11 ខែមីនា ឆ្នាំ2021)។

*“ភាពស្ទាត់ជំនាញផ្នែកភាសាអង់គ្លេសមានកម្រិត”*[4] មានន័យថាជាបុគ្គលដែលមិនចេះនិយាយភាសាអង់គ្លេសជាភាសាគោល ហើយសមត្ថភាពមានកម្រិតលើការអាន និយាយ សរសេរ ឬយល់ភាសាអង់គ្លេស។

*“សង្កាត់”*[5] មានន័យថាជាក្រុមជំរឿន ដែលកំណត់ដោយការិយាល័យជំរឿនរបស់សហរដ្ឋអាមេរិក ដោយមិនរាប់បញ្ចូលអ្នកដែលរស់នៅក្នុងអន្តេវាសិកដ្ឋានរបស់មហាវិទ្យាល័យ និងអ្នកដែលរស់នៅក្រោមការថែរក្សា ឬអាណាព្យាបាលគ្រប់គ្រងផ្លូវការ និងតាមផ្លូវច្បាប់ ដោយរាប់បញ្ចូលទាំងពន្ធនាគារសហព័ន្ធ រដ្ឋ ឬតំបន់។

ព្រាង

---

[4] ការិយាល័យប្រតិបត្តិផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ *គោលនយោបាយនិងការណែនាំសម្រាប់ការទទួលបានភាសា 2* (ថ្ងៃទី20 ខែមីនា ឆ្នាំ2015) *អាចរកបាននៅលើគេហទំព័រ* www.mass.gov/doc/language-access-guidelines/download។

[5] គោលនយោបាយយុត្តិធម៌បរិស្ថាន (បច្ចុប្បន្នភាពឆ្នាំ2021) នៅលើទំព័រ4-5

## សេចក្តីថ្លែងការណ៍បេសកកម្ម

នាយកដ្ឋានសេវាសាធារណៈគឺជាទីភ្នាក់ងារជំនុំជម្រះ ដែលគ្រប់គ្រងដោយគណៈកម្មាធិការដែលមានសមាជិកចំនួន 3 រូប។ នាយកដ្ឋានទទួលខុសត្រូវត្រួតពិនិត្យមើលថាមពលអគ្គិសនី ឧស្ម័នធម្មជាតិ និងប្រព័ន្ធទឹកដែលគ្រប់គ្រងដោយវិនិយគិនក្នុងខំមិនវែល។ ក្រៅពីនេះ នាយកដ្ឋានក៏ទទួលខុសត្រូវក្នុងការបង្កើតជម្រើសផ្សេងទៀតចំពោះបទបញ្ញត្តិតាមទម្លាប់ ត្រួតពិនិត្យគុណភាពសេវាកម្ម ធ្វើនិយ័ត្នកម្មលើវិស័យគមនាគមន៍និងសុវត្ថិភាពបំពង់ឧស្ម័ន និងទីតាំងនៃអគារថាមពលមួយចំនួន។

បេសកកម្មរបស់ក្រសួងសុខភាពសាធារណៈ គឺត្រូវធានាឱ្យបានថាសិទ្ធិរបស់អតិថិជនត្រូវបានការពារ ហើយក៏ត្រូវឱ្យប្រាកដថាក្រុមហ៊ុនផ្តល់សេវាកម្មដ៏គួរឱ្យទុកចិត្តបានបំផុត នៅក្នុងតម្លៃទាបបំផុត។ ក្រសួងសុខភាពសាធារណៈត្រួតពិនិត្យសុវត្ថិភាពសាធារណៈពីបញ្ហាគមនាគមន៍ ឧបទ្ទវហេតុពាក់ព័ន្ធនិងបំពង់ឧស្ម័ន និងដំណើរការទីតាំងរោងចក្រថាមពល។[6] ក្រសួងព្យាយាមជំរុញបញ្ហាសុវត្ថិភាព សន្តិសុខ ការជឿទុកចិត្តបានផ្នែកសេវាកម្ម ការអាចទិញបាន សមភាព និងការកាត់បន្ថយការបញ្ចេញចោលនៃឧស្ម័នផ្ទះកញ្ចក់។

## សេចក្តីថ្លែងការណ៍របស់អាជ្ញាធរ

### លក្ខណៈវិនិច្ឆ័យនៃយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់លេខាធិការដ្ឋាន ពីគោលនយោបាយយុត្តិធម៌បរិស្ថានរបស់ EA

គោលនយោបាយយុត្តិធម៌បរិស្ថានរបស់ EA តម្រូវឱ្យទីភ្នាក់ងាររបស់ខ្លួនទាំងអស់បង្កើតយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរៀងៗខ្លួន ដែលសម្របទៅតាមបេសកកម្មរៀងៗខ្លួន។[7] យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់នាយកដ្ឋាន ត្រូវបានរៀបរចនាសម្ព័ន្ធដែលធានាបាននូវការការពារស្មើភាពគ្នា និងការចូលរួមប្រកបអត្ថន័យពីសំណាក់ប្រជាពលរដ្ឋនិងសហគមន៍ទាំងអស់ ទាក់ទងនឹងការអភិវឌ្ឍន៍ ការអនុវត្តន៍ និងគោរពច្បាប់ បទបញ្ញា និងគោលនយោបាយថាមពល បម្រែបម្រួលបរិយាកាស និងបរិស្ថាន ព្រមទាំងការបែងចែកស្មើភាពគ្នាលើផលប្រយោជន៍និងបន្ទុកផ្នែកថាមពលនិងបរិស្ថាន

---

[6]នាយកដ្ឋាន នឹងពិនិត្យវាយតម្លៃឡើងវិញនូវបបនីយភណ្ឌថាមពលជាក់លាក់នានាដែលស្ថិតនៅក្រោមយុត្តាធិការផ្លូវការរបស់ខ្លួន ដែលត្រូវបានសាងសង់ នៅមុនពេល ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបបនីយភណ្ឌថាមពលត្រូវបានបង្កើតឡើងក្នុងឆ្នាំ1973 (ដែលជាទីភ្នាក់ងារមុនរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបបនីយភណ្ឌថាមពល (“ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង”))។ ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង គឺជាទីភ្នាក់ងារឯករាជ្យដែលតាមលក្ខណៈរដ្ឋបាល ស្ថិតនៅក្នុងនាយកដ្ឋានសេវាសាធារណៈ បើទោះបីជាតាមលក្ខន្តិកៈ ក្រុមប្រឹក្សាភិបាលនេះ មិនស្ថិតនៅក្រោមការគ្រប់គ្រងឬការត្រួតពិនិត្យរបស់នាយកដ្ឋានក៏ដោយ។

[7] គោលនយោបាយយុត្តិធម៌បរិស្ថាន (ដែលធ្វើបច្ចុប្បន្នភាពនៅឆ្នាំ2021) នៅទំព័រ10។

ដោយមិនគិតពីជាតិសាសន៍ ពណ៌សម្បុរ ដើមកំណើតជាតិ ប្រាក់ចំណូល ឬភាពស្ទាត់ជំនាញផ្នែកភាសាអង់គ្លេស។

ក្រៅពីយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន ទីភ្នាក់ងារនីមួយៗរបស់ EEA តម្រូវឱ្យបង្កើតផែនការពាក់ព័ន្ធជាមួយសាធារណៈ និងការចូលរួមរបស់សហគមន៍ ដែលបានគូសបញ្ជាក់ពីកិច្ចប្រឹងប្រែងលើកកម្ពស់ឱកាសចូលរួមជាសាធារណៈសម្រាប់សកម្មភាពរបស់ទីភ្នាក់ងារ ដែលជះឥទ្ធិពលដល់ប្រជាជនយុត្តិធម៌បរិស្ថានប្រកបដោយសក្តានុពល។[8] នាយកដ្ឋានមានបំណងធ្វើឱ្យឯកសារនេះក្លាយទៅជាយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានផង និងផែនការពាក់ព័ន្ធជាមួយសាធារណៈ និងការចូលរួមរបស់សហគមន៍។

## នាយកដ្ឋានយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន

យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់នាយកដ្ឋានបង្កើតបាននូវការអនុវត្តនិងគោលការណ៍ដែលមានស្របគ្នាជាមួយលក្ខខណ្ឌនិងបទបញ្ញត្តិ ដើម្បីជំរុញឱ្យមានការពិចារណាលើយុត្តិធម៌បរិស្ថាន នៅក្នុងដំណើរការរបស់ក្រសួងដែលពាក់ព័ន្ធនិងសហគមន៍យុត្តិធម៌បរិស្ថាន។[9] ដូចបានពណ៌នានៅក្នុងសេចក្តីលម្អិតខាងក្រោម នាយកដ្ឋាននឹងព្យាយាមៈ

- លើកកម្ពស់ការចូលរួមរបស់សាធារណៈនៅក្នុងដំណើរការរបស់នាយកដ្ឋាន។
- បន្តវិភាគលើយុត្តិធម៌បរិស្ថាន ដែលត្រូវបានប្រើប្រាស់នៅក្នុងរាល់សកម្មភាពរបស់នាយកដ្ឋាន និងគោលនយោបាយ និងសំណើមុនពេលដែលនាយកដ្ឋានដែលពាក់ព័ន្ធនឹងសហគមន៍យុត្តិធម៌បរិស្ថាន និង
- ជំរុញការបណ្តុះបណ្តាលបុគ្គលិកផ្នែកភាសា និងបញ្ហាយុត្តិធម៌បរិស្ថាន។

### ការចូលពាក់ព័ន្ធរបស់សាធារណជន និងការចូលរួមរបស់សហគមន៍

**ការពង្រឹងការផ្សព្វផ្សាយរបស់សហគមន៍ ឬសាធារណៈ**

នាយកដ្ឋាននឹងព្យាយាមពង្រឹងការចូលរួមពីសាធារណជនសម្រាប់សវនាការនិងដំណើរការរបស់នាយកដ្ឋាន។ នាយកដ្ឋាននឹងៈ

- ព្យាយាមបង្កើនការផ្សព្វផ្សាយអំពីសហគមន៍ ក្នុងកម្រិតដែលស្របទៅតាមច្បាប់ តាមរយៈការបោះផ្សាយសេចក្តីជូនដំណឹងជាសាធារណៈនៅក្នុងទម្រង់ច្រើនយ៉ាង (ឧទាហរណ៍ បណ្តាញសង្គម ប្រព័ន្ធផ្សព្វផ្សាយបោះពុម្ព)។ យ៉ាងហោចណាស់ នាយកដ្ឋាននឹងនាំមកនូវការបោះផ្សាយសេចក្តីជូនដំណឹងបែបនេះ

---

[8] គោលនយោបាយយុត្តិធម៌បរិស្ថាន (ដែលធ្វើបច្ចុប្បន្នភាពនៅឆ្នាំ2021) នៅទំព័រ10។

[9] ក្រុមប្រឹក្សាទីតាំង ស្ថិតក្នុងដំណើរការនៃការបង្កើតយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់ខ្លួន។

នៅលើគេហទំព័រយុត្តិធម៌បរិស្ថាននៃលេខាធិការដ្ឋានរបស់ EEA គេហទំព័ររបស់ក្រសួង និងគេហទំព័ររបស់ក្រុមហ៊ុនយុត្តាធិការដែលពាក់ព័ន្ធ។

- ព្យាយាមផ្សព្វផ្សាយកាលវិភាគសវនាការសាធារណៈនៅគេហទំព័ររបស់នាយកដ្ឋាន ដែលអាចប្រែសម្រួលភាសា និង
- ថែរក្សាចំណុចទំនាក់ទំនងរបស់យុត្តិធម៌បរិស្ថាន ដើម្បីដោះស្រាយបញ្ហាទាក់ទងនឹងការចូលរួមជាមួយសហគមន៍យុត្តិធម៌បរិស្ថាន និងសិទ្ធិទទួលបានភាសា។

**គេហទំព័ររបស់យុត្តិធម៌បរិស្ថាននៃក្រសួង** នាយកដ្ឋាននឹងបង្កើតគេហទំព័រ ដែលធ្វើឡើងសំដៅលើប្រជាជនយុត្តិធម៌បរិស្ថាន ដែលត្រូវផ្សព្វផ្សាយនៅថ្ងៃទី1 ខែធ្នូ ឆ្នាំ2022។ គេហទំព័ររបស់យុត្តិធម៌បរិស្ថាននឹងរក្សាទុកព័ត៌មាន ដែលមានសារៈប្រយោជន៍សម្រាប់ប្រជាជនយុត្តិធម៌បរិស្ថាន ដោយរាប់បញ្ចូលប៉ុន្តែមិនកម្រិតនៅត្រឹមនេះទេ។

- ព័ត៌មានទំនាក់ទំនងសម្រាប់បុគ្គលទំនាក់ទំនងនៃយុត្តិធម៌បរិស្ថានរបស់ក្រសួង
- តំណភ្ជាប់ទៅកាន់គោលនយោបាយបរិស្ថានរបស់ EEA
- តំណភ្ជាប់ទៅកាន់គេហទំព័រគោលនយោបាយបរិស្ថានរបស់ EEA
- តំណភ្ជាប់ទៅកាន់ផែនការទទួលបានភាសា
- ទម្រង់បណ្តឹងមិនរើសអើងចំណងជើងទីVI នៃ EEA
- ព័ត៌មានសម្រាប់អ្នកចេះនិយាយភាសាអង់គ្លេស និងអ្នកដែលមានភាពស្ទាត់ជំនាញខាងភាសាអង់គ្លេស អំពីការស្នើសុំសេវាកម្មបកប្រែ និងប្រែសម្រួលភាសា។
- ការបកប្រែឯកសារសំខាន់ៗដែលពាក់ព័ន្ធនឹងសិទ្ធិរបស់អតិថិជន[10] និង
- បញ្ជីតំណភ្ជាប់សំខាន់ៗដែលមិនចេះរឹងស្ងួតនៅលើគេហទំព័ររបស់នាយកដ្ឋាន ដើម្បីជួយឱ្យអតិថិជនចាត់ចែងវិក័យប័ត្រថាមពល។ តំណភ្ជាប់បែបនេះអាចរាប់បញ្ចូលទាំងព័ត៌មានស្តីពីកម្មវិធីលើកកម្ពស់ថាមពល និងកម្មវិធីគ្រប់គ្រងផ្នែកខាងក្រោយ។

**គោលនយោបាយទទួលបានភាសា**

នាយកដ្ឋានប្តេជ្ញាចិត្តចំពោះការធានាឱ្យបានថាអ្នកដែលភាពកម្រិតផ្នែកភាសាអង់គ្លេសត្រូវបានផ្តល់ឱកាសក្នុងចូលពាក់ព័ន្ធនិងចូលរួមប្រកបដោយអត្ថន័យនៅក្នុងដំណើរការរបស់នាយកដ្ឋាន ស្របតាមលក្ខណៈវិនិច្ឆ័យផ្លូវច្បាប់ ដូចមានចែងក្នុងព្រឹត្តិប័ត្ររដ្ឋបាលលេខ16 នៃការិយាល័យប្រតិបត្តិផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ (A&F) ដូចដែលបានកែតម្រូវនៅថ្ងៃទី20 ខែមីនា ឆ្នាំ2015។ ផែនការទទួលបានភាសារបស់នាយកដ្ឋានពណ៌នាអំពីសេវាកម្ម គោលនយោបាយ និងនីតិវិធីទទួលបានភាសារបស់នាយកដ្ឋាន និងអាចចូលទៅកាន់គេហទំព័រៈ (ផ្តល់ជូនតំណភ្ជាប់ខាងក្រោម)

---

[10] អង្គភាពដែលមានឯកសារពាក់ព័ន្ធ អាចរាប់បញ្ចូលទាំង អង្គភាពត្រួតពិនិត្យគមនាគមន៍ អង្គភាពបណ្តាញក្រុមហ៊ុនដឹកជញ្ជូន អង្គភាពបំពង់បង្ហូរប្រេងនិងសុវត្ថិភាព អង្គភាពទីតាំង និងអង្គភាពអតិថិជន។

### នាយកដ្ឋានការវិភាគយុត្តិធម៌បរិស្ថាន

ដោយស្របតាមច្បាប់ជាធរមាននិងវិសាលភាពនៃអំណាចរបស់នាយកដ្ឋាន នាយកដ្ឋាននឹងបន្តវិភាគសកម្មភាពរបស់ទីភ្នាក់ងារ ដែលអាចមានឥទ្ធិពលទៅដល់ប្រជាជនយុត្តិធម៌បរិស្ថាន វាយតម្លៃយុទ្ធសាស្ត្រដើម្បីដោះស្រាយបញ្ហាព្រួយបារម្ភអំពីយុត្តិធម៌បរិស្ថាន និងជំរុញឱ្យមានការបែងចែកស្មើភាពគ្នាទាក់ទងនឹងផលប្រយោជន៍ និងបន្ទុកថាមពលនិងបរិស្ថាន។

នៅក្នុងពេលចាប់ផ្តើមដំណើរការរបស់នាយកដ្ឋាន មន្ត្រីសវនាការនឹងកំណត់ថា តើដំណើរការមានឥទ្ធិពលទៅលើសង្កាត់ដែលមានប្រជាជនយុត្តិធម៌មូលដ្ឋាន។ លើសពីនេះទៀត ដំណើរការនេះនឹងពាក់ព័ន្ធត្រួតពិនិត្យប្រព័ន្ធទិន្នន័យព័ត៌មានភូមិសាស្ត្រដែលផ្តល់ដោយEEA ដើម្បីកំណត់ថាតើសហគមន៍ប៉ះពាល់ ឬសហគមន៍ឆ្លើយតបតាមលក្ខណៈវិនិច្ឆ័យសម្រាប់ប្រជាជនយុត្តិធម៌បរិស្ថាន។ ប្រសិនបើប្រជាជនយុត្តិធម៌បរិស្ថានត្រូវបានកំណត់ថាទទួលរងគ្រោះដោយសំណើរនោះ មន្ត្រីសវនាការដែលត្រូវបានតែងតាំងនឹងជូនដំណឹងដល់បុគ្គលិកទំនាក់ទំនងរបស់យុត្តិធម៌បរិស្ថាន អ្នកគ្រប់គ្រងសំណុំរឿង និងប្រធានបុគ្គលិក។ មន្ត្រីសវនាការនឹងផ្តល់ការជូនដំណឹងទាក់ទងនឹងដំណើរការស្របតាមយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន។

### នាយកដ្ឋានក្រុមយុត្តិធម៌បរិស្ថាន

ប្រធានបុគ្គលិករបស់នាយកដ្ឋាននឹងបង្កើតក្រុមយុត្តិធម៌បរិស្ថាន ដែលមានសមាសភាពបុគ្គលិកទំនាក់ទំនងនៃយុត្តិធម៌បរិស្ថាន និងអ្នកតំណាង ដែលជ្រើសតាំងដោយប្រធានបុគ្គលិក និងគណៈកម្មាធិការ។ ក្រុមយុត្តិធម៌បរិស្ថាននឹងត្រួតពិនិត្យវិធីសាស្ត្រដ៏ប្រសើរបំផុតម្តងម្កាល ប៉ុន្តែមិនតិចជាងរៀងរាល់ពីរឆ្នាំម្តង ដើម្បីគោរពតាមយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់នាយកដ្ឋាន។

### ខ្នាតរង្វាស់

នាយកដ្ឋាននឹងបង្កើតនិងតាមដានការវាយតម្លៃដូចខាងក្រោម៖

- ការចូលរួមនៅក្នុងសវនាការសាធារណៈ
- ស្ថិតិគេហទំព័រយុត្តិធម៌បរិស្ថាន
- ការស្នើសុំឱ្យមានការបកប្រែដោយអ្នកចូលរួមនៅក្នុងសវនាការសាធារណៈ
- ភាគរយនៃការស្នើសុំឱ្យមានការបកប្រែដែលត្រូវបំពេញ និង
- ចំនួនដំណើរការដែលជះឥទ្ធិពលជាក់លាក់លើសង្កាត់យុត្តិធម៌បរិស្ថាន និងរបៀបដែលការជូនដំណឹងត្រូវបានផ្តល់ជូននៅក្នុងករណីនីមួយៗ

### ការបណ្តុះបណ្តាល ឬការបែងចែកធនធាន

នាយកដ្ឋាននឹងបើកការបណ្តុះបណ្តាលបុគ្គលិកប្រចាំឆ្នាំស្តីពីសិទ្ធិទទួលបានភាសា និងគោលនយោបាយយុត្តិធម៌បរិស្ថានរបស់នាយកដ្ឋាន។ ការបណ្តុះបណ្តាលទាំងនេះនឹងរួមបញ្ចូល៖

- នីតិវិធីរបស់នាយកដ្ឋានដើម្បីស្នើសុំការបកប្រែ និងសេវាកម្មប្រែសម្រួលឯកសារ។

- នីតិវិធីរបស់នាយកដ្ឋានដើម្បីស្នើសុំធ្វើការជាមួយអ្នកបកប្រែដែលជាអ្នកស្ម័គ្រចិត្ត និង
- របៀបប្រើប្រាស់ឱ្យបានជោគជ័យចំពោះជំនួយលើការស្តាប់ និងឧបករណ៍បកប្រែរបស់នាយកដ្ឋាន។

បុគ្គលិកនាយកដ្ឋាននឹងចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលតាមការតម្រូវ ដែលធ្វើឡើងដោយ EEA។ បុគ្គលិកនឹងត្រូវបានលើកទឹកចិត្តតាមជាក់ស្តែងដើម្បីចូលរួមក្នុងវគ្គបណ្តុះបណ្តាលរបស់ EEA ដែលពាក់ព័ន្ធ៖

- ការប្រើប្រាស់ផែនទីរដ្ឋនិងឧបករណ៍ចាក់បញ្ចាំងដែលអាចរកបានដើម្បីកំណត់ទីតាំងសង្កាត់យុត្តិធម៌បរិស្ថាន និងវាយតម្លៃផលប៉ះពាល់របស់គម្រោងនៅក្នុងតំបន់ទាំងនោះ
- និយមន័យ ការអនុវត្តន៍ និងគោលដៅនៃការចូលរួមរបស់អ្នកពាក់ព័ន្ធ និង
- របៀបនៃការសម្គាល់ទីតាំងសង្កាត់យុត្តិធម៌បរិស្ថាន

### ការអនុវត្តចំពោះភាពទីទៃពីគ្នា និងការជួលបុគ្គលិក

ក្រសួងទទួលស្គាល់ពីសារៈសំខាន់នៃមានកម្លាំងការងាររបស់ទីភ្នាក់ងារ ដែលឆ្លុះបញ្ចាំងពីភាពទទៃពីគ្នានៃសាសន៍ ជាតិពន្ធុ និងសេដ្ឋកិច្ចសង្គមសម្រាប់ប្រជាជននៃរដ្ឋម៉ាសាជូសេត ដោយរាប់បញ្ចូលទាំងតួនាទីស្នូល ដែលកម្លាំងការងារនេះបានដើរតួនាទីក្នុងការធ្វើឱ្យប្រសើរឡើងនូវការសម្រេចចិត្តស្មើភាពគ្នា ទាក់ទងនឹងលិខិតអនុញ្ញាត ទីតាំង ការបង្កើតបទបញ្ញត្តិ គោលនយោបាយ និងការអនុវត្តច្បាប់ និងបញ្ហាដទៃទៀតរបស់បរិស្ថាននិងថាមពល ដែលពាក់ព័ន្ធនឹងយុត្តាធិការរបស់នាយកដ្ឋាន។ នាយកដ្ឋានប្តេជ្ញាចិត្តអនុវត្តសេចក្តីណែនាំទាំងអស់របស់ EEA ទាក់ទងនឹងការអនុវត្តលើការជួលមកបម្រើការងារប្រកបដោយសមភាព។

### សំណួរ

តាមរយៈគោលនយោបាយយុត្តិធម៌បរិស្ថានរបស់ EEA និងយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន ក្រសួងធ្វើការឆ្ពោះទៅការធានាឱ្យបាននូវការការពារស្មើភាពគ្នា និងការចូលរួមប្រកបដោយអត្ថន័យសម្រាប់ពលរដ្ឋនិងសហគមន៍ទាំងអស់ ទាក់ទងនឹងការអភិវឌ្ឍ ការអនុវត្ត និងការគោរពច្បាប់ បទបញ្ញត្តិ និងគោលនយោបាយថាមពល បម្រែបម្រួលបរិយាកាស និងបរិស្ថាន ព្រមទាំងការបែងចែកស្មើភាពគ្នាលើផលប្រយោជន៍ និងបន្ទុកថាមពលនិងបរិស្ថាន។

## ការអនុវត្តយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់ការិយាល័យប្រតិបត្តិផ្នែកថាមពល និងកិច្ចការបរិស្ថាន

ពាក់ព័ន្ធនឹងក្តីបារម្ភ ពាក្យបណ្តឹង ការបំពេញបន្ថែម ឬគំនិតផ្សេងៗពាក់ព័ន្ធនឹងយុត្តិធម៌បរិស្ថាន ឬដើម្បីស្វែងយល់បន្ថែមអំពីកិច្ចខិតខំប្រឹងប្រែងផ្នែកយុត្តិធម៌បរិស្ថាន ថាមពល និងអាកាសធាតុរបស់ទីភ្នាក់ងារយើង សូមទាក់ទងការិយាល័យយុត្តិធម៌បរិស្ថានរបស់ EEA ដែលមានចែងនៅទំព័រទី 19 នៃយុទ្ធសាស្ត្របរិស្ថានរបស់ EEA។

ក្រសួងមានឈ្មោះបុគ្គលិកទំនាក់ទំនងរបស់យុត្តិធម៌បរិស្ថាន ដែលរាយឈ្មោះខាងក្រោមនេះ ដើម្បីឆ្លើយសំណួរ ទាក់ទងនឹងយុទ្ធសាស្ត្រ ឬបញ្ហាផ្សេងទៀតពាក់ព័ន្ធនឹងយុត្តិធម៌បរិស្ថាន។

## ព័ត៌មានសម្រាប់ប្រាស្រ័យទាក់ទងផ្នែកយុត្តិធម៌បរិស្ថានរបស់ទីភ្នាក់ងារ៖

Carline L. Lemoine, អ្នកសម្របសម្រួលភាសា
នាយកដ្ឋានសេវាសាធារណៈ
អង្គភាពច្បាប់
One South Station, Fifth Floor
Boston, MA 02110
Carline.Lemoine@mass.gov
(617) 305-3532

ព្រាង

# ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងឋបនីយភណ្ឌថាមពលរដ្ឋម៉ាសាជូសេត (EFSB)
# យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន

ព្រាង

# តារាងមាតិកា

**ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបបនីយភណ្ឌថាមពលរដ្ឋម៉ាសាជូសេត (EFSB) ...................... 132**

សារតារ ........................................................................................................ 134

និយមន័យ ........................................................................................................ 137

កិច្ចដំណើរការសាធារណៈរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB)........................................ 138

*ការទទួលបានព័ត៌មានអំពីគម្រោង.............................................................................. 139*

*ការចែកចាយសេចក្ដីជូនដំណឹង.................................................................................. 139*

*មតិយោបល់សាធារណៈ.................................................................................................. 140*

*ការចូលរួមក្នុងកិច្ចដំណើរការនិតិវិធី ............................................................................ 141*

*ការទទួលបានសេវាភាសា ............................................................................................ 142*

គោលនយោបាយបម្រែបម្រួលអាកាសធាតុ.............................................................................. 142

សង្គតភាពជាមួយច្បាប់ស្ដីពីគោលនយោបាយបរិស្ថានរដ្ឋម៉ាសាជូសេត (MEPA) ................... 143

ការអនុវត្តយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន ......................................................................... 145

*ផែនការស្ដីពីការចូលរួមរបស់សាធារណជននិងការចូលរួមរបស់សហគមន៍......................... 145*

*ផែនការទទួលបានសេវាភាសា........................................................................................ 145*

*ខ្នាតរង្វាស់ ................................................................................................................ 146*

*ការវាយតម្លៃតាមកាលកំណត់........................................................................................ 147*

ការប្ដេជ្ញាចិត្តរបស់កម្លាំងពលកម្ម ............................................................................... 147

សន្និដ្ឋាន ....................................................................................................... 148

ការអនុវត្តយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់ការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន ...................................................................................................... 148

# សាវតារ

## ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបបនីយកណ្ឋាមពល

ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបបនីយកណ្ឋាមពល (“ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង” ឬ “EFSB”) គឺជាក្រុមប្រឹក្សាភិបាលឯករាជ្យថ្នាក់រដ្ឋ ដែលពិនិត្យវាយតម្លៃសំណើកសាងបបនីយកណ្ឋាមពលធំៗ ដោយរួមទាំងបបនីយកណ្ឋផលិតថាមពល ខ្សែបញ្ជូនអគ្គិសនី បំពង់ឧស្ម័នធម្មជាតិនៅក្នុងរដ្ឋ និងអាងស្តុកឧស្ម័នធម្មជាតិ។ ដើម្បីទទួលបានការអនុម័តយល់ព្រមពីក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) អ្នកគាំទ្របបនីយកណ្ឋដែលត្រូវបានស្នើឡើង ត្រូវបង្ហាញថា បបនីយកណ្ឋនោះអាចផ្តល់ ការផ្គត់ផ្គង់ថាមពលដែលអាចជឿទុកចិត្តបាន ដោយមានផលប៉ះពាល់តិចតួចបំផុតទៅលើបរិស្ថាន និងមានតម្លៃទាបបំផុតតាមដែលអាចធ្វើទៅបាន។ នាយកដ្ឋានសេវាសាធារណៈ (“នាយកដ្ឋាន” ឬ “DPU”) ផ្តល់ជំនួយគាំទ្រផ្នែករដ្ឋបាលដល់កិច្ចការរបស់ ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) និងបុគ្គលិករបស់ក្រុមប្រឹក្សាភិបាលនេះ ក៏ប៉ុន្តែ ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) ដែលមានសមាជិក 9រូបនេះ នឹងធ្វើការសម្រេចចិត្តដោយឯករាជ្យថាតើក្រុមប្រឹក្សាភិបាលត្រូវអនុម័តយល់ព្រមឬបដិសេធគម្រោងទាំងនេះ។ បុគ្គលិករបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) ក៏នឹងអនុវត្តនីតិវិធីពាក់ព័ន្ធនឹងការកំណត់ទីតាំងរបស់នាយកដ្ឋានសេវាសាធារណៈ (DPU) ដែលមិនស្ថិតនៅក្នុងយុត្តាធិការរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) ផងដែរ។[1]

## គោលនយោបាយរបស់ខំមិនវែល

ជាផ្នែកមួយនៃការពិនិត្យវាយតម្លៃឡើងវិញនូវបបនីយកណ្ឋដែលស្ថិតក្រោមយុត្តាធិការរបស់ខ្លួន ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង ត្រូវពិចារណាថាតើផែនការរបស់អ្នកស្នើសុំ ការសាងសង់ស្របជាមួយនឹងគោលនយោបាយ សុខាភិបាល កិច្ចការពារបរិស្ថាន ការប្រើប្រាស់ធនធាន និងការអភិវឌ្ឍ នាពេលបច្ចុប្បន្ន ដែលត្រូវបានអនុម័តដោយខំមិនវែល ដែរឬទេ។ G.L. c. 164, § 69J. សូមអាន G.L. c. 164, § 69J¼ (ដែលតម្រូវឱ្យមានសង្គតភាពជាមួយគោលនយោបាយសុខាភិបាល កិច្ចការពារបរិស្ថាន និងថាមពល នាពេលបច្ចុប្បន្ន)។ ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងពិចារណាទៅលើគោលនយោបាយចម្រុះផ្សេងៗគ្នា ដោយរួមទាំងគោលនយោបាយយុត្តិធម៌បរិស្ថានរបស់ការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន (EEA)[2] និងគោ

---

[1]នាយកដ្ឋាន នឹងពិនិត្យវាយតម្លៃឡើងវិញនូវបបនីយកណ្ឋាមពលជាក់លាក់នានាដែលស្ថិតនៅក្រោមយុត្តាធិការរបស់ខ្លួន ដែលត្រូវបានសាងសង់ នៅមុនពេល ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបបនីយកណ្ឋាមពលត្រូវបានបង្កើតឡើងក្នុងឆ្នាំ1973 (ដែលជាទីភ្នាក់ងារមុនរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបបនីយកណ្ឋាមពល (“ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង”))។ ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង គឺជាទីភ្នាក់ងារឯករាជ្យដែលតាមលក្ខណៈរដ្ឋបាល ស្ថិតនៅក្នុងនាយកដ្ឋានសេវាសាធារណៈ បើទោះបីជាតាមលក្ខន្តិកៈ ក្រុមប្រឹក្សាភិបាលនេះ មិនស្ថិតនៅក្រោមការគ្រប់គ្រងឬការត្រួតពិនិត្យរបស់នាយកដ្ឋានក៏ដោយ។

[2]គោលនយោបាយយុត្តិធម៌បរិស្ថាន មាននៅ៖ https://www.mass.gov/doc/environmental-justice-policy6242021-update/download (បានធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី24 ខែមិថុនា ឆ្នាំ2021)។ គោលនយោបាយយុត្តិធម៌បរិស្ថាន ក៏ត្រូវអនុវត្តចំពោះ ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) ផងដែរ។ សូមអាន ផ្នែក 20។

លនយោបាយទទួលបានសេវាភាសារបស់ខំមិនវែល (ព្រឹត្តិប័ត្ររដ្ឋបាលនិងហិរញ្ញវត្ថុ លេខ16) ផងដែរ។[3][4]

ផ្នែកទី13 នៃគោលនយោបាយយុត្តិធម៌បរិស្ថាន ណែនាំឱ្យទីភ្នាក់ងាររបស់ការិយាល័យប្រតិបត្តិ ផ្នែកថាមពលនិងកិច្ចការបរិស្ថាន (EEA) "អភិវឌ្ឍបង្កើតយុទ្ធសាស្ត្រផ្ទាល់របស់ពួកគេ ដើម្បីពង្រឹង លើកកម្ពស់យុត្តិធម៌បរិស្ថានបែបបុរេសកម្ម នៅគ្រប់សង្កាត់ទាំងអស់ តាមវិធីសាស្ត្រមួយដែលត្រូវបានរៀបចំរចនាឡើង ដើម្បីសម្រេចបេសកកម្ម របស់ទីភ្នាក់ងារទាំងនោះ"។ ព្រឹត្តិប័ត្ររដ្ឋបាលនិងហិរញ្ញវត្ថុ លេខ16 ណែនាំទីភ្នាក់ងារនីមួយៗឱ្យអភិវឌ្ឍបង្កើតផែនការទទួលបានសេវាភាសា (LAP) តាមរយៈផែនការនេះ ទីភ្នាក់ងារនីមួយៗអនុវត្តពិធីសារនានា ដើម្បីផ្តល់សេវាជូនដល់អ្នកមិនចេះនិយាយភាសាអង់គ្លេស និង អ្នកមានចំណេះដឹងភាសាអង់គ្លេសតិចតួច។

## គោលបំណងនៃយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន

យុទ្ធសាស្ត្រយុត្តិធ៌មបរិស្ថានរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) មានគោលដៅធានាឱ្យមានកិច្ចការពារស្មើភាពគ្នានិងការចូលរួមពេញលេញរបស់ប្រជាជនទាំងអស់ និងសហគមន៍ទាំងអស់ ពាក់ព័ន្ធនឹងការអភិវឌ្ឍ ការអនុវត្ត និងការអនុវត្តច្បាប់ បទបញ្ញត្តិ និងគោលនយោបាយ ស្តីពីថាមពល បម្រែបម្រួលអាកាសធាតុ និងបរិស្ថាន និង បំណែងចែកដោយសមធម៌នូវផលប្រយោជន៍និងបន្ទុកផ្នែកថាមពលនិងបរិស្ថាន ដោយមិនគិតពី ជាតិសាសន៍ ពណ៌សម្បុរ ដើមកំណើតជាតិសាសន៍ ប្រាក់ចំណូល ឬចំណេះដឹងភាសាអង់គ្លេស។ ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) នឹងពិចារណាទៅលើគោលការណ៍យុត្តិធម៌បរិស្ថាន ក្នុងការតាក់តែងគោលនយោបាយណាមួយ និងក្នុងការសម្រេចចិត្តណាមួយ ពាក់ព័ន្ធនឹងបញ្ហានានានៅក្នុងយុត្តាធិការ ផ្លូវការរបស់ខ្លួន។ យើងរំពឹងថា យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់យើង នឹងបន្តវិវត្តទៅតាមពេលវេលា ដើម្បីឆ្លុះបញ្ចាំងនូវតម្រូវការរបស់ប្រជាជនយុត្តិធម៌បរិស្ថានរបស់ខំមិនវែល។ ក្នុងរយៈពេលដ៏ខ្លីខាងមុខ យើងរំពឹងថា យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន អាចនឹងត្រូវកែប្រែ និងធ្វើបច្ចុប្បន្នកម្ម ដើម្បីឆ្លុះបញ្ចាំងនូវអនុសាសន៍ដែលត្រូវបានផ្តល់ជូនដោយភាគីពាក់ព័ន្ធនានា ពាក់ព័ន្ធនឹងការផ្សព្វផ្សាយទៅដល់ប្រជាជនយុត្តិធម៌បរិស្ថាន នៅក្នុងកិច្ចដំណើរការបច្ចុប្បន្នដែលកំពុងត្រូវអនុវត្ត ដែលត្រូវហៅថា EFSB 21-01 ដែលនឹងត្រូវពិភាក្សានៅខាងក្រោម។

---

[3] ព្រឹត្តិប័ត្ររដ្ឋបាលនិងហិរញ្ញវត្ថុ មាននៅ https://www.mass.gov/doc/language-access-guidelines/download។

[4] ក្នុងខែមីនា ឆ្នាំ2021 អភិបាលរដ្ឋ Beker បានចុះហត្ថលេខាប្រកាសឲ្យប្រើប្រាស់ ជំពូកទី8 នៃច្បាប់ឆ្នាំ2021 និងច្បាប់បង្កើតផែនទីផ្លូវជំនាន់ក្រោយសម្រាប់គោលនយោបាយអាកាសធាតុរដ្ឋម៉ាសាជូសេត ("ច្បាប់ផែនទីផ្លូវអាកាសធាតុ")។ ក្នុងចំណោមខចែងនៃច្បាប់ផែនទីផ្លូវអាកាសធាតុ មានលក្ខខណ្ឌតម្រូវនិតិបញ្ញត្តិថ្មីៗពាក់ព័ន្ធនឹងការពិចារណាទៅលើយុត្តិធម៌បរិស្ថាន ក្នុងការពិនិត្យវាយតម្លៃឡើងវិញផ្នែកបរិស្ថាន ដែលត្រូវបានធ្វើឡើងនៅក្រោមច្បាប់ស្តីពីគោលនយោបាយបរិស្ថានរដ្ឋម៉ាសាជូសេត (MEPA)។ ខណៈដែលការិយាល័យច្បាប់ស្តីពីគោលនយោបាយបរិស្ថានរដ្ឋម៉ាសាជូសេត (MEPA Office) អនុវត្តលក្ខខណ្ឌតម្រូវទាំងនេះ គោលនយោបាយនិងការអនុវត្តយុត្តិធម៌បរិស្ថាន ដែលប៉ះពាល់ដល់បញ្ហាកំណត់ទីតាំងរបស់នាយកដ្ឋានសេវាសាធារណៈ និងក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) អាចផ្លាស់ប្តូរ ដើម្បីធានានូវសង្គតភាព។

## កិច្ចដំណើរការជូនដំណឹងអំពីការសាកសួរព័ត៌មាន

នៅថ្ងៃទី30 ខែមិថុនា ឆ្នាំ2021 ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង បានបើក កិច្ចដំណើរការជូនដំណឹងអំពីការសាកសួរព័ត៌មាន ("NOI") EFSB 21-01 ដើម្បីស្វែងរកវិធីសាស្ត្រ (1) បង្កើនភាពអាចមើលឃើញនៃការជូនដំណឹងជាសាធារណៈរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) និង (2) ពង្រឹងលើកកម្ពស់ការចូលរួមពេញលេញនិងដោយសមធ៌មរបស់សាធារណជននិភាគីនានា នៅក្នុងកិច្ចដំណើការនិតិវិធីរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB)។[5] តាមរយៈកិច្ចដំណើរការជូនដំណឹអំពីការសាកសួរព័ត៌មាន (NOI) របស់ខ្លួន ក្រុមប្រឹក្សា ភិបាលកំណត់ទីតាំង ស្វែងរកធាតុចូលពីគ្រប់ភាគីពាក់ព័ន្ធ មន្ត្រីសាធារណៈ និងសាធារណជនទាំងអស់ ស្តីពីឧត្តមានុវត្តន៍នានាសម្រាប់លើកកម្ពស់ការចូលរួម របស់សាធារណជននៅក្នុងកិច្ចដំណើរការរបស់ខ្លួន។ ដោយត្រូវធ្វើការពិនិត្យវាយតម្លៃឡើងវិញនិងអនុម័តយល់ព្រម ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង នឹងចេញសេចក្តីសម្រេចជាលាយលក្ខអក្សរចុងក្រោយស្តីពី កិច្ចដំណើរការជូនដំណឹងអំពីការសាកសួរព័ត៌មាន (NOI) ដែលអមដោយ ផែនការស្តីពី ការចូលរួមរបស់សាធារណជននិងការចូលរួមរបស់សហគមន៍ (PIP) និង ផែនការ ទទួលបានសេវាភាសា (LAP) ពាក់ព័ន្ធនឹង ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) ដែលផ្តល់ព័ត៌មានពិស្តារអំពីវិធានការអនុវត្តនិងតារាងពេលវេលាដែលបង្កើនប្រសិទ្ធភាពនៃខចែងនៅក្នុងយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB)។ សូមអាន ផ្នែកទី VI ខាងក្រោម។

ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) ទទួលបានលិខិតបញ្ចេញមតិយោបល់សាធារណៈជាច្រើន ពីភាគីពាក់ព័ន្ធនានានៅក្នុងដំណាក់កាលបញ្ចេញមតិយោបល់ តាមរយៈកិច្ចដំណើរការជូនដំណឹងអំពីការសាកសួរព័ត៌មាន (NOI)ដំបូង។ មតិយោបល់ទាំងនោះ គ្របដណ្តប់គំនិតជាច្រើនផ្សេងៗគ្នាស្តីពីវិធីសាស្ត្រនានា ដែលក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) អាចពង្រឹងនិតិវិធីរបស់ខ្លួន និងរួមបញ្ចូល ការកែលម្អវិធីសាស្ត្រថ្មីសម្រាប់ចែកចាយសេចក្តីជូនដំណឹង ការទទួលបានភាសា និងការស្នាក់នៅ ឱកាសផ្តល់មតិយោបល់សាធារណៈ ការទទួលបានសវនាការផ្តល់មតិយោបល់សាធារណៈ ព័ត៌មានអំពីគម្រោងនៅលើអាសយដ្ឋានវេប របស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) ការគោរពអនុវត្តដោយអ្នកស្នើសុំគម្រោង តម្លាភាពរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) និងការយល់ដឹងអំពីការចូលរួមក្នុងកិច្ចដំណើរការរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB)។ ទោះបីជាអនុសាសន៍ដែលត្រូវផ្តល់ជូននិងកំពុងត្រូវពិនិត្យឡើងវិញនាពេលបច្ចុប្បន្ន មានគោលបំណងកែលម្អតម្លាភាព សេវា និងជំនួយគាំទ្រទូទៅ ដល់ភាគីពាក់ព័ន្ធនានា របស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) ក៏ដោយ អនុសាសន៍ជាច្រើនសាកសមជាពិសេស សម្រាប់តម្រូវការរបស់ប្រជាជនយុត្តិធម៌បរិស្ថាន។

### *ក្រុមការងារកិច្ចដំណើរការជូនដំណឹងអំពីការសាកសួរព័ត៌មាន*

កិច្ចដំណើរការជូនដំណឹងអំពីការសាកសួរព័ត៌មាន (NOI) កំពុងត្រូវអនុវត្តដោយក្រុមការងារមួយដែលមានសមាសភាព នាយកក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) អគ្គទីប្រឹក្សា និងបុគ្គលិក។ ក្រុមការងារកិច្ចដំណើរការជូនដំណឹងអំពីការសាកសួរព័ត៌មាន (NOI) មានគោល

---

[5] សូមអាន https://eeaonline.eea.state.ma.us/DPU/Fileroom/dockets/bynumber/EFSB21-01.

បំណងអភិវឌ្ឍប្រែក្លាយផែនការអនុវត្តពិស្តារ ទៅជាផ្នែកមួយនៃការសម្រេចចិត្ត នាពេលខាងមុខរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) ស្ដីពីកិច្ចដំណើរការជូនដំណឹងអំពីការសាកសួរព័ត៍មាន (NOI) ដែលនឹងពង្រីកបន្ថែមទៅលើខចែងដែលមាននៅក្នុងយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាននេះ។  ពេញមួយឆ្នាំ2022 ក្រុមការងារកិច្ចដំណើរការជូនដំណឹងអំពីការសាកសួរព័ត៍មាន (NOI) នឹងពិចារណាទៅលើចម្លើយតបចំពោះកិច្ចដំណើរការជូនដំណឹងអំពីការសាកសួរព័ត៍មាន (NOI) រួមជាមួយការវាយតម្លៃផ្ទៃក្នុងបន្ថែមទៅលើគោលនយោបាយ និងនិតិវិធីរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង និង/ឬពិគ្រោះពិភាក្សាជាមួយទីភ្នាក់ងារសមស្របដទៃទៀត ដែលអនុវត្តយុត្តិធម៌បរិស្ថានស្រដៀងគ្នា (ឧទាហរណ៍ ទីភ្នាក់ងារដទៃទៀតរបស់ការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន (EEA) និងទីភ្នាក់ងារនិយ័តកម្មថាមពលថ្នាក់រដ្ឋដទៃទៀត) ដើម្បីជួយតម្រង់ទិស ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង ក្នុងការអភិវឌ្ឍនិងអនុវត្តបន្ថែមទៀតនូវយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាននេះ។  នាពេលបច្ចុប្បន្ន ក្រុមការងារកិច្ចដំណើរការជូនដំណឹងអំពីការសាកសួរព័ត៍មាន (NOI) កំពុងរៀបចំពេលវេលាសម្រាប់កិច្ចប្រជុំនិងឱកាសបន្ថែមសម្រាប់ការផ្ដល់មតិយោបល់ពាក់ព័ន្ធនឹងកិច្ចដំណើការនិតិវិធីជូនដំណឹងអំពីការសាកសួរព័ត៍មាន ហើយក្រុមការងារនេះរំពឹងថានឹងចេញសេចក្តីសម្រេចចិត្តមួយពាក់ព័ន្ធនឹងនិងនិតិវិធីនោះ នៅត្រឹមចុងបញ្ចប់ឆ្នាំ2022។

## និយមន័យ

បច្ចេកសព្ទដែលត្រូវកំណត់និយមន័យនៅខាងក្រោម ត្រូវបានដកយកចេញមកពីគោលនយោបាយយុត្តិធម៌បរិស្ថានរបស់ការិយាល័យប្រតិបត្តិនៃកិច្ចការថាមពលនិងបរិស្ថាន (EEA)។ បច្ចេកសព្ទទាំងនេះ ចាំបាច់ត្រូវកំណត់និយមន័យឱ្យបានច្បាស់ ដើម្បីបង្កលទ្ធភាពឱ្យសាធារណជនដាក់សម្ពាធឱ្យ ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) ទទួលខុសត្រូវចំពោះការវិភាគរបស់យើងអំពីបបនីយភណ្ឌដែលត្រូវស្នើឡើងនិងគម្រោងដទៃទៀត។

"ប្រជាជនយុត្តិធម៌បរិស្ថាន" គឺជា (A) សង្កាត់ដែលបំពេញតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោមចាប់ពី 1 ឡើងទៅ៖ (i) ប្រាក់ចំណូលគ្រួសារមធ្យមប្រចាំឆ្នាំ មិនលើសពី65 ភាគរយនៃប្រាក់ចំណូលគ្រួសារមធ្យមប្រចាំឆ្នាំនៅទូទាំងរដ្ឋ (ii) ជនជាតិភាគតិច មានចំនួន 40 ភាគរយឡើងទៅ នៃចំនួនប្រជាជនសរុប (iii) គ្រួសារចំនួន 25 ភាគរយ ឡើងទៅពុំមានចំណេះដឹងភាសាអង់គ្លេស ឬ (iv) ជនជាតិភាគតិច មានចំនួន 25 ភាគរយឡើងទៅនៃប្រជាជនសរុប ហើយប្រាក់ចំណូលគ្រួសារមធ្យមប្រចាំឆ្នាំនៃទីក្រុងដែលសង្កាត់នោះមានទីតាំងស្ថិតនៅ មិនលើសពី 150 ភាគរយនៃប្រាក់ចំណូលគ្រួសារមធ្យមប្រចាំឆ្នាំទូទាំងរដ្ឋ ឬ (B) ចំណែកភូមិសាស្ត្រនៃសង្កាត់ដែលត្រូវកំណត់ដោយរដ្ឋមន្ត្រីថាជាប្រជាជនយុត្តិធម៌បរិស្ថានដោយអនុលោមតាមច្បាប់។

"គោលការណ៍យុត្តិធម៌បរិស្ថាន" គឺជាគោលការណ៍ដែលគាំទ្រកិច្ចការពារឱ្យរួចផុតពីការបំពុលបរិស្ថាន និងគាំទ្រលទ្ធភាពរស់នៅក្នុងនិងទទួលបានបរិស្ថានស្អាត និងប្រកបដោយសុខភាពល្អ ដោយមិនគិតពីជាតិសាសន៍ ពណ៌សម្បុរ ប្រាក់ចំណូល វណ្ណៈ ពិការភាព អត្តសញ្ញាណយេនឌ័រ ទំនោរផ្លូវភេទ ដើមកំណើតជាតិសាសន៍ ជាតិពន្ធុឬពូជពង្ស ជំនឿសាសនា ឬចំណេះដឹងភាសាអង់គ្លេស ដែលរួមបញ្ចូល៖ (i) ការចូលរួមពេញលេញរបស់ប្រជាជនទាំងអស់ពាក់ព័ន្ធនឹងការអភិវឌ្ឍ ការអនុវត្ត

និងការអនុវត្តច្បាប់ បទបញ្ញត្តិ និងគោលនយោបាយបរិស្ថាន ដោយរួមទាំង
គោលនយោបាយស្តីពីបម្រែបម្រួលអាកាសធាតុ និង (ii) បំណែងចែកប្រកបដោយសមធម៌
នូវផលប្រយោជន៍បរិស្ថាននិងថាមពល និងបន្ទុកបរិស្ថាន។

"ការចូលរួមពេញលេញ" មានន័យថាគ្រប់សង្កាត់ទាំងអស់ មានសិទ្ធិនិងឱកាស
ចូលរួមក្នុងការសម្រេចចិត្តទាំងអស់ស្តីពី ថាមពល បម្រែបម្រួលអាកាសធាតុ និងបរិស្ថាន
ដោយរួមទាំងការវាយតម្លៃអំពីតម្រូវការ ការរៀបចំផែនការ ការអនុវត្ត
ការគោរពអនុវត្តតាមនិងការអនុវត្តច្បាប់ និងការវាយតម្លៃ ហើយសង្កាត់ទាំងអស់
ត្រូវផ្តល់លទ្ធភាពនិងទទួលបានជំនួយគាំទ្រផ្នែករដ្ឋបាល ដើម្បីចូលរួមពេញលេញ
តាមរយៈការអប់រំនិងការបណ្តុះបណ្តាល ព្រមទាំងទទួលបានតម្លាភាព/គណនេយ្យភាព
ពីរដ្ឋាភិបាល ពាក់ព័ន្ធនឹងធាតុចូលរបស់សហគមន៍ ព្រមទាំងត្រូវលើកទឹកចិត្តឱ្យអភិវឌ្ឍបង្កើត
ទំនួលខុសត្រូវផ្នែកបរិស្ថាន ថាមពលនិងបម្រែបម្រួលអាកាសធាតុ។

"ច្បាប់ស្តីពីគោលនយោបាយបរិស្ថានរដ្ឋម៉ាសាជូសេត (MEPA)" គឺជាច្បាប់ស្តីពីគោលនយោបាយ
បរិស្ថានរដ្ឋម៉ាសាជូសេត M.G.L.។ ជំពូក 30 ផ្នែក 61-621។ នៅក្រោមលក្ខន្តិកៈរប
ស់ច្បាប់ស្តីពីគោលនយោបាយបរិស្ថានរដ្ឋម៉ាសាជូសេត (MEPA)
ការិយាល័យប្រតិបត្តិនៃកិច្ចការថាមពលនិងបរិស្ថាន (EEA) ពិនិត្យវាយតម្លៃ ឡើងវិញនូវ
ផលប៉ះពាល់បរិស្ថានដែលអាចកើតឡើង របស់សកម្មភាពនានារបស់ទីភ្នាក់ងាររដ្ឋ
ដែលហួសពីកម្រិតកំណត់ផ្លូវការមួយចំនួន។ ច្បាប់ស្តីពីគោលនយោបាយបរិស្ថាន
រដ្ឋម៉ាសាជូសេត (MEPA) រួមបញ្ចូល ការវាយតម្លៃនិងមតិយោបល់សាធារណជន
និងត្រូវគោរពតាមពេលវេលាកំណត់ផ្លូវការដ៏តឹងរឹង
ស្តីពីរយៈពេលនៃការពិនិត្យវាយតម្លៃឡើងវិញ។

"សង្កាត់" សំដៅលើក្រុមសង្កាត់ជំរឿនមួយក្រុមដែលកំណត់ដោយក្រសួងជំរឿនសហរដ្ឋអាមេរិក
(U.S. Census Bureau) ប៉ុន្តែមិនរាប់បញ្ចូលពលរដ្ឋដែលរស់នៅក្នុងអន្តេវាសិកដ្ឋានក្នុង
មហាវិទ្យាល័យ ឬពលរដ្ឋស្ថិតក្រោមការថែមទាំងគ្រប់គ្រងនិងអនុវត្តផ្លូវច្បាប់ ឬស្ថិតក្រោមការ
ឃុំខ្លួន (ឧ.ទា. ពន្ធនាគាររបស់រដ្ឋ ឬសហព័ន្ធ)។

## កិច្ចដំណើរការសាធារណៈរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB)

ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង ផ្តល់ឱកាសជាច្រើនដល់បុគ្គលនិងអង្គការនានា ចូលរួម
និងបញ្ចេញមតិយោបល់តាមរយៈដំណាក់កាលជាច្រើននៃកិច្ចដំណើរការរបស់ខ្លួន
ដោយគិតចាប់ពីការដាក់ឯកសារគ្រាដំបូងដោយអ្នកស្នើសុំសវនាការ មតិយោបល់សាធារណៈ
និងភ័ស្តុតាង រហូតដល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល
និងប្រសិនបើត្រូវអនុម័តយល់ព្រមការសាងសង់និងប្រតិបត្តិការបរិក្ខារ។
ចំណាប់អារម្មណ៍ចូលរួមរបស់បុគ្គលនិងអង្គការនានានៅក្នុងកិច្ចដំណើរការរបស់ក្រុមប្រឹក្សាភិបា
លកំណត់ទីតាំង (EFSB) អាចមានទម្រង់ជាច្រើន ដូចជាការប្រមូលផ្តុំ ព័ត៌មានពីសេចក្តី
ជូនដំណឹងអំពីគម្រោង ឬគេហទំព័ររបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB)
ការផ្តល់មតិយោបល់ជាលាយលក្ខអក្សរនិងផ្ទាល់មាត់ នៅក្នុងសវនាការសាធារណៈ
រហូតដល់ការស្វែងរកសិទ្ធិស្របច្បាប់ពេញលេញក្នុងការចូលរួម ដូចជា ការទទួល
បានឯកសារនិងព័ត៌មានដទៃទៀត ការផ្តល់ភ័ស្តុតាង ការសាកសួរសាក្សី និង
ការប្តឹងសារទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB)។

## ការទទួលបានព័ត៌មានអំពីគម្រោង

ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) ព្យាយាមធានាថា ព័ត៌មានអំពីគម្រោង នឹងត្រូវផ្តល់ជូនដល់ភាគីពាក់ព័ន្ធទាំងអស់ ដើម្បីធ្វើការត្រួតពិនិត្យឡើងវិញ។ សំណើពេញលេញរបស់អ្នកដាក់ពាក្យស្នើសុំគម្រោង ត្រូវផ្តល់ជូននៅតាមទីកន្លែងជាច្រើន និងជាភាសាផ្សេងៗគ្នា (តាមភាពជាក់ស្តែង) ដើម្បីផ្តល់លទ្ធភាពឱ្យសាធារណជនទទួលបានឯកសារទាំងនេះ។ ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង តម្រូវឱ្យអ្នកដាក់ពាក្យសុំ ដាក់តម្កល់សំណៅឯកសារជាក្រដាស នៃឯកសារមួយចំនួននៅក្នុងទីកន្លែងរក្សាទុកឯកសារមួយឬច្រើន ដូចជាបណ្ណាល័យសាធារណៈ ការិយាល័យរដ្ឋាភិបាលមូលដ្ឋាន ការិយាល័យរបស់អ្នកដាក់ពាក្យសុំ ឬទីកន្លែងដទៃទៀតនៅក្នុងសហគមន៍ដែលសាធារណជនអាចចូលទៅដល់។ សាធារណជនក៏អាចស្នើសុំកំណត់ត្រាអំពីគម្រោងដែលមាននៅឯការិយាល័យរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB/នាយកដ្ឋានសេវាសាធារណៈ (DPU)) ឬជាទម្រង់ផ្សេងបន្ថែមទៀត (ដូចជាក្នុងទម្រង់ជាអក្សរធំៗ ឬជាអក្សរសម្រាប់អ្នកពិការភ្នែក)។ សំណៅអេឡិកត្រូនិកនៃសំណើ អាចត្រូវរកបាននៅលើគេហទំព័ររបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) និងគេហទំព័ររបស់អ្នកដាក់ពាក្យស្នើសុំគម្រោង ដែលត្រូវភ្ជាប់តំណជាមួយសេចក្តីជូនដំណឹងសាធារណៈដែលត្រូវចែកចាយយ៉ាងទូលំទូលាយ។

## ការចែកចាយសេចក្តីជូនដំណឹង

ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) តម្រូវឱ្យអ្នកដាក់ពាក្យស្នើសុំធ្វើការជូនដំណឹង ទាន់ពេលវេលានិងយ៉ាងទូលំទូលាយសម្រាប់គម្រោងដែលត្រូវស្នើសុំទាំងអស់ ដោយរួមបញ្ចូលសេចក្តីជូនដំណឹងដែលត្រូវផ្ញើតាមប្រៃសណីយ៍ទៅកាន់អ្នករស់នៅក្នុងតំបន់ (ដោយរួមទាំងម្ចាស់និងអ្នកជួលអចលនទ្រព្យ) អាជីវកម្ម និងមន្ត្រីថ្នាក់ មូលដ្ឋាននិងរដ្ឋ ព្រមទាំងការបោះពុម្ពផ្សាយសេចក្តីជូនដំណឹងនៅលើសារព័ត៌មាន។ ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) តម្រូវឱ្យអ្នកគាំទ្រគម្រោងជូនដំណឹងដល់អ្នករស់នៅ ដែលស្ថិតនៅក្នុងចម្ងាយជាក់លាក់ណាមួយ អំពីបបនីយភណ្ឌថ្មីៗដែលត្រូវស្នើឡើងតាមរយៈប្រៃសណីយ៍សហរដ្ឋអាមេរិក។[6] ដោយផ្អែកលើ ព័ត៌មានប្រជាសាស្ត្ររបស់ប្រជាជនដែលរស់នៅក្បែរគម្រោងដែលត្រូវស្នើសុំ ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង អាចតម្រូវឱ្យបកប្រែសេចក្តីជូនដំណឹងនិងលិខិតជូនដំណឹង តាមប្រៃសណីយ៍ ទៅជាភាសាដទៃផ្សេងទៀត និងបោះពុម្ពផ្សាយសេចក្តីជូនដំណឹងទាំងនោះ នៅក្នុងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលពាក់ព័ន្ធនិងភាសានិងទីកន្លែងនោះ។

ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) ក៏នឹងធានាផងដែរថា ព័ត៌មានស្តីពីគម្រោងនឹងត្រូវដាក់បង្ហាញនៅលើគេហទំព័រ របស់អ្នកដាក់ពាក្យស្នើសុំគម្រោង និងរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB)។ ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) តម្រូវឱ្យអ្នកដាក់ពាក្យសុំ ផ្តល់ការជូនដំណឹងបន្ថែម

---

[6] ជាទូទៅ ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) ប្រើប្រាស់ចម្ងាយពីព្រំប្រទល់ដូចខាងក្រោម ដើម្បីបង្កើតអាសយដ្ឋានដែលគេត្រូវការសម្រាប់ការជូនដំណឹងតាមប្រៃសណីយ៍៖ (a) ចម្ងាយ300 ហ្វីត សម្រាប់ខ្សែបញ្ជូនចរន្ត ឬបំពង់ឧស្ម័ន (b) ចម្ងាយមួយភាគប្រាំបីម៉ាយល៍សម្រាប់ស្ថានីយ៍ផ្លាស់ប្តូរចរន្តអគ្គិសនីថ្មី (c) ចម្ងាយមួយភាគបួនម៉ាយល៍សម្រាប់អនុស្ថានីយ៍ថ្មី ស្ថានីយ៍វាស់បរិមាណឧស្ម័ន និង(d) ចម្ងាយកន្លះម៉ាយល៍ សម្រាប់រោងចក្រផលិតអគ្គិសនីថ្មី ឃ្លាំងស្តុកឧស្ម័ន និងស្ថានីយ៍បំពេញឧស្ម័ន។

ជូនដល់អង្គការដែលមានមូលដ្ឋាននៅក្នុងសហគមន៍ (ដោយរួមទាំងអង្គការយុត្តិធម៌បរិស្ថាន) នៅក្នុងតំបន់គម្រោង ដោយប្រើប្រាស់ “បញ្ជីប្រៃសណីយ៍យុត្តិធម៌បរិស្ថាន” ដែលត្រូវបានបង្កើតឡើងនិងរក្សាទុកដោយការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន (EEA)។ តាមរយៈការជូនដំណឹងដល់អ្នករស់នៅក្បែគម្រោងដែលត្រូវស្នើឡើង ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង ព្យាយាមបង្កើនការយល់ដឹងអំពីសំណើនិងបង្កលទ្ធភាពឱ្យអ្នកដែលចង់ទទួលបានព័ត៌មានច្រើនជាងនេះឬអ្នកដែលចង់ផ្តល់មតិយោបល់នូវឱកាសរួមចំណែកពេញលេញ និងផ្តល់ធាតុចូលដល់ការពិចារណារបស់ក្រុមប្រឹក្សាភិបាលអំពីគម្រោងដែលត្រូវស្នើឡើង។

### មតិយោបល់សាធារណៈ

ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង ទទួលស្គាល់ថាសមាជិករបស់សហគមន៍មួយ ដែលគម្រោងអាចនឹងត្រូវស្នើឡើង មានការយល់ដឹងផ្ទាល់ និងការយល់ដឹងពិសេសពាក់ព័ន្ធនឹងប្រជាជន ទីកន្លែង បរិស្ថាន វប្បធម៌ និងប្រវត្តិ នៅក្នុងទីតាំងបែបនោះ។ ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង ក៏ទទួលស្គាល់នូវគុណតម្លៃនិងសារៈសំខាន់នៃការទទួលបានការយល់ដឹងអំពីទស្សនៈនិងចំណេះដឹងរបស់ប្រជាជនមូលដ្ឋានទាំងអស់នេះ និងសារៈសំខាន់នៃការប្រើប្រាស់ចំណេះដឹងទាំងនេះនៅក្នុងកិច្ចដំណើការពិនិត្យវាយតម្លៃឡើងវិញជាផ្លូវការរបស់ខ្លួន។ ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) ផ្តល់ឱកាសសម្រាប់ការផ្តល់មតិយោបល់ផ្ទាល់មាត់និងជាលាយលក្ខអក្សរស្តីពីគម្រោងដែលត្រូវស្នើឡើងនៅគ្រាចាប់ផ្តើមដំបូងនៃកិច្ចដំណើរការនិតិវិធី។ វត្ថុបំណងរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង ក្នុងការអនុវត្តសវនាការផ្តល់មតិយោបល់សាធារណៈ គឺផ្តល់ជូនវេទិកាមួយដែលមានលក្ខណៈរឹងមាំ មានលក្ខណៈបរិយាប័ននិងមានប្រយោជន៍ដល់សាធារណជន ដើម្បីស្វែងយល់កាន់តែស៊ីជម្រៅអំពីគម្រោងដែលត្រូវស្នើឡើង និងបង្កលទ្ធភាពឱ្យក្រុមប្រឹក្សាភិបាលកំណត់ទីតាំង សិក្សាស្វែងយល់អំពីសេចក្តីព្រួយបារម្ភរបស់សាធារណជន។ ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង ពឹងផ្អែកលើមតិយោបល់របស់សាធារណជន ធ្វើជាប្រភពព័ត៌មានដ៏សំខាន់អំពីបញ្ហាដែលអាចកើតឡើង ដើម្បីធ្វើការស៊ើបអង្កេតក្នុងអំឡុងពេលអនុវត្តកិច្ចដំណើការនិតិវិធី។

ក្នុងការជ្រើសរើសទីកន្លែងនិងកាលបរិច្ឆេទ/ពេលវេលា សម្រាប់សវនាការផ្តល់មតិយោបល់សាធារណៈដោយផ្ទាល់ ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង នឹងពិចារណាទៅលើកត្តាផ្សេងៗ ដោយរួមទាំងសំណួរថាតើ៖

- ពេលវេលានៃកិច្ចប្រជុំនេះអំណោយផលបំផុតសម្រាប់ការចូលរួមរបស់សាធារណជនដែរឬទេ
- ភាគីពាក់ព័ន្ធនៅក្នុងសង្កាត់ឬមន្ត្រីសាលាក្រុង ផ្តល់អនុសាសន៍ឱ្យជ្រើសរើសយកទីកន្លែងនិងពេលវេលានៃកិច្ចប្រជុំនោះដែរឬទេ
- ទីកន្លែងស្ថិតនៅក្បែរទីតាំងគម្រោងដែលត្រូវស្នើឡើងដែរឬទេ
- ទីកន្លែនោះត្រូវប្រើប្រាស់ជាទូទៅដោយសហគមន៍ និងអាចដាក់អ្នកចូលរួមដែលចាប់អារម្មណ៍ទាំងអស់ដែរឬទេ
- ទីកន្លែងនោះគោរពតាមច្បាប់ស្តីពីពលរដ្ឋអាមេរិកដែលមានពិការភាពដែរឬទេ

- ទីកន្លែងនោះស្ថិតនៅក្បែរគមនាគមន៍សាធារណៈ និង/ឬមានចំណតឥតគិតថ្លៃច្រើនដែរឬទេ
- ទីកន្លែងនោះមានសមត្ថភាពភ្ជាប់ឧបករណ៍ចក្ខុទស្សន៍និងសោតទស្សន៍គ្រប់គ្រាន់ដែរឬទេ
- ទីកន្លែងនោះអាចធានាបាននូវសុវត្ថិភាពសាធារណៈគ្រប់គ្រាន់ដែរឬទេ

> នៅថ្ងៃទី16 ខែមិថុនា ឆ្នាំ2021 លោកអភិបាលរដ្ឋ Baker បានចុះហត្ថលេខាប្រកាសឱ្យប្រើច្បាប់ស្ដីពីការពន្យារពេលបន្ថែមនូវវិធានការប្រយុទ្ធប្រឆាំងជំងឺកូវីដ 19 ដែលត្រូវបានអនុម័តក្នុងអំឡុងពេលនៃការប្រកាសដាក់រដ្ឋក្នុងគ្រាអាសន្ន។ ច្បាប់នេះ រួមបញ្ចូលការពន្យារពេលបន្ថែម រហូតដល់ថ្ងៃទី1 ខែមេសា ឆ្នាំ2022 នូវការរៀបចំកិច្ចប្រជុំពីចម្ងាយនៃបទបញ្ជាប្រតិបត្តិរបស់គាត់ចុះថ្ងៃទី12 ខែមីនា ឆ្នាំ2020 ដែលព្យួរនូវខចែងនៃច្បាប់ស្ដីពីកិច្ចប្រជុំបើកចំហរ។ នៅថ្ងៃទី13 ខែកុម្ភៈ ឆ្នាំ2022 លោកអភិបាលរដ្ឋ Baker បានចុះហត្ថលេខាប្រកាសឱ្យប្រើច្បាប់ស្ដីពីការបម្រុងទុកសម្រាប់ឆ្នាំសារពើពន្ធ2022 ដែលរួមបញ្ចូលការពន្យារពេលបន្ថែមនូវខចែងស្ដីពីកិច្ចប្រជុំពីចម្ងាយ រហូតដល់ថ្ងៃទី15 ខែកក្កដា ឆ្នាំ2022។ ចាប់តាំងពីពេលដែលជំងឺរាតត្បាតចាប់ផ្ដើមផ្ទុះរីករាលដាល ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង បានរៀបចំសវនាការផ្ដល់មតិយោបល់សាធារណៈពីចម្ងាយ និងផ្សព្វផ្សាយខ្សែអាត់វីដេអូនៃសវនាការនោះ នៅលើ ទំព័រ YouTube របស់នាយកដ្ឋានសេវាសាធារណៈ (DPU)។ ក្នុងកាលៈទេសៈសមស្រប ក្រុមប្រឹក្សាភិបាលកំណត់ទីតាង មានបំណងបន្តសវនាការដោយផ្ទាល់ឡើងវិញ និងផ្ដល់ជូនការជួបប្រជុំពីចម្ងាយតាមរយៈវីដេអូសម្រាប់អ្នកទាំងឡាយណាដែលមានបំណងចូលរួមពីចម្ងាយ។

## ការចូលរួមក្នុងកិច្ចដំណើរការនិតិវិធី

បុគ្គល អង្គការ អាជីវកម្ម ឬអង្គភាពដទៃ (ដូចជា សាលាក្រុង) ដែលមានបំណងចូលរួមលើសពីដំណាក់កាលផ្ដល់មតិយោបល់សាធារណៈនៃកិច្ចដំណើរការនិតិវិធី អាចដាក់សំណើមកកាន់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង ដើម្បីធ្វើអន្តរាគមន៍ក្នុងនាមជាភាគី ឬចូលរួមក្នុងនាមជាអ្នកចូលរួមដែលមានសិទ្ធិមានកំណត់។ ដើម្បីធ្វើអន្តរាគមន៍ក្នុងនាមជាភាគីមួយ អ្នកស្នើសុំត្រូវបង្ហាញថាគាត់អាច “ទទួលរងផលប៉ះពាល់ជាក់លាក់និងធ្ងន់ធ្ងរ” ពីកិច្ចដំណើរការនិតិវិធី។ បញ្ហានានាដែលត្រូវលើកឡើងនៅក្នុងសំណើធ្វើអន្តរាគមន៍ ត្រូវមានលក្ខណៈជាក់លាក់ចំពោះអ្នកអន្តរាគមន៍ដែលកំពុងស្នើសុំនោះ នឹងត្រូវស្ថិតនៅក្នុងវិសាលភាពនៃការត្រួតពិនិត្យឡើងវិញរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង ដូចជាផលប៉ះពាល់ផ្នែករូបភាព ការបំពុលសម្លេង ខ្យល់ឬទឹក ចរាចរណ៍ ឬដែនម៉ាញ៉េទិក ដែលអាចមានផលប៉ះពាល់បណ្ដោះអាសន្នឬអចិន្ត្រៃយ៍ ទៅលើអ្នកដាក់សំណើ ឬទៅលើទ្រព្យសម្បត្តិរបស់ពួកគេ។ សូមអាន 980 CMR 1.05។ សូមអាន G.L. c. 30A, §§ 1, 10 ផងដែរ។

បុគ្គលឬអង្គការដែលត្រូវអនុញ្ញាតឱ្យធ្វើអន្តរាគមន៍ក្នុងនាមជាភាគី ត្រូវហៅថា “អ្នកអន្តរាគមន៍” ។ ក្នុងនាមជាភាគីពេញលេញមួយ អ្នកធ្វើអន្តរាគមន៍អាចដាក់សំណួរទៅកាន់អ្នកដាក់ពាក្យស្នើសុំគម្រោង សួរសំណួរនៅក្នុងសវនាការភ័ស្តុតាង បង្ហាញភ័ស្តុតាង និងដាក់ឯកសារ ដែលស្របជាមួយនិងវិធាននិតិវិធី និងតារាងពេលវេលាដែលត្រូវបានបង្កើតឡើងសម្រាប់ករណីនោះ។ អ្នកអន្តរាគមន៍ ក៏មានសិទ្ធិប្ដឹងសារទុក្ខប្រឆាំងនឹងសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) ទៅកាន់តុលាការកំពូលនៃរដ្ឋម៉ាសាជូសេត ផងដែរ។ បុគ្គលឬអង្គការដែលមានបំណងចូលរួម ក្នុងនាមជាអ្នកចូលរួមដែលមានសិទ្ធិ មានកម្រិតពុំចាំបាច់បង្ហាញនូវចំណាប់អារម្មណ៍ “ជាក់លាក់និងខ្លាំងក្លា” នោះឡើយ

ក៏ប៉ុន្តែសំណើសុំចូលរួមក្នុងនាមជាអ្នកចូលរួមដែលមានសិទ្ធិមានកម្រិត គួរពិពណ៌នាអំពីរបៀបដែលអ្នកដាក់សំណើចាប់អារម្មណ៍ចំពោះការចូលរួម និងគោលបំណងនៃការចូលរួមដែលត្រូវស្នើឡើង។ អ្នកចូលរួមដែលមានសិទ្ធិមានកម្រិត អាចទទួលបានសំណៅឯកសារនៃការដាក់ឯកសារ និងការដាក់ជូនអង្គហេតុនានា។

### ការទទួលបានសេវាភាសា

ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) ព្យាយាមធានាថា បុគ្គលដែលមានចំណេះដឹងភាសាអង់គ្លេសតិចតួច នឹងទទួលបានឱកាសចូលរួមពេញលេញនៅក្នុងកិច្ចដំណើរការនិតិវិធីរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB)។ នៅពេលចាប់ផ្តើមកិច្ចដំណើការនិតិវិធីបុគ្គលិក ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង នឹងពិនិត្យវាយតម្លៃឡើងវិញនូវព័ត៌មានប្រជាសាស្ត្រសម្រាប់តំបន់ដែលបបនីយកម្ម ត្រូវស្នើឡើង ដើម្បីកំណត់អត្តសញ្ញាណប្រជាជនដែលមានចំណេះដឹងភាសាអង់គ្លេសតិចតួច ដែលអាចត្រូវការសេវាបកប្រែឯកសារនិងបកប្រែផ្ទាល់មាត់។ នៅក្នុងករណីបែបនេះ ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង តម្រូវឱ្យអ្នកស្នើសុំគម្រោង ផ្តល់សេចក្តីជូនដំណឹងជាភាសាផ្សេងបន្ថែមដែលត្រូវប្រើប្រាស់នៅក្នុងសហគមន៍នោះ និងក្នុងករណីចាំបាច់ បោះពុម្ពផ្សាយសេចក្តីជូនដំណឹងលើសារព័ត៌មានមិនមែនជាភាសាអង់គ្លេសដែលចេញផ្សាយនៅក្នុងមូលដ្ឋាន។

ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) រួមបញ្ចូលការបកប្រែប្រដេញសម្រាប់ភាសាបន្ថែមនានាទាំងនៅក្នុងសវនាការបញ្ចេញមតិយោបល់សាធារណៈដោយផ្ទាល់និងតាមអនឡាញ។ សេវាទាំងនេះ ត្រូវផ្តល់ជូននៅពេលគេកំណត់ថាមានប្រជាជនដែលមានចំណេះដឹងភាសាអង់គ្លេសតិចតួច និងនៅពេលមានការស្នើសុំ។ ការបកប្រែផ្ទាល់មាត់ក៏ត្រូវផ្តល់ជូនផងដែរនៅក្នុងសវនាការភ័ស្តុតាង និងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលនៅពេលចាំបាច់។ ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង កំពុងធ្វើបច្ចុប្បន្នកម្មផែនការទទួលបានសេវាភាសារបស់ខ្លួន។ សមាសធាតុនៃផែនការទទួលបានសេវាភាសា ដែលរួមបញ្ចូលផងដែរនូវព័ត៌មានស្តីពីរបៀបវាយតម្លៃតម្រូវការភាសា ត្រូវពិពណ៌នានៅក្នុងផ្នែក Vi.B ខាងក្រោម។

## គោលនយោបាយបម្រែបម្រួលអាកាសធាតុ

ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង ពិចារណាទៅលើផលប៉ះពាល់បច្ចុប្បន្ននិងអនាគតនៃបម្រែបម្រួលអាកាសធាតុ ទៅលើប្រជាជនយុត្តិធម៌បរិស្ថាននិងប្រជាជនផ្សេងទៀតក្នុងការសម្រេចចិត្តរបស់ខ្លួន និងវាយតម្លៃឥរិយាបថរបស់អ្នកស្នើសុំគម្រោង ចំពោះការសម្របខ្លួន ការកាត់បន្ថយ និងភាពធនរឹងមាំទល់នឹងបម្រែបម្រួលអាកាសធាតុដែលជាផ្នែកមួយនៃការពិនិត្យវាយតម្លៃឡើងវិញផ្នែកបរិស្ថានរបស់ខ្លួន។ ជាឧទាហរណ៍ ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) នឹងវិភាគផលប៉ះពាល់នៃ កំណើនកម្ពស់ទឹកសមុទ្រនិងកំណើនព្យុះទៅលើបបនីយកម្មនៅក្នុងសហគមន៍ឆ្នេរ។ ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង ក៏វាយតម្លៃផងដែរ នូវការគោរពអនុវត្តតាមផែនការបម្រែបម្រួលអាកាសធាតុ និងភាពធន់មាំរបស់ក្រុងផងដែរ។ ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) បន្តពិចារណាទៅលើគោលនយោបាយបម្រែបម្រួលអាកាសធាតុបន្ថែមដែលត្រូវអនុម័តដោយខំមិនែល និងក្រុងនានា នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន។

# សង្គតភាពជាមួយច្បាប់ស្តីពីគោលនយោបាយបរិស្ថានរដ្ឋម៉ាសាជូសេត (MEPA)

## ពិធីការថ្មីនៃច្បាប់ស្តីពីគោលនយោបាយបរិស្ថានរដ្ឋម៉ាសាជូសេត (MEPA)

ការិយាល័យច្បាប់ស្តីពីគោលនយោបាយបរិស្ថានរដ្ឋម៉ាសាជូសេត (MEPA) បានចេញពិធីការថ្មីៗ ពាក់ព័ន្ធនឹងយុត្តិធម៌បរិស្ថានៈ (i) ពិធីសារនៃច្បាប់ស្តីពីគោលនយោបាយបរិស្ថានរដ្ឋម៉ាសាជូសេត (MEPA) ស្តីពីការចូលរួមរបស់សាធារណជន សម្រាប់ប្រជាជនយុត្តិធម៌បរិស្ថាន និង (ii) ពិធីសារបណ្តោះអាសន្ននៃច្បាប់ស្តីពីគោលនយោបាយបរិស្ថានរដ្ឋម៉ាសាជូសេត (MEPA) សម្រាប់ការវិភាគផលប៉ះពាល់របស់គម្រោងទៅលើប្រជាជនយុត្តិធម៌បរិស្ថាន។ ពិធីសារនៃច្បាប់ស្តីពីគោលនយោបាយបរិស្ថានរដ្ឋម៉ាសាជូសេត (MEPA) ស្តីពីការចូលរួមរបស់សាធារណជន តម្រូវឱ្យអ្នកស្នើសុំគម្រោង កំណត់អត្តសញ្ញាណប្រជាជនយុត្តិធម៌បរិស្ថានដែលនៅក្បែរ និងចូលរួមក្នុងការផ្សព្វផ្សាយព័ត៌មានជូនដល់ប្រជាជនទាំងនោះនៅមុនពេលដាក់ពាក្យស្នើសុំ។ អ្នកស្នើសុំគម្រោងត្រូវផ្តល់សេចក្តីពិពណ៌នាអំពីយុទ្ធសាស្រ្តជំរុញការចូលរួមរបស់សាធារណជនដែលជាផ្នែកមួយនៃការដាក់ឯកសារដែលតម្រូវដោយច្បាប់ស្តីពីគោលនយោបាយបរិស្ថានរដ្ឋម៉ាសាជូសេត (MEPA) និងបញ្ជាក់ឱ្យបានច្បាស់អំពីរបៀបដែលអង្គការនានាដែលមានមូលដ្ឋាននៅក្នុងសហគមន៍ និងក្រុមកុលសម្ព័ន្ធនានាទទួលបានការជូនដំណឹងអំពីរបៀបស្នើសុំការរៀបចំកិច្ចប្រជុំសហគមន៍។ ការដាក់ពាក្យស្នើសុំសាងសង់ឋបនីយភណ្ឌ នៅចំពោះមុខក្រុមប្រឹក្សាភិបាលកំណត់ទីតាំងជាទូទៅ តម្រូវនូវការដាក់ឯកសារដែលតម្រូវដោយច្បាប់ស្តីពីគោលនយោបាយបរិស្ថានរដ្ឋម៉ាសាជូសេត (MEPA) ផងដែរ។ ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងនឹងសហការជាមួយការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន (EEA)/ ការិយាល័យច្បាប់ស្តីពីគោលនយោបាយបរិស្ថានរដ្ឋម៉ាសាជូសេត (MEPA) ដើម្បីរួមបញ្ចូលការយល់ដឹងអំពីកិច្ចដំណើរការ និងឱកាសចូលរួមក្នុងសកម្មភាពផ្សព្វផ្សាយមុនពេលដាក់ឯកសារ ដែលត្រូវផ្តួចផ្តើមនៅក្រោមលក្ខខណ្ឌតម្រូវរបស់ច្បាប់ស្តីពីគោលនយោបាយបរិស្ថានរដ្ឋម៉ាសាជូសេត (MEPA)

ពិធីសារបណ្តោះអាសន្ននៃច្បាប់ស្តីពីគោលនយោបាយបរិស្ថានរដ្ឋម៉ាសាជូសេត (MEPA) សម្រាប់ការវិភាគអំពីផលប៉ះពាល់របស់គម្រោងទៅលើប្រជាជនយុត្តិធម៌បរិស្ថាន តម្រូវឱ្យអ្នកស្នើសុំគម្រោង វាយតម្លៃនិងពិពណ៌នា អំពីបន្ទុកបរិស្ថានដែលអយុត្តិធម៌ ឬដែលពុំមានសមធម៌ដែលមានស្រាប់ និងផលវិបាកផ្នែកសុខភាពសាធារណៈពាក់ព័ន្ធដែលប៉ះពាល់ប្រជាជនយុត្តិធម៌បរិស្ថាន។ ផលប៉ះពាល់ទាំងនេះរួមបញ្ចូលផលប៉ះពាល់មកពីប្រតិបត្តិការឬគម្រោងពីមុនឬបច្ចុប្បន្ន របស់ឯកជន ឧស្សាហកម្ម ពាណិជ្ជកម្ម រដ្ឋ ឬក្រុង ដែលបានធ្វើឱ្យខូចខាតដល់បរិស្ថានដោយរួមទាំងផលប៉ះពាល់ផ្នែកសុខភាពនិងកំណើនកម្ពស់ទឹកសមុទ្រ។ ក្រុមប្រឹក្សាកំណត់ទីតាំង នឹងពិនិត្យវាយតម្លៃឡើងវិញលើការវិភាគទាំងនេះនៅក្នុងការវាយតម្លៃរបស់ខ្លួនទៅលើសំណើគម្រោងនិងផ្តល់សេចក្តីសំអាងហេតុសមស្របនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន។

## ការកែលម្អការចូលរួមរបស់សាធារណជន

ក្រុមប្រឹក្សាកំណត់ទីតាំង ប្រកាន់យកនូវនិតិវិធីកែលម្អការចូលរួមរបស់សាធារណជននៅក្នុងការពិនិត្យវាយតម្លៃឡើងវិញនូវសំណើឋបនីយភណ្ឌថាមពលទាំងឡាយ។ ផ្នែកទី20

នៃគោលនយោបាយយុត្តិធម៌បរិស្ថាន តម្រូវឱ្យមានការកែលម្អការចូលរួមរបស់សាធារណជន សម្រាប់កិច្ចដំណើការនិតិវិធីរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង ដោយផ្អែកលើកម្រិតកំណត់ស្តីពីផលប៉ះពាល់បរិស្ថានដូចគ្នាដែលត្រូវប្រើប្រាស់ដោយ ការិយាល័យច្បាប់ស្តីពីគោលនយោបាយបរិស្ថានរដ្ឋម៉ាសាជូសេត (MEPA) (ក្នុងផ្នែកទី16) សម្រាប់ការបង្កើនការចូលរួមរបស់សាធារណជនរបស់ខ្លួន។

1) គម្រោងណាមួយដែលលើសពីកម្រិតកំណត់របស់ទម្រង់លិខិតជូនដំណឹងបរិស្ថាន (ENF) សម្រាប់ខ្យល់ កាកសំណល់គ្រោះថ្នាក់ និងសំណល់រឹង (ក្រៅពីគម្រោងកែលម្អ) ឬប្រព្រឹត្តកម្មនិងការបញ្ចេញចោលទឹកកខ្វក់និងកាកសំណល់ភក់ និង
2) ទីតាំងគម្រោង ស្ថិតក្នុងចម្ងាយមួយម៉ាយលស៍នៃប្រជាជនយុត្តិធម៌បរិស្ថាន (ឬក្នុងករណីដែលគម្រោងលើសពីកម្រិតកំណត់របស់ទម្រង់លិខិតជូនដំណឹងបរិស្ថាន (ENF) សម្រាប់ខ្យល់អាកាស ស្ថិតក្នុងចម្ងាយប្រាំម៉ាយល៍នៃប្រជាជនយុត្តិធម៌បរិស្ថាន)។

ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង នឹងបន្តប្រើប្រាស់និតិវិធីបង្កើនការចូលរួមរបស់សាធារណជន ក្នុងការពិនិត្យវាយតម្លៃឡើងវិញនូវសំណើបបនីយភណ្ឌថាមពលនានា។

## ការកែលម្អការវិភាគផលប៉ះពាល់

អនុលោមតាមគោលនយោបាយយុត្តិធម៌បរិស្ថាន ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង អនុវត្តនិតិវិធីវិភាគផលប៉ះពាល់ដែលត្រូវបានកែលម្អ និងនិតិវិធីកាត់បន្ថយផលប៉ះពាល់ ក្នុងការពិនិត្យវាយតម្លៃឡើងវិញនូវបបនីយភណ្ឌថាមពលដែលត្រូវស្នើសុំ។ ផ្នែកទី20 នៃគោលនយោបាយយុត្តិធម៌បរិស្ថាន តម្រូវឱ្យមានការកែលម្អការវិភាគផលប៉ះពាល់ និងការកាត់បន្ថយផលប៉ះពាល់ សម្រាប់កិច្ចដំណើការនិតិវិធីរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង ដោយផ្អែកលើកម្រិតកំណត់ស្តីពីផលប៉ះពាល់បរិស្ថានដូចគ្នាដែលត្រូវប្រើប្រាស់ដោយ ការិយាល័យច្បាប់ស្តីពីគោលនយោបាយបរិស្ថានរដ្ឋម៉ាសាជូសេត (MEPA) (ក្នុងផ្នែកទី17) សម្រាប់ការកែលម្អការវិភាគផលប៉ះពាល់និងការកាត់បន្ថយផលប៉ះពាល់៖

1) លើសពីកម្រិតកំណត់របស់របាយការណ៍ផលប៉ះពាល់បរិស្ថាន (EIR) សម្រាប់ខ្យល់ សំណល់គ្រោះថ្នាក់និងសំណល់រឹង (ក្រៅពីគម្រោងកែលម្អ) ឬប្រព្រឹត្តកម្ម និងការបញ្ចេញចោលទឹកកខ្វក់ និងកាកសំណល់ភក់ និង
2) មានទីតាំងស្ថិតក្នុងចម្ងាយមួយម៉ាយល៍នៃប្រជាជនយុត្តិធម៌បរិស្ថាន (ឬក្នុងករណីដែលគម្រោងលើសពីកម្រិតកំណត់របស់របាយការណ៍ផលប៉ះពាល់បរិស្ថាន (EIR) សម្រាប់ខ្យល់ ស្ថិតក្នុងចម្ងាយប្រាំម៉ាយល៍នៃប្រជាជនយុត្តិធម៌បរិស្ថាន)។ អ្នកគាំទ្រគម្រោង អាចដាក់ទិន្នន័យការធ្វើសំណាកគំរូខ្យល់ពិតប្រាកដស្តីពីតំបន់ ដែលអាចមានផលប៉ះពាល់ទៅលើខ្យល់របស់គម្រោង នៅក្នុងវិសាលភាពនៃរបាយការណ៍ ផលប៉ះពាល់បរិស្ថាន (EIR)ដើម្បីកែប្រែតំបន់រងផលប៉ះពាល់ចម្ងាយប្រាំម៉ាយល៍ ដែលត្រូវបានសន្មត់។

សេចក្តីសម្រេចដែលត្រូវធ្វើឡើងដោយក្រុមប្រឹក្សាភិបាលកំណត់ទីតាំង រួមបញ្ចូលវិធានការ កាត់បន្ថយផលប៉ះពាល់បែបនោះសម្រាប់សហគមន៍ដែលរងការប៉ះពាល់ ដោយតម្រូវឱ្យមានការពិនិត្យវាយតម្លៃកាន់តែហ្មត់ចត់សម្រាប់ទីកន្លែងដែលមាន វត្តមានប្រជាជនយុត្តិធម៌បរិស្ថាន។
នៅក្នុងការពិនិត្យវាយតម្លៃឡើងវិញនូវបបនីយភណ្ឌផលិតថាមពល ក្រុមប្រឹក្សាភិបាល ពិចារ

ណាទៅលើផលប៉ះពាល់បង្ករផ្នែកសុខភាព ដោយរួមទាំងការពិចារណាទៅលើឥទ្ធិពលបន្សំ ដែលបង្កដោយចម្ងាយជិតទៅនឹងប្រភពថាមពល ឧស្សាហកម្ម ឬគមនាគមន៍។ ក្រុមប្រឹក្សាភិបាលកំណត់ទីតាង នឹងបន្តអនុវត្តការវិភាគដែលត្រូវបានកែលំអ អំពីផលប៉ះពាល់និងនិតិវិធីកាត់បន្ថយផលប៉ះពាល់នៅក្នុងការពិនិត្យវាយតម្លៃឡើងវិញនូវបបនីយភណ្ឌថាមពលដែលត្រូវស្នើឡើងដោយអនុលោមតាមផ្នែកទី20។ ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង ក៏នឹងចូលរួមជាមួយកិច្ចខិតខំប្រឹងប្រែងរបស់ភាគីពាក់ព័ន្ធរបស់នាយកដ្ឋានការពារបរិស្ថាន ដើម្បីវាយតម្លៃនិងស្វែងរកមតិយោបល់របស់សាធារណជនស្តីពីការអភិវឌ្ឍបង្កើតវិធីសាស្ត្រវាយតម្លៃផលប៉ះពាល់បង្ក។

## ការអនុវត្តយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន

### ផែនការស្តីពីការចូលរួមរបស់សាធារណជននិងការចូលរួមរបស់សហគមន៍

ទីភ្នាក់ងារការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន (EEA) ទាំងអស់ត្រូវបង្កើតផែនការស្តីពីការចូលរួមរបស់សាធារណជននិងការចូលរួមរបស់សហគមន៍ដែលបង្កើតកម្មវិធីដ៏ហ្មត់ចត់មួយដែលមានលក្ខណៈបរិយាប័ន្នដែលជំរុញការចូលរួមរបស់សាធារណជន ក្នុងសកម្មភាពគន្លឹះរបស់ទីភ្នាក់ងារទាំងនោះ ដែលផ្តោតធនធានរបស់ទីភ្នាក់ងារទាំងនោះទៅលើសកម្មភាពផ្សព្វផ្សាយនានាដែលបង្កើនឱកាសចូលរួមរបស់សាធារណជន ក្នុងសកម្មភាពរបស់ទីភ្នាក់ងារដែលអាចមានផលប៉ះពាល់ចំពោះប្រជាជនយុត្តិធម៌បរិស្ថាន។ ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង **(EFSB)** កំពុងបង្កើតផែនការស្តីពីការចូលរួមរបស់សាធារណជននិងការចូលរួមរបស់សហគមន៍ដែលជាផ្នែកមួយនៃកិច្ចដំណើការ ជូនដំណឹងអំពីការសាកសួរព័ត៌មាន (NOI) (សូមអាន ផ្នែក I.D)។

### ផែនការទទួលបានសេវាភាសា

ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) កំពុងបង្កើតផែនការទទួលបានសេវាភាសាដែលជាផ្នែកមួយនៃកិច្ចដំណើការ ជូនដំណឹងអំពីការសាកសួរព័ត៌មាន (NOI) (សូមអាន ផ្នែក I.D)។ ផែនការទទួលបានសេវាភាសា មានគោលដៅលុបបំបាត់របាំងរារាំងការទទួលបាន និងការបង្កើនឱកាសទទួលបានធាតុចូល និងការចូលរួមរបស់សាធារណជនសម្រាប់ភាគីពាក់ព័ន្ធដែលមានចំណេះដឹងភាសាអង់គ្លេសតិចតួច។ ផែនការទទួលបានសេវាភាសារបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) យ៉ាងហោចណាស់មានព័ត៌មានដូចខាងក្រោម៖

- ការកំណត់កម្រិតគោលសម្រាប់ការបកប្រែឯកសារគម្រោង និងការផ្តល់ការបកប្រែផ្ទាល់មាត់ សម្រាប់សវនាការផ្តល់មតិយោបល់សាធារណៈ សវនាការភ័ស្តុតាង និងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល។
- សេចក្តីពិពណ៌នាអំពីពិធីសារសេវាភាសារបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) (ដូចជា កិច្ចដំណើការស្នើសុំសេវាបកប្រែភាសា ឬការបកប្រែឯកសារ)
- សេចក្តីពិពណ៌នាអំពីលក្ខខណ្ឌតម្រូវរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) សម្រាប់ការជ្រើសរើសសេវាបកប្រែផ្ទាល់មាត់សម្រាប់សវនាការ

- សេចក្តីពិពណ៌នាអំពី “ឯកសារសាធារណៈសំខាន់ៗ” ទូទៅ ដែលក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) នឹងបកប្រែទៅជាភាសាដែលប្រជាជននិយាយច្រើនជាងគេនៅក្នុងខំមិនវែល[7]
- សេចក្តីពិពណ៌នាអំពី “ឯកសារសាធារណៈសំខាន់ៗ” ដែលពាក់ព័ន្ធនឹងគម្រោងដែលក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) នឹងតម្រូវឱ្យបកប្រែកជាភាសាដែលត្រូវប្រជាជនប្រើប្រាស់ជាទូទៅនៅក្នុងតំបន់គម្រោង[8]
- សេចក្តីពិពណ៌នាអំពីគោលវិធីរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) ដើម្បីផ្សព្វផ្សាយទៅដល់ប្រជាជនដែលមានចំណេះដឹងភាសាអង់គ្លេសតិចតួចនៅលើទំព័រវេប និង/ឬ បណ្តាញសង្គម របស់ខ្លួន។

## ខ្នាតរង្វាស់

ដើម្បីវាស់វែងការរីកចម្រើនឆ្ពោះទៅរកគោលដៅយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់ខ្លួន ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង នឹងបង្កើតខ្នាតរង្វាស់ ដើម្បីពិនិត្យតាមដានការចូលរួមរបស់សាធារណជន។ ការិយាល័យប្រត្តិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន នឹងបោះពុម្ពផ្សាយខ្នាតរង្វាស់ និងភាពរីកចម្រើនទាំងនេះ សម្រាប់ទីភ្នាក់ងាររបស់ការិយាល័យប្រត្តិបត្តិនៃកិច្ចការថាមពលនិងបរិស្ថាន នៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន។ លក្ខណៈវិនិច្ឆ័យមួយចំនួនដែលអាចត្រូវពិចារណាដោយក្រុមប្រឹក្សាភិបាលកំណត់ទីតាំង មានដូចខាងក្រោមៈ

- ចំនួនសំណើសុំការបកប្រែផ្ទាល់មាត់និងការបកប្រែសរសេរ ដោយរួមបញ្ចូលភាសាដែលត្រូវស្នើសុំនិងផ្តល់ជូន
- ចំនួនសំណើសុំជំនួយគាំទ្រផ្នែកសម្លេងនិងរូបភាព និងចំនួនសំណើសុំដែលត្រូវផ្តល់ជូន
- ចំនួនសារព័ត៌មានមិនមែនជាភាសាអង់គ្លេសដែលត្រូវប្រើប្រាស់សម្រាប់បោះពុម្ពផ្សាយលិខិតជូនដំណឹង
- ចំនួនសំណើសុំការផ្តល់សេវាបកប្រែផ្ទាល់មាត់និងសរសេរ ដែលត្រូវធ្វើឡើងនិងផ្តល់ជូន

[7]ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងពិចារណាទៅលើឯកសារទាំងនេះ ដើម្បីដាក់បញ្ចូលសៀវភៅព័ត៌មានរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) (ដែលផ្តល់សេចក្តីពិពណ៌នាពិស្តារអំពីកិច្ចដំណើការពិនិត្យវាយតម្លៃឡើងវិញរបស់ ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង និងការពន្យល់អំពីរបៀបផ្សេងៗគ្នាដើម្បីចូលរួមក្នុងកិច្ចដំណើការនោះ) ព័ត៌មានស្តីពីសំណើសុំការស្នាក់នៅ និងយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាននេះ។ ក្រុមការងារកិច្ចដំណើរការជូនដំណឹងអំពីការសាកសួរព័ត៌មាន នឹងបន្តកំណត់បង្ហាញអត្តសញ្ញាណឯកសារបន្ថែមដែលមានសារៈសំខាន់សម្រាប់ប្រជាជនក្នុងការស្វែងយល់អំពីសិទ្ធិរបស់ពួកគេនៅក្នុងបញ្ហានានារបស់ ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) និងធ្វើបច្ចុប្បន្នកម្មតារាងនៅក្នុងផែនការទទួលបានសេវាភាសា។

[8]ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង ពិចារណាទៅលើឯកសារទាំងនេះដើម្បីដាក់បញ្ចូលសេចក្តីជូនដំណឹងជាសាធារណៈ ឯកសារផ្សព្វផ្សាយច្បាប់ស្តីពីគោលនយោបាយបរិស្ថានរដ្ឋម៉ាសាជូសេត (MEPA) (ប្រសិនបើមិនទាន់ត្រូវបានបកប្រែរួចរាល់) សេចក្តីពន្យល់របស់ផែនទី និងឯកសារផ្សព្វផ្សាយផ្សេងបន្ថែមទៀត។ ក្រុមការងារកិច្ចដំណើរការជូនដំណឹងអំពីការសាកសួរព័ត៌មាន នឹងបន្តកំណត់បង្ហាញឯកសារបន្ថែមនិងធ្វើបច្ចុប្បន្នកម្មតារាងនៅក្នុងផែនការទទួលបានសេវាភាសា។

- ចំនួនដងដែលក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) ប្រើប្រាស់បុគ្គលិកធនាគារភាសារបស់នាយកដ្ឋានសេវាសាធារណៈ សម្រាប់ការបកប្រែសរសេរ/ផ្ទាល់មាត់
- មូលនិធិដែលត្រូវចំណាយដោយក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) និងអ្នកដាក់ពាក្យស្នើសុំ សម្រាប់សេវាបកប្រែផ្ទាល់មាត់និងសរសេរ
- ចំនួនមតិយោបល់វិជ្ជមាន/អវិជ្ជមានដែលទទួលបានពាក់ព័ន្ធនឹងគុណភាពនៃការបកប្រែសរសេរ/ផ្ទាល់មាត់
- ចំនួនវគ្គបណ្តុះបណ្តាលពាក់ព័ន្ធនឹងការទទួលបានសេវាភាសាដែលបុគ្គលិកបានចូលរួម
- ចំនួនកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ (ដោយរួមទាំងកិច្ចពិភាក្សាស្តីពីការទទួលបានសេវាភាសាដែលត្រូវផ្តល់ជូនដោយក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB))

### ការវាយតម្លៃតាមកាលកំណត់

ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) នឹងពិនិត្យវាយតម្លៃឡើងវិញនូវយុទ្ធសាស្រ្តយុត្តិធម៌បរិស្ថានរបស់ខ្លួន ផែនការស្តីពីការចូលរួមរបស់សាធារណជននិងការចូលរួមរបស់សហគមន៍ និងផែនការទទួលបានសេវាភាសារបស់ខ្លួន តាមកាលកំណត់ ប៉ុន្តែមិនឱ្យតិចជាងរៀងរាល់ពីរឆ្នាំម្តងនោះឡើយ។ ឯកសារទាំងនេះនឹងត្រូវពិនិត្យឡើងវិញដោយក្រុមការងារយុត្តិធម៌បរិស្ថាន ដែលរួមបញ្ចូលនាយកក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) និងអគ្គទីប្រឹក្សា។ ការពិនិត្យវាយតម្លៃដែលត្រូវធ្វើឡើងដោយក្រុមការងារយុត្តិធម៌បរិស្ថាន នឹងបន្តការវិភាគដែលមិនទាន់ត្រូវបញ្ចប់ណាមួយមកពីក្រុមការងារលិខិតជូនដំណឹងអំពីការសាកសួរព័ត៌មាន និងត្រួតពិនិត្យការបំពេញការងាររបស់ទីភ្នាក់ងារ ដែលត្រូវវាស់វែងដោយទិន្នន័យវាស់វែងដែលត្រូវប្រមូលបាន និងត្រួតពិនិត្យឱកាសថ្មីៗ ឬបច្ចេកទេសថ្មីៗ។

## ការប្តេជ្ញាចិត្តរបស់កម្លាំងពលកម្ម

### ការបណ្តុះបណ្តាល

បុគ្គលិករបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) នឹងចូលរួមក្នុងវគ្គបណ្តុះបណ្តាលដែលត្រូវរៀបចំដោយការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន និងនាយកដ្ឋានស្តីពីគោលនយោបាយទទួលបានសេវាភាសានិងយុត្តិធម៌បរិស្ថាន និង/ឬវគ្គបណ្តុះបណ្តាលសមស្របណាមួយ ដែលត្រូវរៀបចំដោយអង្គការខាងក្រៅ (ដូចជាទីភ្នាក់ងារការពារបរិស្ថានរបស់សហរដ្ឋអាមេរិកជាដើម)។ វគ្គបណ្តុះបណ្តាលចាំបាច់ដែលត្រូវរៀបចំដោយការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន រួមមាន៖

- ការប្រើប្រាស់ឧបករណ៍គូសផែនទីនិងត្រួតពិនិត្យថ្នាក់រដ្ឋដែលមានស្រាប់ដើម្បីកំណត់បង្ហាញអត្តសញ្ញាណសង្កាត់យុត្តិធម៌បរិស្ថាននិងវាយតម្លៃផលប៉ះពាល់របស់គម្រោងនៅក្នុងតំបន់ទាំងនេះ និង
- និយមន័យ ការអនុវត្ត និងគោលដៅនៃការចូលរួមរបស់ភាគីពាក់ព័ន្ធ។

## ការជ្រើសរើសបុគ្គលិក

ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) យល់ដឹងនិងផ្តល់តម្លៃចំពោះសារៈសំខាន់នៃ
ម្លាំងពលកម្មរបស់ទីភ្នាក់ងារ ដែលឆ្លុះបញ្ចាំងនូវភាពចម្រុះផ្នែកជាតិសាសន៍ ជាតិពន្ធុ
និងសេដ្ឋកិច្ចសង្គមនៃប្រជាជនដែលរស់នៅក្នុងរដ្ឋម៉ាសាជូសេត។
ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង យល់ឃើញថាកម្លាំងពលកម្មបែបនេះ មានតួនាទីសំខាន់
ក្នុងការពង្រឹងសេចក្តីសម្រេចដែលមានសមធម៌ពាក់ព័ន្ធនឹងគោលនយោបាយ
ផ្តល់ការអនុញ្ញាតផ្នែកបរិស្ថាននិងថាមពល ការជ្រើសរើសទីតាំង ការបង្កើតច្បាប់បញ្ញត្តិ
គ្រប់គ្រង និងការអនុវត្តច្បាប់ និងបញ្ហាផ្សេងៗទៀតដែលពាក់ព័ន្ធនឹងយុត្តាធិការ
របស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB)។ ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB)
ប្តេជ្ញាអនុវត្តសេចក្តីណែនាំទាំងអស់របស់ការិយាល័យប្រតិបត្តិកិច្ចការថាមពលនិងបរិស្ថាន (EEA)
ពាក់ព័ន្ធនឹងការអនុវត្តការជ្រើសរើសបុគ្គលិកប្រកបដោយសមធម៌។

ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) ដែលមានសមាជិក 9 រូប មានសមាសភាព លេខាធិកា
រការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន (EEA) ជាប្រធាន លេខាធិការនៃការអភិវ
ឌ្ឍលំនៅដ្ឋាននិងសេដ្ឋកិច្ច ស្នងការនៃនាយកដ្ឋានការពារបរិស្ថាន ស្នងការនៃនាយកដ្ឋានធនធា
នថាមពល ស្នងការពីររូបមកពីនាយកដ្ឋានសេវាសាធារណៈ និងសមាជិកសាធារណជន 3
រូបដែលត្រូវតែងតាំងដោយអភិបាលរដ្ឋ។ សមាជិកសាធារណជនបីរូបនោះ
មានបទពិសោធន៍លើបញ្ហាបរិស្ថាន ពលកម្ម និងថាមពល។
សមាសភាពផ្លូវការរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង ផ្តល់ជូននូវចំណេះដឹងអំពី
ប្រធានបទនេះយ៉ាងទូលំទូលាយ ហើយពាក់ព័ន្ធនឹងគោលនយោបាយរបស់ទីភ្នាក់ងារ
ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (EFSB) មានគោលបំណងបង្កើតក្រុមប្រឹក្សាភិបាល
មួយដែលឆ្លុះបញ្ចាំងនូវភាពចម្រុះជាតិសាសន៍ ជាតិពន្ធុ និងសេដ្ឋកិច្ចសង្គមរបស់
ប្រជាជនរស់នៅក្នុងរដ្ឋម៉ាសាជូសេត។

## សន្និដ្ឋាន

តាមរយៈយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់ការិយាល័យប្រតិបត្តិកិច្ចការថាមពលនិងបរិស្ថាន
(EEA) និងយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាននេះ ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង
ប្តេជ្ញាធានាឱ្យមានកិច្ចការពារស្មើភាពគ្នានិងការចូលរួមពេញលេញ
របស់ប្រជាជននិងសហគមន៍ទាំងអស់ ពាក់ព័ន្ធនឹងការអភិវឌ្ឍ ការអនុវត្ត និងការអនុវត្តច្បាប់
បទបញ្ញត្តិ និងគោលនយោបាយ ស្តីពីថាមពល បម្រែបម្រួលអាកាសធាតុ និងបរិស្ថាន និង
បំណែងចែកដោយសមធម៌នូវផលប្រយោជន៍និងបន្ទុកផ្នែកថាមពលនិងបរិស្ថាន។

## ការអនុវត្តយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់ការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន

ពាក់ព័ន្ធនឹងក្តីបារម្ភ ពាក្យបណ្តឹង ការបំពេញបន្ថែម ឬគំនិតផ្សេងៗពាក់ព័ន្ធនឹង
យុត្តិធម៌បរិស្ថាន ឬដើម្បីស្វែងយល់បន្ថែមអំពីកិច្ចខិតខំប្រឹងប្រែងផ្នែកយុត្តិធម៌បរិស្ថាន
ថាមពល និងអាកាសធាតុរបស់ទីភ្នាក់ងារយើង សូមទាក់ទងការិយាល័យយុត្តិធម៌បរិស្ថានរបស់
EEA ដែលមានចែងនៅទំព័រទី 19 នៃយុទ្ធសាស្ត្របរិស្ថានរបស់ EEA។

សម្រាប់សំណួរពាក់ព័ន្ធនឹងយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាននេះ សូមទាក់ទង៖

Andrew Greene
នាយកក្រុមប្រឹក្សាភិបាលកំណត់ទីតាំងឋបនីយភណ្ឌថាមពល
Andrew.Greene@mass.gov

សម្រាប់សំណើសុំការស្នាក់នៅជាក់លាក់ សូមទាក់ទង៖

Geneen Bartley
ជំនួយការរដ្ឋបាល ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងឋបនីយភណ្ឌថាមពល
Geneen.Bartley@mass.gov

ព្រាង

# មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត

MASSACHUSETTS
CLEAN ENERGY
CENTER

# យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន

ព្រាង

# តារាងមាតិកា

**មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត ........ 150**

សារតារនិងបេសកកម្មរបស់មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC)........ 152

គោលនយោបាយយុត្តិធម៌បរិស្ថានរបស់ការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន (EEA)........ 153

យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន និងភាពចម្រុះ សមធម៌និងបរិយាប័ន ........ 155

*ការពង្រឹងលើកកម្ពស់ការអប់រំនិងការយល់ដឹងអំពីយុត្តិធម៌បរិស្ថាន និងភាពចម្រុះ សមធម៌និងបរិយាប័ន........ 155*

*ពង្រឹងបណ្តាញភាគីពាក់ព័ន្ធនៃយុត្តិធម៌បរិស្ថាន និងភាពចម្រុះ សមធម៌ និងបរិយាប័ន និងកែលម្អការប្រាស្រ័យទាក់ទង........ 157*

*យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាននិងភាពចម្រុះ សមធម៌ និងបរិយាប័ន និងខ្វាតរង្វាស់នៅក្នុងតំបន់កម្មវិធី........ 161*

ការអនុវត្តយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់ការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន........ 164

ព្រាង

# មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន ភាពចម្រុះ សមធម៌ និងបរិយាប័ន

## សាវតារនិងបេសកកម្មរបស់មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC)

ដោយត្រូវបង្កើតឡើងដោយជំពូក 23J នៃច្បាប់ទូទៅមជ្ឈមណ្ឌល ថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) ចាប់ផ្តើមដំណើការ នៅក្នុងឆ្នាំ2009។ មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) គឺជាទីភ្នាក់ងារដែលមានចរិតលក្ខណៈដូចទីភ្នាក់ងារសាធារណៈ ដែលជាចម្បងទទួលបានមូលនិធិពីមូលនិធិថាមពលកកើតឡើងវិញរបស់រដ្ឋម៉ាសាជូសេត ដែលត្រូវអនុញ្ញាតដោយសភារដ្ឋម៉ាសាជូសេត ក្នុងឆ្នាំ1997។

មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) ផ្តោតការយកចិត្តទុកដាក់ចំពោះវិស័យថាមពលស្អាតដែលកំពុងរីកចម្រើនលូតលាស់ តាមរយៈការផ្តល់ការគាំទ្រដល់នវានុវត្តន៍ ការជ្រើសរើសនិងការអភិវឌ្ឍទីផ្សារ និងការអភិវឌ្ឍកម្លាំងពលកម្មនិងឧស្សាហកម្ម។ បេសកកម្មរបស់មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) គឺពន្លឿននវានុវត្តន៍ថាមពលស្អាតនិងនវានុវត្តន៍ដំណោះស្រាយបញ្ហាអាកាសធាតុ ដែលមានសារៈសំខាន់ចំពោះការសម្រេចគោលដៅអាកាសធាតុរបស់រដ្ឋម៉ាសាជូសេត ដែលមានគោលដៅប្រែក្លាយរដ្ឋម៉ាសាជូសេត ទៅជាអ្នកនាំមុខអន្តរជាតិផ្នែកអាកាសធាតុ ដោយទន្ទឹមគ្នានេះ ធ្វើឱ្យសេដ្ឋកិច្ចថាមពលស្អាតរបស់រដ្ឋរីកចម្រើនលូតលាស់។

មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) ប្តេជ្ញាបង្កើតអង្គការដែលមានលក្ខណៈចម្រុះមួយដែលមានសមធម៌និងបរិយាប័ន ដែលមនុស្សគ្រប់រូបត្រូវស្វាគមន៍ គាំទ្រ គោរព និងផ្តល់តម្លៃ។ យើងប្តេជ្ញាដាក់បញ្ចូលគោលការណ៍នៃភាពចម្រុះ សមធម៌ បរិយាប័ន និងយុត្តិធម៌បរិស្ថាន ទៅក្នុងគ្រប់ទិដ្ឋភាពទាំងអស់នៃកិច្ចការងាររបស់យើង ដើម្បីពង្រឹងបំណែងចែកដោយសមធម៌នូវផលប្រយោជន៍សុខភាព និងសេដ្ឋកិច្ច នៃថាមពលស្អាត និងជួយគាំទ្រឧស្សាហកម្មថាមពលស្អាតដែលមានលក្ខណៈចម្រុះនិងបរិយាប័ន។ មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) ខិតខំព្យាយាមដឹកនាំនិងបង្កើតដំណោះស្រាយថាមពលស្អាតនិងអាកាសធាតុដែលមានសមធម៌។

ដោយសហការយ៉ាងជិតស្និទ្ធជាមួយការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន (EEA) មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) គាំទ្រដំណោះស្រាយថាមពលស្អាតនិងអាកាសធាតុបែបនវានុវត្តន៍ ដោយផ្តោតលើវិស័យសំខាន់ៗចំនួន4៖ បរិស្ថានដែលបង្កើតដោយមនុស្ស គមនាគមន៍ ខ្សែបណ្តាញចែកចាយដែលផលធៀបនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ស្មើសូន្យ និងថាមពលខ្យល់សមុទ្រ។ តាមរយៈមូលនិធិនិងការវិនិយោគដែលមានលក្ខណៈយុទ្ធសាស្ត្ររបស់ខ្លួន មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) គាំទ្រដំណោះស្រាយនានាដែលពង្រឹងការអភិវឌ្ឍសេដ្ឋកិច្ចថាមពលស្អាតរបស់រដ្ឋ ដែលពន្លឿនការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់របស់រដ្ឋ និងកាត់បន្ថយសោហ៊ុយចំណាយរបស់អាជីវកម្មនិងរបស់អ្នកប្រើប្រាស់នានា ពាក់ព័ន្ធនឹងដំណោះស្រាយថាមពលស្អាតនិងអាកាសធាតុ។ មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត

(MassCEC) ក៏ផ្តល់មូលនិធិជូនដល់កិច្ចខិតខំបណ្តុះបណ្តាលកម្លាំងពលកម្ម ដើម្បីធានាថាយើងមានកម្លាំងពលកម្មថាមពលស្អាតដែលមានលក្ខណៈចម្រុះ និងទទួលបានការបណ្តុះបណ្តាលយ៉ាងល្អ ដើម្បីសម្រេចគោលដៅអាកាសធាតុប្រកបដោយមហិច្ឆតាខ្ពស់របស់រដ្ឋ ហើយមជ្ឈមណ្ឌល ក៏គាំទ្រកម្មវិធីនានាដែលបង្កលទ្ធភាពឱ្យប្រជាជនដែលមានប្រាក់ចំណូលមធ្យមនិងប្រជាជនដែលរស់នៅក្នុងសហគមន៍យុត្តិធម៌បរិស្ថាន ទទួលបានដំណោះស្រាយនិងបច្ចេកវិទ្យាថាមពលស្អាតផងដែរ។ តាមរយៈកម្មវិធីនិងគំនិតផ្តួចផ្តើមផ្សេងៗរបស់ខ្លួន មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) សម្របសម្រួលកិច្ចសហការជាមួយភាគីពាក់ព័ន្ធជាច្រើន (ដោយរួមទាំង ក្រុមហ៊ុននវានុវត្តជនក្នុងវិស័យសិក្សា អ្នកវិនិយោគឯកជន ទីភ្នាក់ងាររដ្ឋាភិបាល អង្គការមិនស្វែងរកប្រាក់ចំណេញ និងសហគមន៍) ដើម្បីពន្លឿន និងដាក់ឱ្យប្រើប្រាស់នូវដំណោះស្រាយអាកាសធាតុនិងថាមពលស្អាត នៅពាសពេញទូទាំងខំមិនវែល។

## គោលនយោបាយយុត្តិធម៌បរិស្ថានរបស់ការិយាល័យប្រតិបត្តិនៃកិច្ចការថាមពល និងបរិស្ថាន (EEA)

គោលនយោបាយយុត្តិធម៌បរិស្ថានរបស់ការិយាល័យប្រតិបត្តិនៃកិច្ចការថាមពលនិងបរិស្ថាន (EEA) តម្រូវឱ្យទីភ្នាក់ងារទាំងអស់របស់ការិយាល័យប្រតិបត្តិនៃកិច្ចការថាមពលនិងបរិស្ថាន (EEA) អភិវឌ្ឍបង្កើតយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់ខ្លួនផ្ទាល់។ គោលនយោបាយនេះចែងថា “ទីភ្នាក់ងារទាំងអស់របស់ការិយាល័យប្រតិបត្តិនៃកិច្ចការថាមពលនិងបរិស្ថាន (EEA) ត្រូវពិចារណាអំពីរបៀបធ្វើសមាហរណកម្មដាក់បញ្ចូលការគិតពិចារណាអំពីយុត្តិធម៌បរិស្ថាន ទៅក្នុងនាយកដ្ឋានរបស់ពួកគេឱ្យបានសមស្រប តាមរយៈគោលនយោបាយ កម្មវិធី និងយុទ្ធសាស្ត្រដទៃផ្សេងទៀត។ ទីភ្នាក់ងារ EEA ត្រូវកំណត់អត្តសញ្ញាណ និងជំរុញគម្រោងដែលមានការឧបត្ថម្ភពីទីភ្នាក់ងារ ដោយផ្តល់ប្រាក់ឧបត្ថម្ភដល់ការធ្វើសេចក្តីសម្រេចចិត្ត ការកំណត់វិធាន ឬចំណាត់ការដទៃទៀតដែលមានបំណងក្នុងការលើកកម្ពស់យុត្តិធម៌បរិស្ថានបន្ថែមទៀតនៅទូទាំងខំមិនវែលទាំងមូល ដើម្បីបង្ហាញពីរបៀបនៃការវាស់វែងការបែងចែកអត្ថប្រយោជន៍ដែលត្រឹមត្រូវ។[1]

គោលនយោបាយយុត្តិធម៌បរិស្ថានពិពណ៌នា “យុត្តិធម៌បរិស្ថាន” តាមរបៀបដូចខាងក្រោម៖

“យុត្តិធម៌បរិស្ថាន គឺផ្អែកលើគោលការណ៍ដែលថា មនុស្សទាំងអស់ មានសិទ្ធិទទួលបានកិច្ចការពារឱ្យរួចផុតពីគ្រោះថ្នាក់បរិស្ថាន និងមានសិទ្ធិរស់នៅនិងទទួលបានបរិស្ថានស្អាតនិងប្រកបដោយសុខភាពល្អ ដោយមិនគិតពីជាតិសាសន៍ ពណ៌សម្បុរ ដើមកំណើតជាតិសាសន៍ ប្រាក់ចំណូល ឬចំណេះដឹងភាសាអង់គ្លេស។ យុទ្ធសាស្ត្រយុត្តិធ៌មបរិស្ថាន

---

[1] គោលនយោបាយយុត្តិធម៌បរិស្ថានរបស់ការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន ថ្ងៃទី24 ខែមិថុនា ឆ្នាំ2021 https://www.mass.gov/doc/environmental-justice-policy6242021-update/download។ មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) ស្ម័គ្រចិត្តជ្រើសរើសយកគោលនយោបាយនេះ ធ្វើជាឧត្តមានុវត្តន៍ ដោយផ្អែកលើទំនាក់ទំនងការងារយ៉ាងជិតស្និទ្ធរបស់ខ្លួនជាមួយ ការិយាល័យប្រតិបត្តិនៃកិច្ចការថាមពលនិងបរិស្ថាន (EEA) និងបំណងរបស់មជ្ឈមណ្ឌល ក្នុងការដោះស្រាយយុត្តិធម៌បរិស្ថាន និងភាពចម្រុះ សមធម៌ និងបរិយាប័ន តាមរបៀបបុរេសកម្ម នៅក្នុងរចនាសម្ព័ន្ធស្ថាប័ននិងកិច្ចការងារជាក់ស្តែងរបស់ខ្លួន។

គឺជាកិច្ចការពារស្មើភាពគ្នា និងជាការចូលរួមពេញលេញរបស់ប្រជាជននិងសហគមន៍ទាំងអស់ពាក់ព័ន្ធនឹងការអភិវឌ្ឍ ការអនុវត្ត និងការអនុវត្តច្បាប់ បទបញ្ញត្តិ និងគោលនយោបាយស្តីពីថាមពល បម្រែបម្រួលអាកាសធាតុ និងបរិស្ថាន និង បំណែងចែកដោយសមធម៌នូវផលប្រយោជន៍និងបន្ទុកផ្នែកថាមពលនិងបរិស្ថាន។"

ជាងនេះទៅទៀត គោលនយោបាយនេះកំណត់និយមន័យ "ផលប្រយោជន៍ថាមពល" ថាជា "ការទទួលបានការផ្តល់មូលនិធិ ការបណ្តុះបណ្តាល ថាមពលថ្មីឬថាមពលកកើតឡើងវិញ ប្រសិទ្ធផលថាមពល ឬធនធានមានប្រយោជន៍ដទៃទៀតដែលត្រូវផ្តល់ជូន ដោយការិយាល័យប្រតិបត្តិនៃកិច្ចការថាមពលនិងបរិស្ថាន (EEA) ទីភ្នាក់ងារនិងការិយាល័យនានារបស់ខ្លួន។"

សង្កាត់យុត្តិធម៌បរិស្ថាន គឺជាសង្កាត់ដែលប្រជាជននៅទីនោះ ត្រូវបានការិយាល័យប្រតិបត្តិនៃកិច្ចការថាមពលនិងបរិស្ថាន (EEA) ចាត់ទុកថាមានហានិភ័យខ្ពស់បំផុតក្នុងការមិនយល់ដឹងឬមិនអាចចូលរួមក្នុងការសម្រេចចិត្តផ្នែកបរិស្ថានឬមិនអាចទទួលបានធនធានបរិស្ថានរបស់រដ្ឋ ឬងាយរងគ្រោះយ៉ាងខ្លាំង។ សង្កាត់ទាំងនេះត្រូវកំណត់និយមន័យថាជាសង្កាត់ (ទិន្នន័យក្រុមប្លុកជំរឿនរបស់ការិយាល័យជំរឿនសហរដ្ឋអាមេរិកសម្រាប់កំណត់លក្ខណៈវិនិច្ឆ័យជនជាតិភាគតិច និងទិន្នន័យការស្ទង់មតិសហគមន៍អាមេរិកសម្រាប់កំណត់លក្ខណៈវិនិច្ឆ័យប្រាក់ចំណូលមធ្យមប្រចាំរដ្ឋនិងភាពឯកោផ្នែកភាសាអង់គ្លេស) ដែលបំពេញតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោមចាប់ពីចំនួនមួយឡើងទៅ៖

- ប្រាក់ចំណូលគ្រួសារមធ្យមប្រចាំឆ្នាំ គឺមិនលើសពី 65 ភាគរយនៃប្រាក់ចំណូលគ្រួសារមធ្យមប្រចាំឆ្នាំទូទាំងរដ្ឋ។ ជនជាតិភាគតិច មានចំនួន 40 ភាគរយឬច្រើនជាងនេះនៅក្នុងចំណោមប្រជាជនសរុប។
- គ្រួសារចំនួន 25 ភាគរយឡើងទៅ ពុំមានចំណេះដឹងភាសាអង់គ្លេស ឬ
- ប្រជាជនភាគតិច មានចំនួន 25 ភាគរយឬច្រើនជាងនេះនៃប្រជាជនសរុប ហើយប្រាក់ចំណូលគ្រួសារមធ្យមប្រចាំឆ្នាំនៃទីក្រុងដែលសង្កាត់នោះមានទីតាំងស្ថិតនៅ គឺមិនលើសពី 150 ភាគរយនៃប្រាក់ចំណូលគ្រួសារមធ្យមប្រចាំឆ្នាំទូទាំងរដ្ឋ។

ក្នុងនាមជាទីភ្នាក់ងាររដ្ឋដែលមានចរិតលក្ខណៈដូចទីភ្នាក់ងារសាធារណៈ មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) ពុំស្ថិតនៅក្រោមគោលនយោបាយយុត្តិធម៌បរិស្ថានរបស់ការិយាល័យប្រតិបត្តិនៃកិច្ចការថាមពលនិងបរិស្ថាន (EEA) នោះឡើយ ប៉ុន្តែមជ្ឈមណ្ឌលនេះ ព្យាយាមធ្វើសមាហរណកម្មគោលការណ៍យុត្តិធម៌បរិស្ថាននិងផ្តល់ផលប្រយោជន៍ថាមពលស្អាតជូនដល់ សង្កាត់យុត្តិធម៌បរិស្ថាននិងប្រជាជនដែលទទួលបានសេវាមិនគ្រប់គ្រាន់ដទៃផ្សេងទៀត។ ជាងនេះទៅទៀត ក្នុងនាមជាទីភ្នាក់ងារដែលគាំទ្រការរីកចម្រើន លូតលាស់នៃឧស្សាហកម្មថាមពលស្អាត មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) ខិតខំផ្សព្វផ្សាយលើកកម្ពស់គោលការណ៍ភាពចម្រុះ សមធម៌ និងបរិយាប័ន នៅពាសពេញទូទាំងឧស្សាហកម្មនេះ និងជួយតម្រង់ទិសដៅនៃកំណើនរបស់ខ្លួន តាមរបៀបមួយដែលមានលក្ខណៈចម្រុះ សមធម៌ និងបរិយាប័ន។

# យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន និងភាពចម្រុះ សមធម៌និងបរិយាប័ន

យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន និងភាពចម្រុះ សមធម៌និងបរិយាប័ន របស់មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) ដាក់ចេញនូវក្របខណ្ឌយុទ្ធសាស្ត្រ និងសកម្មភាពគន្លឹះនានាដែលមជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) នឹងអនុវត្ត ដើម្បីធ្វើសមាហរណកម្មដាក់បញ្ចូលគោលការណ៍យុត្តិធម៌បរិស្ថានទៅក្នុងកម្មវិធី ភាពជាដៃគូ និងតួនាទីជាអ្នកដឹកនាំនិងសមាជិកនៃឧស្សាហកម្មថាមពលស្អាត។

សកម្មភាពគន្លឹះៗរបស់ទីភ្នាក់ងារ៖

- ខិតខំកសាងកម្លាំងពលកម្មរបស់មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) ដែលឆ្លុះបញ្ចាំងភាពចម្រុះជាតិសាសន៍ ជាតិពន្ធុ និងសេដ្ឋកិច្ចសង្គម របស់ប្រជាជនដែលរស់នៅក្នុងរដ្ឋម៉ាសាជូសេត។ អប់រំបុគ្គលិកស្តីពីគោលការណ៍យុត្តិធម៌បរិស្ថាន និងគោលការណ៍នៃភាពចម្រុះ សមធម៌ និងបរិយាប័ន និងចែករំលែកធនធាននិងឧត្តមានុវត្តន៍នានា ជាមួយភាគីពាក់ព័ន្ធខាងក្រៅតាមភាពសមស្រប។
- ពង្រឹងបណ្តាញភាគីពាក់ព័ន្ធទាក់ទងនឹងគោលការណ៍យុត្តិធម៌បរិស្ថាន និងគោលការណ៍នៃភាពចម្រុះ សមធម៌ និងបរិយាប័ន និងពង្រឹងការប្រាស្រ័យទាក់ទងនៅពាសពេញទូទាំងការអភិវឌ្ឍនិងការអនុវត្តកម្មវិធីនិងសកម្មភាពនានារបស់មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) ដើម្បីបង្កលទ្ធភាពឱ្យមានការចូលរួមពេញលេញ និងចែករំលែកដោយសមធម៌នូវផលប្រយោជន៍របស់កម្មវិធីទាំងនេះទៅដល់ប្រជាជននិងសហគមន៍ចម្រុះ ដែលឆ្លុះបញ្ចាំងនូវភាពចម្រុះជាតិសាសន៍ ជាតិពន្ធុ និងសេដ្ឋកិច្ចសង្គម របស់ប្រជាជនដែលរស់នៅក្នុងរដ្ឋម៉ាសាជូសេត
- បង្កើតគោលដៅសម្រាប់ការចំណាយរបស់ទីភ្នាក់ងារទាំងមូល សម្រាប់តំបន់នានាដូចជាសង្កាត់យុត្តិធម៌បរិស្ថាន ទីក្រុងច្រកទ្វាចេញចូល (Gateway Cities) គំនិតផ្តួចផ្តើមប្រាក់ចំណូលទាបនិងមធ្យម និងសេវាបកប្រែ នៅត្រឹមដំណាច់ឆ្នាំសារពើពន្ធ 2023។

ព័ត៌មានពិស្តារបន្ថែមស្តីពីសកម្មភាពរបស់មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) នៅក្នុងតំបន់ទាំងនេះ ត្រូវពិពណ៌នានៅខាងក្រោម៖

## ការពង្រឹងលើកកម្ពស់ការអប់រំនិងការយល់ដឹងអំពីយុត្តិធម៌បរិស្ថាន និងភាពចម្រុះ សមធម៌ និងបរិយាប័ន

មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) ទទួលស្គាល់នូវសារៈសំខាន់នៃវត្តមានកម្លាំងពលកម្មដែលឆ្លុះបញ្ចាំងនូវភាពចម្រុះជាតិសាសន៍ ជាតិពន្ធុ និងសេដ្ឋកិច្ចសង្គម របស់ប្រជាជនដែលរស់នៅក្នុងរដ្ឋម៉ាសាជូសេត ដោយរួមបញ្ចូលតួនាទីគន្លឹះរបស់កម្លាំងពលកម្មបែបនោះ ក្នុងការពង្រឹងលើកកម្ពស់ការសម្រេចចិត្តប្រកបដោយសមធម៌ពាក់ព័ន្ធនឹងបន្ទុកបរិស្ថាននិងថាមពល និងបំណែងចែកមូលនិធិ។

មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) នឹងធានាថាបុគ្គលិករបស់ខ្លួនយល់ដឹងអំពីគោលការណ៍យុត្តិធម៌បរិស្ថាន និងគោលការណ៍នៃភាពចម្រុះ សមធម៌ និងបរិយាប័ន តាមរយៈវគ្គបណ្តុះបណ្តាលនិងសិក្ខាសាលាពាក់ព័ន្ធនឹងគោលការណ៍នៃភាពចម្រុះ



MASSACHUSETTS CLEAN ENERGY CENTER

សមធម៌ និងបរិយាប័ន។ នៅពេលចាំបាច់និងសមស្រប មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) នឹងព្យាយាមចែករំលែកធនធាននិងគោលការណ៍ណែនាំស្តីពីឧត្តមានុវត្តន៍នានា ជាមួយឧស្សាហកម្ម ស្ថាប័នរដ្ឋាភិបាល និងភាគីដែលមានចំណាប់អារម្មណ៍ដទៃទៀត។ ខាងក្រោមនេះ គឺជាបញ្ជីគ្រួសៗនៃសកម្មភាពនានាដែលមជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) នឹងអនុវត្ត ដើម្បីអប់រំបុគ្គលិករបស់ខ្លួនអំពីគោលការណ៍ពាក់ព័ន្ធនឹងភាពចម្រុះ សមធម៌ និងបរិយាប័ន ព្រមទាំង ចែករំលែកឧត្តមានុវត្តន៍ជាមួយសហគមន៍ថាមពលស្អាត៖

- រក្សាទុកទីប្រឹក្សាឯកទេស ភាពចម្រុះ សមធម៌ និងបរិយាប័ន ដើម្បីបណ្តុះបណ្តាល និងអប់រំបុគ្គលិករបស់មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) ស្តីពីគោលការណ៍នៃភាពចម្រុះ សមធម៌ និងបរិយាប័ន។
- បង្កើតក្រុមការងារដែលមានសមាសភាពបុគ្គលិក មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) ដើម្បីវាយតម្លៃនិងអភិវឌ្ឍយុទ្ធសាស្ត្រស្តីពីបញ្ហាយុត្តិធម៌បរិស្ថាន និងភាពចម្រុះ សមធម៌ និងបរិយាប័ន នៅក្នុងមជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) និងនៅក្នុងការរៀបចំកម្មវិធីរបស់មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) ផងដែរ។
- ចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីយុត្តិធម៌បរិស្ថានដែលរៀបចំដោយការិយាល័យប្រតិបត្តិនៃកិច្ចការថាមពលនិងបរិស្ថាន (EEA) និងផ្សព្វផ្សាយចំណេះដឹងសមស្រប និងឧត្តមានុវត្តន៍ ទៅដល់បុគ្គលិកនិងភាគីពាក់ព័ន្ធរបស់មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC)។
- ដាក់បញ្ចូលភាពចម្រុះ ទៅក្នុងការអនុវត្តការជ្រើសរើសបុគ្គលិករបស់យើង និងផ្តល់ការបណ្តុះបណ្តាលជូនដល់អ្នកគ្រប់គ្រងផ្នែកជ្រើសរើសបុគ្គលិក ដើម្បីពង្រឹងការសម្រេចចិត្តប្រកបដោយសមធម៌ ទាំងនៅក្នុងកិច្ចដំណើរការជ្រើសរើសបុគ្គលិក ការវាយតម្លៃសមត្ថភាពអ្នកដាក់ពាក្យស្នើសុំក្នុងការពិចារណាអំពីតម្រូវការរបស់ប្រជាជនងាយរងគ្រោះ សង្កាត់យុត្តិធម៌បរិស្ថាន និងតំបន់ដែលទទួលបានសេវាពុំគ្រប់គ្រាន់នៃខំមិនវែល។
- ដាក់បញ្ចូលការបណ្តុះបណ្តាលស្តីពី យុត្តិធម៌បរិស្ថាន និងភាពចម្រុះ សមធម៌ និងបរិយាប័ន ទៅក្នុងកិច្ចដំណើការសមាហរណកម្មបញ្ចូលបុគ្គលិកថ្មី។
- ព្យាយាមផ្សព្វផ្សាយឱកាសការងារនៅក្នុងមជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) នៅក្នុងវេទិកាពាក់ព័ន្ធនានា ដែលអាចផ្សព្វផ្សាយទៅដល់សមាជិកសហគមន៍យុត្តិធម៌បរិស្ថាន (ដូចជា ផ្ទាំងផ្សព្វផ្សាយការងារនិងអាសយដ្ឋានវេប នៅតាមទីកន្លែងរបស់ក្រុមពាក់ព័ន្ធនិងអង្គការតស៊ូមតិពាក់ព័ន្ធនានា នៅតាមសាកលវិទ្យាល័យនិងមហាវិទ្យាល័យសហគមន៍ដែលផ្តល់សេវាដល់សង្កាត់យុត្តិធម៌បរិស្ថាន
- ការទទួលស្គាល់កិច្ចខិតខំប្រឹងប្រែងរបស់នយោជិតក្នុងការគាំទ្រកិច្ចការងារយុត្តិធម៌បរិស្ថាន និងភាពចម្រុះ សមធម៌ និងបរិយាប័ន របស់មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) ក្នុងអំឡុងពេលពិនិត្យវាយតម្លៃលទ្ធផលបំពេញការងារ។
- ធ្វើបច្ចុប្បន្នកម្មអាសយដ្ឋានវេប **អំពីយើង** របស់មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋ

ម៉ាសាជូសេត (MassCEC) ដើម្បីដាក់បញ្ចូលគុណតម្លៃនិងការប្ដេជ្ញាចិត្តរបស់មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) ដើម្បីសម្រេចឱ្យបានសមធម៌ ព្រមទាំងធ្វើបច្ចុប្បន្នកម្មគេហទំព័រ ការផ្សព្វផ្សាយឱកាសការងារ និងប្រាក់បម្រុងទុកសម្រាប់កម្មវិធី។

- ផ្សព្វផ្សាយឯកសារគន្លឹះរបស់ទីភ្នាក់ងារនិងឯកសារពាក់ព័ន្ធនឹង យុត្តិធម៌បរិស្ថាន និងភាពចម្រុះ សមធម៌ និងបរិយាប័ន នៅលើអាសយដ្ឋានវេប របស់មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) ដើម្បីឱ្យសាធារណជនអាចចូលទាញយកបានជាភាសាផ្សេងៗគ្នាជាច្រើនតាមដែលអាចធ្វើទៅបាន ដោយពិនិត្យតាមដាន ចំនួនឯកសារដែលត្រូវបកប្រែនិងធនធានហិរញ្ញវត្ថុដែលត្រូវប្រើប្រាស់សម្រាប់ការបកប្រែ និង
- ចែករំលែកឧត្តមានុវត្តន៍និងចំណេះដឹងនានា ជាមួយឧស្សាហកម្មថាមពលស្អាត និងស្ថាប័នរដ្ឋាភិបាលដទៃទៀត តាមភាពចាំបាច់និងសមស្រប។

## ពង្រឹងបណ្ដាញភាគីពាក់ព័ន្ធនៃយុត្តិធម៌បរិស្ថាន និងភាពចម្រុះ សមធម៌ និងបរិយាប័ន និងកែលម្អការប្រាស្រ័យទាក់ទង

តាមរយៈតួនាទីរបស់ខ្លួនជាអ្នកពន្លឿនទីផ្សារនិងបច្ចេកវិទ្យាថាមពលស្អាត មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) មានទំនាក់ទំនងយ៉ាងរឹងមាំជាមួយវិស័យឯកជន។ ក៏ប៉ុន្តែ ដើម្បីអភិវឌ្ឍកម្មវិធីនានាដែលធានានូវបំណែងចែកដោយសមធម៌ នូវផលប្រយោជន៍ថាមពលស្អាត មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) ត្រូវអភិវឌ្ឍទំនាក់ទំនងរឹងមាំដោយស្មើភាពជាមួយសង្កាត់យុត្តិធម៌បរិស្ថាន និងក្រុមសហគមន៍ភាពចម្រុះ សមធម៌ និងបរិយាប័ន ក្រុមតស៊ូមតិ និងភាគីពាក់ព័ន្ធនៃយុត្តិធម៌បរិស្ថាន និងភាពចម្រុះ សមធម៌ និងបរិយាប័ន ដទៃទៀត។

មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) នឹងបង្កលទ្ធភាពឱ្យក្រុមទាំងនេះចូលរួមពេញលេញក្នុងការអភិវឌ្ឍកម្មវិធី ការជ្រើសរើសបុគ្គលិក និងការអនុវត្ត។ គោលនយោបាយយុត្តិធម៌បរិស្ថានរបស់ការិយាល័យប្រតិបត្តិនៃកិច្ចការថាមពលនិងបរិស្ថាន (EEA) បញ្ជាក់ថា "ការចូលរួមពេញលេញ" រួមបញ្ចូលធាតុដូចខាងក្រោម៖ "គ្រប់សង្កាត់ទាំងអស់ មានសិទ្ធិ និងឱកាសចូលរួមក្នុងការសម្រេចចិត្តទាំងអស់ស្តីពីថាមពល បម្រែបម្រួលអាកាសធាតុ និងបរិស្ថាន ដោយរួមទាំងការវាយតម្លៃអំពីតម្រូវការ ការរៀបចំផែនការ ការអនុវត្ត ការគោរពអនុវត្តតាម និងការអនុវត្តច្បាប់ និងការវាយតម្លៃ ហើយសង្កាត់ទាំងអស់ត្រូវផ្តល់លទ្ធភាពនិងជួយគាំទ្រផ្នែករដ្ឋបាលដើម្បីចូលរួមពេញលេញ តាមរយៈការអប់រំនិងការបណ្តុះបណ្តាលព្រមទាំងទទួលបាន តម្លាភាព/គណនេយ្យភាពពីរដ្ឋាភិបាល ពាក់ព័ន្ធនឹងធាតុចូលរបស់សហគមន៍ ព្រមទាំងត្រូវលើកទឹកចិត្តឱ្យអភិវឌ្ឍបង្កើតទំនួលខុសត្រូវផ្នែកបរិស្ថាន ថាមពល និងបម្រែបម្រួលអាកាសធាតុ។" ខាងក្រោមនេះ គឺជាបញ្ជីត្រួសៗនៃសកម្មភាពដែលមជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) នឹងអនុវត្ត ដើម្បីពង្រឹងកិច្ចសហការនិងការប្រាស្រ័យទាក់ទងរបស់ខ្លួន មួយភាគីពាក់ព័ន្ធនៃយុត្តិធម៌បរិស្ថាននិង ភាពចម្រុះ សមធម៌ និងបរិយាប័ន។

- ផ្តល់បញ្ជីអង្គការយុត្តិធម៌បរិស្ថាននិងភាពចម្រុះ សមធម៌ និងបរិយាប័ន ក្រុមសហគមន៍ ក្រុមប្រព័ន្ធផ្សព្វផ្សាយយុត្តិធម៌បរិស្ថាន ក្រុមតស៊ូមតិ ដែលបុគ្គលិកទាំងអស់របស់មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) អាចប្រាស្រ័យទាក់ទងជាមួយពួកគេទាំងនោះ។
  - ដាក់បញ្ចូលអង្គការពាក់ព័ន្ធពីពេលមុននិងធ្វើបច្ចុប្បន្នកម្មជាទៀងទាត់នូវទំនាក់ទំនងថ្មីៗ និង
  - ចែករំលែកនិងសម្របសម្រួលជាមួយ ការិយាល័យប្រតិបត្តិនៃកិច្ចការថាមពលនិងបរិស្ថាន (EEA) និងទីភ្នាក់ងាររបស់ការិយាល័យប្រតិបត្តិនៃកិច្ចការថាមពលនិងបរិស្ថាន (EEA) តាមភាពជាក់ស្តែងនិងភាពសមស្រប។
- កសាងទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធនៃយុត្តិធម៌បរិស្ថាននិងភាពចម្រុះ សមធម៌ និងបរិយាប័ន និងក្រុមសហគមន៍នានា តាមរយៈការប្រាស្រ័យទាក់ទងជាប្រចាំ៖
  - រៀបចំកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធនៃយុត្តិធម៌បរិស្ថាននិងភាពចម្រុះ សមធម៌ និងបរិយាប័ន (ដូចជាអង្គការដែលមានមូលដ្ឋាននៅក្នុងសង្កាត់ ក្រុមឧស្សាហកម្មដែលផ្តោតលើភាពចម្រុះ សមធម៌ និងបរិយាប័ន និងក្រុមតស៊ូមតិអ្នកប្រើប្រាស់សេវាសាធារណៈដែលមានប្រាក់ចំណូលទាប ក្រុមតស៊ូមតិយុត្តិធម៌បរិស្ថាន) ដើម្បីស្វែងយល់ពីតម្រូវការនិងអាទិភាពថាមពលស្អាត។
  - ចូលរួមក្នុងកិច្ចប្រជុំស្តាប់មតិយោបល់ដែលដឹកនាំដោយការិយាល័យប្រតិបត្តិនៃកិច្ចការថាមពលនិងបរិស្ថាន (EEA) និងចូលរួមក្នុងក្រុមពិភាក្សាជាមួយភាគីពាក់ព័ន្ធនៃយុត្តិធម៌បរិស្ថាន
- អភិវឌ្ឍបង្កើតឧត្តមានុវត្តន៍នានា ដើម្បីបង្កលទ្ធភាពឱ្យភាគីពាក់ព័ន្ធនៃយុត្តិធម៌បរិស្ថាននិងភាពចម្រុះ សមធម៌ និងបរិយាប័ន អាចចូលរួមក្នុងការអភិវឌ្ឍបង្កើតនិងការអនុវត្តកម្មវិធីរបស់មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC)៖
  - អភិវឌ្ឍបង្កើតក្របខណ្ឌនិងពិធីសារណែនាំ សម្រាប់ប្រមូលធាតុចូលពីភាគីពាក់ពន្ធ័នានា សម្រាប់ការរចនារៀបចំកម្មវិធីរបស់មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) ដោយបង្កលទ្ធភាពឱ្យភាគីពាក់ព័ន្ធនានាបានចូលរួមយ៉ាងឆាប់រហ័សនិងញឹកញាប់ និងផ្តល់សេវាភាសា តាមការស្នើសុំនិងតាមលទ្ធភាពជាក់ស្តែង។
  - អភិវឌ្ឍបង្កើតឧត្តមានុវត្តន៍និងយន្តការគណនេយ្យភាព សម្រាប់ជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធនានានៅពេញទូទាំងកម្មវិធី ឬការអនុវត្តគម្រោងមូលនិធិពាក់ព័ន្ធរបស់មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) ដូចជាការធានាថាក្រុមអភិវឌ្ឍសហគមន៍មួយ អង្គការដែលមានមូលដ្ឋាននៅក្នុងសហគមន៍មួយ ឬអង្គការមិនមែនរដ្ឋាភិបាលមួយ និងក្រុមតស៊ូមតិយុត្តិធម៌បរិស្ថានមួយ អាចផ្តល់អនុសាសន៍ ឧត្តមានុវត្តន៍នានា ស្តីពីការអភិវឌ្ឍកម្មវិធី។
    - <u>ឧទាហរណ៍</u>៖ ឱកាសទទួលបានមូលនិធិ ដោយរួមបញ្ចូលកម្មវិធី EmPower (ដែលជាកម្មវិធីទទួលបានថាមពលស្អាត) កម្មវិធី ACTNow (ដែលជាកម្មវិធីគមនាគមន៍ស្អាត) ហើយកម្មវិធីអភិវឌ្ឍកម្លាំងពលកម្មថាមពលខ្យល់សមុទ្រ បានស្វែងរកមតិយោបល់ពីភាគីពាក់ព័ន្ធនៃយុត្តិធម៌បរិស្ថាននិងភាពចម្រុះ សមធម៌

        និងបរិយាប័ន ដើម្បីអភិវឌ្ឍបង្កើតឯកសារបញ្ចុះបញ្ចូល ដោយមានការប្រាស្រ័យទាក់ទងស្ទង់មតិនិងការជូនដំណឹងអំពីបំណង។ កម្មវិធីទាំងនេះ ក៏ព្យាយាមស្វែងរកមតិយោបល់ក្រៅផ្លូវការតាមរយៈការប្រាស្រ័យទាក់ទងដោយផ្ទាល់ផងដែរ។
        - ឧទាហរណ៍៖ គម្រោងសាកល្បងចែករំលែករថយន្តអគ្គិសនីដែលបែងចែកកម្រិតប្រាក់ចំណូល នៅក្រោមកម្មវិធី ACTNow របស់មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) ដាក់បញ្ចូលសាជីវកម្មអភិវឌ្ឍសហគមន៍ ជាសមាជិកមួយនៃក្រុមការងារគម្រោងមូលនិធិ ដើម្បីជួយក្នុងការអភិវឌ្ឍបង្កើតគំរូភាពជាដៃគូសហគមន៍ សម្រាប់ការអនុវត្តគម្រោងនាពេលអនាគត។
        - ឧទាហរណ៍៖ ប្រើប្រាស់ក្រុមការងារថាមពលស្អាតនិងសមធម៌របស់មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) ដើម្បីផ្តល់ធាតុចូលក្នុងការអភិវឌ្ឍបង្កើតយុទ្ធសាស្ត្រ និងការរៀបចំកម្មវិធីអភិវឌ្ឍកម្លាំងពលកម្មរបស់មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC)។
- អភិវឌ្ឍបង្កើតវិធីសាស្ត្រណែនាំបណ្តុះបណ្តាល នៅក្នុងកម្មវិធីសមស្របនានារបស់មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) ដើម្បីបង្កើតច្រកចម្រុះផ្សេងៗគ្នានាពេលអនាគត សម្រាប់អ្នកដាក់ពាក្យសុំនិងអ្នកទទួលមូលនិធិ។
    - ផ្តោតគោលដៅលើការកសាងសមត្ថភាពជាមួយដៃគូពាក់ព័ន្ធនឹងយុត្តិធម៌បរិស្ថាន និងភាពចម្រុះ សមធម៌ និងបរិយាប័ន សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ សាកលវិទ្យាល័យសហគមន៍ អង្គការដែលមានមូលដ្ឋានក្នុងសហគមន៍ និងអង្គការមិនរកប្រាក់ចំណេញ ។ល។
        - ឧទាហរណ៍៖ កម្មវិធីហ្វឹកហាត់ការងារថាមពលស្អាត ដែលសម្របសម្រួលការដាក់បញ្ចូលនិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ និងនិស្សិតទើបបញ្ចប់ការសិក្សាទៅក្នុងអាជីពថាមពលស្អាត មានមូលនិធិពិសេសសម្រាប់និស្សិតជនជាតិភាគតិចព្រមទាំងការប្រើប្រាស់អង្គការ ដៃគូបណ្តុះបណ្តាលដែលអាចជឿទុកចិត្តបានធ្វើការប្រាស្រ័យទាក់ទងជាមួយនិស្សិតទាំងនេះ។ កម្មវិធីនៅក្នុងឆ្នាំសារពើពន្ធ2022 នឹងជួយគាំទ្រដល់អង្គការចំនួន4 ក្នុងចំណោមអង្គការទាំងនេះ ដើម្បីជ្រើសរើសនិងណែនាំបង្វឹកនិស្សិតជនជាតិភាគតិច។
        - ឧទាហរណ៍៖ កម្មវិធីនវានុវត្តន៍បច្ចេកវិទ្យារបស់មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) ផ្តល់ជំនួយគាំទ្របន្ថែមដល់អ្នកបណ្តុះ អ្នកជំរុញ និងដៃគូឧស្សាហកម្មនវានុវត្តន៍ដទៃទៀត សម្រាប់គំនិតផ្តួចផ្តើមយុត្តិធម៌បរិស្ថាន និងភាពចម្រុះ សមធម៌


MASSACHUSETTS CLEAN ENERGY CENTER

និងបរិយាប័ន នានា ដើម្បីជួយគាំទ្រពិពិធកម្ម ឧស្សាហកម្មនវានុវត្តន៍ថាមពលស្អាត។

- ផ្សព្វផ្សាយកម្មវិធី ឱកាសមូលនិធិជំនួយ និងវគ្គបណ្តុះបណ្តាលពាក់ព័ន្ធនានា នៅក្នុងសង្កាត់យុត្តិធម៌បរិស្ថានដែលមានផ្ទាំងផ្សព្វផ្សាយព័ត៌មាន ការឧបត្ថម្ភក្រុមសហគមន៍ ខិត្តប័ណ្ណផ្សព្វផ្សាយ ឬព្រឹត្តិការណ៍ផ្សព្វផ្សាយនៅក្នុងមជ្ឈមណ្ឌលរបស់សហគមន៍ មជ្ឈមណ្ឌលបែបជំនឿ និងមធ្យោបាយដែលមានស្រាប់របស់សង្កាត់
- ផ្តល់អាទិភាពឱ្យប្រជាជនយុត្តិធម៌បរិស្ថាន និងប្រជាជនដែលទទួលបានសេវាពុំគ្រប់គ្រាន់ដទៃទៀតក្នុងការចូលរួមកម្មវិធីនានា តាមភាពសមស្របតាមរយៈ ការប្រាស្រ័យទាក់ទង ការអប់រំ និងការបណ្តុះបណ្តាល ដែលផ្តោតលើពួកគេ៖
    - វាយតម្លៃនិងបង្កើនការទទួលបានការប្រាស្រ័យទាក់ទងនិងការផ្សព្វផ្សាយព័ត៌មាន នាពេលបច្ចុប្បន្ន
        - ផ្តល់ឯកសារស្តីពីកម្មវិធីជាភាសាដទៃផ្សេងទៀត តាមភាពសមស្រប
        - ធ្វើពិពិធកម្មច្រកប្រាស្រ័យទាក់ទង តាមភាពសមស្រប (ឧទាហរណ៍ ប្រើប្រាស់បណ្តាញដៃគូសហគមន៍ និងច្រកប្រាស្រ័យទាក់ទងដោយមនុស្សផ្ទាល់ដែលមានស្រាប់នៅក្នុងសង្កាត់យុត្តិធម៌បរិស្ថាន ដូចជា៖ វិហារគ្រិស្ត ទីផ្សាររបស់កសិករ ការតាំងពិព័រណ៍ មជ្ឈមណ្ឌលសហគមន៍ សាលារៀន ។ល។)
        - បន្តប្រើប្រាស់បណ្តាញសង្គមនិងឧបករណ៍ដែលមានមូលដ្ឋានលើបណ្តាញអ៊ិនធឺណិតដទៃទៀត ដើម្បីផ្សព្វផ្សាយទៅដល់ទស្សនិកជនកាន់តែទូលំទូលាយ។
    - ព្យាយាមបង្កើតភាពជាដៃគូជាមួយដៃគូសហគមន៍ដែលជឿទុកចិត្តបានដើម្បីប្រាស្រ័យទាក់ទងជាមួយប្រជាជនអាទិភាព។
    - អភិវឌ្ឍបង្កើតសម្ភារៈឯកសារអប់រំ កម្មវិធី ឬគំនិតផ្តួចផ្តើមអប់រំ ដោយផ្អែកលើមតិយោបល់ពីក្រុមការងារថាមពលស្អាតនិងសមធម៌របស់មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC)
        - អាចរួមបញ្ចូលគំនិតផ្តួចផ្តើមអក្ខរកម្មបច្ចេកទេស យុទ្ធនាការតាមប្រព័ន្ធផ្សព្វផ្សាយដែលមានទិសដៅជាក់លាក់ ។ល។
        - <u>ឧទាហរណ៍៖</u> កម្មវិធីសាកល្បង EmPower របស់មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) បានរួមបញ្ចូលសិក្ខាសាលាសម្រាប់ភាគីពាក់ព័ន្ធ ដោយផ្តោតទៅលើភាគីដែលមានប្រវត្តិធ្វើជាតំណាងរបស់សហគមន៍ ដែលទទួលបានសេវាមិនគ្រប់គ្រាន់ឬងាយទទួលរងគ្រោះ (ដោយរួមទាំងសហគមន៍យុត្តិធម៌បរិស្ថាន អ្នកតស៊ូមតិ ដែលមានប្រាក់ចំណូលទាប ក្រុមជនជាតិភាគតិច) ដោយមានគោលដៅកំណត់អត្តសញ្ញាណអ្នកដាក់ពាក្យសុំ និងសម្របសម្រួលទំនាក់ទំនងសម្រាប់ទទួលបានឱកាស ទទួលបានមូលនិធិ។ ប្រសិនបើអ្នកដាក់ពាក្យស្នើសុំមូលនិធិសម្រាប់កម្មវិធីនោះ

មិនមែនជាអង្គការដែលមានមូលដ្ឋាននៅក្នុងសហគមន៍
អ្នកដាក់ពាក្យសុំត្រូវបង្កើតដៃគូជាមួយអង្គការ
ដែលមានមូលដ្ឋានក្នុងសហគមន៍ ដើម្បីអនុវត្តគម្រោងនោះ។

## យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាននិងភាពចម្រុះ សមធម៌ និងបរិយាប័ន និងខ្នាតរង្វាស់នៅក្នុងតំបន់កម្មវិធី

មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) នឹងពិចារណា ព្រមទាំងដាក់បញ្ចូល យុត្តិធម៌បរិស្ថាននិងគោលការណ៍នៃភាពចម្រុះ សមធម៌ និងបរិយាប័ន នៅក្នុងគ្រប់កម្មវិធីនិងគំនិតផ្តួចផ្តើមយុទ្ធសាស្ត្ររបស់ខ្លួន ដោយចាប់ផ្តើមនៅកម្រិតកម្មវិធីត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2022។ តាមរយៈការចូលរួមពេញលេញរបស់ភាគីពាក់ព័ន្ធនៃយុត្តិធម៌បរិស្ថាននិងភាពចម្រុះ សមធម៌ និងបរិយាប័ន ទីភ្នាក់ងារ នឹងព្យាយាមស្វែងយល់អំពីអាទិភាពនិងតម្រូវការ យុត្តិធម៌បរិស្ថាននិងភាពចម្រុះ សមធម៌ និងបរិយាប័ន នៅក្នុងនវានុវត្តន៍ ការអភិវឌ្ឍនិងការជ្រើសរើសទីផ្សារ និងកម្មវិធីអភិវឌ្ឍកម្លាំងពលកម្មនិងអភិវឌ្ឍឧស្សាហកម្មរបស់ខ្លួន។

មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) នឹងអភិវឌ្ឍបង្កើតឧត្តមានុវត្តន៍នានា ដើម្បីធ្វើសមាហរណកម្មបញ្ចូលការគិតពិចារណាអំពីយុត្តិធម៌បរិស្ថាននិងភាពចម្រុះ សមធម៌ និងបរិយាប័ន ទៅក្នុងមុខងារចម្បងៗរបស់ខ្លួន ក្នុងនាមជាទីភ្នាក់ងារ (ឧទាហរណ៍ ការអភិវឌ្ឍបង្កើតកម្មវិធី ការចាប់ផ្តើមឧស្សាហកម្ម) នៅត្រឹមរដូវស្លឹកឈើជ្រុះ ឆ្នាំ2022។

មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) នឹងចាប់ផ្តើមពិនិត្យតាមដានការចំណាយរបស់ទីភ្នាក់ងារទាំងមូលនៅក្នុងសង្កាត់យុត្តិធម៌បរិស្ថាន ទីក្រុងច្រកចេញចូល គំនិតផ្តួចផ្តើមភាពចម្រុះ សមធម៌ និងបរិយាប័ន គំនិតផ្តួចផ្តើមប្រាក់ចំណូលទាបនិងមធ្យម និងសេវាបកប្រែ នៅក្នុងឆ្នាំសារពើពន្ធ2024។ មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) នឹងកំណត់គោលដៅរបស់ទីភ្នាក់ងារទាំងមូលសម្រាប់ពេលអនាគត នៅក្នុងតំបន់ទាំងនេះ នៅត្រឹមខែកក្កដា ឆ្នាំ2022។ ខាងក្រោមនេះ គឺជាបញ្ជីត្រួសៗនៃសកម្មភាពដែលមជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) នឹងអនុវត្តដើម្បីដាក់បញ្ចូលគោលការណ៍យុត្តិធម៌បរិស្ថាន និងភាពចម្រុះ សមធម៌ និងបរិយាប័ន ទៅក្នុងវិស័យកិច្ចការងាររបស់ខ្លួន៖

- ប្រមូលមតិយោបល់ពីភាគីពាក់ព័ន្ធ ដោយរួមទាំងតំណាងសង្កាត់យុត្តិធម៌បរិស្ថាន តាមរយៈគំនិតផ្តួចផ្តើមនានា ដូចជា កិច្ចប្រជុំស្តាប់មតិយោបល់យុត្តិធម៌បរិស្ថានរបស់ការិយាល័យប្រតិបត្តិនៃកិច្ចការថាមពលនិងបរិស្ថាន (EEA) ដើម្បីកំណត់អត្តសញ្ញាណ ចម្រាញ់ និងអនុវត្ត គោលដៅនិងអាទិភាពយុត្តិធម៌បរិស្ថាន និងភាពចម្រុះ សមធម៌ និងបរិយាប័ន នៅក្នុងកម្មវិធីពាក់ព័ន្ធនិងគំនិតផ្តួចផ្តើមយុទ្ធសាស្ត្រនានារបស់មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC)
- ធ្វើសមាហរណកម្មបញ្ចូលគោលការណ៍យុត្តិធម៌បរិស្ថាន និងភាពចម្រុះ សមធម៌ និងបរិយាប័ន និងគោលដៅដែលត្រូវបានកំណត់ ទៅក្នុងការសម្រេចចិត្តកម្មវិធី


MASSACHUSETTS CLEAN ENERGY CENTER

ការដោះស្រាយ ការអភិវឌ្ឍកម្មវិធីរបស់មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋជូសេត (MassCEC) ទាំងមូល និងការសម្រេចចិត្តពាក់ព័ន្ធនឹងគម្រោងដាក់លាក់ ដើម្បីសម្របសម្រួលបំណែងចែកផលប្រយោជ៍ថាមពលប្រកបដោយយុត្តិធម៌ ភាពចម្រុះ សមធម៌ និងបរិយាប័ន និងផលប៉ះពាល់ដទៃទៀតរបស់មជ្ឈមណ្ឌល ថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) នៅពាសពេញទូទាំងខំមិនវែល។

- បង្កើតគោលដៅសម្រាប់ការចំណាយរបស់ទីភ្នាក់ងារទាំងមូលសម្រាប់តំបន់នានាដូចជាសង្កាត់យុត្តិធម៌បរិស្ថាន ទីក្រុងច្រកចេញចូល គំនិតផ្តួចផ្តើមប្រាក់ចំណូលទាប និងមធ្យម និងសេវាបកប្រែ នៅក្នុងឆ្នាំសារពើពន្ធ2023។ ការចំណាយនឹងត្រូវពិនិត្យតាមដាននៅក្នុងតំបន់ទាំងនេះ ដោយចាប់ផ្តើមនៅឆ្នាំសារពើពន្ធ2024។
- អភិវឌ្ឍនិងធានានូវការអនុវត្តកិច្ចដំណើរការនិងទម្រង់គំរូដែលមានស្តង់ដារ ដែលរួមបញ្ចូលលក្ខណៈវិនិច្ឆ័យយុត្តិធម៌បរិស្ថាន និង/ឬ ភាពចម្រុះ សមធម៌ និងបរិយាប័ន និងភាសាទៅក្នុងការបញ្ចុះបញ្ចូល ការស្នើសុំសំណើ និងកិច្ចសន្យាតាមភាពសមស្រប ដើម្បីពង្រឹងលើកកម្ពស់ឧស្សាហកម្មថាមពលស្អាតដែលមានភាពចម្រុះ សមធម៌ និងបរិយាប័ន។
    - ឧទាហរណ៍៖ កិច្ចសន្យានៅក្រោមកម្មវិធីប្រាក់កម្ចីវិនិយោគ BRIDGES បានដាក់បញ្ចូលខចែងដែលតម្រូវឱ្យក្រុមហ៊ុនមួយ ក្នុងរយៈពេលកៅសិប (90) ថ្ងៃនៃការព្រមព្រៀង ជាលាយលក្ខអក្សរ ត្រូវដាក់ចេញនូវគោលនយោបាយភាពចម្រុះ សមធម៌ និងបរិយាប័ន ដើម្បីជំរុញលើកទឹកចិត្តការជ្រើសរើសក្រុមការងារដែលមានលក្ខណៈចម្រុះ ប្រព្រឹត្តឥរិយាបថប្រកបដោយយុត្តិធម៌និងសមធម៌ចំពោះសមាជិកក្រុមទាំងអស់ និងធានាឱ្យមានបរិយាកាសនៅទីកន្លែងបម្រើការងារដែលសមាជិកក្រុមទាំងអស់មានអារម្មណ៍ថាពួកគេទទួលបានការផ្តល់តម្លៃ និងមានឱកាសចូលរួមពេញលេញក្នុងការបង្កើតជោគជ័យអាជីវកម្មនិង
    - ឧទាហរណ៍៖ ក្រុមការងារថាមពលខ្យល់សមុទ្រ របស់មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) បានដាក់បញ្ចូលផ្នែកមួយទៅក្នុងលក្ខណៈវិនិច្ឆ័យជ្រើសរើស សម្រាប់ការទាក់ទាញការអភិវឌ្ឍកម្លាំងការងារថាមពលខ្យល់សមុទ្រ ដែលពិចារណាទៅលើកម្រិតដែលអ្នកដាក់ពាក្យសុំ បង្ហាញការប្តេជ្ញាចិត្តបែបបុរេសកម្ម និងពិតប្រាកដ ចំពោះភាពចម្រុះ សមធម៌ និងបរិយាប័ននិងយុត្តិធម៌បរិស្ថាន ក្នុងនាមជាផ្នែកមួយនៃកិច្ចដំណើការវាយតម្លៃនិងជ្រើសរើស។
- អភិវឌ្ឍបង្កើតមូលនិធិឬគំនិតផ្តួចផ្តើមដើម្បីផ្តល់ផលប្រយោជន៍ថាមពលស្អាតជូនដល់សង្កាត់យុត្តិធម៌បរិស្ថាននានា។ កំណត់អត្តសញ្ញាណមូលនិធិឬគំនិតផ្តួចផ្តើមដែលមានស្រាប់ របស់មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) ដែលនឹងមានទំនាក់ទំនងជាមួយប្រជាជនយុត្តិធម៌បរិស្ថាន និងបំពេញការងារជាមួយអ្នកទទួលមូលនិធិ និង/ឬដៃគូនានាដើម្បីស្វែងរកវិធីសាស្ត្របង្កើនផលប្រយោជន៍ជូនដល់សហគមន៍ទាំងនេះ

ដោយរួមទាំងការកាត់បន្ថយឬការលុបបំបាត់ការចែករំលែកសោហ៊ុយដែលជាកាតព្វកិច្ចត្រូវធ្វើ។

- ឧទាហរណ៍៖ កម្មវិធីមូលនិធិ EmPower របស់មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) ត្រូវបានរចនាបង្កើតឡើងយ៉ាងពិសេសដើម្បីនាំមកនូវផលប្រយោជន៍ថាមពលស្អាត ជូនដល់ប្រជាជនដែលមានប្រវត្តិទទួលបានសេវាមិនគ្រប់គ្រាន់ ដោយរួមទាំងសង្កាត់យុត្តិធម៌បរិស្ថាន ហើយគម្រោងទាំងអស់នឹងត្រូវដឹកនាំដោយអង្គការដែលមានមូលដ្ឋាននៅក្នុងសហគមន៍ បុគ្គល ឬក្រុមដទៃទៀតដែលមានប្រវត្តិបំពេញការងារជាមួយប្រជាជនទាំងនេះ។ គោលដៅរបស់កម្មវិធីនេះ គឺអនុវត្តគម្រោងថាមពលស្អាតនៅក្នុងសហគមន៍ទាំងនេះ និងកសាងសមត្ថភាពរបស់ស្ថាប័ននិងសហគមន៍ សម្រាប់គម្រោងនាពេលអនាគត។
- ឧទាហរណ៍៖ កម្មវិធីគមនាគមន៍ស្អាត ACTNow បានកាត់បន្ថយការចែករំលែកសោហ៊ុយចំណាយដែលជាកាតព្វកិច្ចតម្រូវ (25% ជំនួសឱ្យចំនួនស្តង់ដារ 50%) សម្រាប់គម្រោងទាំងឡាយដែលផ្តល់ប្រយោជន៍ដល់សហគមន៍យុត្តិធម៌បរិស្ថាន និង
- ឧទាហរណ៍៖ កម្មវិធីហ្វឹកហាត់ការងារថាមពលស្អាត បម្រុងទុកមូលនិធិសម្រាប់និស្សិតនិងនយោជិត នៅក្នុងទីក្រុងច្រកចេញចូល ដើម្បីធ្វើពិពិធកម្មនិស្សិតនិងនយោជិតនៅក្នុងកម្មវិធី។
- ឧទាហរណ៍៖ កម្មវិធីសាកល្បងពាណិជ្ជកម្មបច្ចេកទេស (Technical Trades) កំពុងសិក្សាស្វែងយល់អំពីរបៀបដែលមជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) អាចជួយគាំទ្រការបណ្តុះបណ្តាលដែលផ្តល់វិញ្ញាបនបត្រ ការទទួលស្គាល់ និងការបណ្តុះបណ្តាលអំឡុងពេលបំពេញការងារ ដើម្បីធ្វើឱ្យការបណ្តុះបណ្តាលអាចផ្តល់សេវាកាន់តែប្រសើរជាងមុន ដល់ប្រជាជនដែលពុំអាចសិក្សាយកសញ្ញាបត្រថ្នាក់មហាវិទ្យាល័យ។

- ផ្តល់អាទិភាពឱ្យកម្មវិធីនិងគំនិតផ្តួចផ្តើមទាំងឡាយដែលពង្រឹងលើកកម្ពស់ គោលដៅយុត្តិធម៌បរិស្ថាន និងភាពចម្រុះ សមធម៌ និងបរិយាប័ននៅក្នុងកិច្ចដំណើរការរៀបចំផែនការកម្មវិធីរបស់មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) ។
  - ឧទាហរណ៍៖ កម្មវិធីមូលនិធិ Catalyst នាពេលថ្មីៗនេះ បានចាប់ផ្តើមជាមួយនឹងការលក់ចេញនូវក្រុមហ៊ុនបុត្រសម្ព័ន្ធ សម្រាប់ក្រុមហ៊ុនក្មេងខ្ចីដែលមានម្ចាស់កម្មសិទ្ធិជាស្ត្រីនិងជាជនជាតិភាគតិច ដើម្បីគាំទ្រភាពចម្រុះនៅក្នុងឧស្សាហកម្មថាមពលស្អាត។
  - ឧទាហរណ៍៖ មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (MassCEC) បានបង្កើតកម្មវិធីមូលនិធិគមនាគមន៍ ACT4ALL (“ការពន្លឿនគមនាគមន៍ស្អាតសម្រាប់មនុស្សទាំងអស់”) ដែលចាត់ទុកការទទួលបានសេវាគមនាគមន៍ដោយសមធម៌និងការកាត់បន្ថយបន្ទុក គឺជាគោលដៅគន្លឹះនៃគម្រោងនាពេលអនាគត។

## ការអនុវត្តយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់ការិយាល័យប្រតិបត្តិផ្នែកថាមពល និងកិច្ចការបរិស្ថាន

ពាក់ព័ន្ធនឹងក្តីបារម្ភ ពាក្យបណ្តឹង ការបំពេញបន្ថែម ឬគំនិតផ្សេងៗពាក់ព័ន្ធនឹងយុត្តិធម៌បរិស្ថាន ឬដើម្បីស្វែងយល់បន្ថែមអំពីកិច្ចខិតខំប្រឹងប្រែងផ្នែកយុត្តិធម៌បរិស្ថានថាមពល និងអាកាសធាតុរបស់ទីភ្នាក់ងារយើង សូមទាក់ទងការិយាល័យយុត្តិធម៌បរិស្ថានរបស់ EEA ដែលមានចែងនៅទំព័រទី 19 នៃយុទ្ធសាស្ត្របរិស្ថានរបស់ EEA។

### ព័ត៌មានសម្រាប់ប្រាស្រ័យទាក់ទងផ្នែកយុត្តិធម៌បរិស្ថានរបស់ទីភ្នាក់ងារៈ

Beverly Craig
អ្នកគ្រប់គ្រងកម្មវិធីជាន់ខ្ពស់
កម្មវិធីប្រាក់ចំណូលទាបនិងមធ្យម
bcraig@masscec.com
617-447-3133

ឬ

Jade Lu
អ្នកគ្រប់គ្រងកម្មវិធីគមនាគមន៍ស្អាត
jlu@masscec.com

ព្រាង

# អាជ្ញាធរធនធានទឹករដ្ឋម៉ាសាជូសេត

# យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន

# តារាងមាតិកា

**អាជ្ញាធរធនធានទឹករដ្ឋម៉ាសាជូសេត ...... 165**

បេសកកម្ម ...... 167

គោលបំណង ...... 167

យុទ្ធសាស្ត្រ និងគោលការណ៍យុត្តិធម៌បរិស្ថានរបស់ MWRA ...... 167

*ការចូលរួមនិងផ្សព្វផ្សាយជាសាធារណៈ ...... 168*

*ការទំនាក់ទំនង ...... 169*

*ការបណ្តុះបណ្តាល ...... 169*

*ឱកាសផ្តល់មូលនិធិជំនួយ ...... 170*

*ការវិភាគលើផលប៉ះពាល់ដែលកើនឡើង ...... 170*

*ការពិនិត្យឡើងវិញនូវការបំពេញការងារ និងការជួលបុគ្គលិក ...... 170*

*អនុលោមភាពផ្នែកបរិស្ថាន ...... 171*

ការអនុវត្តយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់ការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន ...... 171

## បេសកកម្ម

បេសកកម្មរបស់អាជ្ញាធរធនធានទឹករបស់រដ្ឋម៉ាសាជូសេត (WMRA) គឺត្រូវបង្កើតឡើងដើម្បីផ្តល់សេវាកម្មទឹកគុណភាព ខ្ពស់ប្រកបដោយការជឿទុកចិត្តនិងមានប្រសិទ្ធភាពខ្ពស់លើការចំណាយ និងប្រព័ន្ធលូទឹក ដែលការពារសុខភាពសាធារណៈ ជំរុញការគ្រប់គ្រងបរិស្ថាន រក្សាបាននូវការទុកចិត្តពីអតិថិជន និងគាំទ្រសេដ្ឋកិច្ចប្រកបដោយវិបុលភាព។

## គោលបំណង

ការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន (EEA) គោលនយោបាយយុត្តិធម៌បរិស្ថាន[1] បានដឹកនាំទីភ្នាក់ងារ EEA ទាំងអស់ ដើម្បីបង្កើតយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់ខ្លួន។ យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាននៃធនធានទឹករបស់រដ្ឋម៉ាសាជូសេត គូសបញ្ជាក់ពីសកម្មភាពនិង ចក្ខុវិស័យរបស់ WMRA ដើម្បីលើកកម្ពស់ការពិនិត្យពិចារណាលើយុត្តិធម៌បរិស្ថាន នៅក្នុងកម្មវិធី គោលនយោបាយ និងសកម្មភាពរបស់ WMRA។

MWRA ប្តេជ្ញាចិត្តចំពោះបេសកកម្មនេះ ដែលមានចែងនៅក្នុងមាត្រាទី97 នៃរដ្ឋធម្មនុញ្ញរបស់រដ្ឋម៉ាសាជូសេត សម្រាប់ពលរដ្ឋទាំងអស់នៅក្នុងខំមិនវែល។ ក្នុងនាមជាឯកសាររស់ យុទ្ធសា ស្ត្រនេះនឹងត្រូវបានត្រួតពិនិត្យ ហើយបានកែសម្រួលរួចរាល់តាមភាពចាំបាច់ ក្នុងការពិចារណាទៅលើបញ្ហា កម្មវិធី គោលនយោបាយ និងសកម្មភាពរបស់យុត្តិធម៌បរិស្ថាន។

## យុទ្ធសាស្ត្រ និងគោលការណ៍យុត្តិធម៌បរិស្ថានរបស់ MWRA

**ការប្តេជ្ញាចិត្តរបស់អាជ្ញាធរធនធានទឹករបស់រដ្ឋម៉ាសាជូសេតចំពោះការពង្រីកយុត្តិធម៌បរិស្ថាន ហួសពីបរិបទនៃយុទ្ធសាស្ត្រនេះ។** យើងបន្តចូលរួមនៅក្នុងសកម្មភាពបន្ត ដើម្បីធ្វើឱ្យប្រសើរឡើងនូវការទំនាក់ទំនង សិទ្ធិទទួលបាន និងការចូលរួមពីសមាជិកទាំងអស់ក្នុងចំណោមសាធារណជន។ ខណៈដែលយើងបន្តដាក់បញ្ចូលគោលការណ៍យុត្តិធម៌បរិស្ថាននៅក្នុងដំណើរការនៃការសម្រេច ចិត្តរបស់យើង យុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាននឹងក្លាយជាផែនទីបង្ហាញផ្លូវ ដែលអាជ្ញាធរនឹងប្រើប្រាស់ដើម្បីធ្វើជាមាគ៌ា សម្រេចបាន និងពង្រីកគោលដៅ សកម្មភាព និងគំនិតផ្តួចផ្តើមរបស់យើង។

MWRA ទទួលស្គាល់ពីសេចក្តីត្រូវការក្នុងការបន្តសហការជាមួយសហគមន៍ ដើម្បីដោះស្រា យបញ្ហាយុត្តិធម៌បរិស្ថាន និងលើកទឹកចិត្តឱ្យមានភាពជាដៃគូនៅតាមសហគមន៍ជាមួយ អ្នកពាក់ព័ន្ធផ្សេងៗទៀត ពង្រីកនិងលើកកម្ពស់ការផ្សព្វផ្សាយអប់រំ។ យើងធ្វើការឆ្ពោះទៅការធានាឱ្យបានថា យើងមានតំណាងខាងយុត្តិធម៌បរិស្ថាននៅក្នុងក្រុមការងារនៃផ្លូវរថភ្លើងរូងក្រោមដី (Metropolitan Tunnel) និងគោលបំណងនៃការរាប់បញ្ចូលការពិនិត្យពិចារណា

[1] https://www.mass.gov/environmental-justice

ផ្នែកយុត្តិធម៌បរិស្ថាន ខណៈដែលយើងជំរុញទៅមុខទៀតពាក់ព័ន្ធនឹងផែនការ និងការធ្វើគំនូសប្លង់ផ្លូវរូងក្រោមដីថ្មីនេះ។ យើងក៏មានបំណងគោរពតាមតម្រូវការថ្មីរបស់យុត្តិធម៌បរិស្ថានរបស់ MEPA ដែរ នៅក្នុងរបាយការណ៍ព្រាងស្តីពីផលប៉ះពាល់បរិស្ថាននាពេលខាងមុខសម្រាប់ MEPA។ លើសពីនេះទៀត MWRA កំពុងចាប់ផ្តើមពិចារណាពីមធ្យោបាយដែលយើងអាចកំណត់អត្តសញ្ញាណ និងតាមដានគម្រោងនៅក្នុងសង្កាត់របស់យុត្តិធម៌បរិស្ថាន ដោយគម្រោងទាំងនោះអាចផ្តល់ផលប្រយោជន៍ដល់សហគមន៍យុត្តិធម៌បរិស្ថាន។

តាមរយៈគំនិតផ្តួចផ្តើមខាងក្រោមនេះ MWRA គ្រោងពង្រឹងនិងបំពេញសេចក្តីត្រូវការបន្ថែមទៀតរបស់ពលរដ្ឋនៅក្នុងខំមិនវែល។

## ការចូលរួមនិងផ្សព្វផ្សាយជាសាធារណៈ

សេវាកម្មដូចបាននគូសបញ្ជាក់ខាងក្រោមនេះត្រូវបានធ្វើឡើងដើម្បីលើកកំពស់ និងបង្កើនការយល់ដឹងជាសាធារណៈនិងសិទ្ធិទទួលបានព័ត៌មានស្តីពីគេហទំព័ររបស់ MWRA ជាមួយពលរដ្ឋម៉ាសាជូសេត សមាជិកពលរដ្ឋយុត្តិធម៌បរិស្ថាន និងក្រុមគាំពារមតិ ស្តីពីសកម្មភាព និងធនធាន ដែលពាក់ព័ន្ធនឹងយុត្តិធម៌បរិស្ថាន។ តាមរយៈកិច្ចប្រឹងប្រែងនេះ MWRA នឹងបង្កើនៈ

- មធ្យោបាយបច្ចុប្បន្នក្នុងការអនុវត្តបច្ចេកវិទ្យាថ្មីដើម្បីចែករំលែកព័ត៌មានយុត្តិធម៌បរិស្ថាន មានដូចជាបណ្តាញសង្គមជាដើម។ បណ្តាញ Twitter និងការប្រើប្រាស់បញ្ជីឈ្មោះអង្គការយុត្តិធម៌បរិស្ថានរបស់ EEA ជាព្រឹត្តិប័ត្រផ្សព្វផ្សាយព័ត៌មានតាមជម្រើស នឹងស្ថិតក្នុងចំណោមមធ្យោបាយថ្មីដែលត្រូវពិចារណា ដោយរាប់បញ្ចូលដោយមិនកម្រិត ចំពោះក្រុមពិភាក្សាគ្នាតាមអ៊ីម៉ែលរបស់សហគមន៍មជ្ឈមណ្ឌលជាន់ខ្ពស់និងសហគមន៍ ព្រមទាំងការសែតផ្សព្វផ្សាយបែបវប្បធម៌។

- MWRA នឹងពិភាក្សាជាមួយ EEA និងក្រុមការងារអន្តរទីភ្នាក់ងារ ដើម្បីធានាបាននូវការគោរពព្រឹត្តិប័ត្រលេខ16 របស់ A&F ដោយតម្រូវឱ្យមានផែនការទទួលបានភាសាសម្រាប់នាយកដ្ឋាននីមួយៗ។ បន្ថែមពីនេះទៀត MWRA នឹងលើកកម្ពស់គេហទំព័ររបស់ខ្លួនតាមរយៈ ឧបករណ៍ប្រែសម្រួលតាមអ៊ីនធឺណិត និងរកបាននូវសេវាកម្មប្រែសម្រួលនិងបកប្រែភាសា ខណៈដែលពលរដ្ឋដែលនៅមានកម្រិតផ្នែកភាសាអង់គ្លេស ត្រូវបានរកឃើញ ឬនៅពេលស្នើឡើងដោយពលរដ្ឋយុត្តិធម៌បរិស្ថាន។

- MWRA នឹងផ្តល់និងបែងចែកការកត់សម្គាល់លើសហគមន៍ដែលទទួលផលប៉ះពាល់ទាក់ទងនឹងគម្រោងសាងសង់នៅក្នុងវិស័យសាធារណៈ ដើម្បីដោះស្រាយសហគមន៍ទាំងនោះដែលត្រូវរងផលប៉ះពាល់យ៉ាងខ្លាំងក្លា។

- MWRA ធ្វើការប្រជុំសាធារណៈ សម្រាប់ការប្រជុំនិងវេទិកានោះ ដែលរួមបញ្ចូលទាំងជនជាតិពន្ធុ និងប្រជាជនមានប្រាក់ចំណូលទាប។ ប្រសិនបើចាំបាច់ សូមរាប់បញ្ចូល ការផ្សព្វផ្សាយឬការចូលរួមតាមប្រព័ន្ធអ៊ីនធឺណិត ឬ សេវាកម្មដទៃទៀត ដែលអនុញ្ញាតឱ្យកិច្ចប្រជុំនោះកើតឡើងដោយមិន ចាំបាច់មានអ្នកចូលរួមនៅក្នុងកន្លែងតែមួយឡើយ។

- MWRA នឹងបន្តវាយតម្លៃលើភាពងាយទទួលរងគ្រោះនៃកម្រិតសំណរខ្ពស់នៅក្នុងទឹកពិសា និងចាត់វិធានការដើម្បីពង្រីកការវាយតម្លៃនោះ ដើម្បីដឹកនាំកម្មវិធីសាកល្បងនោះ និងធនធានដែលផ្តោតលើសហគមន៍យុត្តិធម៌បរិស្ថាន។

## ការទំនាក់ទំនង

គេហទំព័រ MWRA ផ្តល់ព័ត៌មានដ៏មានសារៈប្រយោជន៍ មានដូចជា បុគ្គលិកទំនាក់ទំនងរបស់ MWRA តំណភ្ជាប់ទៅកាន់ច្បាប់សហព័ន្ធនិងបទបញ្ញារបស់អគ្គប្រតិបត្តិ ផែនទីយុត្តិធម៌បរិស្ថាន និងអ្នកចូលទៅកាន់យុត្តិធម៌បរិស្ថានរបស់ EEA។ ព័ត៌មានស្តីពីជំនួយបកប្រែឬប្រែសម្រួលភាសារបស់ MWRA នឹងអាចរកបានដែរ។

MWRA នឹងបន្តធ្វើបច្ចុប្បន្នភាពនិងប្រើប្រាស់គេហទំព័រនេះជាឧបករណ៍ដើម្បីទំនាក់ទំនងជាមួយ បុគ្គលិករបស់ MWRA ពលរដ្ឋរបស់ខំមិនវែល សមាជិកនៃប្រជាជនយុត្តិធម៌បរិស្ថាន និងក្រុមគាំពារមតិអំពីប្រភេទនៃកម្មវិធី គម្រោង និងសកម្មភាពរបស់យុត្តិធម៌បរិស្ថាន ដែល MWRA ជាប់ពាក់ព័ន្ធ ព្រមទាំងឱកាសសម្រាប់ពលរដ្ឋក្នុងការចូលរួម។

## ការបណ្តុះបណ្តាល

MWRA នឹងអនុវត្តគំនិតផ្តួចផ្តើមដូចខាងក្រោម ដើម្បីជំរុញឱ្យមានការពិចារណាលើយុត្តិធម៌បរិស្ថាន។

- ដើម្បីធានាឱ្យបានថាបុគ្គលិករបស់ទីភ្នាក់ងារបានយល់ពីតម្រូវការនិងបញ្ហារបស់យុត្តិធម៌បរិស្ថាន MWRA នឹងអប់រំនិយោជិករបស់ខ្លួនអំពីគោលនយោបាយយុត្តិធម៌បរិស្ថានរបស់យើង និងការទទួលខុសត្រូវ ដើម្បីសហការជាមួយសមាជិក និងសហគមន៍យុត្តិធម៌បរិស្ថាន។

- បុគ្គលិករបស់ MWRA ត្រូវបានលើកទឹកចិត្តឱ្យចូលរួមការបណ្តុះបណ្តាល ដែលរៀបចំឡើងដោយ EEA ឬអ្នកប្រឹក្សាយោបល់ភាគីទីបី ទាក់ទងនឹងបញ្ហាយុត្តិធម៌បរិស្ថានដោយមានការបណ្តុះបណ្តាល ដើម្បីរាប់បញ្ចូលថាតើត្រូវប្រើប្រាស់ផែនទីថ្មីយុត្តិធម៌បរិស្ថានដោយរបៀបណា

និងថាតើអ្វីជាភាគីពាក់ព័ន្ធឬការចូលរួមរបស់សហគមន៍?
តើអ្វីជាសង្កាត់យុត្តិធម៌បរិស្ថាន?

- សម្រាប់សង្កាត់ដែលខ្លួនកំពុងធ្វើការឬផ្តល់មូលនិធិ MWRA មាននិងបន្តការរៀបចំការជួបប្រជុំអំពីព័ត៌មានយុត្តិធម៌បរិស្ថាន ដើម្បីជូនដំណឹងដល់សមាជិកសហគមន៍ស្តីពី របៀបនៃការផ្តល់មតិយោបល់ ទទួលព័ត៌មាន និងអនុវត្តយ៉ាង ក្នុងការទំនាក់ទំនងទៅវិញទៅមករវាង MWRA។

## ឱកាសផ្តល់មូលនិធិជំនួយ

MWRA នឹងប្រើប្រាស់លក្ខខណ្ឌតម្រូវរបស់យុត្តិធម៌បរិស្ថាន និងបញ្ចូលភាសានោះទៅក្នុងមូលនិធិឱ្យបានសមស្រប ដើម្បីបង្កើនឱកាសទទួលបានមូលនិធិ ដែលអាចរកបាននៅក្នុងចំណោមប្រជាជនយុត្តិធម៌បរិស្ថាន ដើម្បីជួយឧបត្ថម្ភ និងផ្តល់អំណាចដល់ជនជាតិភាគតិច ប្រជាជនមានប្រាក់ចំណូលទាប និងកុលសម្ព័ន្ធ ក្នុងកិច្ចប្រឹងប្រែងដើម្បីកសាងនិងធ្វើឱ្យមានចីរភាពសម្រាប់សហគមន៍សមស្របផ្នែកបរិស្ថាន។

## ការវិភាគលើផលប៉ះពាល់ដែលកើនឡើង

នៅក្រោមលក្ខខណ្ឌតម្រូវនៃគោលនយោបាយយុត្តិធម៌បរិស្ថានរបស់ EEA MWRA តម្រូវឱ្យវាស់វែងភាពរីកចម្រើនទៅមុខនៃកិច្ចការរបស់យុត្តិធម៌បរិស្ថាន និងសរសេររបាយការណ៍អំពីកិច្ចការនេះប្រចាំឆ្នាំ។ ដោយរាប់ចាប់ពីឆ្នាំ2022 MWRA នឹងពិនិត្យមើលគម្រោងរបស់អាជ្ញាធរ ដែលកំពុងអនុវត្ត និងការចំណាយ និងផលប្រយោជន៍ដែលពាក់ព័ន្ធទៅនឹងសហគមន៍ (ជាពិសេសសហគមន៍យុត្តិធម៌បរិស្ថាន) និងធ្វើការឆ្ពោះទៅកាន់ការបង្កើតវិធីសាស្ត្រ ដើម្បីកំណត់បរិមាណនៃផលប៉ះពាល់កើនឡើងនៅក្នុងដំណើរគម្រោងតាមការស្នើ។ បន្ថែមពីនេះទៀត MWRA នឹងសហការជាមួយរដ្ឋនិងទីភ្នាក់ងារសហព័ន្ធដទៃទៀត និងត្រួតពិនិត្យព្រមទាំងកសាងការងារបច្ចុប្បន្ន ដែលធ្វើឡើងដើម្បីកំណត់អត្តសញ្ញាណសហគមន៍យុត្តិធម៌បរិស្ថាន និងកុលសម្ព័ន្ធឥណ្ឌា ដែលទទួលរងនូវការប៉ះពាល់បរិស្ថានក្នុងកម្រិតខ្ពស់ខ្លាំង។

## ការពិនិត្យឡើងវិញនូវការបំពេញការងារ និងការជួលបុគ្គលិក

MWRA ទទួលស្គាល់អំពីសារៈសំខាន់នៃកម្លាំងការងាររបស់ទីភ្នាក់ងារ ដែលឆ្លុះបញ្ចាំងពីភាពទីទៃពីគ្នានៃសាសន៍ ជាតិពន្ធ និងសេដ្ឋកិច្ចសង្គមរបស់ពលរដ្ឋក្នុងរដ្ឋម៉ាសាជូសេត ដោយរាប់បញ្ចូលទាំងតួនាទីស្នូល ដែលកម្លាំងការងារបានបំពេញដើម្បីលើកកម្ពស់ការសម្រេចចិត្តប្រកបដោយសមភាព ទាក់ទងនឹងលិខិតអនុញ្ញាតផ្នែកបរិស្ថាននិងថាមពល ទីតាំង ការបង្កើតបទបញ្ជា និងការផ្តល់មូលនិធិ និងការអនុវត្តច្បាប់។ ទីភ្នាក់ងាររបស់យើងប្តេជ្ញាចិត្តដាក់បញ្ចូលការអនុវត្តនៃការជួលមនុស្សមកធ្វើការពីក្រុមដទៃពីគ្នា និងផ្តល់ការបណ្តុះបណ្តាលសម្រាប់ការជួលអ្នកចាត់ចែងការងារ ដើម្បីជំរុញឱ្យមានការសម្រេចចិត្តប្រកបដោយសមភាព

ដោយរាប់បញ្ចូលទាំងលក្ខខណ្ឌតម្រូវនៅក្នុងសំណួរនៃបទសម្ភាសន៍ ដែលទាមទាឱ្យ
អ្នកដាក់ពាក្យដោគជ័យបង្ហាញចំណេះដឹង
និងការយល់ដឹងអំពីសេចក្តីត្រូវការរបស់ក្រុមប្រជាជនងាយរងគ្រោះ សង្កាត់យុត្តិធម៌បរិស្ថាន
និងតំបន់ខ្វះលទ្ធភាពរបស់ ខំមិនវែល។ បន្ថែមពីនេះទៀត MWRA មាន
និងបន្តចូលរួមក្នុងពិព័រណ៍ការងារ ដែលទាក់ទងនឹងការទទួលខុសត្រូវ ភាពចម្រុះ សមភាព
និងការរួមបញ្ចូលផ្នែកបរិស្ថាននិងសង្គម។

## អនុលោមភាពផ្នែកបរិស្ថាន

MWRA ប្តេជ្ញាចិត្តដាក់បញ្ចូលយុត្តិធម៌បរិស្ថាននៅក្នុងដំណើរការរបស់ខ្លួន
កម្មវិធីសម្រាប់ធ្វើការសម្រេចចិត្ត និងពិចារណាស្នើឱ្យមានគម្រោងយុត្តិធម៌បរិស្ថាន
ប្រសិនបើគម្រោងបរិស្ថានបន្ថែមត្រូវបានតម្រូវ
ដោយសារតែសកម្មភាពរបស់រដ្ឋឬអង្គភាពអនុវត្តច្បាប់របស់សហព័ន្ធ។

# ការអនុវត្តយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថានរបស់ការិយាល័យប្រតិបត្តិផ្នែកថាមពល និងកិច្ចការបរិស្ថាន

ពាក់ព័ន្ធនឹងក្តីបារម្ភ ពាក្យបណ្តឹង ការបំពេញបន្ថែម ឬគំនិតផ្សេងៗពាក់ព័ន្ធនឹង
យុត្តិធម៌បរិស្ថាន ឬដើម្បីស្វែងយល់បន្ថែមអំពីកិច្ចខិតខំប្រឹងប្រែងផ្នែកយុត្តិធម៌បរិស្ថាន
ថាមពល និងអាកាសធាតុរបស់ទីភ្នាក់ងារយើង សូមទាក់ទងការិយាល័យយុត្តិធម៌បរិស្ថានរបស់
EEA ដែលមានចែងនៅទំព័រទី 19 នៃយុទ្ធសាស្ត្របរិស្ថានរបស់ EEA។

## ព័ត៌មានសម្រាប់ប្រាស្រ័យទាក់ទងផ្នែកយុត្តិធម៌បរិស្ថានរបស់ទីភ្នាក់ងារ៖

Tomeka Cribb-Jones
ជំនួយការពិសេសសម្រាប់សកម្មភាពវិជ្ជមាននិងអនុលោមភាព
Tomeka.Cribb-Jones@mwra.com